ឥន្ទបញ្ញោភិក្ខុ ហ. មណីចិន្តា

# មគ្គុទ្ទេសក៍ជីវិត



ការផ្សាយរបស់
ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ជាមួយការឧបត្ថម្ភដោយ
មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, ប្រទេសអាល្លឺម៉ង់
A publication of *Buddhism for Development*
Supported by the Konrad-Adenauer-Foundation, Germany

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

www.budinst.gov.kh        www.elibraryofcambodia.org

ឥន្ទបញ្ញោភិក្ខុ ហ. មណីចិន្ដា

# មគ្គុទ្ទេសក៍ ជីវិត

# Life according to Buddha

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



www.budinst.gov.kh www.elibraryofcambodia.org

២១៩.៤៣

ឥន្ទបញ្ញោភិក្ខុ ហ. មណីចិន្តា

# មគ្គទេសក៍ជីវិត

បោះពុម្ពផ្សាយលើកទី៣

LIBRARY
BUDDHIST INSTITUTE
៣៦៤៦/៩៨

ការផ្សាយរបស់

*ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍*

ឧបត្ថម្ភដោយ

មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, អាល្លឺម៉ង់

អន្លង់វិល

១៩៩៧

www.budinst.gov.kh www.elibraryofcambodia.org

Indapaññо Bhikkhu **Heng Monychenda**

# LIFE ACCORDING TO BUDDHA

Third Revised Edition

A publication of
*Buddhism for Development*

Supported by the
Konrad-Adenauer-Foundation, Germany

Anlongvil

1997

www.budinst.gov.kh www.elibraryofcambodia.org

# មាតិកា


| | |
|---|---|
| អនុស្សតិកថា | I |
| អារម្ភកថានៃការបោះពុម្ពលើកទី ២ | V |
| អារម្ភកថានៃការបោះពុម្ពលើកទី ១ | VII |
| សាសនាសំរាប់សកលលោក | ១ |
| ពុទ្ធសាសនាក្នុងប្រទេសខ្មែរ | ៣ |
| អង្គប្រកបពុទ្ធសាសនា | ៧ |
| ត្រៃសរណគមន៍ | ១៦ |
| ព្រះពុទ្ធ | ១៧ |
| ការយកព្រះពុទ្ធជាទីពឹង | ៤៥ |
| ព្រះធម៌ | ៥០ |
| អ្វីទៅព្រះធម៌ | ៥១ |
| ធម៌ព្រះពុទ្ធ | ៥៥ |
| ទ្រង់ទ្រាយពុទ្ធធម៌ | ៧០ |
| យកព្រះធម៌ជាទីពឹង | ១០៣ |
| ព្រះសង្ឃ | ១០៥ |
| ការបួស | ១០៩ |
| លក្ខណៈសំគាល់ព្រះសង្ឃ | ១២៥ |
| យកព្រះសង្ឃជាទីពឹង | ១២៩ |
| ពុទ្ធសាសនា និងសង្គមខ្មែរ | ១៣៤ |
| បច្ឆិមកថា | ១៤០ |
| ឯកសារពិគ្រោះ | ១៤១ |
| តារាងអង្គការលេខពុទ្ធសាសនា | ១៤២ |


www.budinst.gov.kh www.elibraryofcambodia.org

ជាបុណ្យកុសលឧទ្ទិសចំពោះ



ញោមបិតានាម ហេង ដានី

គ.ស ១៩៣៤-១៩៩៤

www.budinst.gov.kh www.elibraryofcambodia.org

# អនុស្សាវរីយ៍ / អនុស្សតិកថា

## ចំពោះញោមបិតា ហេង ដានី

គឺជាងមួយឆ្នាំហើយ ចាប់តាំងពីប៉ាបានអញ្ជើញទៅកាន់សុគតិភពនាថ្ងៃទី ២៥ ធ្នូ ១៩៩៥ មក ។ កូនមិនដឹងថាពេលវេលានេះយូរឬឆាប់ទេ បើប្រៀបធៀបទៅនឹងរយៈពេលដែលកូនឃ្លាតពីប៉ាទៅរស់នៅជំរំជនភៀសខ្លួនឯព្រំប្រទល់ខ្មែរ-ថៃ ។ ១២ ឆ្នាំ នៅជំរុំជនភៀសខ្លួន កូនរង់ចាំតែថ្ងៃដើម្បីត្រឡប់មកផ្ទះវិញ ហើយកូនក៏ដឹងថា ប៉ាត្រូវរស់នៅដោយក្រៀមក្រំ ដោយមិនទឹកស្មានថានឹងអាចជួបមុខកូនទៀតទេ ។

ថ្ងៃទី ២៩ មករា ១៩៩២ កូនត្រឡប់ពីជំរុំវិញតាមផ្លូវការជាលើកទីមួយ ។ ពេលមកដល់ កូនមិនទាន់បានជួបប៉ាភ្លាមទេ ព្រោះប៉ារវល់កិច្ចការរដ្ឋ ។ កូនចាំបានថា កាលពីឆ្នាំ ១៩៧៩ ពេលដែលកូនត្រឡប់ពីកងចល័តនៅស្រុកបរិលមកផ្ទះវិញ បន្ទាប់ពីអង្គការបញ្ជូនទៅធ្វើការទីនោះអស់មួយឆ្នាំ កូនក៏មិនបានជួបប៉ាភ្លាមដូចគ្នា ។ ពេលល្ងាចប៉ាត្រឡប់ពីធ្វើការឲ្យអង្គការវិញ កូនស្ទុះទៅទទួល ហើយប៉ាក៏អួលដើមក យំ និយាយថា « ប៉ាទឹកថាលែងបានជួបមុខកូនទៀតហើយ! » ។ ល្ងាចទី ២៩ នោះ កូនស្ទុះទៅឱបប៉ា ប៉ាចាប់ក្រសោបកូន ហើយយើងយំទាំងអស់គ្នា ។ យើងគ្មានពាក្យអ្វីនិយាយទេ តែបេះដូងយើងរំជួលនិយាយថា “ យើងលែងបែកគ្នាទៀតហើយ ” ។

ការព្រាត់ប្រាសគ្នាគឺពិតជារឿងមួយឈឺចាប់ណាស់ ។ ១៣ ឆ្នាំដែលនៅបែកពីគ្នា មិនមែនជារឿងមួយដែលអាចនិយាយត្រឹមតែពីរ-បីបន្ទាត់ចប់ទេ ជាពិសេស ទឹកចិត្តរបស់ឪពុកចំពោះកូន ។ កូនយល់អំពីអារម្មណ៍របស់ប៉ាណាស់ គឺប៉ាទឹកកូន ជាងកូនទឹកប៉ា ដូចពាក្យខ្មែរដែលពោលថា “ *ម៉ែឪទឹកកូនដូចចង្វារប្រដេញ កូនទឹកម៉ែឪវិញ ដូចព្រះបែរខ្នង* ” ។ ប៉ាទឹកកូនណាស់ តែលទ្ធិកុំមុយនិស្តមិនអនុញ្ញាតឲ្យប៉ាបង្ហូរមនោសញ្ចេតនាតាមរយៈពាក្យសម្ដី និងការសរសេរសំបុត្រចំពោះកូនទេ ។ កូនចាំថា ពេលកូនសរសេរសំបុត្រពីប្រទេសអាឡឺម៉ង់ខាងលិចមករកប៉ាក្នុងឆ្នាំ ១៩៨៩ កូនមិនហ៊ានដាក់ឈ្មោះកូនទេ ខ្លាចបក្សរករឿងប៉ា ។ អ្វីដែលធ្ងន់ធ្ងរនោះ គឺពេលដែលប៉ាតបសំបុត្រទៅកូនវិញ (សំបុត្រទី ១ ក្នុងរយៈពេល ១០ ឆ្នាំ) ប៉ាមិនហ៊ានសរសេរទេ

www.budinst.gov.kh www.elibraryofcambodia.org

តែវាយអង្គុលីលេខខ្មែរ ហើយដាក់ឈ្មោះញោមស្រីជំនួសវិញ ព្រោះខ្លាចបក្សគេផែក ឃើញ តែកូនចាំទឹកសម្តីរបស់ប៉ាណាស់ ថានោះ គឺជាស់ដីរបស់ប៉ា ។

ក្នុងសម័យកុំមុយនិស្ត ប៉ាត្រូវបង្ខំកាត់កាល់ឈ្មោះកូនចេញពីបញ្ជីគ្រួសារ ដើម្បីកុំឲ្យបក្សរករឿង ហើយជាញឹកញយគេចោទប៉ាថា មានកូនកំពុងធ្វើការឲ្យខ្មាំង ដើម្បីរករឿងបន្ថយគុណសម្បត្តិរបស់ប៉ា ។ ពេលកូនផ្តាំអ្នកជិតខាងឲ្យមកសួរសុខទុក្ខ ប៉ាមិនដែលស្តាប់គេទេ សុខចិត្តដើរចេញ លុះត្រាតែស្គាល់ទើបប៉ាមកសួរពីបង ឬញោមស្រីវិញ ។

ពេលដែលកូនលាប៉ាមកនៅជាយដែន ប៉ាបានផ្តាំកូន បីយ៉ាង៖ « ទី ១ កូនឯងកុំធ្វើប៉ូលិស, ទី ២ កូនកុំលេងនយោបាយ និងទី ៣ បើសិនជាត្រូវដល់ពេលស្លាប់ កុំលុតជង្គង់ឲ្យសោះ» ។ បណ្តាំទី ១ ទាក់ទងទៅនឹងអត្តចរិតរបស់ប៉ាដែលមិនចេះជិះជាន់ សង្កត់សង្កិនគេ និងស្មោះត្រង់ចំពោះការងារ ឯការងារប៉ូលីសជំនាន់ពីសង្គមវិញ គឺបើមិនចេះរកលុយដោយការសង្កត់សង្កិនទេ គឺមិនអាចឡើងបុណ្យសក្តិបានឡើយ ។ បណ្តាំទី ២ ទាក់ទងទៅនឹងការពិសោធន៍ក្នុងឆាកជីវិតរបស់ប៉ាខាងរឿងនយោបាយស្រុកខ្មែរ ដែលជារឿងគួរឲ្យភ័យខ្លាចជាប់ជានិច្ច ដោយសារការចោទប្រកាន់ និងការប្រកាន់បក្សពួក ជាពិសេស ច្រើនតែបានត្រឹមធ្វើឈ្នាន់របស់គេតែប៉ុណ្ណោះ ។ បណ្តាំទី ៣ គឺជាសេចក្តីក្លាហានរបស់ប៉ាផ្ទាល់ គឺការមិនចេះខ្លាចចំពោះអំណាចជិះជាន់ខុសច្បាប់ ហើយប៉ាជឿថា បើវាត្រូវស្លាប់ហើយ ទោះលុតជង្គង់ក៏វានៅតែស្លាប់ដែរ ដូច្នេះត្រូវមានសេចក្តីក្លាហានជានិច្ច ។ បណ្តាំទាំងនេះ កូនចាំជានិច្ចរហូតដល់ឥឡូវ!

នៅពីក្មេង ពេលដែលសប្បាយចិត្តជាទីបំផុត គឺពេលដែលប៉ាខ្វាររអាចម៍ត្រចៀកឲ្យកូន គឺជាពេលដែលមានអារម្មណ៍ស្រួល និងពោរពេញដោយក្តីស្រឡាញ់ ។ ពេលមួយប៉ាប្រាប់កូនថា «កូនឯងខំរៀនណា ប៉ាគ្មានអ្វីចែកឲ្យកូនទេ មានតែការសិក្សានេះឯង» ។ កូនគិតថា កូនមិនបានធ្វើឲ្យប៉ាខុសបំណងពីរឿងរៀនសូត្ររបស់កូនឡើយ ។

ក្នុងឋានៈជាកូន កូនហ៊ាននិយាយថា ប៉ាជាមនុស្សល្អលើសគេ ព្រោះប៉ាស្រឡាញ់កូនទាំងណាស់ ។ បើទោះជាប៉ាក្រ និងជំពាក់គេយ៉ាងណាក៏ដោយ ក៏ប៉ាមិនដែល

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យកូនៗ លំបាកទេ សុខចិត្តទ្រាំអត់មិនស្តី ។ បើទោះជាមានឧបសគ្គយ៉ាងណា ក៏ប៉ានៅតែប្រឈមមុខជានិច្ច ដើម្បីឲ្យកូនៗរស់ និងបានរៀនសូត្រ ។

នៅពេលដែលកូនធំ ដុះដៃដុះជើង មានស្លាបហោះហើរខ្លួនឯង កូនទៅជាមិនអាចបំពេញនូវកតវេទិតាធម៌ជូនចំពោះលោកអ្នកមានគុណបាន ។ កូនមានវិប្បដិសារី ដែលមិនអាចជួយព្យាបាលជម្ងឺប៉ាឲ្យជា និងមិនបានថែទាំប៉ាឲ្យអស់ពីចិត្ត តាមពេលវេលារបស់កូនដែលមាន និងមិនបានចិញ្ចឹមប៉ា តាមដែលលទ្ធភាពកូនអាចទៅបាន ។ ប៉ាមានការលំបាកទ្រាំណាស់ រហូតមានពេលខ្លះប៉ាខឹងខ្លួនឯងដែលឈឺនាំនូវសេចក្តីទុក្ខដល់កូនៗ ។ តែព្រះអើយ បើទោះជាប៉ាត្រូវឈឺយូរជាងនេះ និងលំបាកដល់កូនជាងនេះទៅទៀតដប់ដងក្តី ក៏នៅមិនអាចប្រៀបធៀបទៅនឹងសេចក្តីលំបាករបស់ប៉ា ដែលមានចំពោះកូនៗបានឡើយ ។

ឥឡូវនេះប៉ាឃ្លាតកូនទៅហើយ ហើយជាការឃ្លាតដែលមិនអាចមានពេលនឹងជួបគ្នាវិញបាន ។ យើងមិនអាចឆ្លើយឆ្លងគ្នាបានទៀតទេ តែកូនដឹងថាប៉ាកំពុងតែនឹកកូនៗទាំងអស់ជានិច្ច៖ បងឡា អាពៅ អាធុល និងកូន ព្រមទាំងចៅៗទាំងអស់ ។ ពេលដែលអាធុលមានគ្រោះថ្នាក់ដល់សន្លប់ នាងនិយាយថា ប៉ាមកសួរសុខទុក្ខ ប៉ាខំជួយទប់កុំឲ្យមានគ្រោះថ្នាក់ដែរ តែជួយមិនរួច ព្រោះប៉ាចាស់ ថាប៉ាឥឡូវនៅជាមួយម៉ាក់ហើយ ប៉ាបង្ខំអាធុលឲ្យត្រឡប់ពីឋានបរលោកនោះមកឋានមនុស្សលោកវិញ ។ កូននិងបងឡាស្តាប់អាធុលយំផង និទានរឿងផង ដោយទឹកចិត្តក្តុកក្តួល ។ ប៉ាចែកស្ថានទៅហើយ តែប៉ានៅតែព្រួយបារម្ភពីកូនទៀត ! ប៉ាគឺជាប៉ាដ៏ល្អបំផុតរបស់កូនៗ ។

សៀវភៅនេះ គឺជាអ្វីដែលកូនអាចជូនចំពោះប៉ាបាននាវេលាចុងក្រោយនៃជីវិតរបស់ប៉ា ។ ពេលដែលប៉ាត្រឡប់មកពីវៀតណាមវិញ ហើយដឹងថាមានជំងឺមហារីក កូនក៏ចាប់ព្រួយបារម្ភ និងចាប់ផ្តើមសរសេរសៀវភៅនេះភ្លាម ព្រោះគិតថាអានិសង្ស ដែលកើតពីសៀវភៅនេះ នឹងបានជាបច្ច័យជួយជ្រោមជ្រែងប៉ាទៅកាន់សុគតិភព ។ ពេលដែលប៉ាត្រឡប់មកពីព្យាបាលនៅបាងកកវិញ ជំងឺប៉ាក៏មិនបានធូរដែរ ព្រោះវាផុតទៅហើយ ។ ពេលនោះ កូនក៏សំរេចចិត្តយកសៀវភៅដែលទើបតែសរសេរបានពីរភាគបី យកទៅជូនប៉ា ដើម្បីជាកិច្ចបញ្ជាក់ថា សៀវភៅនេះកូនជូនប៉ា ហើយជាសម្បត្តិ

www.budinst.gov.kh www.elibraryofcambodia.org

របស់ប៉ាហើយ បុណ្យកុសលដែលកើតពីសៀវភៅនេះទាំងប៉ុន្មាន កូនជូនប៉ាទាំងអស់ ។ ប៉ាសប្បាយចិត្តណាស់ !

កំហុសមួយដែលកូនមិនអាចអត់ឱនឲ្យខ្លួនឯងបាន គឺរយៈពេលជាងមួយឆ្នាំទៅហើយ កូននៅតែមិនអាចបញ្ចប់នូវសៀវភៅនេះបាន ដើម្បីបោះពុម្ពចែកជាធម្មទាន ព្រោះកូនគិតកិច្ចការគេជាងកិច្ចការរបស់ប៉ាខ្លាំងពេក ។ សូម្បីតែឥឡូវនេះសៀវភៅបានសរសេរចប់ទៅហើយក្តី ក៏កូននៅតែពុំទាន់ពេញចិត្ត ព្រោះកូនបញ្ចប់សៀវភៅនេះក្នុងរយៈពេលមួយដែលខ្លីពេក និងព្រោះត្រូវបង្ខំចិត្តបញ្ចប់ មុនកូនចេញទៅបន្តការសិក្សានៅបរទេស ។

ប៉ាជាទីស្រឡាញ់ ! កូនគ្មានអ្វីដែលសំរាប់តបស្នងសងគុណឲ្យសមនឹងទំហំដែលលោកបានធ្វើមកលើកូនទេ ។ កូនសៀវភៅដែលកូនសរសេរជូននេះ គឺជាសម្បត្តិរបស់ប៉ា បុណ្យទាំងឡាយឯណាដែលកើតពីការដែលអ្នកអានបានយល់ដឹងពុទ្ធសាសនាព្រោះបានអានសៀវភៅនេះ បុណ្យទាំងនោះគឺសុទ្ធតែជារបស់ប៉ាទាំងអស់ ។ សូមវិញ្ញាណក្ខន្ធប៉ា បានទទួលដឹង និងអនុមោទនាយកនូវបុណ្យទាំងនេះ ។

យទិ ហីនេ គតោ ឋានេ កាយទុច្ចរិតេន វា ឥមិនា បុញ្ញតេជេន តម្ហា ឋានា បមុញ្ចតុ បើប៉ាទៅកើតក្នុងទីមិនល្អព្រោះកាយទុច្ចរិតក្តី វាចាទុច្ចរិតក្តី មនោទុច្ចរិតក្តី ក៏សូមឲ្យប៉ារួច រំដោះចាកទីមិនល្អនោះ ដោយតេជៈគឺបុណ្យដែលកើតពីសៀវភៅនេះ

យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ ឥមិនា បុញ្ញតេជេន ភិយ្យោ ភិយ្យោ បវឌ្ឍតិ ឬបើទៅកើតក្នុងទេវបុរី ជាវិមានគួររីករាយ ដែលជាស្ថានមានលំអដោយរតនៈផ្សេងៗស្រាប់ហើយ ក៏សូមឲ្យប៉ារីតតែចំរើនជាភិយ្យោភាព ដោយតេជៈគឺបុណ្យនេះ ជាដរាបតរៀងទៅ ។ ៚

វត្តអន្លង់វិល ថ្ងៃអង្គារ ៨ កើត ខែទុតិយាសាឍ ឆ្នាំជូត ព.ស ២៥៤០

ទី ២៣ កក្កដា ១៩៩៦

អំពីកូនរបស់ប៉ា

ឥន្ទបញ្ញោភិក្ខុ ហេង មណីចិន្តា

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា
# ក្នុងការបោះពុម្ពលើកទី ២

សៀវភៅមគ្គុទ្ទេសក៍ជីវិត ដែលបានបោះពុម្ពលើកទី ១ ចំនួន ៥០០ ក្បាល ក្នុងឱកាសបុណ្យទក្ខិណានុប្បទានចំពោះញោមបិតា មុនថ្ងៃដែលអ្នកនិពន្ធចេញដំណើរទៅសិក្សានៅសហរដ្ឋអាមេរិក បានទទួលការយកចិត្តទុកដាក់ពីសំណាក់ពុទ្ធបរិស័ទ គួរឲ្យមោទនភាព ។ តែទោះជាយ៉ាងណាក្តី ក៏អ្នកនិពន្ធនៅតែទទួលស្គាល់ថា សៀវភៅនេះនៅមានការខ្វះខាតជាច្រើន ទាំងខាងផ្នែកបរិបទ សេចក្តីពន្យល់ និងអក្ខរាវិរុទ្ធ ។

នៅក្នុងឱកាសនៃរដូវសំរាករៀនខាខែធ្នូ ១៩៩៦ អ្នកនិពន្ធបានមានឱកាសធ្វើដំណើរវិលមកស្រុកខ្មែរមួយរយៈ ដើម្បីចូលរួមក្នុងឱកាសសិក្ខាសាលាជាតិលើកទី ៣ ស្តីអំពីពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ នៅវត្តអន្លង់វិល ។ លោកពិធ័រ សៀវ ដែលជាតំណាងមូលនិធិ ខុនរ៉ាដអាដិនណៅអ៊ែរ ប្រចាំការនៅទីក្រុងភ្នំពេញ បានសំដែង នូវការរីករាយក្នុងការជួយឧបត្ថម្ភបោះពុម្ពសៀវភៅនេះជាលើកទី ២ និងមានចំនួនច្រើនជាងមុន ។ ក្នុងឱកាសនោះដែរ លោក រស់ ចាន់សន ដែលជាបុគ្គលិក របស់មូលនិធិ បានផ្តល់យោបល់ថា សៀវភៅនេះល្អ តែហាក់ដូចជារហ័សបញ្ចប់ពេក បើសិនជាបានសរសេរបន្ថែមបន្តិចទៀត ប្រាកដជារឹតតែល្អ ។ អ្នកនិពន្ធមានការយល់ ឃើញដូច្នោះមែន ហើយក៏សំរេចចិត្តថានឹងសរសេរបន្ថែម ថ្វីត្បិតតែពេលវេលាខ្លី និងមានការមមាញឹកក៏ដោយ ។ ពុទ្ធសាសនា និង សង្គមខ្មែរ គឺជាវគ្គបន្ថែមក្នុងឱកាសលើកទី ២ នេះ ក៏មិនទាន់ធូនល្មមទៅនឹងអ្វីដែលគួរនឹងសរសេរដែរ ។ អស់លោកអ្នកដែលចង់យល់ច្បាស់ថែមទៀត សូមអញ្ជើញរកអានសៀវភៅដែលជាការចងក្រងអត្ថ បទក្នុងសិក្ខាសាលាជាតិទាំង ៣ លើក ផងចុះ ព្រោះសៀវភៅទាំងនោះប្រជុំដោយអត្ថ បទស្តីអំពីពុទ្ធសាសនា និងសង្គមខ្មែរដ៏វិសេសៗ ជាច្រើន ។

ជាថ្មីម្តងទៀត អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះមូលនិធិខុនរ៉ាដ ដែលតែងតែយកចិត្តទុកដាក់ចំពោះការបោះពុម្ពផ្សាយសៀវភៅដែលមានប្រយោជន៍ ដល់ការយកព្រះពុទ្ធសាសនាទៅអនុវត្តក្នុងការអភិវឌ្ឍន៍ជីវិត និងសង្គមខ្មែរ ។ ចំពោះលោក សុខ

www.budinst.gov.kh www.elibraryofcambodia.org

សុផល ការីកុំព្យូទ័ររបស់ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ ដែលបានវាយអក្សរ និងរៀបចំកែលំអរខ្នាតសៀវភៅឡើងវិញ តាមយោបល់របស់លោកពិទ័រ សៀវ ។ ចំពោះមិត្តអ្នកអានទាំងអស់ដែលតែងតែគាំទ្រចំពោះស្នាដៃអ្នកនិពន្ធ ។ សង្ឃឹមថា ការអាន និងការសិក្សាដោយយកចិត្តទុកដាក់ ប្រាកដជាអាចនាំមកនូវចំណេះដឹង និងការយល់ដឹងអំពីពុទ្ធសាសនារបស់ខ្មែរយើងខ្លះថែមទៀតជាពុំខាន ។

វត្តអន្លង់វិល ថ្ងៃទី ០១ មករា ១៩៩៧
ឥន្ទបញ្ញោភិក្ខុ
វស្សា ទី ១៧

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា
# ក្នុងការបោះពុម្ពលើកទី ១

សៀវភៅនេះចាប់ផ្ដើមសរសេរឡើង នៅក្នុងកាលទេសៈមួយដែលអ្នកនិពន្ធមានអារម្មណ៍មិនស្ងប់ ដោយសារកង្វល់ចំពោះញោមបិតាដែលមានជំងឺមិនអាចមើលឲ្យជាបាន និងបញ្ចប់នៅក្នុងពេលដែលកំពុងរវល់ដើម្បីរៀបចំខ្លួនទៅបន្តការសិក្សា ។ សូមសារភាពថា សៀវភៅនេះមិនធ្ងន់ល្មមចំពោះចិត្តទេ ទាំងកម្រាស់ មាតិកា បរិបទ និងការពន្យល់ ព្រោះមិនទាន់អស់សេចក្ដីដែលនឹងអាចឲ្យអ្នកមិនស្គាល់ពីពុទ្ធសាសនាអាចនឹងយល់ច្បាស់បាន នៅពេលដែលអានសៀវភៅនេះហើយ ។ អ្វីដែលសង្ឃឹមពីសៀវភៅនេះ គឺគ្រាន់តែជាប្រទីបដើមដំបូងសំរាប់ដើរទៅរកការយល់ដឹងវែងឆ្ងាយ និងជ្រាលជ្រៅអំពីពុទ្ធសាសនា ដែលជាសាសនាជាតិខ្មែរ និងសកលលោកតែប៉ុណ្ណោះ ។ សង្ឃឹមថា នឹងមានអ្នកយកប្រទីបដើមផ្សេងដ៏ច្រើនទៀតមកអុជបន្ត ឬបើមានឱកាសក៏នឹងសរសេរបន្ថែមទៀតនៅពេលក្រោយ ។

ប្រជាពលរដ្ឋខ្មែរជាអ្នកកាន់ពុទ្ធសាសនាពីកំណើតជាង ៩៥% នៃប្រជាពលរដ្ឋទាំងអស់ តាំងពីយូរយារណាស់មកហើយ ។ ការយល់ដឹងអំពីពុទ្ធសាសនា ភាគច្រើនធ្វើឡើងនៅក្នុងរូបភាពនៃធម្មទេសនា ដែលពុទ្ធបរិស័ទនិមន្តព្រះភិក្ខុ សាមណេរឲ្យសំដែង ។ ក្រៅពីនេះ ក៏មានការសិក្សាពុទ្ធសាសនាតាមការរៀនភាសាបាលី រៀនធម្មវិន័យ និងសំរាប់តែព្រះសង្ឃប៉ុណ្ណោះ ។ នៅតាមសាលារៀន យើងមិនមានការសិក្សាអំពីពុទ្ធសាសនាទេ លើកលែងតែអត្ថបទអក្សរសិល្ប៍ពុទ្ធសាសនាបន្តិចបន្តួចសោះនឹងខាន ។ ខាងផ្នែកសៀវភៅក្បួនច្បាប់វិញ ក៏មានចំនួនតិច ហើយភាគច្រើនជាភាសាសរសេរដែលសក្ដិសមទៅនឹងទសវត្សរ៍ ទី ៦០-៧០ ឬមនុស្សដែលមានវ័យជាងហាសិបឆ្នាំអាន ។ ចំណុចខ្វះខាតទាំងនេះ ធ្វើឲ្យពុទ្ធបរិស័ទមានការយល់ដឹងពីពុទ្ធសាសនាតិចតួចស្ដួចស្ដើង ថ្វីត្បិតតែសទ្ធា និងជំនឿរបស់គាត់ចាស់ក្លា និងមាំមួនក៏ដោយ ។ រឿងដែលគួរឲ្យសង្វេគនោះ គឺមហន្តរាយនាឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែលបង្កឡើងដោយពួកកុំមុយនិស្តខ្មែរក្រហម បានធ្វើឲ្យពុទ្ធសាសនាត្រូវបាត់បង់នូវសក្តិ និងយសរបស់ខ្លួនស្ទើរតែអស់រលីង ៖ វត្តត្រូវបំផ្លាញ ព្រះសង្ឃត្រូវសម្លាប់ និងចាប់ផ្សឹក ក្បួន

www.budinst.gov.kh www.elibraryofcambodia.org

ច្បាប់ត្រូវដុតកំទេចចោល ដែលជាវិការដ្ឋានមួយដ៏គួរឲ្យសោកសង្រេងសំរាប់ប្រវត្តិសាស្ត្រ របស់ខ្មែរយើង ។

ថ្វីត្បិតតែមានការព្យាយាមស្តារឡើងវិញទាំងក្នុងប្រទេស ទាំងពាមជំរំជនភៀសខ្លួនខ្មែរ និងនៅឯបរទេស បន្ទាប់ពីការដួលរលំនៃរបបកុំមុយនិស្តក្តី ក៏ពុទ្ធសាសនាមិនអាចងើបក្រោកឈរបានដូចពីមុនដែរ អាស្រ័យដោយកត្តាច្រើនយ៉ាង ៖ ឥទ្ធិពលអាក្រក់នៃរបបដ៏ឃោរឃៅដែលបន្សល់ទុក, សង្គ្រាមលុកលុយពីបរទេស, សង្គ្រាមតស៊ូដើម្បីរំដោះទឹកដី, ការគាបសង្កត់ខាងផ្នែកជំនឿ, កង្វះធនធានមនុស្សខាងផ្នែកសាសនា, កំសោយខាងផ្នែកសេដ្ឋកិច្ចរបស់ពុទ្ធបរិស័ទ.....។ ថ្វីត្បិតពេលវេលាបានកន្លង ១៧ ឆ្នាំទៅហើយ ក្រោយរបបខ្មែរក្រហមរលត់ទៅ តែពុទ្ធសាសនាយើងក៏នៅតែមិនទាន់រឹងប៉ឹងសោះ ជាពិសេសលើវិស័យការសិក្សា ។ អ្វីដែលយើងទើបតែធើខ្លួនរួចមកវិញនោះ គឺបរិមាណវត្ត ដែលមានចំនួនស្មើ ឬក៏លើសកាលពីពេលពុំទាន់បាក់បែកទៅទៀត ។ តែនេះមិនមែនជាមោទនភាពចម្បងរបស់យើងទេ ព្រោះបើទោះជាមានវត្តច្រើន តែបើព្រះសង្ឃពុំមានគុណភាព ហើយពុទ្ធបរិស័ទយល់ដឹងពីពុទ្ធសាសនាតិចនោះ ពុទ្ធសាសនាយើងក៏នឹងអាចមានថ្ងៃជួបហេតុការណ៍ អាក្រក់ម្តងទៀតជាពុំខាន ។

សៀវភៅនេះសរសេរឡើង ដើម្បីរួមចំណែកក្នុងការបណ្តុះបណ្តាលគុណភាពព្រះសង្ឃ និងបង្កើនការយល់ដឹងថែមទៀតដល់ពុទ្ធបរិស័ទ នាយុគសម័យថ្មីនេះ ។ ភាសាខ្លះអាចនឹងប្លែកត្រចៀក ការប្រែពីភាសាបាលីមកខ្មែរ អាចនឹងមិនដូចពាក្យប្រែរបស់អាចារ្យពីបុរាណខ្លះ តែក៏មិនមានចេតនាបង្ខូចពុទ្ធវចនៈទេ គឺគ្រាន់តែចង់ឲ្យអ្នកដែលមិនស្គាល់ពីពុទ្ធសាសនា អាចងាយស្គាល់បាន និងសំរាប់មនុស្សសម័យថ្មីស្តាប់ទៅងាយយល់បានស្រួលតែប៉ុណ្ណោះ ។ សូមលោកអ្នកប្រាជ្ញដែលមានការចេះដឹងពីពុទ្ធសាសនាច្រើន មេត្តាអត់ទោសចំពោះការផ្តាំផ្តងទាំងឡាយ ដែលកើតមានដោយអចេតនា ឬដោយការល្ងីតល្ងង់ ។

អ្នកអានជាទីមេត្រី! សៀវភៅដែលលោកអ្នកកំពុងអាននេះ គឺជាកម្លាំងនៃកតញ្ញូកតវេទិតាធម៌របស់អាត្មាភាពដែលមានចំពោះញោមប្រុសជាទីស្រឡាញ់ ។ បើសិនជាសៀវភៅមគ្គទ្ទេសក៍ជីវិតនេះ មានប្រយោជន៍ក្នុងការតម្រង់ជីវិតរបស់លោកអ្នក

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យដើរទៅរកអំពើដែលជាកុសលបាន អ្នកនិពន្ធសូមចែកបុណ្យដែលកើតពីកុសលកម្ម នោះ ជូនចំពោះញោមបិតា ។ បើគិតថា សៀវភៅនេះអាចមានប្រយោជន៍ដល់ជន ដទៃទៀត សូមមេត្តាចែកទៅឲ្យអ្នកនោះបានអានផង លោកអ្នកនឹងរឹតតែបានបុណ្យ ច្រើនថែមទៀតជាពុំខាន ។

ឥន្ទបញ្ញោភិក្ខុ ហេងមណីចិន្តា

www.budinst.gov.kh www.elibraryofcambodia.org

# សាសនាសំរាប់សកលលោក

ពុទ្ធសាសនា (Buddhism) គឺជាសាសនារស់ (living religion) មួយក្នុងចំណោមសាសនាទាំងឡាយចំនួន ១២ គឺ សាសនាយូដាយ (Judaism), សាសនាហ្ស៊ូរ៉ូអាស់ទ្រៀន (Zoroastrianism) សាសនាគ្រឹស្ត (Christianity), សាសនាឥស្លាម (Islam), សាសនា ហិណ្ឌូ (Hinduism), សាសនាជេន (Jainism), សាសនាតៅ (Taoism), សាសនាខុងជឺ (Confucianism), សាសនាស៊ិនតូ (Shinto), សាសនាស៊ិក្ខ (Sikhism) និងសាសនាបាហាយ (Bahai) ដែលគេគោរពបូជានៅក្នុងពិភពលោកយើងនេះ [1] ។

ពុទ្ធសាសនាស្ថិតនៅក្នុងប្រភេទអទេវនិយម (Atheism) គឺមិនយកអាទិទេពជាធំ និងជាមនុស្សនិយម (Humanism) មានដើមកំណើតកាលពី ២៦០០ ឆ្នាំមុន ដោយមហាសមណៈមួយអង្គព្រះនាម **ពុទ្ធៈ** ។ មុននឹងកតាំងជាសាសនា លោកមានអតីតកាលជាក្សត្រមួយអង្គ គង់នៅក្នុងប្រទេសនេប៉ាល (ពីដើមហៅថាជម្ពូទ្វីប ឬភារតប្រទេស ដែលមានរួមទាំងឥណ្ឌា និងប៉ាគីស្ថានបច្ចុប្បន្ននេះផង) ។

ចាប់តាំងពីមានកំណើតរហូតមកដល់ឥឡូវនេះ ពុទ្ធសាសនាបានរីកសាយទូទាំងសាកលលោក ដោយមានពុទ្ធបរិស័ទ ទាយក ទាយិកា និងអ្នកជ្រះថ្លារាប់រយលាននាក់ គោរពបូជា និងដើរតាមការណែនាំពាក្យបង្រៀនរបស់ព្រះពុទ្ធអង្គ ព្រមទាំងមាននិទ្ទាការថា នឹងកាន់តែរីកសាយទូលំទូលាយច្រើនថែមទៀតជារៀងរាល់ថ្ងៃ អាស្រ័យដោយអមតៈវាចា ដែលព្រះពុទ្ធអង្គទ្រង់បានសំដែង ។

តាមស្ថិតិក្នុងសៀវភៅឈ្មោះ The World Almanac and Book of Facts បោះពុម្ពនៅក្នុងឆ្នាំ ១៩៨៨ ចំនួនអ្នកកាន់ពុទ្ធសាសនាក្នុងពិភពលោកនេះ មានចំនួនបីរយ ប្រាំពីរលាន បួនសែន មួយម៉ឺន ប្រាំមួយពាន់ និងសាមសិបនាក់ (៣០៧,៤១៦,០៣០នាក់) ដែលបែកចេញទៅតាមទ្វីបផ្សេងៗ ដូចតទៅ :

អាហ្វ្រិក : ១៣ , ៨៥០នាក់

[1] The Enciclopedia of World Faiths, Peter Bishop & Michael Darton. Macdonal&co(Publishers)Ltd 1987, Great Britain

www.budhist.gov.kh www.elibraryofcambodia.org

| | |
|---|---|
| អាស៊ីខាងកើត | : ១៥៥ , ១៥៩ , ៦៥០នាក់ |
| ទ្វីបអឺរ៉ុប | : ២០៩ , ៦៥០នាក់ |
| អាមេរិកឡាទីន | : ៥៩៦ , ៩៨០នាក់ |
| អាមេរិកខាងជើង | : ១៩៣ , ៥៥០នាក់ |
| អូសេអានី | : ១៦ , ៩៨០នាក់ |
| អាស៊ីខាងត្បូង | : ១៥០ , ៩៧៥ , ៩២០នាក់ |
| សហភាពសូវៀត | : ៣៥៩ , ៧១០នាក់ |

តួលេខនេះ គឺជាស្ថិតិដែលបានមកពីការរាប់ចំនួនអ្នកដែលបានចុះឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណថាជាពុទ្ធសាសនិកជន ឯអ្នកដែលកាន់ និងជឿដោយមិនបានដូរអត្តសញ្ញាណប័ណ្ណនោះមានច្រើនណាស់ ជាពិសេសនៅក្នុងទ្វីបអឺរ៉ុប និងអាមេរិកបន្ទាប់ពីមានជនភៀសខ្លួនពីជប៉ុន ទិបេត៍ និងឥណ្ឌូចិន ទៅកាន់ទីលំនៅថ្មីនៅបណ្ដាប្រទេសទាំងនោះ ។ ពួកគេទាំងនោះ បាននាំទៅជាមួយនូវវប្បធម៌ពុទ្ធសាសនាទៅផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជាហេតុនាំឲ្យមានចលនារឿងពុទ្ធសាសនាយ៉ាងគគ្រឹកគគ្រេងនៅបស្ចិមប្រទេសទាំងនោះ ។ តាមការប៉ាន់ប្រមាណ ចំនួនពុទ្ធសាសនិកជនក្នុងពិភពលោកនេះ មានប្រហែលប្រាំរយលាននាក់ ។

The religion of the future will be acosmic religion. It should trancend a personal God and avoid dogmas and theology. Coverring both the natural and the spiritual, it should be based on a religious sense arising from the experience of all things, natural and spiritual as a meaningful unity. Buddhism answers this description.........If there is any religion that could cope with modern scientific needs it would be Buddhism.

Albert Einstein (1879-1955)

សាសនាពេលអនាគត គប្បីជាសាសនាសាកល ។ សាសនានោះ គប្បីនៅឲ្យផុតពីរឿងរកទេព ដែលមានខ្លួនប្រាណ ហើយគួរជៀសវាងពាក្យប្រៀនប្រដៅដែលជាទេវវិទ្យា និងជាបែបជំនឿផ្ដាច់មុខ (dogma)។ គ្របដណ្ដប់ដោយធម្មជាតិ និងចិត្តវិញ្ញាណ សាសនានោះគួរមានមូលដ្ឋានលើគំនិតសាសនា ដែលកើតឡើងពីការពិសោធន៍ចំពោះអ្វីៗទាំងពួង គឺទាំងធម្មជាតិ និងចិត្តវិញ្ញាណដែលប្រកបដោយឯកភាពដ៏មានន័យ ។ ព្រះពុទ្ធសាសនាឆ្លើយតបទៅនឹងខកំណត់ទាំងអស់នេះបាន..... បើសិនជាមានសាសនាណាដែលអាចទប់ទល់បានទៅនឹងសេចក្ដីត្រូវការខាងវិទ្យាសាស្ត្រនាបច្ចុប្បន្ននេះបាន សាសនានោះគួរតែជាពុទ្ធសាសនា ។

អាល់បែរ អែងស្តែន៍, បិតាទ្រឹស្តីបរមាណូ (១៨៧៩-១៩៥៥)

www.budinst.gov.kh www.elibraryofcambodia.org

# ពុទ្ធសាសនាក្នុងប្រទេសខ្មែរ

បើតាមសិលាចារឹកវ៉ូកាញ់ ដែលរកឃើញក្នុងប្រទេសវៀតណាម ប្រទេសខ្មែរយើងបានទទួលឥទ្ធិពល និងគោរពពុទ្ធសាសនា តាំងពីពាក់កណ្តាលចុងសតវត្សរ៍ទី ២ មកម៉្លេះ គឺនៅក្នុងរាជ្យព្រះបាទស្រីមារៈ ទាជ់ទាន់នគរភ្នំ ។ វិវឌ្ឍនាការក្នុងរយៈពេល ១៧០០ ឆ្នាំនេះ បានធ្វើអោយប្រទេសខ្មែរផ្លាស់ទៅជាប្រទេសពុទ្ធសាសនាមួយដ៏ជាក់លាក់ ដែលមានប្រជាជនអ្នកកាន់រហូតដល់ទៅ ៩៥% ។ ថ្វីត្បិតតែក្នុងសម័យខ្លះ ពុទ្ធសាសនាត្រូវចុះអន់ថយ ដូចជាក្នុងកំឡុងសតវត្សរ៍ ទី ៧-៨ និងស.វទី ១០-១១ ឬសាបសូន្យខ្ទេចខ្ទី ដូចជាក្នុងកំឡុងឆ្នាំ ១៩៧៥-១៩៧៩ ក្តី ក៏ជំនឿដ៏មោះមុតរបស់ខ្មែរ បានធ្វើឲ្យពុទ្ធសាសនារុងរឿង និងមានជីវិតនៅជាប់លាប់រហូតទល់បច្ចុប្បន្ន ។ មិនត្រឹមតែមានឈ្មោះថាជាសាសនារបស់ខ្មែរទេ តែពុទ្ធសាសនាបានក្លាយទៅជាវប្បធម៌ជាតិដ៏មានសក្តានុពលក្នុងការកំណត់វិធីជីវិតរបស់ខ្មែរ តាំងពីកើតរហូតដល់ស្លាប់ទៀតផង ។ ជីវិតក្នុងក្រុមគ្រួសារ ការសិក្សា សេដ្ឋកិច្ច សិល្បៈ ការកសាង និងនយោបាយដឹកនាំរបស់ប្រទេសជាតិ សុទ្ធតែបានទទួលឥទ្ធិពលពីពុទ្ធសាសនាទាំងអស់ ហើយក៏នឹងនៅតែបន្តមានឥទ្ធិពលទៅអនាគតទៀតជានិច្ច ។

ពុទ្ធសាសនានៅប្រទេសខ្មែរនាបច្ចុប្បន្នមានពីរក្រុម ឬនិកាយ គឺមហានិកាយ ដែលជាក្រុមព្រះសង្ឃមាននៅប្រទេសខ្មែរតាំងពីបុរាណកាលមក និងក្រុមធម្មយុត្តិកនិកាយ ដែលជាក្រុមព្រះសង្ឃថ្មី ទើបនឹងហូរចូលមកពីប្រទេសថៃ ក្នុងរជ្ជកាលព្រះបាទអង្គឌួង នាឆ្នាំ ១៨៦៤ ។ តាមពិតពាក្យថា មហានិកាយ ជាពាក្យដែលក្រុមព្រះសង្ឃថ្មីហៅក្រុមព្រះសង្ឃចាស់ ប្រែថាក្រុមមានគ្នាច្រើន ។ និកាយនិមួយៗ មានប្រព័ន្ធការគ្រប់គ្រងរៀងៗខ្លួន គឺមានប្រមុខរបស់ព្រះសង្ឃដែលហៅថា ព្រះសង្ឃរាជ ។

នៅក្នុងឆ្នាំ ១៩៦៧ ប្រទេសយើងមានវត្ត ដែលជានិមិត្តរូបរបស់ពុទ្ធសាសនាចំនួន ៣,១៥៣ វត្ត និងមានព្រះភិក្ខុសាមណេរគង់ចាំវស្សាចំនួន ៦០,៩០៩ អង្គ នៅតាមខេត្ត និងក្រុងទាំង ២០ (សូមមើលតារាងទី១) ។ លុះដល់ឆ្នាំ ១៩៧០-១៩៧៥ សង្គ្រាមស៊ីវិលបានធ្វើឲ្យខូចខាតដល់វត្តមួយចំនួន ដោយសារការបាញ់ផ្លោង និងការទំលាក់គ្រាប់បែក ។ ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ របបកុម្មុយនិស្តខ្មែរក្រហម បានកាប់

www.budinst.gov.kh www.elibraryofcambodia.org

សម្លាប់ប្រជារាស្ត្រ ព្រះសង្ឃ និងបំផ្លាញវត្តអារាមឲ្យខូចខាតខ្ទេចខ្ទីរជាខ្លាំង ។ នៅក្នុងឆ្នាំ ១៩៩៤ នេះ ប្រទេសខ្មែរយើង មានវត្តដែលសេសសល់ពីសម័យខ្មែរក្រហម និងដែលបានកសាងជួសជុលឡើងវិញចំនួន ៣,២៥៣ វត្ត និងមានព្រះភិក្ខុសាមណេរគង់ចាំវស្សាចំនួន ៣៩,៣៥២ អង្គ នៅតាមខេត្ត និងក្រុងទាំង ២១ ។

(សូមមើលតារាងទី២)

ស្ថិតិព្រះសង្ឃ និងវត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងវស្សាឆ្នាំ ២៥១០/១៩៦៧

| ខេត្ត និងក្រុង | មហានិកាយ | ធម្មយុត្តិ | សរុប | ព្រះសង្ឃ |
|---|---|---|---|---|
| ភ្នំពេញ | ២២ | ២ | ២៤ | ១៩៥៦ |
| បាត់ដំបង | ២៨៧ | ៦០ | ៣៤៧ | ៦៧០១ |
| កណ្ដាល | ៣៤៦ | ២១ | ៣៦៧ | ៨៣៩៦ |
| កំពង់ចាម | ៣៩៣ | ១៦ | ៤០៩ | ៨៧០១ |
| តាកែវ | ២៥០ | ១៦ | ២៦៦ | ៤២៦៣ |
| កំពង់ឆ្នាំង | ១៥៣ | ៥ | ១៥៨ | ៣៤១៧ |
| កំពត | ១៥៦ | ២៤ | ១៨០ | ២៧៥៩ |
| កំពង់ធំ | ២០៤ | ២៤ | ២២៨ | ៤០២២ |
| សៀមរាប | ១២៣ | ២៣ | ១៤៨ | ៣៨១៧ |
| កំពង់ស្ពឺ | ១៧៤ | ៩ | ១៨៣ | ៤៣០៣ |
| ស្វាយរៀង | ១៦៤ | ១៥ | ១៧៩ | ២៤៨៤ |
| ព្រៃវែង | ៣៤៣ | ២៥ | ៣៦៨ | ៥៧០៩ |
| ពោធិសាត់ | ៧៧ | ២២ | ៩៩ | ២០៧៧ |
| ក្រចេះ | ៤៥ | ១៧ | ៦២ | ៩៦៩ |
| ស្ទឹងត្រែង | ១៥ | ២៦ | ៤១ | ៣៧៩ |
| កោះកុង | ៣៨ | ៩ | ៤៧ | ៥៤១ |
| រតនគិរី | ១១ | ២ | ១៣ | ១០២ |
| ឧត្តរមានជ័យ | ១១ | ៤ | ១៥ | ៣២២ |
| ព្រះវិហារ | ២១ | | ២១ | ៩២ |
| មណ្ឌលគិរី | | | | |
| សរុប | ២៨៣៣ | ៣២០ | ៣១៥៣ | ៦០៥០៩ |

តារាងទី ១

www.budinst.gov.kh www.elibraryofcambodia.org

ស្ថិតិព្រះសង្ឃ និងវត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងវស្សាឆ្នាំ ២៥៣៨/១៩៩៥

| ខេត្ត និងក្រុង | មហានិកាយ | ធម្មយុត្តិ | សរុប | ព្រះសង្ឃ |
|---|---|---|---|---|
| ភ្នំពេញ | ៧៨ | ៣ | ៨១ | ២៧៣៨ |
| បាត់ដំបង | ១៧៣ | ០៣ | ១៧៦ | ២៩៣៨ |
| កណ្ដាល | ៣៥២ | ២០ | ៣៦២ | ២៥១១ |
| កំពង់ចាម | ៤២០ | ១១ | ៤៣១ | ៣៧៨៧ |
| តាកែវ | ២៨៦ | ១០ | ២៩៦ | ៣៧២៣ |
| កំពង់ឆ្នាំង | ១៧១ | | ១៧១ | ១៩៨២ |
| កំពត | ១៨៤ | ០១ | ១៨៥ | ២០៣៤ |
| កំពង់ធំ | ២០៣ | | ២០៣ | ២៧៧៦ |
| សៀមរាប | ១៨៤ | | ១៨៤ | ៤៥៥៣ |
| កំពង់ស្ពឺ | ១៨៤ | ០៦ | ១៩០ | ២៨១៤ |
| ស្វាយរៀង | ២១០ | ០១ | ២១១ | ១៧៣០ |
| ព្រៃវែង | ៤០៤ | ១១ | ៤១៥ | ៣១៣៣ |
| ពោធិ៍សាត់ | ១០២ | ០២ | ៩៩ | ១២២៧ |
| ក្រចេះ | ៦៧ | ០១ | ៦៨ | ៣០៩ |
| ស្ទឹងត្រែង | ២៣ | | ២៣ | ២៥៧ |
| កោះកុង | ២៤ | | ២៤ | ២៣៩ |
| រតនគិរី | ១១ | | ១១ | ១០៦ |
| បន្ទាយមានជ័យ | ១៥២ | ០៤ | ១៥៦ | ១៩៧៥ |
| កែប | ៣ | | ៣ | ៣៥ |
| ព្រះវិហារ | ២៥ | | ២៥ | ៣៨១ |
| មណ្ឌលគិរី | ០២ | | ០២ | ០៧ |
| **សរុប** | **៣២៥៣** | **៧៣** | **៣៣២៦** | **៣៩៣៥២** |

( តារាងទី ២ )

ចំនួនព្រះសង្ឃនាឆ្នាំ ១៩៩៥ នេះ បើប្រៀបទៅនឹងឆ្នាំ ១៩៦៧ ដែលមានរហូតដល់ទៅ ៦១,០០០ អង្គនោះ ឃើញថាខុសគ្នាឆ្ងាយណាស់ មិនអាចបំពេញសេចក្ដីត្រូវការរបស់ពុទ្ធបរិស័ទបានឡើយ ។ ម្យ៉ាងទៀត ក្រោយការសម្លាប់ និងបំផ្លាញយ៉ាងរង្គាលក្នុងឆ្នាំ ១៩៧៥-១៩៧៩ របស់ពួកកុម្មុយនិស្តខ្មែរក្រហមមក ពុទ្ធសាសនាត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

បាត់បង់នូវបរិស័ទ និងព្រះសង្ឃដែលជាបញ្ញវ័ន្ត ស្ទើរអស់រលីង ជាការមួយដែលធ្វើឲ្យព្រះសង្ឃយើងនាបច្ចុប្បន្ននេះ មានអតុល្យភាពយ៉ាងខ្លាំងរវាងគុណភាព និងបរិមាណ គឺគុណភាពមានកម្រិតទាបណាស់ បើប្រៀបធៀបទៅនឹងសម័យមុន ។

ទោះជាយ៉ាងណាក្តី ក៏យើងនៅតែសង្ឃឹមថា គុណភាពនេះនឹងកាន់តែកើនឡើងៗជាលំដាប់ នៅពេលដែលការសិក្សារបស់ព្រះសង្ឃបើកចំហរទូលំទូលាយ ដែលនឹងអាចឲ្យព្រះសង្ឃយើងក្រេបជញ្ជក់យកចំណេះវិជ្ជាខាងពុទ្ធសាសនា ទាំងពីខាងក្នុងប្រទេស និងបរទេស បានជ្រៅជ្រះជាពុំខាន ។

ជាតិរលំ សាសនារលាយ

ពុទ្ធសាសនាខ្ចាត់ខ្ចាយ រលាយជាតិខ្មែរ

www.budinst.gov.kh www.elibraryofcambodia.org

# អង្គប្រកបពុទ្ធសាសនា

កាលពីឆ្នាំ ១៩៩១ មានគេសួរទៅកាន់ស្ត្រីចំណាស់ម្នាក់ នៅភូមិបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យថា ៖ អ៊ំកាន់សាសនាអ្វី? គាត់ឆ្លើយថា « ខ្ញុំកាន់សាសនាលោកសង្ឃ » ដែលជាចម្លើយមួយអាចឲ្យយើងវាយតម្លៃបានថា ការយល់ដឹងអំពីពុទ្ធសាសនារបស់ប្រជាពលរដ្ឋខ្មែរយើងតិចតួចណាស់ ។ ចំពោះអ្នកដែលមានការរៀនសូត្រ ប្រាកដជាអាចឆ្លើយបាន ព្រោះធ្លាប់ឮជាញឹកញាប់ ឬធ្លាប់បានអានសៀវភៅផ្សេងៗ តែបើគេសួរថា តើពុទ្ធសាសនាមានអ្វីជាសំគាល់ ហើយនៅត្រង់កន្លែងណានោះ ប្រាកដជាង៉េះង៉ះក្នុងចិត្ត រកឆ្លើយមិនកើត ឬបើមិនដូច្នោះទេ ក៏នឹងនឹកទៅដល់ព្រះសង្ឃដែលគង់ក្នុងវត្ត ឬនឹកដល់ព្រះពុទ្ធបដិមាជាពុំខាន ។ ឥឡូវនេះ សូមឲ្យយើងពិចារណាទៅលើអង្គប្រកបពុទ្ធសាសនា ដូចខាងក្រោមនេះ ៖

## ក- អង្គប្រកបបែបដើមរុក្ខជ.តិ

អង្គប្រកបរបស់ព្រះពុទ្ធសាសនា អាចចែកចេញជ. ៦ ប្រការគឺ ៖

*១- ពុទ្ធសាសនបុគ្គល* : បានដល់អ្នកបួសក្នុងព្រះពុទ្ធសាសនា គឺភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី និងអ្នកដែលទ្រទ្រង់នូវគ្រឿងសំគាល់ថាជាអ្នកបួស តែមានភេទជាគ្រហស្ថ ដូចជា ដូនជី តាជីជាដើម ។ ក្រៅពីនេះ អ្នកដែលកាន់ ជឿ ដើរតាមពុទ្ធសាសនា ដែលយើងហៅថាពុទ្ធបរិស័ទ មានឧបាសកនិងឧបាសិកានេះ ក៏អាចរាប់ថាជាពុទ្ធសាសនបុគ្គលដែរ ។

*២- ពុទ្ធសាសនស្ថាន* : បានដល់ទីកន្លែង មានវត្តអារាម ព្រះវិហារ កន្លែងសក្ការៈផ្សេងៗ មានចេតិយបញ្ចុះព្រះសារីរិកធាតុជាដើម រួមទាំងប្រាសាទដែលកសាងឧទ្ទិសចំពោះពុទ្ធសាសនា មានប្រាសាទបាយ័នជាអាទិ៍។

*៣- ពុទ្ធសាសនវត្ថុ* : បានដល់វត្ថុដែលជាគ្រឿងសំគាល់របស់ពុទ្ធសាសនា មានព្រះពុទ្ធរូប ពុទ្ធបដិមា ពោធិព្រឹក្ស ទង់សាសនា រូបធម្មចក្រ ជាដើម។

*៤- ពុទ្ធសាសនពិធី* : គឺពិធីកម្មផ្សេងៗ ដែលមានក្នុងពុទ្ធសាសនា ដូចជា :

www.budinst.gov.kh www.elibraryofcambodia.org

ឧបសម្បទាកម្ម គឺការបំបួស ឧបោសថកម្ម សង្ឃកម្មផ្សេងៗ រួមទាំងបុណ្យទាន ដែលយើងតែងធ្វើ មានបុណ្យផ្កា បុណ្យកឋិន សង្ឃទាន ។ល។

*៥- ពុទ្ធសាសនធម៌* : គឺពាក្យប្រៀនប្រដៅ ឬធម៌ទាំងឡាយដែលព្រះពុទ្ធទ្រង់បានសំដែង ហើយដែលព្រះសង្ឃថេរៈទាំងឡាយលោកបានប្រមូលចងក្រងទុកជាគម្ពីរ ហៅថា ព្រះត្រៃបិដក និងគម្ពីរ សៀវភៅធម៌ផ្សេងៗ ដែលព្រះសង្ឃ និងអ្នកប្រាជ្ញទាំងឡាយបានតែងទុក ។

*៦- ពុទ្ធសាសនបដិបត្តិ* : គឺការបដិបត្តិទៅតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដើម្បីសំរេចនូវប្រយោជន៍គឺសេចក្តីសុខ និងឆ្លងផុតពីទុក្ខឆ្ពោះទៅរកព្រះនិព្វាន ដែលជាគោលដៅចុងបំផុតរបស់ព្រះពុទ្ធសាសនា ។




ទាំង ៦ យ៉ាងនេះ គឺជាអង្គធាតុដែលយើងតែងនឹកស្គាល់ថាជាពុទ្ធសាសនា ហើយជួនកាលអ្នកខ្លះស្គាល់បានត្រឹមតែធាតុណាទីមួយតែប៉ុណ្ណោះ ថាជាពុទ្ធសាសនា តែតាមការពិត អ្វីដែលយើងស្គាល់ថាជាពុទ្ធសាសនានោះ គួរតែរួមផ្សំដោយធាតុទាំង ៦ យ៉ាងនេះ ទើបបរិបូណ៌ជាពុទ្ធសាសនាបាន ។

បើយើងប្រៀបធៀបពុទ្ធសាសនាទៅនឹងដើមឈើមួយដើម ដែលរួមផ្សំដោយ

www.budinst.gov.kh www.elibraryofcambodia.org

ឫស សំបក ដើម ស្លឹក និងផ្លែនោះ យើងនឹងឃើញថាក្នុងឈើមួយដើមនេះ ធាតុណាមួយក៏មានប្រយោជន៍ និងត្រូវពឹងពាក់គ្នាទៅវិញទៅមកដែរ។ បើសិនជាបាត់នូវធាតុណាមួយនោះ ដើមឈើនោះ ក៏នឹងមានជំងឺ សុខភាពមិនល្អ ឬក៏អាចនឹងស្លាប់ផងក៏បាន ។

បើសំរាប់អ្នកដែលយកដើមឈើមកប្រើជាប្រយោជន៍វិញ អ្នកខ្លះក៏ត្រូវការឫស ខ្លះក៏ត្រូវការសំបក ខ្លះក៏ត្រូវការដើម ខ្លះក៏ត្រូវការមែក ខ្លះក៏ស្លឹក ខ្លះក៏ផ្លែ ហើយខ្លះទៀតក៏ត្រូវការទាំងអស់ ។

## តើពុទ្ធសាសនធាតុណាមួយដែលសំខាន់ជាងគេ ?

ទោះជាយ៉ាងណាក្តី ខ្លឹម គឺជាចំណែករបស់ឈើដែលគេត្រូវការជាទូទៅ ក្នុងការយកមកធ្វើជាសសរ ជាក្តារ តុ ទូបាន និងលក់ទៅមានតម្លៃ ។ អាចក្តីគិតថា សាសនបដិបត្តិ មានសារៈសំខាន់ និងផ្តល់នូវផលប្រយោជន៍ជាងគេដល់ពុទ្ធសាសនិកជន ដូចមានគាថាដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា : *“យោ ចខ ធម្មានុធម្មបដិបន្នោ វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ”* អ្នកណាមួយដែលប្រតិបត្តធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដ៏ត្រឹមត្រូវ ជាអ្នកធ្វើតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន បូជា ដល់តថាគត (ព្រះពុទ្ធ) ឈ្មោះថាបានធ្វើបដិបត្តិបូជា ដែលជាបូជាដ៏ឧត្តម។

## ខ- អង្គប្រកបក្នុងលក្ខណៈជាស្ថាប័ន

ដើម្បីឲ្យទៅជាសាសនាមួយដែលគេទទួលស្គាល់ថា ជាសាសនាសំរាប់ពិភពលោកនោះ សាសនានីមួយៗ ត្រូវប្រកបដោយអង្គ ៥ ប្រការគឺ ៖ មានអ្នកបង្កើត, មានពាក្យប្រៀនប្រដៅ, មានគម្ពីរ, មានអ្នកបួស និងមាននិមិត្តសញ្ញា ។ ក្នុងលក្ខណៈជាស្ថាប័ន ពុទ្ធសាសនាយើងមានអង្គប្រកបទាំង ៥ យ៉ាងនេះគ្រប់គ្រាន់ គឺ ៖

១- អ្នកបង្កើត (Founder) គឺព្រះសម្មាសម្ពុទ្ធ

២- ពាក្យប្រៀនប្រដៅ (Teaching) បានដល់ពាក្យប្រៀនប្រដៅទាំងប្រាំបី

www.budinst.gov.kh www.elibraryofcambodia.org

ម៉ឺន បួនពាន់ (៨៤,០០០) ធម្មក្ខន្ធ ដែលព្រះពុទ្ធទ្រង់បានប្រៀនប្រដៅអស់រយៈកាល ៤៥ ឆ្នាំ ជាពិសេសអរិយសច្ចៈ ៤ ប្រការ ដែលនិយាយពីជីវិតមនុស្ស និងការប្រឈមមុខចំពោះសេចក្ដីទុក្ខ, ប្រភពនៃសេចក្ដីទុក្ខ, ការរួចផុតពីសេចក្ដីទុក្ខ, និងវិធីសំរាប់ឆ្លងពីសេចក្ដីទុក្ខនោះ ។

**៣- គម្ពីរ** (Scripture) ដែលជាក្រុមគម្ពីរផ្ទុកនូវវចនៈព្រះពុទ្ធ មាន ៣ យ៉ាងគឺ គម្ពីរ វិន័យបិដក, គម្ពីរសុត្តន្តបិដក និងគម្ពីរអភិធម្មបិដក ។

**៤- អ្នកបួស** (Clergy) ក្នុងពុទ្ធសាសនា អ្នកបួសមានទាំងស្ត្រីភេទ និងបុរសភេទ ។ អ្នកបួសជាបុរសដែលមានអាយុចាប់ពី ២០ ឆ្នាំទៅ ហៅថា ភិក្ខុ បើតិចជាង ២០ ឆ្នាំ ហៅថា សាមណេរ ។ អ្នកបួសជាស្ត្រី ដែលមានអាយុច្រើនជាង ២០ ឆ្នាំ ហៅថា ភិក្ខុនី បើតិចជាង ២០ ឆ្នាំ ហៅថា សាមណេរី ។ នាបច្ចុប្បន្ននេះ ពុទ្ធសាសនានិកាយថេរវាទពុំមានអ្នកបួសជាស្ត្រីភេទទេ មានតែខាងមហាយានប៉ុណ្ណោះ ។

**៥- និមិត្តសញ្ញា** (Symbol ) ពុទ្ធសាសនាមានទង់ ៦ ពណ៌ ជានិមិត្តសញ្ញា ។ ពណ៌ទាំង ៦ នោះ មានពណ៌ខៀវ លឿង ក្រហម ស ហង្សបាទ និងពណ៌ផ្លេក ដូចរូបខាងក្រោម។ ទង់នេះត្រូវប្រទេស និងពុទ្ធសាសនិកជនក្នុងពិភពលោកប្រកាន់យកធ្វើជានិមិត្តសញ្ញាពុទ្ធសាសនា លើកលែងតែប្រទេសថៃ ដែលយករូបធម្មចក្រធ្វើជាទង់វិញ ។



ទង់ព្រះពុទ្ធសាសនា នៅកម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org

## គ- វចនាសម្ព័ន្ធពុទ្ធសាសនា

### ១- ការចូលជាសមាជិក :

អ្នកដែលកាន់ពុទ្ធសាសនា និងអ្នកដែលមានបំណងកាន់ពុទ្ធសាសនា ត្រូវរៀបចំខ្លួន ដើម្បីដើរតាមការណែនាំរបស់អង្គការកំពូលពុទ្ធសាសនាជានិច្ច ដោយឥតឯាកេរ។ អង្គការកំពូលរបស់ពុទ្ធសាសនាមានឈ្មោះហៅថា សរណៈ ប្រែថា ទីពឹង ទីរលឹក មានទាំងអស់ ៣ នាក់ ឬ ៣ ប្រការ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ដើម្បីឲ្យក្លាយទៅជាសមាជិករបស់ព្រះពុទ្ធសាសនា បេក្ខជនម្នាក់ៗ ត្រូវបន្លឺវាចាប្ដេជ្ញាយកនូវវត្ថុទាំង ៣ យ៉ាងនេះ ធ្វើជាទីពឹង ទីរលឹក ជាប្រទីបសំរាប់បំភ្លឺផ្លូវរបស់ខ្លួន ៣ ដង ដូចតទៅ ៖

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះពុទ្ធជាទីពឹង ទីរលឹក
ធម្មំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះធម៌ជាទីពឹង ទីរលឹក
សង្ឃំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះសង្ឃជាទីពឹង ទីរលឹក

ទុតិយម្បិ ←
ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះពុទ្ធជាទីពឹង ទីរលឹក
ធម្មំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះធម៌ជាទីពឹង ទីរលឹក
សង្ឃំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះសង្ឃជាទីពឹង ទីរលឹក
→ ជាលើកទី ២

តតិយម្បិ ←
ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះពុទ្ធជាទីពឹង ទីរលឹក
ធម្មំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះធម៌ជាទីពឹង ទីរលឹក
សង្ឃំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះសង្ឃជាទីពឹង ទីរលឹក
→ ជាលើកទី ៣

### ២- នាទីរបស់សមាជិកពុទ្ធសាសនា :

អ្នកដែលបានបន្លឺវាចាយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរលឹក ជាប្រទីបសំរាប់ជីវិតរបស់ខ្លួនហើយ នឹងក្លាយទៅជាពុទ្ធបរិស័ទ ដោយត្រឹមត្រូវទៅតាមពុទ្ធប្បញ្ញត្តិ បើទោះជាអ្នកនោះពុំបានចុះឈ្មោះនៅក្នុងបញ្ជីថាជាអ្នកកាន់ក៏ដោយ។ បន្ទាប់ពីបានចូលជាសមាជិកពុទ្ធសាសនាហើយ បុគ្គលនោះត្រូវមាននាទី ដែលត្រូវបំពេញ

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះពុទ្ធសាសនា និងសិទ្ធិ ដែលត្រូវទទួលមកវិញ ។ នាទីរបស់ពុទ្ធបរិស័ទមាន ពីរប្រការគឺ : <u>នាទីចំពោះខ្លួនឯងផ្ទាល់</u> និង <u>នាទីចំពោះព្រះពុទ្ធសាសនា</u> ។

**នាទីចំពោះខ្លួនឯង** ចែកចេញជាពីរយ៉ាងគឺ ៖

ក- សិក្សា: ក្នុងនាទីនេះ ពុទ្ធបរិស័ទទាំងអស់គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ត្រូវសិក្សារៀនសូត្រឲ្យដឹង ស្គាល់ យល់ នូវអ្វីដែលហៅថាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងពុទ្ធវចនៈទាំងអស់ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែងទុក ។ ជាការងាយចងចាំ គឺសិក្សាព្រះត្រៃបិដកទាំងបី មានព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម ឲ្យបានច្បាស់ ទាំងអត្ថន័យ អត្ថរស និងវាក្យស័ព្ទរបស់ពុទ្ធវចនៈនិមួយៗ ។ ក្នុងសម័យពុទ្ធកាល លោកប្រើពាក្យថា *សិក្សាព្រហ្មចរិយាធម៌ ឬសិក្សាធម្មវិន័យ* ។

យើងដឹងហើយ ការសិក្សាមានសារៈសំខាន់ណាស់សំរាប់បុគ្គល សង្គម ប្រទេស ឬអង្គការនិមួយៗ ព្រោះវាជាជំហានដំបូងដែលនឹងនាំសិក្ខាកាមឆ្ពោះទៅរកគោលបំណងដែលខ្លួនចង់បាន ។ បើប្រៀបជីវិតទៅនឹងការស្វែងរកកំណប់ទ្រព្យ ការសិក្សា ឧបមាដូចជាផែនទីបង្ហាញផ្លូវដើម្បីរកកំណប់ទ្រព្យ ។ ការសិក្សានេះ ភាសាបាលីហៅថា **បរិយត្តិ** ។




ខ- **ការអនុវត្តន៍** : ក្នុងសម័យពុទ្ធកាល មានភិក្ខុមួយអង្គជាពហុសូត្រ ចេះដឹងជ្រៅជ្រះក្នុងធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធ តែលោកបានត្រឹមតែចេះដឹងប៉ុណ្ណោះ ពុំបានបដិបត្តិឡើយ ។ ព្រះសម្មាសម្ពុទ្ធបានហៅភិក្ខុអង្គនោះថា ***ភិក្ខុគម្ពីរទទេ*** ។ ដូច្នេះយើងឃើញថា ការគោរព ការជឿពុទ្ធសាសនា ពុំមែនស្ថិតនៅត្រឹមតែលើការចេះដឹង សូត្របានរត់មាត់នូវពុទ្ធវចនៈប៉ុណ្ណោះទេ គឺស្ថិតនៅលើការបដិបត្តិជាសំខាន់ ។ ឧបមាទៅនឹងការរកកំណប់ទ្រព្យ បើទោះជាមានផែនទីយ៉ាងល្អ បង្ហាញពីរបៀបរកកំណប់ដ៏ច្បាស់

www.budinst.gov.kh www.elibraryofcambodia.org

លាស់ក៏ដោយ តែបើយើងមិនដើរទៅរក និងមិនអនុវត្តទៅតាមសេចក្តីណែនាំរបស់ផែនទីទេ កំណប់ទ្រព្យនោះក៏នឹងមិនអាចផុះចេញពីដី ហោះមករកយើងឡើយ ។ ត្រង់នេះ ព្រះពុទ្ធជាម្ចាស់ទ្រង់បានមានបន្ទូលថា *"ម្នាលភិក្ខុទាំងឡាយ នុះផ្លូវដែលត្រូវដើរចូរអ្នកដើរទៅ តថាគតគ្រាន់តែជាអ្នកបង្ហាញផ្លូវតែប៉ុណ្ណោះ"* ។

## នាទីចំពោះព្រះពុទ្ធសាសនា

ក្នុងឋានៈជាសមាជិកនៃសង្គមមួយ ជាការចាំបាច់ណាស់សំរាប់សមាជិកគ្រប់រូបដែលបានទទួលផលប្រយោជន៍ពីសង្គមណា ត្រូវតបស្នងទៅនឹងសេចក្តីត្រូវការរបស់សង្គមនោះវិញ ដើម្បីស្ថិរភាព និងការគង់វង្សរបស់សង្គមនោះ ។ ដូច្នេះពុទ្ធបរិស័ទក៏គួរត្រូវមាននាទីចំពោះពុទ្ធសាសនា ដែលជាសាសនារបស់ខ្លួនដែរ ។ នាទីចំពោះពុទ្ធសាសនា អាចគួរត្រូវមាន ៤ ប្រការ គឺ៖

**១- នាទីការពារ** : មិនឲ្យបុគ្គល ក្រុម សាសនា លទ្ធិដទៃ ដែលមានគំនិតចង់បំផ្លាញ បៀតបៀន បង្ខូច មើលងាយ មួលបង្កាច់ ធ្វើឲ្យរីករវរ កកូរឲ្យល្អក់ បំភ្លៃឲ្យសៅហ្មងដល់ពុទ្ធវចនៈនិងស្ថាប័នពុទ្ធសាសនា និងការពារមិនឲ្យពុទ្ធវចនៈនិងស្ថាប័ននេះ ចុះទន់ខ្សោយ កករល្អក់ ឬសៅហ្មងដោយប្រការដទៃណាមួយឡើយ ។ ពុទ្ធសាសនាស្វាគមន៍នូវមនុស្ស និងលទ្ធិជំនឿគ្រប់ប្រភេទ ក្នុងឋានៈជាមិត្តរួមលោក ដើម្បីសេចក្តីសុខរបស់ពិភពលោកនេះ តែក៏មានសិទ្ធិដើម្បីនឹងថែរក្សានូវអត្តសញ្ញាណ សិទ្ធិ និងកម្មសិទ្ធិរបស់ខ្លួនទៅតាមពុទ្ធវចនៈដែលព្រះពុទ្ធអង្គទ្រង់ប្រទានទុកថាសំវរបធានៈ មានន័យថា ព្យាយាមការពារមិនឲ្យរបស់មិនល្អ ចូលមកយាយីដល់សេចក្តីសុខរបស់យើង ។

**២- នាទីកំចាត់** : នូវរឿងហេតុមិនល្អ ភាពសៅហ្មង ការអាស្រូវ ចំណុចខ្សោយ ដែលមានហើយ កើតឡើងហើយ ក្នុងស្ថាប័នពុទ្ធសាសនា ឲ្យអស់មិនឲ្យសល់ មិនបណ្តោយឲ្យរឿងហេតុដែលមិនល្អទាំងនោះចេះតែកើតឡើង និងស៊ីរូងផ្ទៃក្នុងកាន់តែជ្រៅទៀតឡើយ ។

**៣- នាទីបង្កើន** : ធ្វើអោយសម្បូរ បង្កើនអោយច្រើន ផ្សព្វផ្សាយឲ្យទូលំទូលាយថែមទៀត នូវពុទ្ធវចនៈដល់ជនទាំងឡាយគ្រប់ទិសទាំង ៤ គ្រប់ទ្វីប គ្រប់ស្រទាប់វណ្ណៈ ដើម្បីឲ្យជនទាំងឡាយនោះបានត្រេកអរសជាតិព្រះធម៌ ដែលជាផ្លូវរំលត់ទុក្ខដ៏ល្អ

www.budinst.gov.kh www.elibraryofcambodia.org

វិសេស ។

៤- នាទីរក្សា ៖ នូវគុណធម៌ គុណភាព និងបរិមាណរបស់ពុទ្ធបរិស័ទ ពុទ្ធវចនៈ និងស្ថាប័នពុទ្ធសាសនាដែលមានហើយ ដែលចំរើនហើយ កុំឲ្យបាត់បង់ និងឲ្យរឹតតែចំរើនឡើងៗជាអភិយោគភាពតទៅ ដើម្បីជាកេរ្តិ៍មត៌កសំរាប់អនុជនជំនាន់ក្រោយ ។

យើងអាចសរុបនូវនាទីរបស់ពុទ្ធបរិស័ទទាំងចំពោះខ្លួនឯង និងព្រះពុទ្ធសាសនាជាពាក្យខ្លីៗ ៦ ម៉ាត់ ឲ្យងាយចាំ និងងាយអនុវត្តដូចតទៅ ៖

នាទីរបស់យើងជាពុទ្ធបរិស័ទ គឺ ៖ សិក្សា បដិបត្តិ ការពារ កំចាត់ បង្កើន រក្សា ព្រះពុទ្ធសាសនាឲ្យបានត្រឹមត្រូវ

## សិទ្ធិសមាជិកពុទ្ធសាសនា

សមាជិកពុទ្ធសាសនាម្នាក់ៗ អាចទទួលបាននូវសិទ្ធិពីពុទ្ធសាសនាគ្រប់ៗ គ្នាទាំងអស់ បន្ទាប់ពីបានបំពេញនូវនាទីសិក្សា និងបដិបត្តិដោយត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ ។ សិទ្ធិទាំងនោះមាន ៖

១- **សិទ្ធិក្នុងការបដិបត្តិទៅតាមធម៌វិន័យ** ដែលព្រះពុទ្ធបានបញ្ញត្តិ អនុញ្ញាត និងសំដែងទុកទាំងប៉ុន្មាន ដោយសេរី និងស្មើភាពគ្នា ដោយមិនប្រកាន់ជាតិ កំណើត ភេទ ពណ៌សម្បុរ វណ្ណៈ ទីកន្លែង ឬអាជីវកម្មឡើយ ។

២- **សិទ្ធិក្នុងការអភិវឌ្ឍនជីវិតខ្លួន** ពីបុថុជ្ជនទៅជាអរិយជន គ្រប់វ័យទាំងអស់ ទាំងខាងផ្នែករាងកាយ ការប្រព្រឹត្ត ផ្លូវចិត្ត និងសតិបញ្ញា ។

៣- **សិទ្ធិក្នុងការទទួលផលដែលកើតពីការបដិបត្តិ** ទាំងនាបច្ចុប្បន្ន និងអនាគត ទាំងនាលោកិយ៍ គឺសេចក្តីសំរេចក្នុងជីវិតខាងផ្នែកសម្ភារៈ និងលោកុត្តរៈ ដែលជាសេចក្តីសុខខាងផ្លូវចិត្ត ៤ ប្រការ គឺ សោតាបត្តិផល សកទាគាមិផល អនាគាមិផល និងអរហត្តផល ។

៤- **សិទ្ធិក្នុងការចូលរួមចំណែក** និងទទួលខុសត្រូវលើ សុខ ទុក្ខរបស់ពុទ្ធសាសនា ។

ជនណាបានបំពេញនាទី ជននោះនឹងបានទទួលសិទ្ធិ

ជនណាចង់មានសិទ្ធិ ជននោះត្រូវបំពេញនាទី

www.budinst.gov.kh www.elibraryofcambodia.org

## ការអស់សមាជិកភាព

ពុទ្ធបរិស័ទណានិមួយដែលព្យាយាម និងបានជេរត្មះ តិះដៀល បំផ្លិចបំផ្លាញ ដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជននោះនឹងត្រូវដាច់សមាជិកភាពភ្លាមមួយរំពេច បើទោះជាពុំមាននរណាដឹងព្ធក៏ដោយ ។ បើចង់ចូលជាសមាជិកវិញ ត្រូវធ្វើការខមាទោសជាវាចាចំពោះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយតាំងចិត្តថានឹងមិនប្រព្រឹត្តទៀតទេ ហើយត្រូវសមាទានសុំត្រៃសរណគមន៍អំពីព្រះសង្ឃសាជាថ្មីម្តងទៀត បើមិនដូច្នោះទេ បុគ្គលនោះនឹងក្លាយជា មោឃៈបុរស ជាមិនខាន ។

ធម្មោ ហវេ រក្ខតិ ធម្មចារី

អ្នកដែលគោរពនាទីខ្លួន នាទីនោះនឹងថែរក្សាគេវិញ



www.budinst.gov.kh www.elibraryofcambodia.org

# ត្រៃសរណគមន៍

យើងបានដឹងនៅក្នុងវគ្គទី ២ ហើយថា ដើម្បីបានឋានៈជាពុទ្ធបរិស័ទ ឬក្លាយជាសមាជិកពុទ្ធសាសនា គេត្រូវបន្លឺវាចាយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើជាទីពឹងទីរលឹក ។ លុះដល់បុគ្គលនោះជេរត្មះ តិះដៀល សរណៈទាំង ៣ នេះពេលណា ជននោះក៏នឹងដាច់សមាជិកភាពខ្លួនពេលនោះភ្លាម ។ ដូច្នេះសរណៈទាំង ៣ នេះ មានសារៈសំខាន់ជាកំពូលសំរាប់ពុទ្ធបរិស័ទ ដែលត្រូវសិក្សាឲ្យបានដឹងច្បាស់ថា តើសរណៈនោះជាអ្វី ជានរណា មានកំណើតនៅទីណា វេលាណា ហេតុអ្វីទើបត្រូវយកមកធ្វើជាទីពឹង និងយកមកធ្វើជាទីពឹងដោយរបៀបណា ។ ពេលដែលដឹងនូវចម្លើយទាំងអស់នេះហើយ អ្នកដែលមិនទាន់ជឿ នឹងលែងសង្ស័យ ព្រមទាំងអាចធ្វើការវិនិច្ឆ័យសំរេចចិត្តដោយខ្លួនឯង ថាតើគួរយកមកធ្វើជាទីពឹងឬទេ? ។ ចំពោះអ្នកដែលមានជំនឿខ្លះហើយ អាចនឹងមានការវិនិច្ឆ័យកាន់តែល្អ ថាតើគួរជឿទៀតឬទេ? និងធ្វើឲ្យកាន់តែមានជំនឿច្បាស់ថែមទៀត ។ បានជាត្រូវសិក្សាឲ្យច្បាស់អស់សេចក្ដី ព្រោះពុទ្ធសាសនាពុំចង់ឲ្យនរណាជឿទាំងងងឹតងងល់ ដោយពុំបានសិក្សា និងប្រើបញ្ញាដោយសេរី និងពុំមានហេតុផលត្រឹមត្រូវនោះទេ ខុសពីសាសនាដទៃដែលយកអាទិទេពជាធំ ។ សាសនាអាទិទេពនិយម ហាមមិនឲ្យបរិស័ទខ្លួនមានការត្រិះរិះ វិភាគ ឬសាកសួររឿងអ្វីដែលទាក់ទងទៅនឹងអត្ថិភាពរបស់អាទិទេពគេឡើយ គឺត្រូវមានជំនឿប្រភេទ*សិទ្ធាន្ដៈ* ដោយមិនបាច់ធ្វើការដេញដោល (Dogma) ។ ពុទ្ធសាសនាបដិសេធជំនឿរបៀបនេះ ព្រោះពុទ្ធសាសនា មានលក្ខណៈជា*ឯហិបស្សិកោ* គឺបើកចំហរឲ្យធ្វើការពិសោធន៍លើអរិយសច្ចភាពរបស់ខ្លួន បានគ្រប់ពេលវេលា និងកាលសម័យ ។



www.budinst.gov.kh www.elibraryofcambodia.org

# ព្រះពុទ្ធ

ព្រះពុទ្ធអង្គជាអ្នកប្រកាសពុទ្ធសាសនា ជាមហាបុរសប្រចាំពិភពលោកមួយអង្គ ដែលប្រជាករពិភពលោកជាច្រើនគោរពរាប់អាន ព្រោះព្រះអង្គជាអ្នកដែលបានស្រាវជ្រាវរកឃើញវិធីយកឈ្នះលើសេចក្តីទុក្ខរបស់មនុស្ស បានដោយដាច់ខាតជាដំបូងលើលោកនេះ ព្រមទាំងបានបង្ហាត់បង្រៀន បង្ហាញឲ្យគេឯងបានធ្វើតាមផង ។ អ្នកមានបញ្ញាចេះដឹង យល់ និងអនុវត្តតាមពាក្យបង្រៀនរបស់ព្រះអង្គ នឹងបានទទួលលទ្ធផលជាសេចក្តីសុខ ស្ងប់ ផុតទុក្ខ ដូចជាព្រះអង្គដែរ ។ គុណធម៌របស់ព្រះអង្គបានធ្វើឲ្យជនដែលដើរតាមលើកតម្កើងហៅព្រះនាមព្រះអង្គផ្សេងៗគ្នា ទៅតាមការនិយមរបស់ខ្លួន ខ្លះក៏ហៅព្រះអង្គថា សក្យមុនី មានន័យថា *អ្នកប្រាជ្ញចេញពីរាជវង្សសក្យៈ* ខ្លះក៏ហៅថា សមណគោត្តម ប្រែថា *អ្នកបួសចេញពីត្រកូលគោត្តម* ។ អ្នកដែលគោរពព្រះអង្គជាសាស្តាខ្លួន ក៏ហៅព្រះអង្គថា ភគវន្ត ឬព្រះដ៏មានព្រះភាគ ដែលមានន័យថា *អ្នកមានជ័យជំនះក្នុងការរំលត់ទុក្ខ* ។ល។ តែចំពោះព្រះអង្គផ្ទាល់វិញ ទ្រង់ប្រើសព្វនាមជំនួសព្រះអង្គជា " **តថាគត** " ប្រែថា **អ្នកមានដំណើរទៅដូច្នោះឯង** ។

ខ្មែរយើងតែងហៅព្រះអង្គថា ព្រះបរមគ្រូ ព្រោះព្រះអង្គជាគ្រូដ៏ឆ្នើម លើសគ្រូដទៃទៀត។ តែជាទូទៅ យើងតែងហៅព្រះអង្គថា ព្រះពុទ្ធ, ព្រះពុទ្ធអង្គ, ព្រះពុទ្ធជាម្ចាស់ ជាដើម ។ ពាក្យថា " ពុទ្ធៈ " នេះ ជាទូទៅប្រែថា*អ្នកដឹង អ្នកភ្ញាក់ អ្នករីករាយ* ។ ប្រែថា *អ្នកដឹង* ព្រោះព្រះអង្គដឹងរឿងរបស់ជីវិត រឿងច្បាប់របស់ធម្មជាតិ និងវិធីបដិបត្តិឲ្យសមស្របនឹងធម្មជាតិ ។ ប្រែថា *អ្នកភ្ញាក់* ព្រោះព្រះអង្គភ្ញាក់អំពីការគ្របសង្កត់របស់កិលេស ភ្ញាក់ពីភាពល្ងង់ខ្លៅ ភ្ញាក់ពីមោហៈ ទោសៈ រាគៈ លោភៈ ។ ប្រែថា *អ្នករីករាយ* ព្រោះ មិនមានអ្វីដែលនឹងធ្វើឲ្យព្រះអង្គកើតទុក្ខ ឬសៅហ្មងក្នុងដួងហឫទ័យព្រះអង្គឡើយ ។

## ប្រវត្តិ

ក្នុងទឹកដីរបស់ប្រទេសនេប៉ាល់ពីអតីត នាភាគខាងត្បូងភ្នំហិមាល័យ មានរដ្ឋ

www.budinst.gov.kh www.elibraryofcambodia.org

តូចមួយឈ្មោះសក្យៈ ជាទីអាស្រ័យនៅរបស់ជនជាតិអរិយកៈ ឬអារ្យ៉ន ដែលជារដ្ឋមួយចំណុះឲ្យមហារដ្ឋកោសល ។ ក្សត្រដែលគ្រប់គ្រងរដ្ឋសក្កៈនេះព្រះនាមថា សុទ្ធោទនៈ នៃត្រកូលគោត្តម គង់នៅរាជធានីឈ្មោះកបិលព័ស្តុ ។ ព្រះអង្គមានមហេសីព្រះនាម ព្រះនាងមហាមាយា ជាក្សត្រីមកពីទីក្រុងទេវទហៈ ។ នារាត្រីមួយ ព្រះនាងមហាមាយា ជាមហេសី ទ្រង់ព្រះសុបិន្តនិមិត្តឃើញមានស្តេចដំរីសមួយធំ ភ្លុកខៀវ ប្រមោយកាន់ផ្កាឈូក បានយាងចូលមកក្នុងផ្ទៃព្រះនាងប៉ែកខាងស្តាំ ។ និមិត្តបែបនេះ ជាសញ្ញាការបានតាំងគភ៌របស់ព្រះនាង ហើយហោរាប្រចាំវាំងក៏បានទស្សន៍ទាយថា ព្រះនាងនឹងបាន ព្រះរាជបុត្រមួយព្រះអង្គដែលមានតេជៈខ្លាំងក្លា(ភ្លុកខៀវ) និងមានភាពបរិសុទ្ធ(ពណ៌ស) ។

នៅពេលមានគភ៌គ្រប់ទសមាសហើយ ព្រះនាងក៏បានលាព្រះស្វាមីទៅកាន់នគរព្រះនាងវិញ ព្រោះតាមទំនៀមឥណ្ឌាជំនាន់នោះ ស្ត្រីត្រូវទៅប្រសូត្របុត្រនៅឯផ្ទះខាងឪពុកម្តាយខ្លួន ។ ពេលក្បួនដង្ហែរបានមកដល់ព្រៃមួយកន្លែង ឈ្មោះព្រៃលុម្ពិនី ដែលជាទីពាក់កណ្តាលផ្លូវ ព្រះនាងក៏ឲ្យក្បួនឈប់សំរាក ។ ពេលនោះព្រះនាងក៏ចុះអំពីស្នែងទៅឈប់សំរាកក្រោមដើមសាលព្រឹក្សមួយដើមដែលមានម្លប់ត្រឈឹងត្រឈៃ មានផ្ការីកស្គុះស្គាយ និងមែកធ្លាក់យាររយីងរយោង ។ ឃើញដើមសាលព្រឹក្សដូច្នេះ ព្រះនាងក៏លើកព្រះហស្តទៅឈោងចាប់មែកសាលព្រឹក្សមួយមែកដែលនៅទាបជាងគេ ។ ពេលនោះឯង ស្រាប់តែព្រះនាងប្រសូត្រព្រះរាជបុត្រភ្លាម ទាំងអាការៈកំពុងឈរ ដោយពុំមានការឈឺចាប់ ។ ព្រះរាជទារកនោះជាភេទប្រុស ស្អាតប្រិមប្រិយ៍ ។ ថ្ងៃនោះគឺជាថ្ងៃមួយនៃដើមគិម្ហរដូវ ធាតុអាកាស ត្រជាក់ល្មម ពួកបុប្ផារីកស្គុះស្គាយ ត្រូវនឹងថ្ងៃពេញបូណ៌មី ១៥ កើត ខែពិសាខ ឆ្នាំច មុនពុទ្ធសករាជ ៨០ ឆ្នាំ វេលាម៉ោងប្រហែល ១២ ។

## ថ្វាយព្រះនាម

ដោយហេតុថា ព្រះនាងសិរិមហាមាយាទ្រង់ប្រសូត្ររាជបុត្ររួចហើយនោះ ពួកក្បួនដង្ហែរព្រះនាងក៏វិលត្រឡប់មកក្រុងកបិលព័ស្តុវិញដោយរីករាយ ។ ព្រះបាទសុទ្ធោទនៈ ទ្រង់រីករាយជាខ្លាំង ហើយបានប្រជុំព្រាហ្មណ៍ដែលចេះដឹងខាងហោរា ឲ្យមកថ្វាយព្រះនាមព្រះរាជបុត្រ ។ ពួកព្រាហ្មណ៍បានថ្វាយព្រះនាមថា «សិទ្ធត្ថៈ» ប្រែថា ញុំាងប្រយោជន៍ឲ្យសំរេចតាមប្រាថ្នា ព្រមទាំងបានទាយថា បើព្រះកុមារធំឡើង ហើយ

www.budinst.gov.kh www.elibraryofcambodia.org

នៅគ្រងរាជសម្បត្តិ នឹងបានទៅជាស្តេចចក្រពត្តិ បើចេញសាងព្រះផ្នួសនឹងបានទៅជាព្រះពុទ្ធ អាស្រ័យដោយសាររូបលក្ខណៈរបស់ព្រះកុមារ ត្រូវទៅតាមក្បួនមហាបុរិសលក្ខណៈ ៣២ ប្រការ ឥតមានខ្ចោះ ។

## ព្រាត់ព្រះមាតា

បន្ទាប់ពីប្រសូត្រព្រះកុមារបាន ៧ ថ្ងៃ ព្រះនាងសិរិមហាមាយា ក៏ចូលទិវង្គតចោលព្រះរាជបុត្រឲ្យនៅកំព្រា ។ ព្រះរាជកុមារត្រូវបានទទួលការចិញ្ចឹមបីបាច់រក្សាពីព្រះរាជមាតុច្ឆា (ម្តាយមីង) របស់ព្រះអង្គព្រះនាម មហាបជាបតី ដែលត្រូវជាព្រះមហេសីទី ២ របស់ព្រះបិតា រហូតដល់ព្រះអង្គធំ ។

## វ័យកុមារ

ព្រះសិទ្ធត្ថ ជាកុមារម្នាក់ដែលប្រកបទៅដោយទឹកចិត្តមេត្តាករុណា តាំងពីនៅតូច ជាពិសេសមានបញ្ញាឆ្លៀវឆ្លាតខ្លាំងណាស់ អាចរៀនចេះចប់នូវមុខវិជ្ជាដែលមានក្នុងសម័យនោះទាំង ១៦ យ៉ាង បានយ៉ាងឆាប់រហ័សនិងល្អជាទីបំផុត ។ ព្រះអង្គមានឧបនិស្ស័យខាងធ្វើសមាធិ តាំងតែពីនៅវ័យកុមារ ។

## យុវវ័យ

នៅពេលព្រះជន្មាយុបាន ១៦ វស្សា ព្រះសិទ្ធត្ថៈបានរៀបអភិសេកជាមួយម្ចាស់ក្សត្រី ពិម្ពាយសោធរា ដែលជាព្រះរាជធីតារបស់ព្រះបាទ សុប្បពុទ្ធ និងព្រះនាងអមិតា ក្សត្រសោយរាជ្យនៅនគរទេវទហៈ ជាកោលិយវង្ស ។

## រាជបំណងរបស់ព្រះបិតា

ចាប់តាំងពីឮទំនាយរបស់ហោរាចារ្យថា ព្រះរាជបុត្រព្រះអង្គអាចនឹងទៅជាមេសាសនាក្នុងលោកនោះ ព្រះបាទសុទ្ធោទនៈមានព្រះទ័យមិនរីករាយឡើយ ព្រោះព្រះអង្គចង់ឲ្យរាជបុត្រសោយរាជ្យ និងទៅជាស្តេចចក្រពត្តិ ។ ដើម្បីសំរេចបំណងនេះ ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

អង្គបានខិតខំបំប៉នទូវសេចក្ដីត្រូវការខាងកាមគុណដល់ព្រះសិទ្ធត្ថៈជាខ្លាំង គឺគិតតែឲ្យសប្បាយនឹងរឿងកាមលោកីយ៍តែប៉ុណ្ណោះ ។ ពេលរៀបអភិសេកហើយ ព្រះអង្គបានសាងប្រាសាទដែលជារមណីយដ្ឋានចំនួន ៣ កន្លែង តម្រូវទៅនឹងរដូវទាំង ៣ គឺរដូវក្ដៅ, ភ្លៀង, និងរងារ ព្រមទាំងមានស្រីស្នំក្រមការបំរើប្រណិបត្តិ ច្រៀងរាំថ្វាយកំសាន្តគ្រប់ពេលវេលាទាំងអស់ ដើម្បីឲ្យព្រះអង្គជាប់ជំពាក់នឹងកាមលោកីយ៍ មានបំណងគ្រងរាជ្យសម្បត្តិ ។ តែទោះជាយ៉ាងណាក្ដី អ្វីក៏មានចំណុចទីបំផុតរបស់វាដែរ ដូចជាទឹកដែលដាក់អំបិលច្រើនពេកទៅ មានពេលមួយនោះ អំបិលនឹងឈប់រលាយតទៅទៀតហើយ។ ព្រះសិទ្ធត្ថៈក៏ដូចគ្នាដែរ ការពេញប្រៀបដោយកាមគុណ បានធ្វើឲ្យព្រះអង្គដល់ចំណុចឆ្អែត ។ ថ្ងៃមួយ ពេលដែលព្រះអង្គចេញកំសាន្ត ទ្រង់បានទតឃើញនូវមនុស្សចាស់ជរា មនុស្សឈឺ មនុស្សស្លាប់ ព្រះអង្គក៏កើតសង្វេគក្នុងចិត្តថា ជីវិតនេះគ្មានអ្វីទៀងទេ ទីបំផុតនឹងឈានទៅរកការចាស់ ជរា ព្យាធិ និងស្លាប់ទាំងអស់? តើហេតុអ្វីបានជាមនុស្សយើងនៅតែវង្វេងនឹងប្ដី ប្រពន្ធ ទ្រព្យសម្បត្តិ មាសប្រាក់ទៅវិញ ។ ចាប់តាំងពីនោះមក ព្រះអង្គក៏ចេះតែត្រិះរិះពិចារណាថា ធ្វើម្ដេចហ្ន៎ដើម្បីឲ្យផុតពីការកើត ចាស់ ឈឺ ស្លាប់នេះបាន ?

## ចេញសាងផ្នួស

ការត្រិះរិះស្រាវជ្រាវរកការរួចពីសេចក្ដីទុក្ខរបស់ព្រះសិទ្ធត្ថៈ ស៊ីរយៈពេលយ៉ាងយូរ តែក៏មិនអាចរកឃើញឡើយ ដោយសារការដែលព្រះអង្គមានមហេសី និងជាប់ជំពាក់ដោយកាមគុណច្រើនពេក រហូតដល់ថ្ងៃមួយព្រះអង្គបានឃើញអ្នកបួសទាំងឡាយដែលជាអ្នកគ្មានផ្ទះសំបែង ពុំមានកង្វល់ដោយប្រពន្ធកូន គិតតែពីរឿងការស្រាវជ្រាវរកវិធីរំលត់ទុក្ខ ទ្រង់ក៏មានគំនិតថា នឹងចេញសាងផ្នួស ដើម្បីរកឲ្យឃើញនូវវិធីរំលត់សេចក្ដីទុក្ខក្នុងជីវិត គឺ កើត ចាស់ ឈឺ ស្លាប់ឲ្យបាន ។ ព្រះមាតាបិតា និងព្រះនាងពិម្ពា ព្រមទាំងសេវកាមាត្យ បានព្យាយាមស្រែកយំអង្វរករ ហាមឃាត់ កុំឲ្យព្រះអង្គចេញបួសបាន ។ តែទីបំផុត ថ្ងៃនោះក៏មកដល់ គឺជាពេលដែលព្រះអង្គមានជន្មាយុបាន ២៩ វស្សា ព្រះនាងពិម្ពាជាមហេសី ក៏ប្រសូត្របានព្រះរាជឱរសដ៏ស្អាតមួយអង្គ ។ ព្រះអង្គក៏សំរេចព្រះទ័យថា នឹងចេញបួសក្នុងថ្ងៃនោះ ព្រោះគិតថាចំណងបានកើតឡើងមួយខ្សែ

www.budinst.gov.kh www.elibraryofcambodia.org

ទៀតហើយ ។ ព្រះអង្គទ្រង់ដឹងច្បាស់ថា ការចេញបព្វជានេះ នឹងធ្វើឲ្យព្រះបិតា និងព្រះជាយា សោកសៅយ៉ាងខ្លាំងជាមិនខាន តែទ្រង់ក៏គិតថា នៅពេលដែលជនទាំងឡាយ រួមទាំងព្រះបិតា ព្រះជាយា និងព្រះឱរសព្រះអង្គ កំពុងតែប្រឈមមុខជាមួយនឹងសេចក្តីទុក្ខរបស់ពិភពលោកយ៉ាងនេះទៅហើយ ទើបគួរតែព្រះអង្គប្រញាប់ចេញទៅស្វែងរកសច្ចធម៌ ទាន់កំលាំងពលំនៅមាន ដើម្បីជាប្រយោជន៍ដល់បុគ្គល ដែលជាទីស្រឡាញ់ទាំងនោះ និងដល់មនុស្សទាំងឡាយគ្រប់គ្នា ។ ការដែលចេញចាកចោល ព្រះនគររាជសម្បត្តិ និងព្រះរាជគ្រួសារនោះ លោកហៅថា មហាភិនេស្រ្កមណ៍ ប្រែថា ការចេញចាកដើម្បីគុណដ៏ធំធេង ដូចដែលព្រះអង្គបានត្រាស់នៅក្នុងសគារវសូត្រ ព្រាហ្មណវគ្គ ក្នុងគម្ពីរសុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកថាៈ " ម្នាលភិក្ខុទាំងឡាយ ក្នុងពេលនោះ តថាគតនៅក្មេងល្អក់ សក់ខ្មៅរលើប បរិបូណ៌ដោយយុវភាពដែលកំពុងចំរើន កំពុងស្ថិតនៅក្នុងបឋមវ័យផង ពេលដែលមាតាបិតាមិនប្រាថ្នាផង កំពុងទាំគ្នាស្រែកយំទឹកភ្នែកហូររហេមរហាមផង តថាគតក៏បានកោរសក់ និងពុកមាត់ ពុកចង្កា ដណ្តប់សំពត់ដែលជ្រលក់ដោយទឹកអម្ចត់ ហើយចេញពីផ្ទះទៅបួស ជាអ្នកដែលមិនមានផ្ទះហើយ " ។

## ការស្វែងរកសច្ចធម៌

នៅរាត្រីដែលមានព្រះច័ន្ទរះពេញវង់នៃខែអាសាឍ ឆ្នាំថោះ ព្រះសិទ្ធត្ថៈក៏យាងចាកចេញពីព្រះនគរទាំងពេលយប់ ព្រមដោយអាមាត្យព្រះអង្គម្នាក់ឈ្មោះ ឆន្នៈ និងសេះឈ្មោះ កណ្ឋកៈ ដែលជាយានជំនិះ ។ លុះទៅដល់មាត់ស្ទឹងឈ្មោះ អនោមា ដែលជាព្រំដែននៃរដ្ឋសក្យៈ និងរដ្ឋមល្លៈ ព្រះអង្គក៏ចូលកាន់ភេទជាបព្វជិតដោយការអធិដ្ឋាន ហើយត្រាស់បញ្ជាឲ្យឆន្នៈនាំសេះ និងគ្រឿងអលង្ការទៅថ្វាយព្រះរាជបិតា និងផ្តាំទូលថា " ព្រះអង្គបានលះបង់រាជសម្បត្តិហើយ ដើម្បីស្វែងរកសច្ចធម៌ បើសិនជាបានជួបហើយ ព្រះអង្គនឹងត្រឡប់មកជូតទឹកព្រះនេត្ររបស់ព្រះបិតា និងព្រះជាយា ដោយសំពត់ដ៏ពិសេស គឺសច្ចធម៌នោះជាពុំខាន " ។



www.budinst.gov.kh www.elibraryofcambodia.org

ព្រះសមណៈសិទ្ធត្ថៈបានឮដំណឹងថាមានតាបស ២ រូប ដែលជាគ្រូល្បីល្បាញ អាចកំចាត់នូវសេចក្តីទុក្ខបាន និងមានសិស្សគណជាច្រើន ។ ព្រះអង្គបានយាងចូលទៅកាន់សំណាក់របស់គ្រូទី ១ ឈ្មោះអាឡារតាបសកាលាមគោត្រ ដើម្បីសិក្សានូវវិធីនោះ។ តែលុះដល់ព្រះអង្គបានរៀនចប់ពីគ្រូអស់ហើយ ព្រះអង្គទៅតែឃើញថា ព្រះអង្គពុំទាន់បានរួចចាកពីសេចក្តីទុក្ខឡើយ ។ ព្រះសមណៈសិទ្ធត្ថៈបានចាកចេញពីអាឡារតាបស កាលាមគោត្រ ដើម្បីទៅរកគ្រូទី ២ ទៀត ដែលល្បីថាចេះដឹង និងមានភូមិធម៌លើសពីតាបសដំបូង ។ តែព្រះអង្គក៏អស់សង្ឃឹម ព្រោះចំណេះដឹងដែលព្រះអង្គទទួលពីតាបសទីពីរឈ្មោះ ឧទកតាបស រាមបុត្រ នេះ នៅតែពុំអាចឲ្យព្រះអង្គចាកចេញពីសេចក្តីទុក្ខ ដែលនៅរួបរឹតក្នុងសន្តានចិត្តព្រះអង្គបានឡើយ ។ ទីបំផុត ព្រះអង្គក៏យាងចាកចេញពីទីនោះទៀត ហើយសម្រេចព្រះទ័យថា នឹងស្វែងរកសច្ចធម៌នោះដោយខ្លួនឯងម្តង ។ លុះទៅដល់តំបន់មួយឈ្មោះ ឧរុវេលាសេនានិគម ទ្រង់បានទតឃើញថាភូមិប្រទេសទីនោះមានព្រៃខៀវខ្ចី មានស្ទឹងនេរញ្ជរាផ្លាដូចកញ្ចក់ ជាទីស្ងប់ស្ងាត់គួរដល់ការប្រកបសេចក្តីព្យាយាមដើម្បីស្វែងរកមោក្ខធម៌ (ធម៌សំរាប់ធ្វើខ្លួនឲ្យរួចផុតពីសេចក្តីទុក្ខ) ហើយមិនឆ្ងាយប៉ុន្មានពីភូមិអ្នកស្រុក ដែលអាចឲ្យព្រះអង្គទៅបិណ្ឌបាត្របាន ទើបទ្រង់ជ្រើសរើសយកទីនោះដើម្បីបំពេញភាវនាតទៅ ។

## វយៈទី២ : អត្តកិលមថានុយោគវិធី

ក្នុងវយៈទី ២ នៃការស្វែងរកមោក្ខធម៌ដោយព្រះអង្គឯង ព្រះអង្គទ្រង់បំពេញសេចក្តីព្យាយាមតាមបែបពួកអ្នកបួសផ្សេងៗក្នុងសម័យនោះ គឺទ្រង់បានព្យាយាមសាកល្បងធ្វើទារុណកម្មកាយឲ្យលំបាក ដែលមានឈ្មោះហៅថា *វិធីអត្តកិលមថានុយោគ* ជាវិធីដែលគេនិយមថា នឹងអាចធ្វើឲ្យរួចចាកផុតពីសេចក្តីទុក្ខបាន ។ វិធីដែលព្រះអង្គធ្វើនោះមាន ៖

- អាក្រាតកាយ
- ឈរជើងមួយចំហៀងរហូត
- ឈរ ដើរ ដេក លើបន្លាស្រួចមុត
- បរិភោគអាហារដែលជាសំបកឈើ សារាយ កញ្ចុងអង្ករ កន្ទក់ ផ្លែឈើ

www.budinst.gov.kh www.elibraryofcambodia.org

ឫសឈើ និងសូម្បីតែស្មៅ និងលាមកគោ ក៏ព្រះអង្គបានសាកល្បងសោយដែរ

- យកសំពត់រុំខ្មោចដែលគេចោល មកហ៊ុំដណ្ដប់ខ្លួន
- យកស្បូវភ្លាំង ស្លឹកឈើ មកក្រងជាសំពត់ស្លៀកដណ្ដប់
- យកស្បែកសត្វស្លាប់មកស្លៀកដណ្ដប់
- បណ្ដោយឲ្យល្អងធូលីដីប្រឡាក់ខ្លួន រហូតបែកស្រកាដោយមិនខ្ចីស្រង់ទឹក
- ទ្រង់គេចពីមនុស្ស មិនឲ្យជួបទាល់តែសោះ
- ក្នុងរដូវរងារដែលមានទឹកកកធ្លាក់ ពេលយប់ព្រះអង្គចេញមកនៅកណ្ដាលវាល ពេលថ្ងៃចូលទៅក្នុងព្រៃដែលជ្រៅ
- ក្នុងរដូវក្ដៅ ពេលថ្ងៃព្រះអង្គនៅកណ្ដាលវាល លុះដល់ពេលយប់ក៏ចូលទៅនៅក្នុងព្រៃជ្រៅវិញ
- ព្រះអង្គផ្ទំជាមួយសាកសព និងឆ្អឹងសពទាំងឡាយនៅទីប៉ាឆា
- ជួនកាលពេលព្រះអង្គកំពុងភាវនាធម៌ មានពួកក្មេងឃ្វាលគោមករំខានស្រែកហ៊ោរកញ្ជ្រៀវដាក់ត្រចៀក ខ្លះនោមដាក់ ខ្លះបាចល្អងធូលីលើខ្លួនព្រះអង្គ ខ្លះយកឈើស្រួចៗ មកឆ្អារត្រចៀកលេង ដោយសំគាល់ថា ព្រះអង្គឆ្កួត តែព្រះអង្គក៏មិនក្រោធខឹងជាមួយក្មេងទាំងនោះឡើយ ។

## រយៈទី ៣ ៖ ទុក្ករកិរិយា វិធី

ពេលដែលពិសោធនូវវិធីផ្សេងៗ ដែលគេនិយមធ្វើក្នុងជំនាន់នោះហើយ ក៏នៅតែពុំទាន់បានរួចផុតទុក្ខទៀត ព្រះអង្គក៏ចាប់ផ្ដើមវិធីធ្វើទារុណកម្មបែបថ្មីចំនួន ៣ យ៉ាងទៀត ដែលពុំទាន់ដែលមាននរណាធ្វើសោះគឺ ៖

១- យកធ្មេញលើខាំជាប់ធ្មេញក្រោម ដោយមិនព្រមកំរើក ហើយយកអណ្ដាតទៅទល់នឹងពិដានមាត់ ។

២- អត់ដង្ហើមដោយមិនព្រមដកចេញ ដកចូល រហូតទាល់តែស្ទះស្ទើរប្រកាច់ទើបដកដង្ហើមវិញ ហើយក៏អត់ទៀត ។

៣- ទ្រង់អត់អាហារ គឺបន្ថយអាហារតាំងពីមួយចាន មកនៅកន្លះចាន រហូត

www.budinst.gov.kh www.elibraryofcambodia.org

ទាល់តែដាច់ មិនព្រមសោយសោះ ។

## វយៈទី ៤ : មជ្ឈិមាបដិបទាវិធី

ការស្វែងរកសច្ចធម៌ដោយការសាកល្បងនូវវិធីផ្សេងៗ ជាពិសេសវិធីទី ២ និងទី ៣ បានធ្វើឲ្យព្រះពោធិសត្វស្គមស្គាំងសល់តែស្បែក និងឆ្អឹង រហូតឈរ អង្គុយលែងជាប់ ក៏ដេកដួលនៅលើព្រះធរណីដូចខ្មោចស្លាប់ដែលត្រូវកំដៅថ្ងៃ ស្អួតស្វិតក្រញ៉ង់ តែក៏ពុំអាចរំដោះខ្លួនឲ្យរួចផុតពីទុក្ខឡើយ គឺរកមោក្ខធម៌ពុំទាន់ឃើញ ។ ពេលនោះព្រះអង្គទ្រង់ព្រះតម្រិះថា : " ក្នុងអតីតកាលដែលកន្លងមកហើយដ៏យូរក្តី ក្នុងអនាគតកាលដ៏យូរទៅខាងមុខក្តី ឬសូម្បីនាបច្ចុប្បន្ននេះក្តី សមណៈឬព្រាហ្មណ៍ណាដែលបានសោយទុក្ខវេទនាយ៉ាងឈឺចាប់ខ្លោចផ្សារ ព្រោះការបំពេញព្យាយាមយ៉ាងខ្លាំងក្លាដូចព្រះអង្គធ្វើនេះ ពុំមានទេ ព្រោះព្រះអង្គបំពេញមក ៦ ឆ្នាំហើយ ក៏នៅមិនអាចសំរេចធម៌ដ៏ប្រសើរបំផុត តាមរបៀបដ៏លំបាកឈឺចាប់នេះបាន " ទ្រង់គិតថា ផ្លូវនេះពិតជាពុំអាចដើរទៅដល់ទេ ប្រាកដជាមានផ្លូវដទៃទៀតពុំខាន ។ ពេលនោះ សតិសម្បជញ្ញៈរបស់ព្រះអង្គក៏រលឹកនឹកឃើញដល់សិល្បៈនៃការប្រគំតន្ត្រី មានឧបករណ៍ពិណដែលទ្រង់ធ្លាប់បានជួបកាលដែលនៅពីគ្រហស្ថថា " ខ្សែពិណដែលរឹតធូរពេក សម្លេងនឹងមិនពិរោះ ឬខ្សែពិណដែលរឹតតឹងពេក ក៏នឹងឈ្លើយ ហើយបើរឹតតឹងថែមទៀត ក៏ប្រាកដជាដាច់ ។ ឯខ្សែពិណដែលរឹតល្មមមធ្យម តែងមានសម្លេងពិរោះ ប្រគំទៅសម្លេងគួរជាទីគាប់ចិត្ត " ។ ទើបព្រះអង្គប្រៀបធៀបមកនឹងការព្យាយាមរបស់ព្រះអង្គថា ជនដែលមានរាងកាយស្គាំងស្គម និងស្រេកឃ្លានបែបព្រះអង្គនេះ នឹងពុំអាចសំរេចធម៌ឡើយ ។ ក៏ដូចជាអ្នកដែលជ្រមុជជ្រមុលនឹងកាមបរិភោគ ក៏នឹងមិនមានថ្ងៃអាចសម្រេចធម៌បានដែរ ។ ព្រះតម្រិះដូច្នេះហើយ ព្រះអង្គក៏ងាកទៅឆាន់អាហារវិញ លុះត្រាតែមានសុខភាពបរិបូរណ៍ដូចដើម ព្រមគ្នានឹងការដុះសំអាតផ្លូវចិត្តឲ្យកាន់តែធូរផង់ថែមទៀត តាមផ្លូវកណ្តាល គឺមិនតឹងពេក មិនធូររលុងពេក ដែលហៅថា មជ្ឈិមាបដិបទា ។ ទ្រង់បានងាកមកតម្រង់ទិដ្ឋិព្រះអង្គអោយបានត្រឹមត្រូវវិញ (សម្មាទិដ្ឋិ) តម្រង់ការត្រិះរិះគិតអោយបានត្រឹមត្រូវ (សម្មាសង្កប្បៈ) តម្រង់វាចាអោយបានត្រឹមត្រូវ (សម្មាវាចា) តម្រង់សកម្មភាពអោយបានត្រឹមត្រូវ (សម្មាកម្មន្តៈ) តម្រង់ការចិញ្ចឹមជីវិតអោយបានត្រឹមត្រូវ (សម្មា

www.budinst.gov.kh www.elibraryofcambodia.org

អាជីវៈ) តម្រង់សេចក្តីព្យាយាមអោយបានត្រឹមត្រូវ (សម្មាវាយាមៈ) តម្រង់សតិអោយបានត្រឹមត្រូវ (សម្មាសតិ) និងតម្រង់ចិត្តអោយបានត្រឹមត្រូវវិញ (សម្មាសមាធិ)ម្តងបន្តិចៗ រហូតទាល់តែត្រឹមត្រូវ ត្រឹមត្រង់ ត្រឹមល្មម ល្អឥតខ្ចោះ ។ ផ្លូវទាំង ៨ នេះ គឺជាការច្របាច់ត្រងលើការពិសោធន៍ជាច្រើនលើក ច្រើនគ្រា អស់រយៈកាល ៦ ឆ្នាំ រហូតទីបំផុតព្រះអង្គក៏បានឃើញដោយច្បាស់ផ្ទាល់ (សន្ទិដ្ឋិកោ) ថានេះ គឺពិតជាមាគ៌ាឆ្ពោះទៅរកការត្រាស់ដឹងមែន ។

## ត្រាស់ដឹង

ទីបំផុតនៃការស្វែងរកដ៏យូរ ៦ ឆ្នាំ ដោយវិធីទាំង ៥ មានឈានវិធី អត្តកិលមថានុយោគវិធី ទុក្ករកិរិយាវិធី និងមជ្ឈិមាបដិបទាមក ព្រះសិទ្ធត្ថៈក៏បានទៅដល់គោលដៅដែលទ្រង់កំណត់ទុកគឺ មោក្ខៈ (ការរួចពីសេចក្តីទុក្ខ) ឬ និព្វាន នៅថ្ងៃ ពុធ ១៥ កើត ខែពិសាខ មុនគ្រឹស្តសករាជ ៥៨៨ ឆ្នាំ វេលាថ្ងៃជិតរះ ។

ក- បុេ្គជា

ថ្ងៃនោះនៅវេលាព្រឹក ព្រះអង្គបានទទួលចង្ហាន់ជាបាយដែលដាំលាយដោយទឹកឃ្មុំ និងស្ករ មានឈ្មោះជាបាលីថា មធុបាយាស ដែលនាងសុជាតានាំមកថ្វាយ ។ ពេលឆាន់រួច ព្រះអង្គក៏យាងសំដៅទៅរកដើមឈើមួយដើមដែលមានស្លឹកសាខា មានម្លប់ត្រឈឹងត្រឈៃ ក្បែរមាត់ស្ទឹងដ៏មានទឹកថ្លាត្រជាក់ ។ ទីនោះ ព្រះពោធិសត្វបានទទួលស្បូវចំនួន ៣ បាច់ ពីបុរសម្នាក់ឈ្មោះសោត្ថិយៈ ដែលមានសេចក្តីពេញចិត្តចំពោះកិរិយា និងការស្វែងរកមោក្ខធម៌របស់ព្រះអង្គ ។ ព្រះសមណៈបានយកស្បូវនោះទៅក្រាលពីខាងកើតគល់ឈើ ហើយក៏គង់ចុះបែរព្រះភក្ត្រទៅទិសខាងកើត ដោយតាំងអធិដ្ឋានថា បើព្រះអង្គមិនបានត្រាស់ដឹងទេ ព្រះអង្គនឹងមិនក្រោកពីទីកន្លែងនោះជាដាច់ខាត បើទោះជាសាច់ និងឈាមត្រូវហួតហែង ក្រៀមស្វិតនៅសល់តែស្បែកសរសៃយ៉ាងណាក៏ដោយ ។ តាំងអធិដ្ឋានរួច ព្រះអង្គក៏សង្រួមចិត្តតាំងសមាធិ ស្រាវជ្រាវរកមោក្ខធម៌តទៅទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

៦- សម្រេចគោលដៅ

ពេលដែលចិត្តរៀបចាប់ផ្ដើមមានសមាធិ (ចិត្តនឹង) កិលេសគឺចិត្តអកុសល ដែលនៅមានសេសសល់ក្នុងសន្ដានចិត្ត ក៏ចាប់ផ្ដើមចេញមកសំដែងរិទ្ធិ ៖ ការត្រេកត្រអាលក្នុងកាមារម្មណ៍ដែលទ្រង់ធ្លាប់បានទទួល កាលពីមិនទាន់ចេញសាងផ្នួស (រាគៈ), សេចក្ដីប្រាថ្នា ចំណង់ផ្សេងៗដែលធ្លាប់មានតាំងតែពីតូចមក (តណ្ហា), និងភាពអផ្សុក អស់ទឹកចិត្ត រវើរវាយ ព្រោះការព្យាយាមដ៏យូរមកហើយពុំចេះបានសម្រេច (អរតិ) ក៏ចូលមកលងចិត្តរបស់ព្រះអង្គ តែព្រះសមណៈក៏អាចយកឈ្នះចិត្តដ៏អកុសលទាំងនោះបានដោយជោគជ័យ ដោយអំណាចសទ្ធាធិដ្ឋាន និងកម្លាំងសមាធិចិត្តដ៏ខ្ពស់របស់ទ្រង់ ។ នៅខាងដើមរាត្រីដែលស្ងប់ស្ងាត់ ក្រោមពន្លឺដួងច័ន្ទពេញវង់ និងខ្យល់រាយោបក់រំភើយនៃខែឧសភា ដួងចិត្តរបស់ព្រះសមណៈ ក៏កាន់តែស្ងប់ទៅៗ ស្អាតទៅៗ បរិសុទ្ធទៅៗ ឧបមាដូចជាសំពត់សដែលប្រឡាក់ភក់ ហើយត្រូវទឹក និងសាប៊ូចូលមកកាត់ឲ្យជ្រះម្ដងបន្តិចៗ ដូច្នោះដែរ ។ ពេលដែលចិត្តស្ងប់ហើយ បញ្ញាញាណក៏កើតឡើង ។ ព្រះសមណៈអាចរលឹកនឹកឃើញនូវអតីតកាលរបស់ព្រះអង្គទាំងអស់បាន ចាប់តាំងពីវិនាទីដែលព្រះអង្គកំពុងគង់ រហូតដល់ពីព្រឹក ពីម្សិលមិញ ពីខែមុន ឆ្នាំមុន ជាតិមុន និងរាប់ជាតិថយក្រោយ រកប្រមាណមិនបាន ។ ព្រះអង្គអាចដឹងថា ពេលនោះព្រះអង្គបានធ្វើអ្វី និយាយអ្វី កើតជាអ្វី ព្រោះកម្មប្រភេទណា ដោយសព្វឥតចន្លោះ ។ មិនសំរាប់តែព្រះអង្គទេ សូម្បីតែសត្វឯទៀតក៏ព្រះអង្គអាចមើលឃើញបានទាំងអស់ ។

ការដែលដួងចិត្តព្រះអង្គ អាចមានសមត្ថភាពរឮកដឹងបាននូវអតីតកាលរបៀបនេះ ឈ្មោះថាព្រះអង្គបានសម្រេចនូវវិជ្ជាមួយដែលមានឈ្មោះថា បុព្វេនិវាសានុស្សតិញាណ ប្រែថា ញាណរលឹកឃើញនូវអតីតកាលបាន ។ លុះដល់ពាក់កណ្ដាលអធ្រាត្រ ព្រះច័ន្ទចរចំពីលើត្រង់ ចិត្តរបស់ព្រះអង្គក៏កាន់តែស្ងប់ថែមទៀត ដែលជាហេតុធ្វើឲ្យបញ្ញាព្រះអង្គកាន់តែផុសផុល ។ នៅពេលនោះ ព្រះអង្គអាចសម្លឹងមើលទៅកាន់អនាគតបានយ៉ាងច្បាស់ក្រឡែត នូវជីវិតរបស់សត្វគ្រប់រូប ថាតើសត្វនោះនឹងក្លាយទៅជាយ៉ាងណា កើតជាអ្វី ព្រោះអំពើអ្វី បានដោយឥតទាស់ និងពុំកំណត់ដោយពេលវេលាឡើយ ។ វិជ្ជាប្រភេទនេះ លោកហៅថា ចុតូបបាតញ្ញាណ (Clair Voyance) ។

www.budinst.gov.kh www.elibraryofcambodia.org

នៅខាងចុងនៃរាត្រីដ៏ទក្ខត្តឫក្សនោះ ព្រះទ័យព្រះអង្គក៏កាន់តែមានភាពបរិសុទ្ធឡើងៗ និងស្ងប់ជាទីបំផុត ដែលអាចឲ្យព្រះអង្គស្រាវជ្រាវបញ្ចប់នូវការរុករកវិធី ដើម្បីរំលត់ទុក្ខ ។ ព្រះសមណៈបានស្រាវជ្រាវអំពីអត្ថិភាពរបស់ព្រះអង្គ និងការរំលត់ទុក្ខដោយរបៀបថយក្រោយ និងទៅមុខ ជាបែបសំណួរដូចតទៅ ៖

ចំណាស់ ជរា មរណៈ ការខ្សឹកខ្សួលក្នុងចិត្ត ទុក្ខព្រួយ ការតូចចិត្ត ការចង្អៀតចង្អល់ចិត្ត ដែលមនុស្សតែងជួបប្រទះជារៀងរាល់ថ្ងៃនេះ កើតមកពីអ្វីហ្ន៎ ?

ព្រះអង្គក៏បានស្រាវជ្រាវពិចារណាឃើញថា ទាំងអស់នេះមាន **ជាតិ** គឺកំណើតដែលជាហេតុ ។ កំណើតមានអត្ថិភាពបាន ក៏ព្រោះមាន **ភព** គឺកម្មដែលជាហេតុ ។ ភពកើតមានបាន ក៏ព្រោះអាស្រ័យ **ឧបាទាន** គឺការប្រកាន់ខ្ជាប់ជាដើមហេតុ។ ឧបាទានកើតឡើងបាន ក៏ព្រោះមាន **វេទនា** គឺការទទួលដឹងអារម្មណ៍ថាសុខ ទុក្ខ មិនជាសុខមិនជាទុក្ខ ជាហេតុ ។ វេទនាកើតមានបាន ក៏ព្រោះមាន **ផស្សៈ** គឺការប៉ះទង្គិចគ្នារវាងអារម្មណ៍ខាងក្រៅ និងអាយតនៈទាំង ៦ ជាហេតុ ។ ផស្សៈកើតមានឡើងបាន ក៏ព្រោះមកពីមាន**អាយតនៈទាំង ៦** គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ជាដើមហេតុ ។ អាយតនៈកើតមាន ព្រោះមកពីមាន **នាមរូប** គឺកាយ និងចិត្ត ជាដើមហេតុ ។ នាមរូបកើតមាន ព្រោះមកពីមាន **វិញ្ញាណ** គឺការដឹង ជាដើមហេតុ ។ វិញ្ញាណកើតមានព្រោះមកពីមាន **សង្ខារ** គឺការគិតអញ្ចេះ គិតអញ្ចុះ ជាដើមហេតុ ។ សង្ខារកើតមានព្រោះមកពីមាន **អវិជ្ជា** គឺការមិនដឹងនូវការពិតរបស់ធម្មជាតិ ជាដើមហេតុ។

រួចហើយ ព្រះអង្គក៏ពិចារណាពីអវិជ្ជាទៅវិញថា តើពិតជានាំទៅរកការកើត ចាស់ ឈឺ ស្លាប់ ឬទេ ដូចតទៅ៖

ព្រោះ**អវិជ្ជា** គឺការមិនដឹងការពិតជាហេតុ ទើបនាំឲ្យកើតសង្ខារ គឺការគិតអញ្ចេះ អញ្ចុះ ជាផល ។ ព្រោះសង្ខារជាហេតុ ទើបនាំឲ្យកើតវិញ្ញាណ គឺការដឹង ។ ព្រោះ វិញ្ញាណជាហេតុ ទើបនាំឲ្យកើតនាមរូប គឺកាយនិងចិត្ត ។ ព្រោះនាមរូបជាហេតុ ទើបនាំឲ្យកើតអាយតនៈទាំង ៦ គឺ ភ្នែក ច្រមុះ ត្រចៀក អណ្តាត កាយ ចិត្ត ។ ព្រោះអាយតនៈជាហេតុ ទើបនាំឲ្យកើតផស្សៈ គឺការប៉ះទង្គិចរវាងអាយតនៈនឹងអារម្មណ៍ ។ ព្រោះផស្សៈជាហេតុ ទើបនាំឲ្យកើតវេទនា គឺការដឹងថាទុក្ខ សុខ មិនទុក្ខ មិនសុខ ។ ព្រោះវេទនាជាហេតុ ទើបនាំឲ្យកើតតណ្ហា គឺសេចក្តីប្រាថ្នាផ្សេងៗ ។ ព្រោះតណ្ហា

www.budinst.gov.kh www.elibraryofcambodia.org

ជាហេតុ ទើបនាំឲ្យកើតឧបាទាន គឺការប្រកាន់ខ្ជាប់មាំលើសេចក្ដីប្រាថ្នានោះ ។ ព្រោះឧបាទានជាហេតុ ទើបនាំឲ្យកើតភព គឺកម្មផ្សេងៗ មានល្អ អាក្រក់ និងជាអព្យាក្រឹត្យ ។ ព្រោះភពជាហេតុ ទើបនាំឲ្យកើតជាតិ គឺកំណើតជាសត្វផ្សេងៗ ហើយការមានជាតិនេះឯង ដែលនាំឲ្យមានចាស់ ឈឺ ស្លាប់ សេចក្ដីសោកសៅ ខ្សឹកខ្សួល ទុក្ខទោមនស្សផ្សេងៗ ក្នុងជីវិតរាប់មិនអស់ ។

ពេលពិចារណាឃើញច្បាស់នូវវិធីកម្ម (Process) នៃការកើតទុក្ខដូច្នេះហើយ ព្រះអង្គក៏ពិចារណាថា តើដំណើរដូចម្ដេចហ្ន៎ ទើបនាំទៅរកការរំលត់ទុក្ខ? ទ្រង់ក៏ឃើញថា៖

**ព្រោះការរលត់អស់ទៅនៃអវិជ្ជា** សង្ខារក៏រលត់ទៅដែរ, **ព្រោះការរលត់អស់ទៅនៃសង្ខារ** វិញ្ញាណក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃវិញ្ញាណ** នាមរូបក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃនាមរូប** សឡាយតនៈក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃអាយតនៈទាំង ៦** ផស្សៈក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃផស្សៈ** វេទនាក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃវេទនា** តណ្ហាក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃតណ្ហា** ឧបាទានក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃឧបាទាន** ភពក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃភព** ជាតិក៏រលត់ដែរ, **ព្រោះការរលត់អស់ទៅនៃជាតិ** ការចាស់ ឈឺ ស្លាប់ សេចក្ដីសោកសៅ ខ្សឹកខ្សួល ទុក្ខទោមនស្សផ្សេងៗ ក្នុងជីវិតរាប់មិនអស់ ក៏រមែងរលត់ទៅអស់ ។

ពេលព្រះអង្គពិចារណា នូវវិធីកម្មនៃការកើតឡើងនៃទុក្ខ និងការរលត់ទៅនៃសេចក្ដីទុក្ខ ជារបៀបស្រប (អនុលោម) និងបញ្ច្រាស(បដិលោម) ជាច្រើនលើកច្រើនសារ ព្រះអង្គក៏បានឃើញច្បាស់ និងត្រាស់ដឹងនូវរបៀបដើម្បីកំចាត់នូវសេចក្ដីទុក្ខទាំងនោះដោយមានប្រសិទ្ធិភាព ហើយព្រះអង្គក៏អាចកំចាត់បង់បាននូវ ហេតុដែលនាំឲ្យកើតទុក្ខគឺ **អវិជ្ជា** បាន ដោយអស់រលីងពីក្នុងខន្ធសន្តានព្រះអង្គ គឺបានត្រាស់ដឹងជាពុទ្ធៈ ជាអ្នកដែលលែងកើតទុក្ខតទៅទៀតហើយ មានតែសេចក្ដីស្ងប់ រីករាយ និងបញ្ញាភ្លឺស្វាងក្នុងធម្មជាតិទាំងឡាយទាំងពួង ។ រាគៈ គឺសេចក្ដីត្រេកត្រអាលក្នុងកាមារម្មណ៍, ទោសៈ គឺសេចក្ដីខឹងក្រោធប្រទូសរ៉ាយ និងមោហៈ គឺភាពល្ងិតល្ងង់ មិនដឹងការពិត

www.budinst.gov.kh www.elibraryofcambodia.org

ក៏វិនាសអន្តរាយចេញពីខន្ធសន្តាន ។ ក្នុងដួងព្រះហឫទ័យ មានតែភាពបរិសុទ្ធនៃចិត្ត ដូចជាទឹកដែលគេបានបន្សុទ្ធ ពុំមានមេរោគដូច្នោះដែរ ។ ព្រះអង្គបានឲ្យឈ្មោះ វិធិកម្ម នៃការកើតឡើងរបស់សេចក្តីទុក្ខ និងការរំលត់សេចក្តីទុក្ខនេះថា **បដិច្ចសមុប្បាទ** ។[2]

ទីបំផុត គឺពេលជិតភ្លឺនៃរាត្រី ១៥កើត ខែវិសាខនោះ ព្រះអង្គក៏បានរកឃើញ នូវហេតុនៃសេចក្តីទុក្ខ និងវិធីកំចាត់នូវសេចក្តីទុក្ខរបស់ព្រះអង្គបាន ព្រមទាំងបានទទួល ឋានៈជាពុទ្ធៈ **គឺអ្នកត្រាស់ដឹង** ក្រោមដើមឈើក្បែរមាត់ស្ទឹងនេរញ្ជរា ហើយដែល ក្រោយមក ដើមឈើនោះក៏ត្រូវគេប្រសិទ្ធិនាមថា **ពោធិព្រឹក្ស** ឬដែលអាចប្រែថា «ព្រឹក្សានៃការត្រាស់ដឹង» ដើម្បីជាអនុស្សាវរីយ៍ដល់កន្លែងដែលព្រះអង្គបានត្រាស់ ដឹងជាពុទ្ធៈ ។ ដើមពោធិព្រឹក្ស ក៏បានក្លាយទៅជាវត្ថុតំណាងពុទ្ធសាសនា ដែលពុទ្ធ បរិស័ទគោរពរហូតមកដល់ឥឡូវនេះ ។

---

[2] អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ

**អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ**

www.budinst.gov.kh www.elibraryofcambodia.org

## បដិច្ចសមុប្បាទ

**( Dependent Origination )**




www.budinst.gov.kh www.elibraryofcambodia.org







www.budinst.gov.kh www.elibraryofcambodia.org

## អ្វីទៅការត្រាស់ដឹង ?

តាមពិតពាក្យនេះមិនជាចំឡែកទេ គឺចេះនិយាយសឹងតែគ្រប់គ្នា ឲ្យតែជាពុទ្ធសាសនិកជន តែបើមានគេមិនដឹងហើយសួរថា អ្វីទៅគឺការត្រាស់ដឹងនោះ ទាំងគេ ទាំងអាចក្តី ពិបាកនឹងពន្យល់ជាទីបំផុត ព្រោះរឿងនេះវាទាក់ទងនឹងផ្លូវចិត្ត ផ្លូវបញ្ញា ដែលមានតែអ្នកបានត្រាស់ដឹងគឺ ពុទ្ធៈ ទេ ដែលអាចដឹងច្បាស់ថាអ្វីគឺការត្រាស់ដឹង ។ ក្នុងបាលិ ពាក្យថា ការត្រាស់ដឹង លោកហៅថា ពោធិ ជានាម ប្រែថាចំណេះដឹង បើជាកិរិយាស័ព្ទលោកប្រែថា ដឹង ។ ពោធិ បើអង់គ្លេសប្រើពាក្យ Enlightenment ក៏បាន ស្មើនឹង Knowledge ក៏បាន។ ហើយបើជាកិរិយាស័ព្ទក៏ប្រើ To know ។ តាមន័យនេះ ពាក្យថា ការត្រាស់ដឹង បានដល់ ការសម្រេចបាននូវចំណេះដឹងលើរឿងអ្វីមួយ ឬបើតាមពាក្យបច្ចេកទេសវិទ្យាសាស្ត្រគឺការ បានចំណេះដឹងលើរឿងអ្វីមួយ ក្រោយពីបានស្រាវជ្រាវរុករកពិសោធន៍ឃើញថាពិតហើយ ។ បើជាកិរិយាស័ព្ទគឺ ត្រាស់ដឹង បានសេចក្តីថាដឹងក្នុងរឿងអ្វីមួយ ។ តែក្នុងទីនេះ ពាក្យថា ការត្រាស់ដឹងក្តី ដឹងក្តី សំដៅលើការ ដឹង និង យល់ច្បាស់ ពីរឿងអ្វីដែលជាសេចក្តីទុក្ខរបស់ជីវិត និងផ្លូវសំរាប់រំលត់ កំចាត់ នូវសេចក្តីទុក្ខនោះជាពិសេស ។

តាមពិតពាក្យត្រាស់ដឹងនេះ ដែលធ្វើឲ្យយើងលំបាក ក៏ព្រោះមកពីមានពាក្យថា ត្រាស់មួយម៉ាត់ ដែលជាពាក្យបុរាណនៅពីមុខតែប៉ុណ្ណោះ ដែលប្រែថាសម្រេចបាន។ តែសូមចំណាំថាពាក្យ ពោធិ និង ពុទ្ធៈ គេប្រើសម្រាប់តែនៅក្នុងបរិបទនៃពុទ្ធសាសនាតែប៉ុណ្ណោះ ។

## ការផ្សព្វផ្សាយនូវអ្វី ដែលព្រះអង្គបានត្រាស់ដឹង

ក្រោយពីបានត្រាស់ដឹងជាពុទ្ធៈ និងសំរាកតាមសមគួរដល់ពេលវេលាហើយ ព្រះអង្គក៏រៀបចំផែនការដើម្បីផ្សព្វផ្សាយនូវអ្វីដែលព្រះអង្គបានត្រាស់ដឹង ឲ្យដល់អ្នកដែលពុំទាន់ដឹងដទៃទៀតក្នុងជម្ពូទ្វីប ។ ទ្រង់បានយាងចេញពីស្ទឹងនេរញ្ជរាឆ្ពោះទៅតំបន់មួយឈ្មោះ ព្រៃឥសិបតនមិគទាយវ័ន ដែលជាទីស្នាក់អាស្រ័យរបស់ភិក្ខុក្រុមអ្នកបួស ៥ នាក់ ដែលធ្លាប់តាមបំរើព្រះអង្គកាលដែលកំពុងប្រព្រឹត្តទុក្ករកិរិយា ហើយដែលចេញចោលព្រះអង្គអស់ក្នុងពេល ដែលព្រះអង្គងាកទៅរកទាន់ចង្ហាន់ដែលជាផ្លូវកណ្តាលវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

ទីនោះ ព្រះសម្មាសម្ពុទ្ធបានបង្ហាញដល់អ្នកបួសទាំង ៥ អំពីសច្ចធម៌ដែលព្រះអង្គបានរកឃើញ និងកើតឡើងដល់ព្រះអង្គ ក្រោយអ្នកបួសនោះចេញចោល ។ ព្រះអង្គបានឲ្យឈ្មោះសច្ចធម៌របស់ព្រះអង្គ ដែលរកឃើញនោះថា **អរិយសច្ចៈ** ប្រែថា ការពិតដ៏ប្រសើរបំផុត ។ ន័យសំខាន់ៗរបស់ការសម្តែងធម៌ជាលើកទីមួយ ដែលទ្រង់បានសម្តែងប្រាប់ដល់អ្នកបួសទាំង ៥ នោះមាន :

១- ទ្រង់ចាប់ផ្តើមនិទានពីផ្លូវចាស់ពីរយ៉ាង ដែលគេធ្លាប់ដឹងថាជាផ្លូវពុំអាចរកនិព្វាន គឺការរំលត់ទុក្ខបានទេ ព្រោះជាផ្លូវវង្វេង និងស្ថាំនិយមជ្រុលពេក (អន្តធម៌) គឺបើមិនតឹងពេក ក៏ធូររលុងពេក។

២- ទ្រង់បង្ហាញពីផ្លូវថ្មីដែលទើបតែរកឃើញឈ្មោះ មជ្ឈិមាបដិបទា ជាផ្លូវកណ្តាល មិនធូរពេក មិនតឹងពេក ជាផ្លូវអាចឲ្យកើតបញ្ញា ធ្វើឲ្យកើតសេចក្តីដឹងប្រាកដ ធ្វើឲ្យកើតការស្ងប់ ធ្វើឲ្យរំលត់ទុក្ខបាន។

៣- ទ្រង់បញ្ជាក់ថា ផ្លូវកណ្តាលដ៏ប្រសើរនោះ ត្រូវប្រកបដោយអង្គ ៨ប្រការ៖

៣.១- សម្មាទិដ្ឋិ ត្រូវមានប្រាជ្ញាយល់ត្រឹមត្រូវ

៣.២- សម្មាសង្កប្បៈ ត្រូវមានសេចក្តីត្រិះរិះត្រឹមត្រូវ

៣.៣- សម្មាវាចា ត្រូវមានការនិយាយស្តីត្រឹមត្រូវ

៣.៤- សម្មាកម្មន្តៈ ត្រូវមានទង្វើត្រឹមត្រូវ

៣.៥- សម្មាអាជីវៈ ត្រូវមានការចិញ្ចឹមជីវិតត្រឹមត្រូវ

៣.៦- សម្មាវាយាមៈ ត្រូវមានសេចក្តីព្យាយាមត្រឹមត្រូវ

៣.៧- សម្មាសតិ ត្រូវមានការរលឹកត្រឹមត្រូវ

៣.៨- សម្មាសមាធិ ត្រូវមានការតម្កល់ចិត្តឲ្យបានត្រឹមត្រូវ

៤- ព្រះអង្គបានបង្ហាញថា ជីវិតមនុស្សពោរពេញទៅដោយសេចក្តីទុក្ខ[3] និងបញ្ហាគ្រប់បែបយ៉ាង ដែលមានតាំងពីជាតិទុក្ខ (កំណើត) ជរាទុក្ខ (ចាស់) មរណៈទុក្ខ (ស្លាប់) សោកៈ (ការសោកសៅ) បរិទេវៈ (ខ្សឹកខ្សួល) ទុក្ខៈ (ទុក្ខផ្លូវកាយ)

[3] ទុក្ខៈ ន.សភាវៈដែលទ្រាំបានដោយលំបាក, សេចក្តីទុក្ខ, ទុរគតភាព, កំសត់, ការឈឺចាប់, ជម្ងឺ, ការសោកសៅ, អផាសុខភាព, ការតានតឹងក្នុងចិត្ត, ទំនាស់........

www.budinst.gov.kh www.elibraryofcambodia.org

ទោមនស្សៈ (ទុក្ខផ្លូវចិត្ត) ឧបាយាសៈ (សេចក្តីចង្អៀតចង្អល់ចិត្ត) អប្បិយេហិសម្បយោគោ (ការជួបនឹងវត្ថុ ឬសត្វដែលមិនជាទីស្រឡាញ់) បិយេហិវិប្បយោគោ (ការព្រាត់ប្រាសពីរបស់ដែលជាទីស្រឡាញ់) យម្បិច្ឆំនលភតិ (ចង់បានរបស់ណា ហើយមិនបានរបស់នោះ) ។ រួមសេចក្តីឲ្យខ្លីទៅ ព្រះអង្គទ្រង់សម្តែងថា បញ្ចុបាទានក្ខន្ធាទុក្ខា គឺសេចក្តីទុក្ខទាំងឡាយនេះកើតឡើងព្រោះតែការប្រកាន់ខ្ជាប់ថា *នេះជាអញ នេះជារបស់អញ* ។ ព្រះអង្គបានហៅភាពពិតរបស់ទុក្ខដែលមានទាំង អស់នេះថា ទុក្ខអរិយសច្ចៈ ប្រែថា ទុក្ខ គឺជាសច្ចៈធម៌ដែលគួរឲ្យដឹងជាទីបំផុត ។

ទ្រង់បង្ហាញឲ្យដឹងទៅដល់ជម្រៅរបស់ទុក្ខនេះថា **កើតឡើងព្រោះហេតុ** ដែលមានឈ្មោះថា **តណ្ហា**[4] គឺ *សេចក្តីប្រាថ្នា, ចំណង់* ។ តណ្ហានោះមាន ៣ គឺកាមតណ្ហា, ភវតណ្ហា និងវិភវតណ្ហា ។ ព្រះអង្គហៅការពិតនៃហេតុរបស់ទុក្ខនេះថា **ទុក្ខសមុទយអរិយសច្ចៈ** ប្រែថា ហេតុដែលនាំឲ្យកើតទុក្ខ ជាសច្ចៈធម៌ដែលគួរដឹងជាទីបំផុត ។

ទ្រង់បានត្រាស់បង្ហាញឲ្យដឹងថា មានសភាវធម៌មួយឈ្មោះនិរោធ[5] ដែលជាសភាវៈប្រាសចាកទុក្ខ គ្មានទុក្ខ ដែលគេអាចទៅដល់បាន និងសំរេចបាន ។ ព្រះអង្គហៅការពិតនេះថា **ទុក្ខនិរោធអរិយសច្ចៈ** ប្រែថាការរំលត់ទុក្ខ ជាសច្ចៈធម៌ដែលគួរដឹងជាទីបំផុត ។

ជាចុងក្រោយ ទ្រង់ក៏បង្ហាញពីវិធីសំរាប់ទៅឲ្យដល់នូវសភាវធម៌ដែលហៅថា និរោធ ឬសភាវៈដែលមិនមានទុក្ខនោះ ។ វិធីនោះគឺ **អរិយមគ្គទាំង ៨**[6] ។ ព្រះអង្គបានហៅផ្លូវនេះថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ** ប្រែថា បដិបទាដែលជាផ្លូវសម្រាប់ទៅកាន់ទីរំលត់ទុក្ខ ជាសច្ចៈធម៌ដែលគួរដឹងជាទីបំផុត ។

៥- បន្ទាប់ពីបានសំដែងអំពីអរិយសច្ចៈទាំង ៤ ហើយ ព្រះអង្គក៏បន្តទៅលើកិច្ចរបស់អរិយសច្ចៈទាំង ៤ ឬរបៀបត្រួតពិនិត្យលើអរិយសច្ចៈទាំង ៤ ដែលមាន ៣ ដំណាក់កាល និង ១២ ចំណុច (បរិវដ្ត ៣ និងអាការៈ ១២) ។

---

[4] កាមតណ្ហា =សេចក្តីប្រាថ្នាក្នុងកាម ក្នុងគ្រឿងសប្បាយទាំងឡាយ; ភវតណ្ហា =សេចក្តីប្រាថ្នាក្នុងភព ប្រាថ្នាចង់ទៅជានេះជានោះ; វិភវតណ្ហា =សេចក្តីប្រាថ្នាប្រាសចាកភព ប្រាថ្នាមិនចង់ទៅជានេះជានោះ

[5] និរោធ ន. សភាវគ្មានទុក្ខ; ការរំលត់ទុក្ខ; សភាវៈគ្មានបញ្ហា; សភាវៈដែលតណ្ហាទាំង ៣ រលត់ហើយ

[6] សូមមើលផ្លូវកណ្តាលទាំង ៨ នៅទំព័រ ៣៣

www.budlist.gov.kh www.elibraryofcambodia.org

យើងអាចសំដែងតារាងអរិយសច្ចៈទាំង ៤ និងកិច្ចដូចតទៅ ៖

| អរិយសច្ចៈ | សច្ចញ្ញាណ | កិច្ចញ្ញាណ | កតញ្ញាណ |
|---|---|---|---|
| ទុក្ខ | ❶ទុក្ខមានពិត | ❺ទុក្ខគួរកំណត់ឲ្យដឹង | ❾ទុក្ខបានដឹងហើយ |
| ទុក្ខសមុទយ | ❷ហេតុឲ្យកើតទុក្ខមានពិត | ❻ហេតុឲ្យកើតទុក្ខ គួរតែលះចេញ | ❿ហេតុឲ្យកើតទុក្ខនោះ បានលះចេញហើយ |
| និរោធ | ❸ភាវៈគ្មានទុក្ខមានពិត | ❼និរោធ គួរធ្វើឲ្យកើតឡើង | ⓫ និរោធបានធ្វើសំរេចហើយ |
| មគ្គ | ❹វិធីដោះស្រាយបញ្ហាមានពិត | ❽វិធីដោះស្រាយបញ្ហា ត្រូវធ្វើឲ្យគ្រប់ទាំងអស់ | ⓬វិធីនោះបានចម្រើនឲ្យកើតគ្រប់អស់ហើយ |

នៅចុងបញ្ចប់នៃព្រះសូត្រ អ្នកបួសមួយក្នុងចំណោមទាំង ៥ អង្គ ក៏បានសម្រេចធម៌ផ្ទាល់សោតាបត្តិផលជាដំបូងក្នុងលោក ដែលជាការបញ្ជាក់ថា ការត្រាស់ដឹងដែលព្រះអង្គទទួលបាននោះ ជាសច្ចធម៌ដ៏ពិតមែន ។

ធម៌ទេសនាលើកដំបូងនេះ ត្រូវបានអ្នកប្រាជ្ញលោកហៅថា ធម្មចក្កប្បវត្តនសូត្រ គឺព្រះសូត្រដែលមានកង់គឺធម៌វិលទៅមុខហើយ ព្រោះចាប់ពីពេលនោះឯងដែលព្រះធម៌របស់ព្រះពុទ្ធអង្គវិលទៅមុខ រហូតដល់សព្វថ្ងៃនេះ ។

## ទទួលសាវ័ក

នៅពេលសំដែងធម្មចក្កប្បវត្តនសូត្រចប់ អ្នកបួសទាំង ៥ អង្គ ក៏បានសុំបួសជាមួយព្រះសម្មាសម្ពុទ្ធ ។ ព្រះអង្គបានហៅអ្នកបួសទាំង ៥ អង្គ នោះថា ភិក្ខុ ដែលប្រែថា «អ្នកឃើញភ័យនៅក្នុងវដ្តសង្សារ» ។ ថ្ងៃនេះផងដែរ គឺជាថ្ងៃកំណើតរបស់ព្រះសង្ឃក្នុងពុទ្ធសាសនា ហើយដែលពុទ្ធបរិស័ទតែងធ្វើបុណ្យមួយនៅថ្ងៃ ១៥ កើត ខែអាសាធ ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកដល់ថ្ងៃកំណើតព្រះសង្ឃពុទ្ធសាសនា និងជាថ្ងៃកំណើតនៃការផ្សព្វផ្សាយពុទ្ធធម៌ទៀតផង (ឈ្មោះបុណ្យអាសាឡ្ហបូជា តែខ្មែរយើងហៅបុណ្យចូលព្រះវស្សា) ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅជាមួយភិក្ខុសង្ឃទាំង ៥ អង្គ អស់រយៈពេលមួយរដូវវស្សាគឺ ៣ ខែ ព្រមទាំងបានប្រោសសំដែងធម៌អប់រំដល់ភិក្ខុទាំង ៥ រហូតបានសម្រេចជាព្រះអរហន្ត[7] ។ ក្នុងវស្សានោះផងដែរ ព្រះអង្គបានបំបួសបុរស ៥៥ រូបថែមទៀត ឲ្យទៅជាភិក្ខុសង្ឃ និងបានបង្រៀន អប់រំ ហ្វឹកហាត់ ឲ្យចេះដឹងក្នុងព្រះធម៌ ដែលព្រះអង្គបានត្រាស់ដឹង រហូតដល់បានសម្រេចជាព្រះអរហន្តគ្រប់អង្គទាំងអស់ ព្រមទាំងបានទទួលគ្រហស្ថមួយគ្រួសារជាសាវ័កព្រះអង្គទៀតផង ។ ទ្រង់បានហៅសាវ័កដែលជាគ្រហស្ថនោះថា ឧបាសក សំរាប់បុរស និង ឧបាសិកា សំរាប់ស្ត្រី ប្រែថា អ្នកដែលចូលជិតព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះ ធម៌ និងព្រះសង្ឃ ។

## បេសកកម្មពុទ្ធសាវ័ក

ផុតរដូវវស្សាហើយ រដូវរងារក៏ចូលមកដល់ ។ អាកាសត្រជាក់ ខ្យល់បក់រំភើយ ធម្មជាតិជុំវិញក៏រីកស្រស់ញញឹម ព្រោះត្រូវទឹកភ្លៀងស្រោចស្រប់អស់មួយរដូវវស្សាមកហើយ ។ ព្រះសម្មាសម្ពុទ្ធ ដែលដួងព្រះហឫទ័យមានតែភាពបរិសុទ្ធ និងពោរពេញទៅដោយមេត្តា ករុណា បានហៅអស់ភិក្ខុដែលព្រះអង្គបានខិតខំបង្រៀន អប់រំ ហ្វឹកហាត់នូវចំណេះដឹងដែលជាសច្ចធម៌ដ៏ប្រសើរគ្មានអ្វីប្រៀបទាំង ៦០ រូប ឲ្យមកប្រជុំគ្នា ហើយបានណែនាំភិក្ខុ សង្ឃទាំង ៦០ រូប ជាសិស្សដ៏ចំណានទាំងនោះថា: *ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជន សុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មាឯកេន ទ្វេ អគ្គមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ ......*

<ម្នាលភិក្ខុទាំងឡាយ ចូរអ្នកត្រាច់ទៅកាន់ទីចារិក គឺភូមិ និគម និងធានី ហើយសម្ដែងធម៌ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវជាមួយគ្នាឡើយ ។ ម្នាលភិក្ខុ

---

ជាឈ្មោះគុណធម៌ជាន់ខ្ពស់បំផុតក្នុងពុទ្ធសាសនា ។ អ្នកដែលសម្រេចជាព្រះអរហន្តមិនមានកិលេសក្នុងខ្លួនទេ ។ ខ្លះហៅថា លោកបានសម្រេចនិព្វាន

www.budinst.gov.kh www.elibraryofcambodia.org

ទាំងឡាយ អ្នកទាំងឡាយចូរសម្ដែងធម៌អោយពិរោះបទដើម បទកណ្ដាល និងបទចុង ចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថៈ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ ។ សត្វទាំងឡាយដែលមានធូលីគឺកិលេសតិចក៏មាន សត្វទាំងឡាយនោះនឹងសាបសូន្យចាកសន្តិភាព ព្រោះមិនបានស្ដាប់ធម៌ ឯសត្វទាំងឡាយដែលបរុងត្រាស់ដឹងធម៌ក៏មានដែរ................ ។

ពុទ្ធដិការបស់ព្រះអង្គនេះ គឺជាធុរៈប្រកាស (Mission Statement) របស់ព្រះអង្គ និងពុទ្ធសាសនា ដែលយើងទាំងអស់គ្នាជាពុទ្ធបរិស័ទ ពិសេសព្រះសង្ឃ គួរតែយកចិត្តទុកដាក់ជាទីបំផុត ព្រោះថានេះជាបេះដូងរបស់ពុទ្ធសាសនា និងដើម្បីឆ្លើយតបទៅនឹងចម្ងល់រួមរបស់មនុស្សជាតិថា <ព្រះសង្ឃ និងពុទ្ធសាសនាមានប្រយោជន៍អ្វី> និងដើម្បីឲ្យយើងជាពុទ្ធបរិស័ទអាចសាកសួរនិងវាយតម្លៃលើខ្លួនយើងថា តើយើងបានធ្វើទៅតាមផែនការដែលព្រះសាស្ដាយើងបានរៀបចំហើយឬនៅ ។ ខ្ញុំគិតថា ពុទ្ធបរិស័ទយើងគួរតែរើសយកថ្ងៃណាមួយក្នុងខែកត្តិក ឬមិគសិរ ធ្វើជាថ្ងៃបុណ្យពុទ្ធសាសនាដើម្បីរំលឹកដល់ថ្ងៃបេសកកម្មរបស់ព្រះសម្មាសម្ពុទ្ធ និងព្រះសង្ឃ ដែលបានឧទ្ទិសជីវិតដើម្បីសន្តិភាពរបស់មនុស្សជាតិ ឲ្យមានលក្ខណៈដូចជាថ្ងៃវិសាខបូជា និងមាឃបូជាដែលយើងធ្លាប់ធ្វើរួចមកហើយនោះផង ក៏ជាការប្រសើរណាស់ ។

## មហាសន្និបាត

ក្រោយពីបានផ្ដល់ឱវាទដល់ភិក្ខុដែលជាបរិស័ទទាំង ៦០ រូបហើយ ព្រះសម្មាសម្ពុទ្ធក៏បានយាងធ្វើដំណើរទៅកាន់រដ្ឋមគធៈ ដែលជារដ្ឋមួយមានការរីកចម្រើន និងសម្បូរទៅដោយបញ្ញវ័ន្ត មេសាសនា និងលទ្ធិផ្សេងៗ ។ ទីនោះព្រះអង្គបានធ្វើឲ្យមេលទ្ធិដ៏មានឥទ្ធិពល ៣នាក់ និងសាវ័ករបស់គេចំនួន ១,០០០នាក់ លះបង់លទ្ធិបូជាភ្លើងរបស់ខ្លួនចេញ ហើយស្ម័គ្រចិត្តមកបួសជាមួយព្រះអង្គទាំងអស់គ្នា ហើយដែលហេតុការណ៍នេះបានធ្វើឲ្យកក្រើកដល់មជ្ឈដ្ឋានមហាជន ក្សត្រ ព្រាហ្មណ៍ មេសាសនា និងសាសនិកសាសនាដទៃយ៉ាងខ្លាំង ។ គេទាំងអស់នោះបាននាំគ្នានិយាយតគ្នាដោយរំភើបថាៈ មានព្រះអរហន្តកើតឡើងក្នុងលោកហើយ! លោកជាព្រះពុទ្ធដែលត្រាស់ដឹង ដោយព្រះអង្គឯង, ជាអ្នកបរិបូរណ៍ដោយចំណេះវិជ្ជា និងមានការប្រព្រឹត្តល្អឥតខ្ចោះ, លោកជាអ្នកមាន

www.budihst.gov.kh www.elibraryofcambodia.org

ដំណើរជីវិតដ៏ល្អប្រពៃ, ជាវិទូប្រចាំពិភពលោក, ជាអ្នកពូកែក្នុងការប្រៀនប្រដៅ អប់រំមនុស្សដោយគ្មានគូប្រៀប, ទាំងមនុស្សនិងទេវតា[8] ដ៏ច្រើនសន្ធឹកសន្ធាប់បានមកបង្គំសុំលោកធ្វើជាគ្រូ,ជាអ្នកដែលរកឃើញនូវសេចក្តីទុក្ខពិតប្រាកដរបស់ជីវិតនិងហេតុនៃសេចក្តីទុក្ខទាំងនោះ ព្រមទាំងវិធីដើម្បីរំលត់នូវសេចក្តីទុក្ខទាំងនោះ ដោយមានប្រសិទ្ធិភាពជាទីបំផុត, ហើយព្រះអង្គ គឺជាអ្នកដែលពូកែក្នុងចំណែកធម៌ដ៏ចំណានម្នាក់ក្នុងលោក[9] ។

ជោគជ័យដ៏ធំរបស់ព្រះអង្គលើមេលទ្ធិបូជាភ្លើងទាំង ៣ នាក់ បានធ្វើឲ្យព្រះបាទពិម្ពិសារ ក្សត្រក្នុងរដ្ឋមគធៈ ក្លាយទៅជាពុទ្ធបរិស័ទដ៏មានកម្លាំងមួយអង្គ ក្នុងការជួយផ្សព្វផ្សាយពុទ្ធវចនៈ ។ ក្នុងរយៈពេលត្រឹមតែ ៦ ខែ ប៉ុណ្ណោះ ព្រះអង្គបានទទួលបេក្ខជនមកបួសជាព្រះសង្ឃដល់ទៅជាង ១ ពាន់អង្គ និងឧបាសកឧបាសិកាដល់ទៅពាន់នាក់ ។

ឥទ្ធិពលរបស់ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ បានឆ្លុះបញ្ចាំងនៅក្នុងការប្តេជ្ញារបស់វេរញ្ជព្រាហ្មណ៍ ជាអ្នកបួសនៃសាសនាព្រាហ្មណ៍ ដែលបន្ទាប់ពីបានស្តាប់នូវការបកស្រាយធម៌អំពីព្រះពុទ្ធហើយ ក៏ប្រកាសថាៈ «បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គជាចម្បងជាងមនុស្ស ប្រសើរបំផុតជាងមនុស្ស បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោតដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានភ្នែករមែងមើលឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹកចាប់រាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់សរណគមន៍ ស្មើដោយជីវិត ....។[10]

---

[8] ទេវតាក្នុងសង្គមឥណ្ឌា មានន័យ ២យ៉ាង គឺសម្មតិទេព(ទេវតាដោយសន្មត) បានដល់ថ្នាក់អ្នកដឹកនាំមានក្សត្រ ជាដើម និងឧប្បត្តិទេព(ទេវតាដោយកំណើត) បានដល់ទេវតាដែលយើងជឿថានៅឋានសួគ៌ ។

[9] ជាសេចក្តីប្រែរបស់ពុទ្ធគុណៈ ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

[10] វេរញ្ជកណ្ឌ, វិន័យបិដក មហាវិភង្គ, ភាគ ១ ទំព័រ ១៧ ។

www.budihst.gov.kh www.elibraryofcambodia.org

ដោយឃើញចំនួនពុទ្ធបរិស័ទកាន់តែមានច្រើនឡើងៗដូច្នេះហើយ ព្រះអង្គក៏បានរៀបចំធ្វើជាមហាសន្និបាត (congress) មួយឡើង ដើម្បីប្រកាសសាសនាព្រះអង្គដល់មនុស្សជាតិទាំងពួងជាផ្លូវច្បាប់ និងជាសាកលថា ពុទ្ធសាសនាមានកំណើតក្នុងលោកហើយ ។ មហាសន្និបាតនោះ ធ្វើនៅថ្ងៃ ១៥ កើត ខែមាឃ (កុម្ភៈ) ឆ្នាំរការ ក្រោយពេលព្រះអង្គបានត្រាស់ដឹងហើយចំនួន ៩ ខែ នៅព្រៃវេឡុវ័ន (ព្រៃឫស្សី) ជិតក្រុងរាជគ្រឹះនៃរដ្ឋមគធៈ ដោយមានព្រះភិក្ខុសង្ឃបួសផ្ទាល់នឹងព្រះអង្គចំនួន ១,២៥០ រូប ដែលសុទ្ធសឹងជាព្រះអរហន្ត មកចូលរួមជាសមាជិកមហាសន្និបាត ។

ក្នុងឱកាសនៃមហាសន្និបាតនេះ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានប្រកាសនូវធម្មនុញ្ញរបស់សាសនាព្រះអង្គដល់សមាជិកមហាសន្និបាតទាំងអស់ សម្រាប់ធ្វើជាក្រឹត្យក្រមអនុវត្ត និងដើម្បីប្រកាសផ្សព្វផ្សាយដល់មហាជនទាំងពួង ឲ្យបានដឹងអំពីគោលការណ៍ដែលព្រះពុទ្ធសាសនាប្រកាន់យក ក្នុងឋានៈជាសាសនាទើបកើតថ្មី ។ ធម្មនុញ្ញសាសនានេះ ព្រះអង្គឲ្យឈ្មោះថា ឱវាទបាដិមោក្ខ មានទាំងអស់ ១១ មាត្រា ដែលអាចចែកចេញទៅជា ៥ ជំពូកគឺ៖[11]

## ក-គោលការណ៍

| | |
|---|---|
| ១. សព្វបាបស្ស អករណំ | មិនធ្វើបាបទាំងពួងជាដាច់ខាត |
| ២. កុសលស្សូបសម្បទា | បំពេញកុសលឲ្យបរិបូរណ៍ |
| ៣. សចិត្តបរិយោទបនំ | ធ្វើចិត្តរបស់ខ្លួនឲ្យស្អាតល្អ |

## ខ-គោលបំណង

| | |
|---|---|
| ៤. និព្វានំ បរមំ វទន្តិ ពុទ្ធា | និព្វានជារបស់ដ៏ឧត្តមដែលព្រះពុទ្ធទាំងឡាយត្រាស់សំដែង |

## គ-វិធី

[11] ការបែងចែកនេះ ជាការវិភាគ និងជាមតិរបស់អ្នករៀបរៀង ដោយយោលទៅតាមបែបផែននៃលក្ខន្តិកៈដែលអង្គការមួយគួរមាន និងងាយយល់។ ចំពោះលំដាប់លំដោយដើមគឺ ១,២,៣,៥,៤,៦,១០,១១,៧,៨,៩ ។

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ៥. ខន្តី បរមំ តបោតីតិក្ខា | ការអត់ធន់ ជាតបធម៌ដ៏ឧត្តម |

## ឃ-សមាជិកភាព

| | |
|---|---|
| ៦. ន ហិ បព្វជិតោ បរូបឃាតិ សមណោ ហោតិ បរំ វិហេឋយន្តោ | អ្នកបួសណាដែលសម្លាប់សត្វ អ្នកនោះមិន មែនជាសមណៈក្នុងពុទ្ធសាសនាទេ |
| ៧. មត្តញ្ញុតា ច ភត្តស្មឹ | បរិភោគអាហារដោយស្គាល់ប្រមាណ |
| ៨. បន្តញ្ច សយនាសនំ | ពេញចិត្តកន្លែងដេក និងទីអង្គុយ ដែលស្ងប់ស្ងាត់ |
| ៩. អធិចិត្តេ ច អាយោគោ | ព្យាយាមធ្វើចិត្តរបស់ខ្លួនឲ្យទៅជា អធិចិត្ត |

## ង-ការផ្សព្វផ្សាយ

| | |
|---|---|
| ១០. អនូបវាទោ អនូបឃាតោ | កុំតិះដៀលគេ កុំបៀតបៀនគេ |
| ១១. បាដិមោក្ខេ ច សំវរោ | ចូរសំរួមនៅក្នុងច្បាប់គោល ការណ៍របស់ខ្លួន |

ឱវាទដែលព្រះអង្គបានសម្តែងទាំង ១១ ប្រការនេះ គឺជាធម្មនុញ្ញមួយដែលមានលក្ខណៈសម្បូរគ្រប់គ្រាន់ទាំងអស់ ដែលអាចឲ្យសមាជិកម្នាក់ៗបង្ហាញនូវភាពរួមរបស់សាសនាខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុត សំរាប់អ្នកដែលចង់ដឹង និងជារង្វាស់សម្រាប់វាស់ថា អ្នកណាមួយជាសមាជិករបស់ពុទ្ធសាសនាពិតប្រាកដ ។ ដោយសារខ្លឹមសារ និងភាពទាក់ទាញអារម្មណ៍របស់ខ្លួន ធម្មនុញ្ញនេះបានក្លាយទៅជាមេដែកឆក់ស្រូបយកជនដែលអស់សង្ឃឹមក្នុងជីវិត ជនដែលសម្លឹងពិភពលោកក្នុងន័យអាក្រក់ (Pessimist) ជនដែលសម្លឹងពិភពលោកថាគ្មានន័យអ្វីទាំងអស់ ជនដែលរងគ្រោះដោយសារការបោកបញ្ឆោតអំពីអ្វីដែលហៅថាគោលដៅជីវិតដែលល្អបំផុត ជនដែលរងគ្រោះដោយសារការផ្សព្វផ្សាយសាសនា ដោយរបៀបហឹង្សា និងកុហក ជនដែលរងគ្រោះដោយសារជំនឿ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាប់មុខ និងជនដែលកំពុងស្វែងរកសច្ចធម៌យ៉ាងច្រើន ឲ្យចូលមកសាកល្បងរស់នៅក្នុងវិថីជីវិតថ្មីនេះជាបន្តបន្ទាប់ ។ ទីបំផុតគេក៏បានឃើញច្បាស់ដោយខ្លួនគេផ្ទាល់ថា ធម្មទុញ្ញនេះ សច្ចធម៌នេះ ឱវាទនេះ ពិតជាបានផ្តល់ឲ្យគេនូវជីវិតមួយដែលមានសេរីភាពពិតប្រាកដ និងមានឯករាជ្យ មិនធ្លាក់ទៅក្នុងអំណាចនៃលោភៈ ទោសៈ និងមោហៈ មែន ។

## ៥៥ ឆ្នាំដែលមិនអាចកាត់ថ្លៃបាន

ចាប់តាំងពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធបរមគ្រូបើកមហាសន្និបាតនោះមក គោលការណ៍ពុទ្ធសាសនាក៏បានរីកសាយភាយទូទាំងជម្ពូទ្វីបដោយឆាប់រហ័ស ។ នៅទីណាក៏តែងតែឮសូរមាត់អួតសរសើរអំពីការកើតឡើងនៃព្រះពុទ្ធ សរសើរពីធម៌ ដែលមានសច្ចភាព និងអួតនូវគុណរបស់ព្រះសង្ឃដែលបរិសុទ្ធគ្រប់ទីកន្លែង ឯចំនួនពុទ្ធបរិស័ទក៏កើនឡើងយ៉ាងឆាប់រហ័ស ។ ពេលនោះឯងដែលកិត្តិគុណ ៩ យ៉ាង របស់ព្រះសម្មាសម្ពុទ្ធបានកើតឡើង ដោយការប្រសិទ្ធិនាមរបស់ពុទ្ធបរិស័ទ និងជនជាតិជម្ពូទ្វីបទាំងមូល ។ ពុទ្ធសាសនិកជនទាំងនោះ បានហៅព្រះអង្គថាជា ៖

១- **អរហំ** គឺអ្នកដែលមានដួងចិត្តបរិសុទ្ធ គ្មានកិលេស រាគៈ ទោសៈ មោហៈ

២- **សម្មាសម្ពុទ្ធោ** គឺអ្នកដែលបានត្រាស់ដឹងរកឃើញនូវអរិយសច្ចៈទាំង ៤ ដោយព្រះអង្គឯងមុនគេ ដោយពុំមានអ្នកណាប្រាប់ណែនាំឡើយ

៣- **វិជ្ជាចរណសម្បន្នោ** គឺជាអ្នកប្រាជ្ញមានចំណេះវិជ្ជាច្រើនខ្ពង់ខ្ពស់ គ្មាននរណាប្រៀប និងមានការប្រព្រឹត្តកិរិយាមាយាទ ដ៏ល្អឥតខ្ចោះ

៤- **សុគតោ** គឺអ្នកដែលមានដំណើរជីវិតដ៏ល្អ និងបានសំរេចនូវគោលដៅជីវិត គឺផុតទុក្ខដោយជោគជ័យ

៥- **លោកវិទូ** គឺវិទូរបស់ពិភពលោក ជាអ្នកប្រាជ្ញប្រចាំលោក ជាអ្នកដឹងរឿងរ៉ាវ និងដំណើររបស់ជីវិត សង្គម ពិភពលោក និងវដ្តសង្សារ ដោយជាក់ច្បាស់

៦- **អនុត្តរោបុរិសទម្មសារថិ** គឺអ្នកហ្វឹកហាត់ថ្នាក់ខ្ពស់ ដែលពូកែអប់រំហ្វឹក

www.budinst.gov.kh www.elibraryofcambodia.org

ហ៊្វីនបុរស ស្ត្រីទាំងឡាយឲ្យក្លាយទៅជាបណ្ឌិត និងសំរេចនូវនិព្វាន ដោយពុំអាចរកនរណាមកប្រៀបធៀបបានឡើយ

៧- សត្ថាទេវមនុស្សានំ គឺជាសាស្តា ជាគ្រូរបស់មនុស្សសាមញ្ញ ពួកអ្នកមន្ត្រី ខ្ញុំរាជការ ព្រះមហាក្សត្រ ទេវតា ឥន្ទព្រហ្មទាំងឡាយ

៨- ពុទ្ធោ គឺជាព្រះពុទ្ធ ជាអ្នកដឹងអំពីអ្វីដែលហៅថាទុក្ខរបស់ជីវិត មូលហេតុរបស់ទុក្ខនោះ ការរំលត់ទុក្ខ និងវិធីសំរាប់រំលត់ទុក្ខទាំងនោះ

៩- ភគវា គឺជាអ្នកពូកែវែកញែកធម៌ បែងចែកធម៌ ឲ្យទៅតាមពួកតាមក្រុម តាមប្រភេទ និងជាអ្នកធ្វើការអ្វីដែលតែងមានជោគជ័យ មានគេជ្រោមជ្រែង គាំទ្រគ្រប់ទីកន្លែងទាំងអស់

គុណសម្បត្តិទាំង ៩ យ៉ាងនេះ អាចសង្ខេបឲ្យមកនៅត្រឹមតែ ៣ យ៉ាង គឺ ៖

១- *បញ្ញាធិគុណ*៖ ព្រះអង្គជាបញ្ញាជន ជាអ្នកប្រាជ្ញ ជាបណ្ឌិត មានបញ្ញាចេះដឹងសព្វ សារពើ ជាសព្វញ្ញូ ជាអ្នកដឹងនូវអ្វីដែលជាបញ្ហាជីវិត និងវិធីរំលត់នូវហេតុនៃបញ្ហានោះ ។

២- *ករុណាធិគុណ*៖ ព្រះអង្គជាអ្នកដែលមានព្រះទ័យពោរពេញទៅដោយមេត្តា គឺស្រឡាញ់ អាណិតដល់សព្វមនុស្សសត្វទាំងអស់ និងករុណា គឺមានព្រះទ័យជួយសង្គ្រោះមនុស្ស សត្វ ឲ្យរួចផុតពីសេចក្តីទុក្ខ ដោយព្រះធម៌ទេសនា អស់រយៈពេល ៤៥ ឆ្នាំគត់ ។

៣- *វិសុទ្ធិគុណ*៖ ព្រះអង្គជាមនុស្សបរិសុទ្ធ គ្មានកិលេស ជនណាដែលនឹករលឹកព្រះអង្គ យកព្រះអង្គជាទីពឹង បានធ្វើការបូជា ធ្វើបុណ្យនឹងព្រះអង្គ អ្នកនោះរមែងបាននូវសេចក្តីសុខដ៏លើសលប់ ។

ពុទ្ធគុណទាំង ៩ ឬទាំង ៣ នេះ បានធ្វើឲ្យពិភពលោកយើងកែប្រែនូវមុខមាត់របស់ខ្លួនពីបាតដៃមកខ្នងដៃ ។ ជនទាំងឡាយដែលគ្មានជំនឿលើខ្លួនឯងថា អាចកំណត់នូវជោគជីវិតរបស់ខ្លួន ព្រោះជីវិតនេះត្រូវបានលិខិតមកជាស្រេចហើយ ដោយព្រហ្ម ដោយអាទិទេពផ្សេងៗនៃសាសនាទេវនិយមដទៃនោះ បានភ្ញាក់បើកភ្នែក ក្រោកឈរកម្រើកដៃជើង និងជឿច្បាស់លើខ្លួនឯងថា ខ្លួនគេអាចឆ្លងផុតពីបញ្ហាជីវិត និងសេច

www.budinst.gov.kh www.elibraryofcambodia.org

ក្តីទុក្ខទាំងនោះបាន ដោយសេចក្តីព្យាយាមរបស់គេ និងតាមការណែនាំរបស់ព្រះពុទ្ធ ដែលជាគ្រូ និងជាអ្នកហ្វឹកហាត់ដ៏ចំណាន ដោយពិតប្រាកដ។

លោកអាល់បេរ ស្វ័យស៊ែរ (Albert Schweitzer) ជាអ្នកទេវវិទ្យា អ្នកបង្រៀនសាសនា ជាពេទ្យ និងជាតន្ត្រីករជាតិបារាំងដែលបានទទួលរង្វាន់ណូបែលសាខាសន្តិភាព ក្នុងឆ្នាំ ១៩៥២ បានសរសេរថា: "........He gave expression to truths of everlasting value and advanced the ethics of not India alone but of humanity. Buddha was one of the greatest ethical men of genius ever bestowed upon the world."
<ព្រះពុទ្ធទ្រង់បានសំដែងនូវសច្ចធម៌ដែលមានតម្លៃជាអមតៈ និងបានធ្វើឲ្យរីកចំរើនខាងចរិយធម៌ មិនត្រឹមតែសម្រាប់ឥណ្ឌាប៉ុណ្ណោះទេ តែថែមទាំងសម្រាប់មនុស្សជាតិទៀតផង ព្រះពុទ្ធអង្គជាអច្ឆរិយបុគ្គលម្នាក់ខាងសីលធម៌ ក្នុងចំណោមអច្ឆរិយបុគ្គលទាំងឡាយ ដែលពិភពលោកធ្លាប់មាន> ។

តែគួរស្តាយណាស់ដែលធម្មជាតិមិនអាចមិនប្រែប្រួល ។ ជីវិតដែលកើតឡើងត្រូវតែស្លាប់ ។ ជីវិតព្រះសម្មាសម្ពុទ្ធ ក៏មិនអាចមានករណីពិសេសដែលធម្មជាតិលើកលែងបានដែរ ព្រះអង្គបានចាកលោកនេះទៅដោយស្ងៀមស្ងាត់ បន្ទាប់ពីការបំពេញករណីយកិច្ចក្នុងឋានៈជាព្រះពុទ្ធ ដើម្បីសត្វលោកអស់រយៈកាល ៤៥ ឆ្នាំ ។ នៅថ្ងៃចុងក្រោយបង្អស់នៃឆ្នាំទី ៨០ នៃព្រះជន្មាយុ ដែលត្រូវនឹងថ្ងៃ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ **ព្រះពុទ្ធរបស់ពិភពលោកយើង** ក៏យាងចូលបរិនិព្វានទៅចន្លោះក្រោមដើមព្រឹក្សា ១គូ ឈ្មោះដើមសាលៈ ដែលមានមែកទោរទន់ដោយផ្ការយីងរយោងនាវេលាម៉ោងប្រហែល ៦ ព្រឹក ក្រោយពីបានផ្តាំជាចុងក្រោយបង្អស់ថា: < *យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា អហំ ឯកកោវ បរិនិព្វាយិស្សាមិ អហញ្ច បរិទាមិ ឯកកោវ ឱវទាមិ អនុសាសេមិ*> ម្នាលអានន្ទ ធម៌ក្តី វិន័យក្តី ដែលតថាគតបានសំដែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ ព្រះធម៌ និងវិន័យនោះ លុះឥតពីតថាគតទៅ នឹងទៅជាគ្រូរបស់អ្នកទាំងឡាយហើយ ។ តថាគតគឺជាព្រះពុទ្ធមួយអង្គ ដែលតែងតែប្រៀនប្រដៅដល់អ្នកទាំងឡាយ តែឥឡូវនេះតថាគតនឹងបរិនិព្វានហើយ > ។

www.budinst.gov.kh www.elibraryofcambodia.org

ក្តីទុក្ខទាំងនោះបាន ដោយសេចក្តីព្យាយាមរបស់គេ និងតាមការណែនាំរបស់ព្រះពុទ្ធ ដែលជាគ្រូ និងជាអ្នកហ្វឹកហាត់ដ៏ចំណាន ដោយពិតប្រាកដ។

លោកអាល់បើរ ស្វ៊ែយស៊ែរ (Albert Schweitzer) ជាអ្នកទេវវិទ្យា អ្នកបង្រៀនសាសនា ជាពេទ្យ និងជាវត្រ្តីករជាតិបារាំងដែលបានទទួលរង្វាន់ណូបែលសាខាសន្តិភាព ក្នុងឆ្នាំ ១៩៥២ បានសរសេរថា: "........He gave expression to truths of everlasting value and advanced the ethics of not India alone but of humanity. Buddha was one of the greatest ethical men of genius ever bestowed upon the world."
<ព្រះពុទ្ធទ្រង់បានសំដែងនូវសច្ចធម៌ដែលមានតម្លៃជាអមតៈ និងបានធ្វើឲ្យរីកចំរើនខាងចរិយធម៌ មិនត្រឹមតែសម្រាប់ឥណ្ឌាប៉ុណ្ណោះទេ តែថែមទាំងសម្រាប់មនុស្សជាតិទៀតផង ព្រះពុទ្ធអង្គជាអច្ឆរិយបុគ្គលម្នាក់ខាងសីលធម៌ ក្នុងចំណោមអច្ឆរិយបុគ្គលទាំងឡាយ ដែលពិភពលោកធ្លាប់មាន> ។

តែគួរស្តាយណាស់ដែលធម្មជាតិមិនអាចមិនប្រែប្រួល ។ ជីវិតដែលកើតឡើងត្រូវតែស្លាប់ ។ ជីវិតព្រះសម្មាសម្ពុទ្ធ ក៏មិនអាចមានករណីពិសេសដែលធម្មជាតិលើកលែងបានដែរ ព្រះអង្គបានចាកលោកនេះទៅដោយស្ងៀមស្ងាត់ បន្ទាប់ពីការបំពេញករណីយកិច្ចក្នុងឋានៈជាព្រះពុទ្ធ ដើម្បីសត្វលោកអស់រយៈកាល ៤៥ ឆ្នាំ ។ នៅថ្ងៃចុងក្រោយបង្អស់នៃឆ្នាំទី ៨០ នៃព្រះជន្មាយុ ដែលត្រូវនឹងថ្ងៃ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ **ព្រះពុទ្ធរបស់ពិភពលោកយើង** ក៏យាងចូលបរិនិព្វានទៅចន្លោះក្រោមដើមព្រឹក្សា ១គូ ឈ្មោះដើមសាលៈ ដែលមានមែកទោរទន់ដោយផ្ការយើងរយោងនាវេលាម៉ោងប្រហែល ៦ ព្រឹក ក្រោយពីបានផ្តាំជាចុងក្រោយបង្អស់ថា: < *យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា អហំ ឯកកោវ បរិនិព្វាយិស្សាមិ អហញ្ច បនិទានិ ឯកកោវ និវាមិ អនុសាសេមិ*> ម្នាលអានន្ទ ធម៌ក្តី វិន័យក្តី ដែលតថាគតបានសំដែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ ព្រះធម៌ និងវិន័យនោះ លុះឥតពីតថាគតទៅ នឹងទៅជាគ្រូរបស់អ្នកទាំងឡាយហើយ ។ តថាគតគឺជាព្រះពុទ្ធមួយអង្គ ដែលតែងតែប្រៀនប្រដៅដល់អ្នកទាំងឡាយ តែឥឡូវនេះតថាគតនឹងបរិនិព្វានហើយ > ។

www.budinst.gov.kh www.elibraryofcambodia.org

ផ្កាសាលព្រឹក្សរោយរុះជាប់ន្តបន្ទាប់ ដូចជាសំដែងនូវមរណទុក្ខចំពោះព្រះបរមគ្រូពិភពលោកអង្គនេះ លាយឡំជាមួយនឹងដំណក់ទឹកម្នែករាប់លានដំណក់នៃពុទ្ធបរិស័ទដែលហូរធ្លាក់ចុះមកឥតអាក់ ។ ដួងប្រទីបដើម ទី១ សំរាប់ទ្វីបមនុស្សរលត់ទៅហើយ! ទម្រាំនឹងមានប្រទីបបែបនេះកើតឡើងលើលោកទៀតនោះ គឺយូរណាស់ ជួលកាលយើងអាចនឹងគ្មានវាសនាបានទទួលពន្លឺនោះផងក៏មិនដឹង ? តែទោះជាព្រះអង្គយាងទៅបាត់ហើយក្តី ក៏ខ្ញុំសូមលុតជង្គង់ ប្រណម្យហត្ថ បែរភក្ត្រាឆ្ពោះទៅទិសខាងលិច ធ្វើសច្ចាថា «ពុទ្ធំ សរណំ គច្ឆាមិ» ខ្ញុំសូមយកព្រះពុទ្ធជាទីពឹង ទីរលឹក លុះអវសានជីវិត!

| | | |
|---|---|---|
| *សូមយកព្រះពុទ្ធ* | *ម្ចាស់ខ្ពស់បំផុត* | *ធ្វើជាទីពឹង* |
| *ពេលខ្ញុំជួបទុក្ខ* | *បញ្ហាទន់រឹង* | *លោកជាត់ទឹង* |
| | *ពង្រឹងបញ្ញា ។* | |

"As a student of comparative religions, I believe that Buddhism is the most perfect one the world has ever seen. The philosophy of the Buddha, the theory of evolution and the Law of Karma were far superior to any other creed."

Professor Carl Gustav Jung

"ក្នុងឋានៈជាអ្នកសិក្សាសាសនាប្រៀបធៀប ខ្ញុំជឿថា ពុទ្ធសាសនាជាសាសនាដ៏សុក្រឹតជាទីបំផុត ដែលពិភពលោកធ្លាប់បានជួបប្រទះ។ ទស្សនវិជ្ជារបស់ព្រះពុទ្ធអង្គ ទ្រឹស្តីវិវឌ្ឍនាការ និងច្បាប់កម្មរបស់ទ្រង់ ធំធេងខ្ពង់ខ្ពស់ជាងលទ្ធិដទៃ ឆ្ងាយណាស់ " ។

www.budinst.gov.kh www.elibraryofcambodia.org

# ការយកព្រះពុទ្ធជាទីពឹង

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំសូមយកព្រះពុទ្ធជាទីពឹង ទីរលឹក! នេះជាវាចាដែលពុទ្ធសាសនិកបន្លឺឡើង ដើម្បីប្ដេជ្ញាខ្លួនជាបរិស័ទ ។ បានសេចក្ដីថា ដើម្បីបានក្លាយខ្លួនទៅជាសមាជិករបស់ពុទ្ធសាសនាដែលពេញក្របខណ្ឌ បេក្ខជនម្នាក់ៗត្រូវបន្លឺវាចាប្ដេជ្ញាយកព្រះពុទ្ធជាទីពឹង ជាមុនដំបូងបង្អស់ ទើបយកព្រះធម៌ និងព្រះសង្ឃជាលំដាប់ ។

តាមការសង្កេត ពុទ្ធបរិស័ទយើងហាក់ដូចជាមានការស្មុគស្មាញនៅក្នុងចិត្តលើការយកព្រះពុទ្ធជាទីពឹងនេះ ថាតើយកជាទីពឹង ជាទីរលឹកដោយរបៀបណា ទើបត្រឹមត្រូវទៅតាមពុទ្ធបំណង ។

ជាទូទៅយើងចេះនិយាយប្រយោគ <ខ្ញុំសូមយកព្រះពុទ្ធជាទីពឹង ទីរលឹក> នេះគ្រប់គ្នា តែអាចយល់នៅក្នុងបរិបទផ្សេងៗគ្នា ដូចជា ៖

## ក- ពឹងព្រះពុទ្ធឲ្យជួយដោះស្រាយបញ្ហា :

ក្នុងសម័យពុទ្ធកាល កាលណាពុទ្ធបរិស័ទណាមួយមានបញ្ហាអ្វី ដែលដោះស្រាយមិនចេញ មិនយល់ ឬដឹងមិនដល់ ក៏ធ្វើដំណើរទៅថ្វាយបង្គំព្រះ ដើម្បីឲ្យព្រះអង្គជួយបំភ្លឺ និងដោះស្រាយ ដូចជាករណីព្រះបាទពិម្ពិសារ ដែលឮសំរែករបស់ពួកប្រេតស្រែកក្នុងពេលរាត្រី មានការភ័យរន្ធត់ ខ្លាចកើតហេតុមិនស្រួលដល់រាជបល្ល័ង្ក ក៏ទៅសាកសួរសុំឲ្យព្រះសម្មាសម្ពុទ្ធជួយបំភ្លឺ ។

## ខ- ពឹងព្រះពុទ្ធឲ្យជួយសង្គ្រោះ :

លើករណីនេះ ក្នុងទស្សនៈរបស់ពុទ្ធបរិស័ទ ព្រះសម្មាសម្ពុទ្ធគឺជាអាទិទេព ឬទេវតាសក្តិសិទ្ធិ ដែលអាចជួយដោះស្រាយបញ្ហា ឬផ្ដល់នូវអ្វីមួយទៅតាមសំណូមពររបស់ពុទ្ធបរិស័ទដែលមកសុំ ឬបន់ស្រន់ ។ ការណ៍នេះ កើតឡើងព្រោះព្រះពុទ្ធអង្គទ្រង់បរិនិព្វានបាត់ទៅហើយ បរិស័ទមិនដឹងទៅរកព្រះអង្គឯណា ក៏ទៅបន់ពុទ្ធរូបនៅតាមវត្តនានាទៅ ។ បែបនេះមានច្រើនណាស់នាបច្ចុប្បន្ន ដូចជាអ្នកខ្លះបន់សុំកូន បន់សុំលាភ

www.budinst.gov.kh www.elibraryofcambodia.org

សុំជ័យ បន់សុំឲ្យរួចពីគ្រោះថ្នាក់ផ្សេងៗជាដើម ។

## គ-ទីពឹងខាងផ្លូវចិត្ត

ពេលដែលមានភ័យចូលមកយាយី ពុទ្ធបរិស័ទតែងតែរលឹកទឹកដល់ព្រះនាមព្រះអង្គ ដើម្បីឲ្យបាត់ភ័យខ្លាច មានកំឡាំងចិត្តសំរាប់តស៊ូតទៅទៀត ។ ក្នុងសម័យពុទ្ធកាល ព្រះសម្មាសម្ពុទ្ធក៏បានត្រាស់ដែរ (ធជគ្គសូត្រ) ដូចជាពួកភិក្ខុដែលចេញដើរទៅក្នុងព្រៃស្ងាត់ ឬតាមរូងភ្នំដាច់ស្រយាលដើម្បីចំរើនធម៌ ហើយមានការខ្លាចភ័យរន្ធត់ ព្រះអង្គក៏ត្រាស់ឲ្យរលឹកទឹកដល់ព្រះនាមរបស់ព្រះអង្គឲ្យជាប់ ។

នាបច្ចុប្បន្ន ពេលមានផ្គើកបន្ទោរ មានភ័យ មានសង្គ្រាម ឬខ្លាចខ្មោចជាដើម ពុទ្ធបរិស័ទនាំគ្នាទន្ទេញពុទ្ធោៗជាប់មាត់ ដើម្បីបំបាត់ការភ័យខ្លាចទាំងនោះ ហើយមានជំនឿថា ព្រះនាមរបស់ព្រះអង្គនឹងជួយគេឲ្យរួចពីគ្រោះថ្នាក់ ។ អ្នកខ្លះក៏បានយកព្រះនាមព្រះអង្គមកចារជាខ្សែចង្កេះ ជាកន្សែងយ័ន្ត ឬយកមកសាក់ជាប់នឹងខ្លួន ដើម្បីការពារខ្លួនឲ្យផុតពីគ្រោះអន្តរាយ ។

ទាំង ៣ ខាងលើនេះ ជាការយកព្រះពុទ្ធជាទីពឹង ទីរលឹករបស់ពុទ្ធបរិស័ទយើង ។ អាចក្តីមិនទាន់ថា ទីពឹងទីរលឹកយ៉ាងណាត្រូវឬខុសទេ តែចង់ឲ្យពុទ្ធបរិស័ទទាំងអស់ ងាកមកពិចារណាលើពាក្យ <សរណៈ> ដែលជាពាក្យដើមសិន ។

ពាក្យថា សរណៈ នៅក្នុងវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពក្នុងឆ្នាំ ១៩៦៨ មានសេចក្តីជាភាសាខ្មែរថាៈ ទីរលឹក ការរលឹកដល់ ទីពឹងពំនាក់ ទីអាង ទីជ្រកអាស្រ័យ ផ្ទះ លំនៅ គ្រឿងការពារ គ្រឿងគ្រប់គ្រងរក្សា ព្រះនិព្វាន ។

នៅក្នុង Dictionary of Buddhism និពន្ធដោយព្រះភិក្ខុ ទេព វាទី និងបោះពុម្ព ដោយមហាវិទ្យាល័យសង្ឃ មហាចុឡាឡុងកនរាជវិទ្យាល័យ បានប្រែពាក្យ សរណៈ ជាភាសាអង់គ្លេសថាៈ (Sarana: Refuge, Help, Protection, Guide, Remembrance) ។ ក្នុងពាក្យប្រែរបស់ សរណៈ ជាភាសាខ្មែរ ពាក្យដែលយើងធ្លាប់បានជួបជាញឹកញាប់ គឺពាក្យទីរលឹក និងទីពឹង ឯពាក្យក្រៅពីនេះ បើយើងបានឃើញគង់យល់ថាស្មើនឹងពាក្យទាំងពីរនេះជាពុំខាន ។ តែមានពាក្យមួយម៉ាត់ ដែលអាចក្តីគិតថា មានសារៈសំខាន់ និងប្រយោជន៍យ៉ាងខ្លាំងដល់ពុទ្ធបរិស័ទ បើសិនជាយើងយកពាក្យ

www.budinst.gov.kh www.elibraryofcambodia.org

នោះមកប្រើឲ្យបានទូលំទូលាយ គឺពាក្យថាទីអាង ដែលប្រែមកពីពាក្យថាសរណៈដែរ ។ ពាក្យថាទីអាងក្នុងទីនេះ សំដៅដល់ទីសំអាង ដែលអ្នកនិពន្ធ និងអ្នកស្រាវជ្រាវទាំងឡាយតែងប្រើក្នុងសំនេររបស់ខ្លួន នៅឯភាគចុងបញ្ចប់សៀវភៅ ដែលពាក្យភាសាអង់គ្លេសហៅថា Referee និងនៅឯខាងក្រោមទំព័រ ទីមួយៗដែលអង់គ្លេសហៅថា Footnote ។ គឺថា បើអ្នកអានមិនជឿ ឬចង់ដឹងការពិតឲ្យច្បាស់ ថាពាក្យនោះពិតឬពុំពិតនោះ អាចទៅបើកមើលនៅសៀវភៅ ឬពាក្យសម្ដីដែលគេបានដាក់ជាទីសំអាងនៅចុងសៀវភៅ ឬខាងក្រោមទំព័រនោះស្រាប់ ។ ដូចគ្នានេះដែរ ពុទ្ធបរិស័ទដែលយកព្រះពុទ្ធជាសរណៈ មុននឹងនិយាយ ធ្វើ ឬគិត គប្បីយកនូវពុទ្ធវចនៈ និងពុទ្ធចរិយាធ្វើជាទីអាងសិន ថាការនេះ បញ្ហានេះ ព្រះសម្មាសម្ពុទ្ធលោកបានធ្វើយ៉ាងដូចម្ដេច ប្រាប់ឲ្យយើងដោះស្រាយយ៉ាងម៉េច ។ ការដែលយើងមានទីអាង គឺព្រះពុទ្ធសំរាប់ប្រព្រឹត្តិកម្មរបស់យើង នឹងអាចធ្វើឲ្យយើងមានសេចក្ដីសុខ និងផុតពីគ្រោះភ័យបាន ។

លើកជាឧទាហរណ៍ នៅក្នុងព្រះបរិត្តឈ្មោះពុទ្ធជ័យមង្គល លោកបានសំដែងបង្ហាញអំពីវិធីដើម្បីយកជ័យជំនះលើបញ្ហា ៨ ប្រការ ដែលអាចឲ្យយើងយកធ្វើជាទីសំអាងបាន កាលណាជួបបញ្ហាប្រអាទដូចគ្នានេះ ។ វិធីទាំង ៨ ប្រការនោះគឺ ÷

១- បើជួបនឹងសត្រូវដែលមានចិត្តលោភលន់ លោកឲ្យផ្ចាញ់ដោយ ទាន គឺអំណោយ

២- អ្នកដែលមានចិត្តរឹងរូស មិនងាយប្រដៅបាន លោកឲ្យប្រើ ខន្តី គឺការអត់ធ្មត់

៣- បើជួបនឹងមនុស្សសត្វដែលមានចិត្តកាចឃោរឃៅ លោកឲ្យយើងប្រើមេត្តា

៤- ជនខ្លះមិនអាចប្រើមេត្តាបានទេ លោកឲ្យប្រើ រិទ្ធិអំណាច របស់យើងទៅបង្ក្រាបវិញ

៥- ជនដែលមានប្រក្រតីនិយាយកុហក បោកប្រាស បង្កាច់បង្ខូច លោកឲ្យប្រើ សច្ចៈ គឺការទៀងត្រង់សំរាប់ទប់ទល់

៦- ចំពោះជនដែលមានល្បិច លោកឲ្យយើងប្រើ បញ្ញា តប

៧- ចំពោះជនដែលមានអស្មិមានៈរឹងរូសខ្លះ យើងពុំអាចផ្ចាញ់បានដោយខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ឯងទេ គប្បី ប្រើឲ្យ អ្នកដទៃ ទៅផ្ចាញវិញក៏បានដែរ

៨- ចំពោះអ្នកដែលជាបញ្ញវ័ន្ត មានការចេះដឹងជ្រៅជ្រះ លោកក៏ឲ្យប្រើចំណេះវិជ្ជា

វិធីទាំង ៨ នេះ ជាវិធីដែលព្រះពុទ្ធលោកបានប្រើរួចហើយ ដូច្នេះពេលជួបបញ្ហា ប្រាកដជាអាចដោះស្រាយបាន ព្រោះយើងមានពុទ្ធសរណៈ គឺមានព្រះពុទ្ធជាទីរវាងត្រឹមត្រូវ។

ក្នុងភាសាអង់គ្លេស សរណៈ ប្រែថា Refuge = ទីពឹង, Help = ជំនួយ Protection = ការថែរក្សា Guide = មគ្គុទេសក៍ Remembrance = ការចងចាំ ។ ក្នុងភាសាអង់គ្លេសនេះ អាចក្តីឃើញពាក្យ Guide ដែលប្រែថា មគ្គុទ្ទេសក៍ នេះមានន័យល្អ និងត្រឹមត្រូវទៅតាមបរិបទរបស់ពាក្យថា សរណៈ សំរាប់ពុទ្ធបរិស័ទយើងណាស់ ។ មគ្គុទ្ទេសក៍ ប្រែថាអ្នកនាំផ្លូវ សំដៅដល់អ្នកដែលដឹងផ្លូវ ស្គាល់ផ្លូវល្អជាងយើង ហើយបង្ហាញយើង នាំយើងមិនឲ្យវង្វេងនិងមានគ្រោះថ្នាក់ ជាពិសេសការយកនូវដំណើរជីវិតរបស់ព្រះពុទ្ធជាមគ្គុទ្ទេសក៍សំរាប់ជីវិតយើង គឺជាការចាប់យកនូវការអភិវឌ្ឍន៍ជីវិតពីភាពថយថោក ឆ្ពោះទៅរកភាពថ្លៃថ្នូរដោយពិតៗ ដូចដែលព្រះអង្គបានមានពិសោធន៍ផ្ទាល់រួចមកហើយ ។

ដូច្នេះយើងអាចដាក់ន័យនិងពាក្យប្រែឲ្យដល់ពាក្យថា ពុទ្ធំ សរណំ គច្ឆាមិ ឲ្យចំទៅនឹងពុទ្ធបំណងរបស់ព្រះសម្មាសម្ពុទ្ធថា៖ ខ្ញុំរលឹកដល់ទីសំអាង គឺព្រះពុទ្ធ ដើម្បីធ្វើជាមគ្គុទ្ទេសក៍សំរាប់ជីវិត ។

**រលឹកជាមគ្គុទ្ទេសក៍សំរាប់ជីវិត ដូចម្តេចទៅ ?**

ក្នុងន័យនេះ បានដល់ការយកបដិបទាជីវិតរបស់ព្រះអង្គមកសិក្សា និងអនុវត្តតាមបដិបទានោះ ។ ជាធម្មតា មនុស្សយើងតែងមានដំណើរជីវិតដែលទាក់ទងនឹងហេតុការណ៍ ៤ ប្រការគឺ ÷[12]

១- ការចិញ្ចឹមជីវិត

២- ការរស់នៅក្នុងសង្គម

៣- ការប្រឈមមុខនឹងវិបត្តិផ្លូវចិត្ត

[12] យកចេញពីន័យរបស់ភាវនា ៤ គឺ កាយភាវនា, សីលភាវនា, ចិត្តភាវនា និងបញ្ញាភាវនា

www.budinst.gov.kh www.elibraryofcambodia.org

៥- ការស្វែងរកទូវគោលដៅសំរាប់ជីវិត

ដំណើរជីវិតទាំង ៥ ប្រការនេះ ព្រះសម្មាសម្ពុទ្ធលោកបានដកពិសោធន៍ និងចងក្រងរួចអស់ហើយ ដែលជាការងាយអាចអោយយើងយកព្រះអង្គមកធ្វើជាមគ្គុទ្ទេសក៍សំរាប់ជីវិតយើងបានយ៉ាងប្រសើរ ។ យើងនឹងនិយាយអំពីបដិបទាជីវិតនេះនៅខាងមុខឲ្យបានពិស្តារថែមទៀត តែពេលនេះគ្រាន់តែនិយាយឲ្យយល់ពីអ្វីដែលហៅថា ការយកព្រះពុទ្ធជា ទីពឹង ដោយរបៀបណាតែប៉ុណ្ណោះ ។

## ពីមនុស្សម្នាក់ ទៅជាព្រះមួយអង្គ

ជាមនុស្សម្នាក់ដែលពោរពេញទៅដោយកិលេស ឯបង់ឯល់ក្នុងកាមគុណ ប្រាថ្នាទូវអំណាចដើម្បីគ្រប់គ្រងពិភពលោក ជាបុថុជ្ជនម្នាក់ដូចគេឯង ចេះចង់បាន ចេះខឹង និងគ្រប់ដណ្តប់ដោយអវិជ្ជា សិទ្ធត្ថៈបានអភិវឌ្ឍន៍ជីវិតខ្លួនពីការប្រណាំងប្រជែងផ្លូវលោក ពីការបង្កឲ្យកើតសង្គ្រាម ឲ្យទៅជាជីវិតដែលស្ងប់សុខ និងជាអ្នកកសាងសន្តិភាពពិភពលោកដ៏អស្ចារ្យម្នាក់ ។ នេះជាភស្តុតាងឲ្យឃើញថា មនុស្សមានផ្លូវជ្រើសរើសសម្រាប់ជីវិតដែលប្រសើរជាងអត្ថិភាពឥឡូវនេះ និងអាចកសាងសង្គមមួយដែលមានសន្តិភាពជាងបច្ចុប្បន្នបាន ប្រសិនជាគេបានដើរតាមផ្លូវមួយដែលត្រូវល្អ ។ មនុស្សម្នាក់ អាចធ្វើខ្លួនឲ្យមានសេចក្តីសុខ ដោយខ្លួនឯងបាន និងអាចជួយអ្នកដទៃរាប់មិនអស់ ឲ្យបានទទួលនូវសេចក្តីសុខដែរ ។ អនារ្យជន មិនមែនជាអ្នកដែលមិនទាន់សម័យ ឬមិនស៊ីវិល័យទេ តែគឺជាជនណាដែលមានបេះដូងពោរពេញទៅដោយលោភៈ ទោសៈ និងមោហៈ ហើយអារ្យជន ក៏មិនមែនជាអ្នកដែលមានទ្រព្យសម្បត្តិ ស៊ីវិល័យ ទាន់សម័យនោះដែរ តែគឺជាអ្នកដែលមានដួងចិត្តបរិសុទ្ធ ផុតពីការបៀតបៀនរបស់កិលេស និងមានបេះដូងដែលពោរពេញទៅដោយមេត្តា ករុណា ។ គេនឹងអាចក្លាយទៅជាអារ្យជនបាន នៅពេលដែលគេបានរស់នៅក្នុងអារ្យមគ្គតែប៉ុណ្ណោះ ។ ព្រះពុទ្ធអង្គជាអារ្យបុគ្គលម្នាក់ ជាព្រះមួយអង្គ ដែលឆ្លងពីអនារ្យភាព ដោយសារលោករស់នៅក្នុងគន្លងអារ្យមគ្គ (ផ្លូវប្រសើរ ៨ យ៉ាង) ។ ពួកយើងជាអនារ្យជនមែន តែយើងក៏អាចក្លាយខ្លួនទៅជាអារ្យបុគ្គល ក្លាយខ្លួនទៅជាព្រះ ដូចជាព្រះអង្គដែរ បើសិនជាយើងយកអារ្យមគ្គនោះ មកធ្វើជាវិថីជីវិតរបស់ខ្លួន !!

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះធម៌

ព្រះធម៌គឺអ្វី ? ព្រះធម៌ គឺព្រះធម៌

ធម៌មានកំណើតនៅទីណា ? នៅកន្លែង ដែលមានធម៌

នៅពេលណា? ពេលណាក៏មានធម៌ដែរ

ហេតុអ្វីបានជាយើងត្រូវយកធម៌ជាទីពឹង ? បើមិនយកធម៌ជាទីពឹង
តើយកអ្វីទៅវិញ បើព្រះពុទ្ធក៏លោកពឹងធម៌ដែរនោះ !

តើយើងពឹងធម៌ដូចម្ដេច ? សូមអញ្ជើញបើកទៅទំព័រខាងមុខ !

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល
ឲ្យវិលវល់អន្ទោល ក្នុងភពតូច និងភពធំ ។

ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតឧត្ដម
ព្រះពុទ្ធទ្រង់ស្រោវផ្ដុំ យកណែនាំដល់ជនា ។

ខ្ញុំសូមឱនប្រណម្យ ហត្ថបង្គំនមស្សការ
ព្រះធម៌វិសេសថ្លា ទុកជាការរលឹកហោង ។

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

# អ្វីទៅព្រះធម៌

អាចក្តីមានការលំបាកចិត្តជាខ្លាំង នៅពេលដែលសរសេរមកដល់វត្ថុត្រង់ព្រះធម៌ ព្រោះពាក្យថា ធម៌ នេះមានសេចក្តីទូលំទូលាយជ្រាលជ្រៅណាស់ ដែលសតិបញ្ញាជាបុថុជ្ជនដូចពួកយើង មិនអាចនឹងងាយយល់បាន ។ ដូច្នេះអាចក្តីសូមទោសទុកជាមុនក្រែងលោសរសេរអំពីព្រះធម៌នេះពុំបានគ្រប់ជ្រុងជ្រោយអស់សេចក្តី ។

ធម៌ ជាភាសាសំស្ក្រឹតសរសេរបែបខ្មែរ បើជាភាសាបាលីសរសេរថា ធម្ម អានថា ធាំមៈ ។ អស់លោកអ្នកប្រាជ្ញពុទ្ធសាសនាគ្រប់ជាតិទាំងអស់ក្នុងលោក គឺទាំងអាស៊ី និងអឺរ៉ុប បានព្យាយាមប្រែពាក្យ ធម្មៈ ឲ្យទៅជាភាសារបស់ខ្លួនដើម្បីងាយយល់ តែក៏ចាញ់ចំណោះ ព្រោះថាប្រែទៅៗ ក៏មិនចេះគ្រប់ជ្រុងជ្រោយរបស់ពាក្យថាធម៌នេះឡើយ ។ ក្នុងបាលី លោកបានឲ្យន័យរបស់ពាក្យធម៌ថាៈ ធារេតីតិ > ធម្មោ ប្រែថា សភាវៈទ្រទ្រង់។ ក្នុងវចនានុក្រមខ្មែរ ធម៌ ប្រែថាៈ សភាវៈទ្រទ្រង់សត្វលោក, បុណ្យ, បាប, សុចរិត, ទុច្ចរិត, ហេតុ, សភាព, ធម្មតា, ប្រក្រតី, ធម្មជាតិ, ប្រាជ្ញាញាណ, គុណ, សេចក្តីចំរើន, អារម្មណ៍ខាងផ្លូវចិត្ត, ការរិះគិត, សង្ខារ, កិរិយាមារយាទ, បរិយត្តិ, ច្បាប់ ។ល។

ភាសាអង់គ្លេសបានព្យាយាមប្រែពាក្យធម្មៈថា Nature, Phenomena, Thing, Law, System, Doctrine, Religion, Cause, Truth, Duty, Virtue, Moral, Quality, Righteouness, Ideal, Dictionary ជាដើម។

យើងឃើញថា សូម្បីពាក្យ Dictionary ដែលប្រែថាវចនានុក្រម ក៏ស្ថិតនៅក្នុងពាក្យថាធម៌ដែរ គឺមានន័យថា ឲ្យតែមានពាក្យហៅសំគាល់ គឺហៅថាធម៌ទាំងអស់ ។ ក្នុងសៀវភៅខ្លះទៀតបានប្រែធម៌ថា God, Middle Way, Holy Life, Freedom, Fitness, Harmony, Utmost Goodness, Void, Life of eternity, Peace ។ ជាសង្ខេប ធម៌ អាចស្គាល់ក្នុងន័យ ៣ យ៉ាងគឺ **អ្វីដែលល្អ** *(កុសលាធម្មា)* **អ្វីដែលអាក្រក់** *(អកុសលាធម្មា)* និងអ្វីដែលមិនអាចកំណត់បានថាល្អ ឬអាក្រក់ ជាអព្យាក្រឹតកណ្តាលៗ *(អព្យាកតាធម្មា)* ។

សមណមេធីមួយអង្គដ៏ល្បីល្បាញក្នុងប្រទេសថៃ ព្រះនាមពុទ្ធទាសឥន្ទបញ្ញោ-

www.budinst.gov.kh www.elibraryofcambodia.org

ភិក្ខុ បានឲ្យន័យទៅលើពាក្យថា ធម៌ នៅក្នុងបរិបទ ៤ យ៉ាង ថាៈ

១- ធម៌ នៅក្នុងន័យដែលស្មើនឹងពាក្យថា សភាវធម៌ គឺតួធម្មជាតិទាំងមូល ដែលប្រាកដនៅក្នុងលោកនេះ (Nature) ទាំងចាប់ប៉ះពាល់បានក្តី (រូបធម៌ = corporeality), ទាំងចាប់ប៉ះពាល់មិនបានក្តី (អរូបធម៌ = incorporeality) ដែលកើតឡើងព្រោះការផ្សំប្រុងតែងក្តី (សង្ខតធម៌ = conditioned things, compounded things) និងដោយមិនមានបច្ច័យប្រុងតែងក្តី (អសង្ខតធម៌ = the unconditioned) សុទ្ធតែហៅថាធម៌ទាំងអស់ ។

បើនិយាយជាន័យអក្សរសាស្ត្រ ធម្មៈអាចប្រែថា អ្វី ឬរបស់ គឺអ្វី ឬរបស់ដែលធ្វើឲ្យពាក្យដែលប្រកបជាមួយសំរេចប្រយោជន៍តាមនោះ ដូចជាៈ

- បើប្រកបជាមួយពាក្យថាវឌ្ឍនៈ គឺជាវឌ្ឍនធម៌ ដែលប្រែថា អ្វី ឬរបស់ ដែលសំដែងភាពច្រើនឡើងៗ ឬនាំឲ្យកើតច្រើនឡើងៗ ។
- បើប្រកបជាមួយមនុស្ស គឺជាមនុស្សធម៌ ដែលប្រែថា របស់សំរាប់មនុស្ស ឬរបស់ដែលនាំឲ្យមានលក្ខណៈជាមនុស្ស ។ល។

២- ធម៌ ក្នុងន័យដែលប្រែថា ច្បាប់ធម្មជាតិ (Law of Nature) ។ ធម្មជាតិ ឬអ្វីៗ គ្រប់យ៉ាងតែងមានច្បាប់ ឬលក្ខណៈប្រចាំខ្លួនរបស់វា ។ ច្បាប់ ឬលក្ខណៈនេះ ជាគ្រឿងទ្រទ្រង់របស់នោះឲ្យមានអត្ថិភាព ជាច្បាប់ដែលមានតាំងពីដើមមក និងត្រូវស្ថិតនៅជាមួយរបស់នោះជាអមតៈ ។ ឧទាហរណ៍ ធម្មជាតិគ្រប់យ៉ាងមានលក្ខណៈជា អនត្តា គឺមិនមានអ្វីជារបស់ខ្លួន និងមិនមែនជាខ្លួន ។ អ្វីដែលយើងហៅថារទេះមួយគ្រឿង តាមពិតគឺគ្រាន់តែជាសន្មតិប៉ុណ្ណោះ ព្រោះបើយើងលើកដៃចង្អុលថាត្រង់នេះ ត្រង់នោះជារទេះនោះ គឺមិនមានទេ មានតែប្រែក ទឹម ទ្រពង កូនគ្រែ ទូក កង់ កាំ ។ល។ តែប៉ុណ្ណោះ ។ លក្ខណៈដូចដែលបានរៀបរាប់ដោយខ្លីៗនេះ គឺជាធម៌ដែលស្ថិតនៅក្នុងន័យថា ច្បាប់របស់ធម្មជាតិ ។ ច្បាប់ធម្មជាតិដទៃទៀតដូចជាច្បាប់ទំនាញផែនដី, ច្បាប់ផែនដីវិលជុំវិញព្រះអាទិត្យ, ច្បាប់ទឹកពុះនៅសីតុណ្ហភាព ១០០ អង្សាសេ ជាដើមនេះ ក៏រាប់ថាជាធម៌ទាំងអស់ ។

៣- ធម៌ ក្នុងន័យដែលប្រែថា នាទីដែលត្រូវបដិបត្តិចំពោះធម្មជាតិទាំងពួង (Duty to Nature) ឬដែលបាលីហៅថា *បដិបត្តិធម៌* ។ ធម៌ត្រង់នេះ គឺជានាទីរបស់

www.budinst.gov.kh www.elibraryofcambodia.org

យើង ដែលត្រូវបដិបត្តិចំពោះអ្វីដែលយើងមានទំនាក់ទំនងជាមួយ ឲ្យសមទៅតាមនាទីរបស់យើង បន្ទាប់ពីយើងបានរៀនដឹងថា របស់គ្រប់យ៉ាងសុទ្ធតែជាធម្មៈ តាមន័យទី ១ និងមានច្បាប់ដ៏ច្បាស់លាស់ តាមន័យទី ២ ។

ដូច្នេះតើយើងត្រូវធ្វើយ៉ាងណា ដើម្បីកុំឲ្យខុសពីច្បាប់របស់វត្ថុនោះ? ឧៈ កែវ គឺជាធម្មៈ (ន័យទី ១) ។ កែវមានលក្ខណៈស្រួយឆាប់បែក (ស្រួយ គឺជាច្បាប់របស់កែវ ឬជាធម្មៈ របស់កែវក្នុងន័យទី ២) ។ ការដែលយើងត្រូវធ្វើដូចម្ដេចដើម្បីកុំឲ្យកែវឆាប់បែក ដូចជាត្រូវកាន់ថ្នមៗជាដើមនេះ ឈ្មោះថាយើងកំពុងមានធម៌ហើយ (នៅក្នុងន័យទី ៣ នៃពាក្យថាធម៌) ពោលគឺការបំពេញនាទី, ការប្រតិបត្តិនាទី ។ ធម៌ត្រង់នេះត្រូវទៅនឹងបច្ឆិមពុទ្ធវចនៈ ដែលព្រះអង្គបានត្រាស់មុននឹងចូលបរិនិព្វានថាៈ <យោ បន ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយបូជាយ បដិបត្តិបូជាយៈ <អ្នកឯណាមួយ ជាអ្នកប្រតិបត្តនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្ត ដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្ដីគោរព រាប់អាន បូជា ដល់ព្រះតថាគត ដោយបដិបត្តិបូជា ដែលជាបូជាដ៏ឧត្ដម > ។

៥- ធម៌ ដែលប្រែនៅក្នុងន័យថា ផលដែលកើតចេញអំពីការបដិបត្តិ (Result) ឬដែលភាសាបាលីហៅថា បដិវេធធម៌ ឬវិបាកធម៌ ។ ធម៌ក្នុងន័យនេះ គឺផលដែលកើតចេញពីការដែលយើងបានបំពេញនាទី ឬបដិបត្តិចំពោះធម្មជាតិទាំងពួង ។ បើជាការបដិបត្តិដែលត្រូវ ក៏នឹងបានទទួលផលជាសេចក្ដីស្ងប់សុខ ទាំងចំពោះខ្លួន និងសង្គម ។ តែបើបដិបត្តិខុស មិនត្រឹមត្រូវ មិនសមគួរទៅតាមច្បាប់ធម្មជាតិទេ ក៏នឹងបានទទួលផលជាទុក្ខ ទាំងចំពោះខ្លួន និងសង្គមដូចគ្នាដែរ ។ សុខ ទុក្ខ ស្ងប់ ជ្រួលច្របល់ ទាំងអស់នេះ គឺជា *ធម្មៈ* ដែលប្រែថា ផលរបស់ការបដិបត្តិ ។

Buddhism has done more for the advance of world civilization and true culture than any other influences in the chronicles of mankinds.

H.G. Wells, English Historian (1866 - 1946)

ពុទ្ធសាសនាបានធ្វើឲ្យមានការរីកចំរើននូវអារ្យធម៌លោក និងវប្បធម៌ដែលពិតៗ ជាងឥទ្ធិពលដទៃៗ ទៀត ដែលមាននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។

អេច្ឆ ជី វ៉ែល ប្រវត្តិវិទូអង់គ្លេស(១៨៦៦ - ១៩៤៦)

www.budinst.gov.kh www.elibraryofcambodia.org

# ធម៌ព្រះពុទ្ធ

ដូចអ្នកអានបានជ្រាបហើយថា បន្ទាប់ពីព្រះសិទ្ធត្ថបព្វជិតបានត្រាស់ជាព្រះសម្មាសម្ពុទ្ធហើយ ទ្រង់ក៏បានសំដែងប្រាប់នូវអ្វីដែលទ្រង់ត្រាស់ដឹងនោះដល់មនុស្សនិករទាំងឡាយ អស់រយៈពេល ៤៥ ឆ្នាំ ។ អ្វីដែលទ្រង់បានសំដែងប្រាប់ក្នុង ៤៥ ឆ្នាំនោះហើយ ដែលហៅថាធម៌ព្រះពុទ្ធ ឬបើឲ្យពិរោះស្តាប់បន្តិចក៏ហៅថា ពុទ្ធធម៌ ។

ធម្មៈដែលព្រះលោកបានសំដែងហើយនោះ បុរាណាចារ្យលោកបានចងក្រងទុកជាឯកសារ ដោយឲ្យឈ្មោះថា **បិដក** ។ បិដកនេះចែកចេញជា ៣ ផ្នែក ដោយផ្នែកទីមួយ និយាយអំពីរឿងវិន័យ ហៅថា*វិន័យបិដក*, ផ្នែកទីពីរ និយាយអំពីចំណេះដឹងនិងការប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ហៅថា*សុត្តន្តបិដក*, និងផ្នែកទីបី និយាយអំពីសភាវធម៌ជាន់ខ្ពស់ ហៅថា***អភិធម្មបិដក*** ។

## ព្រះត្រៃបិដក

ព្រះត្រៃបិដក ឬដែលហៅជាភាសាបាលីថា តិបិដកៈ, តិបិដកៈ នេះ ជាគម្ពីរខាងព្រះពុទ្ធសាសនាយើង ដែលបានអភិវឌ្ឍន៍ម្តងបន្តិចៗ ពីការទន្ទេញផ្ទាល់មាត់ ទៅជាចារឹកនៅលើស្លឹករឹត រួចហើយក៏បោះពុម្ពជាសៀវភៅ ដែលជាការនិយមរបស់សម័យសព្វថ្ងៃ ។ ឥឡូវនេះ ប្រទេសខ្លះ ដូចជាថៃជាដើម បានសំរេចជោគជ័យមួយជំហានទៀត ក្នុងការធ្វើព្រះត្រៃបិដកឲ្យទៅជាប្រព័ន្ធកុំព្យូទ័រ (Computer System) ។ ចំពោះប្រទេសខ្មែរយើង ព្រះត្រៃបិដកបានចាប់កំណើតឡើងលើសាស្ត្រាស្លឹករឹតជាយូរមកហើយ ដោយសរសេរជាអក្សរខ្មែរបុរាណ អានជាបាលី ។ លុះដល់ថ្ងៃ ៣ កើតខែបុស្ស ឆ្នាំមមី ទោស័ក ព.ស.២៤៧២ ត្រូវនឹងថ្ងៃទី ២ មករា ១៩៣០ ក្រុមជំនុំព្រះត្រៃបិដកនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត បានចាប់ផ្តើមផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវ និងប្រែពីភាសាបាលីមកជាភាសាខ្មែរ នៅក្នុងព្រះរាជបណ្ណាល័យកម្ពុជាក្រុងភ្នំពេញ ។ ការកសាងព្រះត្រៃបិដកនេះ នៅក្រោមព្រះរាជូបត្ថម្ភពីព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្សព្រះចៅក្រុងកម្ពុជាធិបតី ។ លុះដល់ឆ្នាំ ព.ស.២៤៧៤ គ.ស.១៩៣១ ព្រះត្រៃបិដក

www.budinst.gov.kh www.elibraryofcambodia.org

ជាសៀវភៅពុម្ពដំបូងបង្អស់ ក៏បានបោះពុម្ពស្រេចដោយជោគជ័យ និងល្អប្រសើរលើស គេ ព្រោះមានតែព្រះត្រៃបិដកខ្មែរទេ ដែលមានបាលី និងសម្រាយនៅជាមួយគ្នា។

អស់លោកជាអ្នកមានគុណក្នុងការធ្វើព្រះត្រៃបិដកខ្មែរនេះ បានកំណត់ឈ្មោះកិច្ចការនេះថាជា ឧត្តមសង្គីតិ ប្រែថាការលើកសង្គាយនាដ៏ប្រសើរបំផុត ព្រោះសង្គាយនា ជាចំណាំតៗមក មិនដែលមានធ្វើច្បាប់ដែលជាបាលីនិងសម្រាយនៅជាមួយគ្នាទេ ។ ព្រះត្រៃបិដកខ្មែរមានទាំងអស់ចំនួន ១១០ ក្បាល ចែកជាវិន័យបិដកមាន ១៣ ក្បាល គឺពីលេខ ១ ដល់លេខ ១៣; សុត្តន្តបិដកមាន ៦៤ ក្បាល គឺពីលេខ ១៤ ដល់លេខ ៧៧; អភិធម្មបិដក មាន ៣៣ ក្បាល គឺពីលេខ ៧៨ ដល់លេខ ១១០ ដោយគិតជាទំព័រទាំងអស់បាន ៣៦,៦៣០ ទំព័រភាសាបាលី និង ៣៦,៦៣០ ទំព័រជាភាសាខ្មែរ ។

តាមប្រវត្តិព្រះត្រៃបិដកដែលចារឹកជាតួអក្សរ និងជាភាសាបាលីលើកដំបូងបង្អស់នោះ ធ្វើនៅប្រទេសលង្កាក្នុងកំឡុងព.ស. ៥៣៣ (ខ្លះថា ៥៥០) ដោយចារនៅលើស្លឹករឹត ។ តែគំនិតនៅក្នុងការរៀបរៀងធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធឲ្យមានបែបផែនជាក្រុម ជាពួក ងាយស្រួលក្នុងការចងចាំ និងរក្សាទុកជាកេរ្តិ៍មរតកនោះ បានកើតតាំងពីសម័យព្រះទ្រង់គង់ព្រះជន្មានៅឡើយ ។ មានសេចក្តីនៅក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ បាសាទិកសូត្រថា ព្រះចុន្ទថេរៈដែលត្រូវជាប្អូនព្រះសារីបុត្រ បានឃើញនិគ្រន្ថនាដបុត្រ ដែលជាសាស្តាចារ្យនៃលទ្ធិមួយដ៏សំខាន់នាសម័យនោះ ចូលមរណភាព ។ ក្រោយមរណភាពនោះ សាវ័ករបស់និគ្រន្ថនាដបុត្រក៏បែកខ្ញែកគ្នាជាក្រុមពួក ទៅតាមការយល់ឃើញរបស់ខ្លួន ព្រោះអត់ពីអាចារ្យទៅហើយ ។ ព្រះចុន្ទថេរៈលោកខ្លាចក្រែងហេតុការណ៍បែបនេះកើតចំពោះព្រះពុទ្ធសាសនា ក៏បានចូលទៅទូលព្រះអានន្ទ ហើយក៏ទៅគាល់ព្រះសម្មាសម្ពុទ្ធ ។ ព្រះបរមគ្រូក៏បានណែនាំព្រះចុន្ទថេរៈ ឲ្យរួបរួមធម្មភាសិតរបស់ព្រះអង្គ ហើយធ្វើសង្គាយនា គឺចាត់របៀបទាំងអត្ថៈ និងព្យញ្ជនៈ ដើម្បីឲ្យព្រហ្មចរិយធម៌តាំងមាំតរៀងទៅ ។ ព្រះពុទ្ធដីកាត្រង់នេះ ឈ្មោះថាជាការចាប់ផ្តើមនៃកំណើតព្រះត្រៃបិដកនាបច្ចុប្បន្ន ។ នៅក្នុងសង្គីតិសូត្រនៃទីឃនិកាយបាដិកវគ្គ ក៏បានប្រាប់ពួនូវរឿងនិគ្រន្ថនាដបុត្រដូចគ្នា ហើយព្រះសារីបុត្របានណែនាំពួកភិក្ខុឲ្យរួបរួមចងក្រងធម្មវិន័យ ដោយសំដែងតួយ៉ាងក្នុងការចាត់ពួកធម៌ជាក្រុមៗ ជាពួកៗ តាំងពីពួក ១ ដល់ពួក ១០ ថាតើពួកទីមួយៗមានធម៌អ្វីខ្លះ ជាដើម ។ គំនិតបែបនេះ បានត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធអង្គលោករ៉ាប់រងថា ត្រឹមត្រូវល្អ ។

## ការសង្គាយនា ជាហេតុនាំឲ្យកើតព្រះត្រៃបិដក

សង្គាយនា ប្រែថាចងក្រង គឺការដែលព្រះសង្ឃប្រជុំគ្នាចងក្រង ចាត់របៀបរៀបជាក្រុម ពួក នូវពុទ្ធវចនៈរបស់ព្រះពុទ្ធអង្គដែលបានសម្ដែងក្នុងរយៈពេល ៤៥ ឆ្នាំ ។ លុះប្រជុំសម្រេចគ្នាថាយ៉ាងនេះៗហើយ ក៏នាំគ្នាទន្ទេញនូវពុទ្ធវចនៈនោះ ។ ក្នុងសម័យព្រះពុទ្ធអង្គ ការសង្គាយនាធ្វើឡើងដើម្បីឲ្យព្រះពុទ្ធសាសនាគង់វង្សមិនសាបសូន្យ ។ លុះចំណេរតៗមក ក៏មានការយល់ខុស ប្រព្រឹត្តខុស កើតឡើងក្នុងក្រុមសង្ឃ សង្ឃក៏នាំគ្នាសង្គាយនាទៀត ដោយក្រោយៗនេះ មានគោលដៅដើម្បីជម្រះធម៌វិន័យឲ្យបានត្រឹមត្រូវបរិសុទ្ធដូចដើមវិញ ។ ជួនកាលការពិនិត្យផ្ទៀងផ្ទាត់ធម៌វិន័យ ដើម្បីចារលើស្លឹករឹត ឬចារជាគម្ពីរឲ្យបានត្រឹមត្រូវ ច្បាស់លាស់ ងាយស្រួលក្នុងការថែរក្សានោះ ក៏ហៅថាសង្គាយនាដែរ ដូចជាសង្គាយនានៅប្រទេសលង្កានៅឆ្នាំព.ស. ៤៣៣ ដើម្បីកត់ត្រាព្រះត្រៃបិដកជាអក្សរនោះជាដើម ។ ដូច្នេះ សង្គាយនាគឺការចាត់ចែងរៀបចំចងក្រងធម៌វិន័យរបស់ព្រះពុទ្ធអង្គឲ្យមានរបៀបរៀបរយទៅជាព្រះត្រៃបិដកនេះឯង ។

## ព្រះត្រៃបិដកមានអ្វីខ្លះ

ព្រះត្រៃបិដកចែកជា វិន័យបិដក សុត្តន្តបិដក និងអភិធម្មបិដក ។ អត្ថកថា សមន្តបាសាទិកា ដែលអធិប្បាយព្រះវិន័យ និងនិពន្ធដោយព្រះពុទ្ធឃោសាចារ្យ បានអធិប្បាយពីព្រះត្រៃបិដក ទុកក្នុងបឋមកណ្ឌ មានសេចក្ដីថា ៖

*ន័យទី១* វិន័យបិដក ជាអាណាទេសនា គឺការសម្ដែងធម៌ក្នុងលក្ខណៈភាគច្រើនជាការបង្គាប់ ។

សុត្តន្តបិដក ជាវោហារទេសនា គឺការសម្ដែងធម៌ដោយសំនួនឲ្យសមទៅនឹងចរិត អធ្យាស្រ័យរបស់អ្នកស្ដាប់ ។

អភិធម្មបិដក ជាបរមត្ថទេសនា គឺការសម្ដែងធម៌ ដែលប៉ុនប៉ងចំពោះតែប្រយោជន៍ដ៏ខ្ពង់ខ្ពស់តែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

*ន័យទី២* វិន័យបិដក ជា យថាបរាធសាសនៈ គឺការប្រៀនប្រដៅទៅតាមកំហុស ឬទោសផ្សេងៗ ដែលគប្បីវៀរចាក ។

សុត្តន្តបិដក ជា យថានុលោមសាសនៈ គឺការប្រៀនប្រដៅដោយអនុលោមដល់ចរិតអធ្យាស្រ័យរបស់អ្នកស្តាប់ផ្សេងៗ ។

អភិធម្មបិដក ជាយថាធម្មសាសនៈ គឺការប្រៀនប្រដៅតាមសាច់ធម៌សុទ្ធៗ ។

*ន័យទី៣* វិន័យបិដក ជាសំវរាសំវរកថា គឺជាកថាដែលពោលដោយការសំរួម និងមិនសំរួម។

សុត្តន្តបិដក ជាទិដ្ឋិវិនិវេដ្ឋនកថា គឺកថាដែលប្រៀនប្រដៅឲ្យបន្ធូរបន្ថយនូវទិដ្ឋិ គឺការយល់ឃើញខុស ។

អភិធម្មបិដក ជា នាមរូបបរិច្ឆេទកថា គឺកថាដែលប្រៀនប្រដៅឲ្យកំណត់នាមរូប គឺរាងកាយ និងចិត្ត ។

*ន័យទី៤* វិន័យបិដក ជាអធិសីលសិក្ខា គឺបទសិក្សាដែលទាក់ទងនឹងសីលជាន់ខ្ពស់ ។

សុត្តន្តបិដក ជាអធិចិត្តសិក្ខា គឺបទសិក្សាដែលទាក់ទងនឹងសមាធិជាន់ខ្ពស់។

អភិធម្មបិដក ជា អធិបញ្ញាសិក្ខា គឺបទសិក្សាដែលទាក់ទងនឹងបញ្ញាជាន់ខ្ពស់។

*ន័យទី៥* វិន័យបិដក ជាវីតិក្កមបហាន គឺគ្រឿងលះកិលេសដែលគ្រោតគ្រាត ដែលជាហេតុឲ្យប្រព្រឹត្តល្មើសនឹងសីល ។

សុត្តន្តបិដក ជាបរិយុដ្ឋានបហាន គឺគ្រឿងលះកិលេសមធ្យមដែលរួតរឹតចិត្តបានដល់នីវរណធម៌ ដែលជាកិលេសបិទបាំងចិត្តមិនឲ្យមានសមាធិ ។

អភិធម្មបិដក ជាអនុសយបហាន គឺគ្រឿងលះកិលេសយ៉ាងល្អិត គឺកិលេសដែលដេកត្រាំក្នុងសន្តានចិត្ត ដូចតូលីដែលធ្លាក់នៅបាតក្អម បើមិនមានអ្វីរុក គួនទេ ក៏នឹងមិនកំរើកឡើយ ។

**ក-វិន័យបិដក** វិន័យបិដក គឺជាគម្ពីរដែលប្រមូលនូវវិន័យ សិក្ខាបទសំរាប់ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ដែលចែកចេញជា ៥ គម្ពីរ បោះពុម្ពជាសៀវភៅចំនួន ១៣ ក្បាល ឬ ៥,៤៣៥ ទំព័រ ។

www.budinst.gov.kh www.elibraryofcambodia.org

១-មហាវិភង្គ ឬភិក្ខុវិភង្គៈ និយាយពីសិក្ខាបទ ២២៧ ក្នុងបាដិមោក្ខផ្នែកភិក្ខុសង្ឃ (ចាប់ពី ភាគ១ ដល់ ភាគ៥)

២-ភិក្ខុនីវិភង្គ : និយាយពីសិក្ខាបទ៣១១ ក្នុងបាដិមោក្ខផ្នែកភិក្ខុនីសង្ឃ (ភ.៥)

៣-មហាវគ្គៈ និយាយពីពុទ្ធប្រវត្តិពីដំបូងៗ សិក្ខាបទក្រៅបាដិមោក្ខ និងពិធីកម្មខាងព្រះវិន័យ ។ មហាវគ្គនេះ ចែកចេញជាខន្ធកៈ (ក្រុម) ចំនួន ១០ខន្ធកៈ(ភ.៦-៨) គឺ៖

៣.១- មហាខន្ធកៈ = ក្រុមធំ
៣.២-ឧបោសថខន្ធកៈ = ក្រុមឧបោសថ
៣.៣-វស្សូបនាយិកាខន្ធកៈ = ក្រុមថ្ងៃចូលវស្សា
៣.៤-បវារណាខន្ធកៈ = ក្រុមបវារណា
៣.៥-ចម្មខន្ធកៈ = ក្រុមស្បែក
៣.៦-ភេសជ្ជខន្ធកៈ = ក្រុមភេសជ្ជៈ
៣.៧-កឋិនខន្ធកៈ = ក្រុមកឋិន
៣.៨-ចីវរខន្ធកៈ = ក្រុមចីវរ
៣.៩-ចម្បេយ្យខន្ធកៈ = ក្រុមហេតុការណ៍នៅរដ្ឋចំប៉ា
៣.១០-កោសម្ពិខន្ធកៈ = ក្រុមហេតុការណ៍នៅរដ្ឋកោសម្ពី

៤-ចុល្លវគ្គ : និយាយពីពិធីកម្មខាងព្រះវិន័យ ប្រវត្តិកំណើតនាងភិក្ខុនី និងប្រវត្តិការធ្វើសង្គាយនា ។ ចុល្លវគ្គ ចែកចេញជា ១២ខន្ធកៈ (ភ.៩-១១)

៤.១-កម្មខន្ធកៈ = ក្រុមសង្ឃកម្ម
៤.២-បរិវាសិកខន្ធកៈ = ក្រុមអ្នកនៅបរិវាស
៤.៣-សមុច្ចយា = ក្រុមការរួបរួម
៤.៤-សមថ = ក្រុមវិធីរំងាប់អធិករណ៍
៤.៥-ខុទ្ទកវត្ថុ = ក្រុមរឿងតូចតាច
៤.៦-សេនាសនៈ = ក្រុមកន្លែងស្នាក់អាស្រ័យ

www.budinst.gov.kh www.elibraryofcambodia.org

៥.៧-សង្ឃភេទ = ក្រុមសង្ឃបែកគ្នា

៥.៨-វត្តខន្ធកៈ = ក្រុមវត្ត ឬបដិបត្តិ

៥.៩-បាដិមោក្ខដ្ឋបនខន្ធកៈ = ក្រុមការឈប់សូត្របាដិមោក្ខ

៥.១០-ភិក្ខុនីខន្ធកៈ = ក្រុមនាងភិក្ខុនី

៥.១១-បញ្ចសតិក្ខន្ធកៈ = និយាយពីព្រះអរហន្ត ៥០០រូប ដែលធ្វើសង្គាយនាលើកទី ១

៥.១២-សត្តសតិក្ខន្ធកៈ = និយាយពីព្រះអរហន្ត៧០០រូបដែលធ្វើសង្គាយនាលើកទី ២

**៥-បរិវារ** : និយាយពីវត្តប្រតិបត្តិកំប៉ិកកំប៉ុក ការសួរ - ការឆ្លើយ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹងខាងព្រះវិន័យដែលមាននិយាយរួចហើយក្នុងភិក្ខុវិភង្គ និងភិក្ខុនីវិភង្គ មហាវគ្គ និងចុល្លវគ្គ ។ គម្ពីរបរិវារចែកចេញជាចំណុចសំខាន់ៗ ចំនួន ២១ ចំណុច (វារៈ) (ភ.១២-១៣)

៥.១-មហាវិភង្គសោឡសមហាវារៈ និយាយជាថ្មីម្តងទៀត ពីសិក្ខាបទ ២២៧ របស់ភិក្ខុ ដែលមានហើយក្នុងមហាវិភង្គ

៥.២-ភិក្ខុនីវិភង្គសោឡសមហាវារៈ និយាយជាថ្មីម្តងទៀត ពីសិក្ខាបទ ៣១១ របស់ភិក្ខុនី ដែលមានហើយក្នុង ភិក្ខុនីវិភង្គ

៥.៣-សមុដ្ឋានសីលសង្ខេបៈ ជាការរួបរួមសិក្ខាបទទាំងអស់មកនិយាយម្តងទៀត ពីរឿងសមុដ្ឋាន គឺ កាយ វាចា ចិត្ត ដោយចាត់ជាក្រុមពួក ថាពួកណាកើតពីសមុដ្ឋានណា

៥.៤-កតិបុច្ឆាវារៈ ជាការតាំងសំនួរថាតើរឿងនោះៗ មានប៉ុន្មាន ដូចជាថា តើអាបត្តិមានប៉ុន្មាន ជាដើម

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ៥.៥-វិសតិវារៈ | ជាការតាំងសំនួរ ហើយឆ្លើយរឿងដែលទាក់ទង នឹងអាបត្តិសមុដ្ឋាន អាបត្តិអធិករណ៍ វិធីរំងាប់អធិករណ៍ រួមជា ៣០ ចំណុច |
| ៥.៦-ខន្ធកបុច្ឆាវារៈ | ការសួររឿងដែលទាក់ទងនឹងខន្ធកៈទាំង ២២ ដែលមាននៅក្នុងមហាវគ្គ និងចុល្លវគ្គ ថាតើ ខន្ធកៈនិមួយៗ មាននិយាយពីអាបត្តិប៉ុន្មានប្រភេទ |
| ៥.៧-ឯកុត្តរិកវារៈ | ជាការបញ្ចាក់រឿងព្រះវិន័យដោយតួលេខ ថាតើ ពួក ១ មានអ្វីខ្លះ ពួក ២ មានអ្វីខ្លះ រហូតដល់ ពួក ១១ ដូចជា ឧបោសថមាន២ គឺ ១៥ រោជ និង ១៥ កើត ជាដើម |
| ៥.៨-ឧបោសថាទិបុច្ឆាវិសជ្ជនាវារៈ | ជាការសួរឆ្លើយរឿងឧបោសថ |
| ៥.៩-អត្ថវសេបករណវារៈ | និយាយពីការដែលព្រះមានព្រះភាគទ្រង់សំដែងពីវត្ថុបំណងក្នុងការបញ្ញត្តិវិន័យ១០ ប្រការ |
| ៥.១០-គាថសង្គណិកវារៈ | ប្រជុំគាថាឬពាក្យឆន្ទ សំដែងពីពាក្យសួរឆ្លើយរបស់សង្គីតិកាចារ្យ ដែលសង្គាយនារឿងវិន័យ |
| ៥.១១-អធិករណភេទវារៈ | ពោលពីប្រភេទនៃអធិករណ៍ |
| ៥.១២-អបរគាថាសង្គណិកវារៈ | ជំនុំគាថាទាក់ទងនឹងការប្ដឹងចោទ ការសួរឲ្យរលឹកជាដើម រួមទាំងលក្ខណៈដែល នឹងរាប់ថាជាអាលជ្ជី |
| ៥.១៣-ចោទនាកណ្ឌវារៈ | ពោលពីរបៀបចោទប្ដឹង ថាគួរនឹងធ្វើយ៉ាងណា |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ៥.១៤-ចូឡសង្គាមវារៈ | ពោលពីរបៀបបដិបត្តិរបស់ភិក្ខុជាប់ចោទ ថាតើគួរធ្វើយ៉ាងណា រួមទាំងរបៀបប្តឹង របៀបវិនិច្ឆ័យ |
| ៥.១៥-មហាសង្គាមវារៈ | ដូចចំណុច ៥.១៤ ដែរ គ្រាន់តែពិស្តារជាង |
| ៥.១៦-កឋិនភេទវារៈ | ពោលពីប្រភេទកឋិន និងរបៀបផ្សេងៗ នៃកឋិនកិច្ច |
| ៥.១៧-ឧបាលិបញ្ចកវារៈ | ពាលពីសំនួរក្រាបទូលសួររបស់ព្រះឧបាលិ និងចម្លើយរបស់ព្រះសម្មាសម្ពុទ្ធចំនួន ១៤ វគ្គ |
| ៥.១៨-សមុដ្ឋានវារៈ | ពោលពីសមុដ្ឋាននៃអាបត្តិ និងការចេញចាកអាបត្តិ |
| ៥.១៩-ទុតិយគាថាសង្គណិកវារៈ | ជំនុំគាថាទី ២ ឬសេចក្តីពិស្តាររបស់ចំណុច ៥.១០ និង ៥.១២ |
| ៥.២០-សេទមោចនគាថាវារៈ | គាថាបែកញើស ជាពាក្យនិពន្ធ សួរបញ្ហាដែលពិបាកៗតែមិនមានចម្លើយ (មានតែនៅក្នុងអដ្ឋកថា) ចំនួន ៥៣ សំនួរ |
| ៥.២១-បញ្ចវគ្គវារៈ | ពោលពីរឿងផ្សេងៗចំនួន ៥ ចំណុច |

## ខ-សុត្តន្តបិដក :

ជាគម្ពីរដែលប្រមូលផ្តុំ កត់ត្រានូវព្រះធម្មទេសនា ការអធិប្បាយធម៌ និងរឿងរ៉ាវផ្សេងៗ ដែលទាក់ទងទៅនឹងបុគ្គល ឬឱកាសនានា ។ សុត្តន្តបិដក ឬព្រះសូត្រ ចែកចេញជា ៥ និកាយ(ប្រជុំ ជំនុំ) បោះពុម្ពជាសៀវភៅចំនួន ៦៤ ក្បាល ឬ ២០,៦៧៩ ទំព័រ ។

www.budinst.gov.kh www.elibraryofcambodia.org

១-ទីឃនិកាយ :ប្រជុំសូត្រដែលមានខ្នាតវែង មានទាំងអស់ចំនួន ៣៤ សូត្រ ចែកចេញជា ៣ វគ្គ ៖

១.១-សីលខន្ធវគ្គ :សូត្ររបស់វគ្គនេះនិយាយពីរឿងសីល ទើបដាក់ឈ្មោះថាសីលខន្ធ វគ្គមានទាំងអស់ ១៣ សូត្រ (ភ.១៤-១៥)

១.២-មហាវគ្គ :វគ្គនេះមានទាំងអស់ ១០ សូត្រ ហើយដោយហេតុថាសូត្រដំបូងមានឈ្មោះថា មហាបទានសូត្រ ទើបវគ្គនេះឈ្មោះមហាវគ្គ (ភ.១៦-១៧)

១.៣-បាដិកវគ្គ :សូត្រដំបូងក្នុងវគ្គនេះ ឈ្មោះបាដិកសូត្រ ទើបវគ្គនេះឈ្មោះបាដិកសូត្រ មានទាំងអស់ ១១ សូត្រ (ភ.១៨-១៩)

**២-មជ្ឈិមនិកាយ:** ប្រជុំសូត្រដែលមានខ្នាតវែងជាមធ្យមចំនួន ១៥២ សូត្រ ចែកចេញជា ៣ បណ្ណាសកៈ ។ បណ្ណាសកៈប្រែថា ក្រុម ៥០ ព្រោះក្នុងមួយបណ្ណាសកៈមានសូត្រចំនួន ៥០ លើកលែងតែបណ្ណាសកៈទី ៣ ដែលមានចំនួន ៥២ ។

២.១-មូលបណ្ណាសកៈ ក្រុមសូត្រចំនួន ៥០ ឧបមាបីដូចជាឫសរុក្ខជាតិ (ភ.២០-២២)

២.២-មជ្ឈិមបណ្ណាសកៈ ក្រុមសូត្រចំនួន ៥០ ឧបមាបីដូចជាដើមរុក្ខជាតិ (ភ.២៣-២៥)

២.៣-ឧបរិបណ្ណាសកៈ ក្រុមសូត្រចំនួន ៥២ ឧបមាបីដូចជាចុងរុក្ខជាតិ (ភ.២៦-២៨)

នៅក្នុងបណ្ណាសកៈនីមួយៗ លោកបែងចែកទៅជាវគ្គទៀត ដោយមួយវគ្គៗមាន សូត្រចំនួន ១០ ដើម្បីឲ្យងាយចាំ ។

**៣-សំយុត្តនិកាយ** ជាគម្ពីរដែលប្រមូលនូវធម៌ ឬរឿងរ៉ាវជាពួកៗ ហៅថាសំយុត្ត៖ ឧទាហរណ៍ដូចជារឿងព្រះកស្សបៈ ក៏ហៅថាកស្សបសំយុត្ត, រឿងរ៉ាវដែលមាននៅក្នុងរដ្ឋកោ

www.budinst.gov.kh www.elibraryofcambodia.org

សល ក៏ហៅថាកោសលសំយុត្ត ។ គម្ពីរសំយុត្តនិកាយ មានទាំងអស់ចំនួន ៧,៧៦២ សូត្រ ឬ ៥៦ សំយុត្ត ។ សំយុត្តនេះចែកចេញជា ៥ វគ្គ :

៣.១-សគាថវគ្គ : មាន ១១ សំយុត្ត និងជាសូត្រដែលមានលក្ខណៈជាគាថា ឬជាបទកវី (ភ.២៩-៣១)

៣.២-និទានវគ្គ : មាន ១០ សំយុត្ត អធិប្បាយពីធម្មៈដែលជាហេតុបច្ច័យនៃការកើត ស្លាប់ ដែលហៅថា បដិច្ចសមុប្បាទ (ភ.៣១-៣២)

៣.៣-ខន្ធវារវគ្គ : មាន ១៣ សំយុត្ត និយាយអំពីភារៈរបស់ខន្ធ គឺកងរូប និងនាម (ភ.៣៣-៣៥)

៣.៤-សឡាយតនវគ្គៈ មាន ១០ សំយុត្ត និយាយពីរឿងអាយតនៈទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត (ភ.៣៥-៣៦)

៣.៥-មហាវគ្គ : មាន ១២ សំយុត្ត និយាយពីធម៌សំខាន់ៗ ដូចជា មគ្គ ពោជ្ឈង្គ ឥន្ទ្រិយ៍ ជាដើម (ភ.៣៧-៣៩)

**៤-អង្គុត្តរនិកាយ** គម្ពីរដែលមានព្រះសូត្រចាត់ជាពួកៗហៅថា និបាត តាមលំដាប់ចំនួនដូចជាធម្មៈពួក ១ , ធម្មៈពួក ២, ពួក ៣ ជាដើម ដោយក្នុងពួកនីមួយៗមានចំនួនគោលធម៌១, ឬ២, ឬ៣ ទៅតាមឈ្មោះពួក ។ គម្ពីរនេះមានទាំងអស់ចំនួន ១១ និបាត គិតាំងពីនិបាត ទី១ (ឯកនិបាត) ដល់និបាតទី ១១ (ឯកាទសនិបាត) រួមទាំងអស់ ៩,៥៥៧ សូត្រ (ភ.៥០-៥១)

**៥-ខុទ្ទកនិកាយ** ជាគម្ពីរប្រជុំនូវព្រះសូត្រ ធម៌ ពាក្យអធិប្បាយ និងរឿងរ៉ាវតូចតាចកំប៉ិកកំប៉ុក ដែលរួមទាំងភាសិតរបស់ព្រះសាវ័ក ប្រវត្តិផ្សេងៗ និងជាតកជាដើម ។ ខុទ្ទកនិកាយ មានទាំងអស់ ១៥ គម្ពីរ :

៥.១-ខុទ្ទកបាឋ :និយាយពីបទសូត្រតូចៗ (ភ.៥២)

៥.២-ធម្មបទ :ពោលពីសុភាសិតខ្លីៗប្រមាណ ៤២៣ គាថា (ភ.៥៣)

www.budinst.gov.kh www.elibraryofcambodia.org

៥.៣-ឧទាន :និយាយពីការឧទានបន្លឺវាចារបស់ព្រះពុទ្ធអង្គ ដែលទ្រង់ឧទានឡើង ដើម្បីប្រាប់នូវហេតុការណ៍នោះៗ ចំនួន ៨០ ឧទាន (ភ.៥៥)

៥.៤-ឥតិវុត្តក :និយាយពីពាក្យសម្ដីដែលអះអាងថា ជាភាសិតរបស់ព្រះដ៏មានព្រះភាគ ដែលទ្រង់បានសម្ដែង ចំនួន ១១២ សូត្រ (ភ.៥៣)

៥.៥-សុត្តនិបាត :ប្រជុំនូវព្រះសូត្រខ្នាតខ្លី ឬជាគាថាសុទ្ធផ្សេងៗ ចំនួន ៧១ សូត្រ (ភ.៥៥)

៥.៦-វិមានវត្ថុ :និយាយពីរឿងវិមានរបស់ពួកកើតជាទេវតា ចំនួន ៨៥ រឿង (ភ.៥៥)

៥.៧-បេតវត្ថុ :និយាយពីអ្នកដែលស្លាប់ទៅកើតជាប្រេត ចំនួន ៥១ រឿង (ភ.៥៦)

៥.៨-ថេរគាថា :ធម្មភាសិត ជាគតិដាស់តឿនចិត្តរបស់ព្រះថេរៈចំនួន ២៦៤ អង្គ (ភ.៥៦)

៥.៩-ថេរីគាថា :ធម្មភាសិត ជាគតិដាស់តឿនចិត្តរបស់ព្រះថេរីចំនួន ៧៣ អង្គ (ភ.៥៧)

៥.១០-ជាតក :ជារឿងនិទានដែលពោលពីការយោនយកកំណើតរបស់ព្រះពោធិសត្វ មានទាំងអស់ចំនួន ៥៤៧ រឿង (ភ.៥៨-៦៣)

៥.១១-និទ្ទេស :ជាការអធិប្បាយព្រះសូត្រ ៣២ សូត្រ ដែលមាននៅក្នុងសុត្តនិបាត ដោយព្រះសារីបុត្រ ។ និទ្ទេសនេះចែកជា ២ គឺមហានិទ្ទេស (ភ.៦៥-៦៦) និងចូឡនិទ្ទេស (ភ.៦៧-៦៨) ដោយនិទ្ទេសមួយៗ មាន ១៦ សូត្រ

៥.១២-បដិសម្ភិទា :ជាសេចក្ដីអធិប្បាយសព្វធម្មៈផ្សេងៗចំនួន ៣០ របស់ព្រះសារីបុត្រ យ៉ាងពិសេសពិស្ដារ (ភ.៦៩-៧១)

៥.១៣-អបទាន :និយាយពីការធ្វើអំពើល្អ អំពើអាក្រក់របស់ព្រះពុទ្ធ ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

បច្ចេកពុទ្ធ និងព្រះសាវ័កផ្សេងៗពីអតីតកាល មានទាំងអស់ ៥៥០ រឿង (ភ.៧២-៧៦)

៥.១៤-ពុទ្ធវង្ស :និយាយពីរឿងដែលទាក់ទងនឹងព្រះសម្ពុទ្ធ ២៥ អង្គ តាំងពីអតីត រហូតបច្ចុប្បន្ន និងរឿងការចែកព្រះសារីរិកធាតុព្រះគោតុមជាដើម (ភ.៧៧)

៥.១៥-ចរិយាបិដក :និយាយពីព្រះពុទ្ធចរិយា គឺការដែលព្រះអង្គបំពេញបារមីទាំង ១០ កាលពីអតីត មានទាំងអស់ ៣៥ រឿង (ភ.៧៧)

## គ-អភិធម្មបិដក

អភិធម្មបិដកជាគម្ពីរទីបីរបស់ពុទ្ធសាសនា ដែលនិយាយពីគោលធម៌សុទ្ធៗ មិនទាក់ទងដល់បុគ្គល ហេតុការណ៍ និងរឿងរ៉ាវផ្សេងៗឡើយ ជាវិជ្ជាសុទ្ធៗ មិនមាននិទាន ឬការសប្បាយលាយឡំទេ ។ អភិធម្មបិដកចែកជា ៧ គម្ពីរធំៗបោះពុម្ពជាសៀវភៅ ៣៣ ក្បាល ឬ ១០,៥១៤ ទំព័រ ។

១-ធម្មសង្គណី :ពោលពីការ រួមក្រុមធម៌ គឺការចាត់ឲ្យមានរបៀបនូវធម្មៈទាំងឡាយដែលរាយប៉ាយច្រើនកន្លែង ឲ្យមកនៅជាក្រុម ពួក មានឈ្មោះក្បាលធម៌ខ្លីៗ ឧបមាដូចជាការនាំគ្រឿងផ្សេងៗរបស់នាឡិកាមកបញ្ចូលគ្នា ឲ្យទៅជានាឡិកាទាំងគ្រឿងបាន ។ ធម្មសង្គណីបែងជា ៥ ក្រុមធំៗ (ភ.៧៨-៧៩)

១.១-មាតិកា :ឈ្មោះមេក្រុម ឬមេបទ ជាខ្លឹម ឬសារៈរបស់សង្គណីតែមាន សេចក្តីសង្ខេបទេ ។ មាតិកានេះមានពីរគឺអភិធម្មមាតិកា និងសុត្តន្តមាតិកា មានទាំងអស់ ១៦៥ មាតិកា ។

១.២-ចិត្តុប្បាទកណ្ឌ :គឺការអធិប្បាយពីរឿងចិត្ត ថាកើតឡើងយ៉ាងដូចម្តេច និងអធិប្បាយ ពីរឿងធម៌ដែលកើតឡើងជាមួយនឹងចិត្ត គឺចេតសិក

១.៣-រូបកណ្ឌ :គឺការអធិប្បាយអំពីរឿងរូប បានដល់មហាភូតរូប និងឧបាទាយរូប

១.៤-និក្ខេបកណ្ឌ :ជាការអធិប្បាយមាតិកាដែលមាននៅក្នុងចំណុច ទី១.១

www.budinst.gov.kh www.elibraryofcambodia.org

ដោយមិន ដែងពេក មិនខ្លីពេក

១.៥-អត្ថុទចារកណ្ឌៈការអធិប្បាយមាតិកា ដែលមាននៅក្នុងចំណុចទី ១.១ យ៉ាងសង្ខេប

២-វិភង្គ :គម្ពីរនេះនិយាយពីការចែក(វិភង្គ) គឺញែកក្រុមធម៌ផ្សេងៗឲ្យឃើញពិស្តារល្អិតល្អន់ ដូចជាខន្ធ ៥ អាយតនៈ ១២ បែងចែកឲ្យល្អិតថាតើមានអ្វីខ្លះ ។ វិភង្គញែកពួកធម៌ចេញជា ១៨ ក្រុម (១៨វិភង្គ) មានខន្ធវិភង្គោជាដើមរាទ៏ និងធម្មហទយវិភង្គោជាទីបញ្ចប់ (ភ.៨០-៨២)

៣-ធាតុកថា : និយាយពីរឿងធាតុ ពោលគឺនាំយកនូវមាតិកាក្នុងធម្មសង្គណី និងបទក្នុងវិភង្គ ចំនួន ១២៥ យ៉ាង ព្រមទាំងមេបទក្នុងធម្មសង្គណីមកសង្គ្រោះជាមួយធម៌ ៣ យ៉ាង គឺ ខន្ធ អាយតនៈ និងធាតុ ថាតើចូលគ្នាបាន ឬមិនបានយ៉ាងណា ។ ធាតុកថាមានទាំងអស់ចំនួន ១៤ មេ គឺតាំងពី សង្គហោ អសង្គហោ ដល់ វិប្បយុត្តេនសង្គហិតំអសង្គហិតំ ជាទីបញ្ចប់ (ភ.៨៣)

៤-បុគ្គលប្បញ្ញត្តិ : និយាយពីការបញ្ញត្តិបុគ្គល ដោយពោលដល់គុណធម៌ខ្ពស់ទាបរបស់បុគ្គល។ បុគ្គលប្បញ្ញត្តិ មានទាំងអស់ ៦ យ៉ាង គឺតាំងពីខន្ធបញ្ញត្តិ រហូតដល់បុគ្គលប្បញ្ញត្តិ (ភ.៨៣)

៥-កថាវត្ថុ : គឺជាគម្ពីរមួយដែលអត្ថកថាពោលថា ព្រះមានព្រះភាគទ្រង់បានសំដែងជាមេបទតែបន្តិចបន្តួចទេ ក្រៅពីនោះ ព្រះមោគ្គលីបុត្តតិស្សថេរៈបានរៀបរៀងឡើងក្នុងសង្គាយនាលើកទី ៣ ។ គម្ពីរនេះបញ្ចុះដោយពាក្យសួរ និងពាក្យឆ្លើយ ដើម្បីដោះស្រាយ និងដេញដើងចំពោះលទ្ធិដទៃ ក្រៅពីពុទ្ធសាសនា ឬដែលបែកចេញពីពុទ្ធសាសនា តែពុំមានលក្ខណៈត្រឹមត្រូវ។ កថាវត្ថុ មានពាក្យសួរឆ្លើយទាំងអស់ ២១៩ កថា (ភ.៨៥-៨៦)

៦-យមកៈ គឺគម្ពីរដែលពោលពីធម៌ដែលជាគូ មានទាំងអស់ ១០ គូ គឺតាំងពីមូលយមកៈ

www.budinst.gov.kh www.elibraryofcambodia.org

រហូតដល់ ឥន្ទ្រិយមកៈ (ភ.៨៧-៩៣)
៧-មហាបដ្ឋាន :គឺជាគម្ពីរដែលពោលពីទីតាំង គឺបច្ច័យ ២៤ ដោយសំដែងថាអ្វីជាបច្ច័យរបស់អ្វីផ្នែកខាងធម៌ មានចាប់តាំងអំពីហេតុបច្ច័យរហូតដល់អវិគតបច្ច័យ(ភ.៩៥-១១០)

## អដ្ឋកថា

ព្រះត្រៃបិដកជាគម្ពីរដើមដែលលំបាកនឹងអានឲ្យបានយល់ច្បាស់ណាស់ ដូច្នេះហើយទើបព្រះអាចារ្យជំនាន់ក្រោយបានព្យាយាមសរសេរ ពន្យល់ អធិប្បាយគម្ពីរទាំងអស់នៃព្រះត្រៃបិដកឲ្យងាយយល់ និងងាយស្តាប់ប្រយោជន៍ដល់ការសិក្សាឲ្យបានទូលំទូលាយ ។ ឈ្មោះគម្ពីរអដ្ឋកថាមានដូចខាងក្រោម ៖

១-ព្រះវិន័យ

| ព្រះត្រៃបិដក | អដ្ឋកថា |
|---|---|
| ឈ្មោះគម្ពីរ | ឈ្មោះគម្ពីរ |
| មហាវិភង្គ | វិនយអដ្ឋកថា(សមន្តបាសាទិកា) |
| ភិក្ខុនីវិភង្គ | វិនយអដ្ឋកថា(សមន្តបាសាទិកា) |
| មហាវគ្គ | វិនយអដ្ឋកថា(សមន្តបាសាទិកា) |
| ចុល្លវគ្គ | វិនយអដ្ឋកថា(សមន្តបាសាទិកា) |
| បរិវារ | វិនយអដ្ឋកថា(សមន្តបាសាទិកា) |

២-ព្រះសូត្រ

| | |
|---|---|
| ទីឃនិកាយ សីលក្ខន្ធវគ្គ | ទីឃនិកាយដ្ឋកថា(សុមង្គលវិលាសិនី) |
| ទីឃនិកាយ មហាវគ្គ | ទីឃនិកាយដ្ឋកថា(សុមង្គលវិលាសិនី) |
| ទីឃនិកាយ បាដិកវគ្គ | ទីឃនិកាយដ្ឋកថា(សុមង្គលវិលាសិនី) |
| មជ្ឈិមនិកាយ មូលបណ្ណាសកៈ | មជ្ឈិមនិកាយដ្ឋកថា(បបញ្ចសូទនី) |
| មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ | មជ្ឈិមនិកាយដ្ឋកថា(បបញ្ចសូទនី) |
| មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ | មជ្ឈិមនិកាយដ្ឋកថា(បបញ្ចសូទនី) |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| សំយុត្តនិកាយ សគាថវគ្គ | សំយុត្តនិកាយត្ថកថា(សារត្ថបកាសិនី) |
| សំយុត្តនិកាយ និទានវគ្គ | សំយុត្តនិកាយត្ថកថា(សារត្ថបកាសិនី) |
| សំយុត្តនិកាយ ខន្ធវារវគ្គ | សំយុត្តនិកាយត្ថកថា(សារត្ថបកាសិនី) |
| សំយុត្តនិកាយ សឡាយតនវគ្គ | សំយុត្តនិកាយត្ថកថា(សារត្ថបកាសិនី) |
| សំយុត្តនិកាយ មហាវារវគ្គ | សំយុត្តនិកាយត្ថកថា(សារត្ថបកាសិនី) |
| | |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| អង្គុត្តរនិកាយ | អង្គុត្តរនិកាយត្ថកថា(មនោរថបូរណី) |
| | |
| ខុទ្ទកនិកាយ | ខុទ្ទកនិកាយត្ថកថា ខុទ្ទកបាឋវណ្ណនា |
| ខុទ្ទកនិកាយ | (បរមត្ថជោតិកា) |
| ខុទ្ទកនិកាយ | ខុទ្ទកនិកាយត្ថកថា ខុទ្ទកបាឋវណ្ណនា |
| ខុទ្ទកនិកាយ | (បរមត្ថជោតិកា) |
| ខុទ្ទកនិកាយ | ខុទ្ទកនិកាយត្ថកថា ខុទ្ទកបាឋវណ្ណនា |
| | (បរមត្ថជោតិកា) |

៣-ព្រះអភិធម្ម

| | |
|---|---|
| ធម្មសង្គណី | អដ្ឋសាលិនី |
| វិភង្គ | សម្មោហវិនោទនី |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ធាតុកថា | បញ្ចបករណដ្ឋកថា |
| បុគ្គលបញ្ញត្តិ | បញ្ចបករណដ្ឋកថា |
| កថាវត្ថុ | បញ្ចបករណដ្ឋកថា |
| យមក | បញ្ចបករណដ្ឋកថា |
| បដ្ឋាន | បញ្ចបករណដ្ឋកថា |

គម្ពីរសំខាន់ៗដែលតែងដោយខ្មែរ

មិលិន្ទបញ្ហា

វិមុត្តិមគ្គ[13]

វិសុទ្ធិមគ្គ ១

អភិធម្មត្ថសង្គហៈ

"Alone of all the great world religions, Buddhism made its way without persecution, consorship or inquisition. In all these respects its record is enormously superior to other religion, which made its way among people addicted to militarism".

Aldous Huxley(1894 - 1963)

"ក្នុងចំណោមសាសនាដែលធំៗក្នុងពិភពលោក ពុទ្ធសាសនាជាសាសនាតែមួយគត់ ដែលបានដំណើរការដោយមិនមានការបៀតបៀន ការត្រួតត្រា និងការសាកសួរជីវិត(ដោយមានតុលាការដើរការដើម្បីរកកំហុស ឬត្រួតត្រាអ្នកណាដែលមិនព្រមជឿ)។ ចំពោះរឿងទាំងអស់នេះ ពុទ្ធសាសនាមានកំណត់ត្រាប្រវត្តិសាស្ត្រ លើសសាសនាដទៃៗទាំងអស់ ដោយហេតុថាសាសនាដទៃទៀត មានដំណើការដោយប្រជាជនដែលជាប់ជំពាក់ដោយរបបយោធានិយម" ។

លោក អាល់ដាស់ ហាក់លី ស្មេរជនជាតិអង់គ្លេស

13 វិមុត្តិមគ្គ និពន្ធឡើងដោយព្រះអរហន្តព្រះនាម ឧបតិស្សៈនៅលង្កា និងប្រែពីភាសាបាលីទៅជាចិន នៅស្រុកចិន ដោយព្រះសង្ឃខ្មែរព្រះនាម តិបិដកសង្ឃបាលៈ ក្នុងសម័យនគរភ្នំ តែបច្ចុប្បន្ននេះពុំមានជាភាសាខ្មែរទេ មានតែភាសាចិន និងអង់គ្លេស ។

www.budinst.gov.kh www.elibraryofcambodia.org

# ទ្រទ្រង់ទ្រាយពុទ្ធធម៌

នៅទំព័រមុន អ្នកអានបានឃើញហើយថា ធម៌ជាពាក្យសាកល ដែលមានន័យ ៤ ប្រការធំៗ គឺអ្វីទាំងឡាយទាំងពួងដែលជាធម្មជាតិ, ច្បាប់របស់ធម្មជាតិ, នាទីដែលត្រូវបដិបត្តិចំពោះធម្មជាតិ, និងផលដែលកើតចេញពីការបដិបត្តិចំពោះធម្មជាតិ ។ រួចហើយអ្នកអានបានស្គាល់នូវអ្វីដែលហៅថាធម៌ព្រះពុទ្ធ ដែលព្រះសង្ឃថេរៈទាំងឡាយពីអតីតបានចារឹកចងក្រងទុកជាគម្ពីរព្រះត្រៃបិដកឲ្យយើងសិក្សានាបច្ចុប្បន្ននេះ។ ឥឡូវនេះយើងងាកមកមើលពុទ្ធធម៌ម្តងទៀត ថាតើមានលក្ខណៈសម្គាល់យ៉ាងណាខ្លះ ។

ពុទ្ធធម៌មានលក្ខណៈគួរឲ្យកត់សំគាល់បាន ២ ប្រការ គឺសាធារណលក្ខណៈ (general characteristic) និងបច្ចក្ខករណីយលក្ខណៈ (practical characteristic) ៖

## ១- សាធារណលក្ខណៈ (general characteristics)

ចាប់តាំងពីសំដែងធម៌លើកដំបូងបង្អស់ រហូតដល់ថ្ងៃចុងក្រោយនៃព្រះជន្មាយុ និងបន្តមកដល់សព្វថ្ងៃ ពុទ្ធសាសនាមានអាយុកាល ២៥៤៥ ឆ្នាំហើយ ។ ការដែលអាចស្ថិតស្ថេរនៅដ៏យូរអង្វែងបានដូច្នេះ ក៏ព្រោះពុទ្ធធម៌មានគុណលក្ខណៈ ៦ យ៉ាងដែលពុំមានសាសនាណាដូចឡើយ ។ គុណទាំង ៦ ប្រការនោះគឺ :[14]

១.១-ជាសច្ចធម៌ ដែលសំដែងឡើងដោយបុគ្គលដែលបានត្រាស់ដឹង ពុំមានកិលេសក្នុងចិត្ត មានហេតុផល មានប្រយោជន៍ ជាគោលការណ៍សំរាប់គ្រប់គ្រងជីវិតដ៏ប្រសើរបរិសុទ្ធ បរិបូណ៌គ្រប់គ្រាន់ទាំងអស់ សំរាប់ជីវិតបច្ចុប្បន្ន និងជីវិតអនាគត (ស្វាក្ខាតោ ភគវតា ធម្មោ) ។ ជាឧទាហរណ៍ ព្រះពុទ្ធលោកសំដែងថាជីវិតនេះមានបញ្ហា មានទុក្ខ, ទុក្ខនេះកើតឡើងព្រោះមានហេតុ, តែជីវិតនេះក៏អាចផុតពីសេចក្តីទុក្ខបានដែរ បើយើងអាចកំចាត់ហេតុរបស់វាបាន ។ ហេតុ នេះ អាចកំចាត់បាន បើយើងដើរតាមអរិយមគ្គទាំង ៨ របស់ព្រះអង្គ ។ មានមនុស្សរាប់លានទាក់បានយកសច្ចធម៌នេះទៅបដិបត្តិតាម

---

[14] យកតាមន័យលក្ខណៈរបស់ធម្មគុណ (ស្វាក្ខាតោ......)

www.budhist.gov.kh www.elibraryofcambodia.org

ក៏បានរួចផុតទុក្ខមែន ដែលជាការបង្ហាញថា ធម៌នេះមានលក្ខណៈពិត មិនក្លែងក្លាយទេ; ជីវិតមនុស្សយើងមានការប្រែប្រួល (អនិច្ចំ) ធន់នៅបានដោយលំបាក (ទុក្ខំ) និងមិនមែនជារបស់ខ្លួន (អនត្តា) ជាសច្ចធម៌ដែលមិនអាចប្រកែកបាន ហើយដែលយើងជួបប្រទះនៅក្នុងជីវិតរាល់ថ្ងៃ ។

១.២- បដិបត្តិ ឬអនុវត្តដោយខ្លួនឯង គឺពុទ្ធធម៌ទាមទារឲ្យមនុស្សធ្វើ គឺអ្នកណាធ្វើអ្នកនោះបាន មិនបាច់អង្វរករ បន់ស្រន់ បួងសួងទេ គឺត្រូវពឹងពាក់លើខ្លួនឯង និងទទួលខុសត្រូវដោយខ្លួនឯង (សន្ទិដ្ឋិកោ)។ ជាឧទាហរណ៍ សេចក្តីសុខក្តី និព្វានក្តី កើតមានព្រោះយើងស្វែងរកដោយខ្លួនឯង មិនអាចអ្នកដទៃរកឲ្យបានទេ ។ បើឃ្លានត្រូវញ៉ាំដោយខ្លួនឯង មិនអាចឲ្យគេញ៉ាំជំនួស ហើយយើងឆ្អែតនោះទេ ។

១.៣-មិនកំណត់ដោយកាលទេ គឺបើពិតយ៉ាងណាពីអតីត បច្ចុប្បន្ន និងអនាគត ក៏នឹងនៅតែពិតយ៉ាងនោះរហូត ។ម្យ៉ាងទៀត ការបដិបត្តិធម៌មិនកំណត់ដោយកាលទេ គឺបើបច្ច័យ (Factor) គ្រប់គ្រាន់ពេលណា លទ្ធផលក៏នឹងកើតនៅពេលនោះ មិនមែនបានសេចក្តីថា ពុទ្ធធម៌អាចបដិបត្តិបានតែជំនាន់ព្រះពុទ្ធអង្គគង់មានព្រះជន្មនោះទេ (អកាលិកោ) ។

១.៤-ធម៌ណាដែលអាចពិសោធបាន នោះគឺជាពុទ្ធធម៌ ។ ពុទ្ធធម៌បោយដៃឲ្យជនគ្រប់រូប ចូលមកធ្វើពិសោធបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់ ដោយមិនមានការព្រួយបារម្ភ ព្រោះជារបស់ពិតមិនក្លែងក្លាយ ។ អ្នកដែលចង់ឃើញនរកសួគ៌ និព្វាន អាចចូលមកពិសោធបាន ថាតើរបស់នោះមានពិត ឬពុំពិត (ឯហិបស្សិកោ) ។

១.៥-គួរនាំយកមកទុកក្នុងខ្លួន គឺជនណាដែលបាននាំយកពុទ្ធធម៌មកដាក់ក្នុងចិត្ត ហើយបដិបត្តិ អ្នកនោះនឹងបានសំរេចគោលដៅជីវិតរបស់ខ្លួនបាន ទាំងនាបច្ចុប្បន្ន និងអនាគត ទាំងសុខនាលោកនេះ និងបរមសុខគឺព្រះនិព្វាន (ឱបនយិកោ) ។

www.budinst.gov.kh www.elibraryofcambodia.org

១.៦-បញ្ញាជនដឹងបានតែចំពោះខ្លួនឯង គឺធ្វើឲ្យគ្នាមិនបានទេ ហើយយកពីគ្នាក៏មិនបានដែរ (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ) ។

ក្នុងគម្ពីរអង្គុត្តរនិកាយ សត្តកនិបាត ព្រះពុទ្ធអង្គទ្រង់បានសំដែងចំពោះព្រះឧបាលិ ដែលជានិតិបណ្ឌិតជំនាញក្នុងវិន័យរបស់ព្រះអង្គ នូវលក្ខណៈ ៧ ប្រការ[15] សម្រាប់សំគាល់ថាជាធម៌វិន័យរបស់ព្រះអង្គ គឺធម៌ទាំងឡាយណាដែលប្រព្រឹត្តទៅ ៖

១-ដើម្បីការនឿយណាយ មិនវង្វេងទៅក្នុងកិលេស តណ្ហា (ឯកន្តនិព្វិទា)

២-ដើម្បីឲ្យការត្រេកត្រអាលរសាយបាត់ទៅ ដើម្បីឥស្សរភាព (វិរាគ)

៣-ដើម្បីធ្វើឲ្យកិលេសរលត់ ដើម្បីឲ្យអស់ទៅនូវសេចក្តីទុក្ខ (និរោធៈ)

៤-ដើម្បីសេចក្តីស្ងប់ សន្តិភាព និងការមិនច្រួលច្របល់ (ឧបសមៈ)

៥-ដើម្បីការដឹងច្បាស់ ដើម្បីអភិញ្ញា (អភិញ្ញា)

៦-ដើម្បីការត្រាស់ដឹងនូវអរិយសច្ចធម៌ (សម្ពោធៈ)

៧-ដើម្បីនិព្វាន (និព្វាន)

ទាំង ៧ នេះ គប្បីដឹង និងសម្គាល់ថាជាធម៌ ជាវិន័យ ជា*សត្ថុសាសន៍* គឺពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។

ក្នុងឱកាសដែលទ្រង់សម្តែងធម៌ដល់ព្រះនាងមហាបជាគោតមី ព្រះអង្គបានលើកពីលក្ខណៈដែលសំគាល់ថាជាធម៌ជាវិន័យ ជាសត្ថុសាសន៍ ចំនួន ៨ ប្រការ[16] ថា គឺធម៌ទាំងឡាយណាដែលប្រព្រឹត្តទៅ ៖

១-ដើម្បីឥស្សរភាព បំបាត់នូវការត្រេកត្រអាល បន្ថយនូវការប្រកាន់ខ្ជាប់ (វិរាគៈ)

២-ដើម្បីបណ្តាច់នូវចំណងកិលេស ឬចំណងដែលនាំឲ្យកើតទុក្ខ (វិសំយោគ)

៣-ដើម្បីមិនបន្ថែមនូវកិលេសឲ្យរីតតែច្រើនឡើង (អបចយៈ)

---

[15] សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត

[16] សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត

www.budinst.gov.kh www.elibraryofcambodia.org

៤-ដើម្បីការប្រាថ្នាតិច មិនប្រាថ្នាច្រើន បន្ថយនូវមហិច្ឆិតា (អប្បិច្ឆតា)
៥-ដើម្បីសេចក្តីសន្តោស ពេញចិត្តតែនឹងរបស់ដែលខ្លួនមាន (សន្តុដ្ឋិ)
៦-ដើម្បីសេចក្តីស្ងប់ស្ងាត់ មិនមែនដើម្បីការច្របូកច្របល់ (បវិវេកៈ)
៧-ដើម្បីប្រកបសេចក្តីព្យាយាម មិនមែនដើម្បីខ្ជិល (វីរិយារម្ភៈ)
៨-ដើម្បីការចិញ្ចឹមជីវិតដោយងាយៗ មិនមែនពិបាកចិញ្ចឹម (សុភរតា)

## ២- បច្ចក្ខករណីយលក្ខណៈ (Practical Characteristics)

បច្ចក្ខករណីយលក្ខណៈ គឺជាលក្ខណៈដែលអាចយកទៅអនុវត្តបាន ពោលគឺពុទ្ធធម៌មិនត្រឹមតែជាទ្រឹស្តី ឬទស្សនៈនោះទេ តែគឺជាធម៌មួយដែលទាមទារ ការរៀនឲ្យបានដិតដល់ (បរិយត្ត) ការយកទៅបដិបត្តិឲ្យដល់កម្រិត (បដិបត្តិ) និងទទួលនូវលទ្ធផលដែលសមគួរទៅនឹងការបដិបត្តិ (បដិវេធ) ។ កត្តាទាំង ៣ ប្រការនេះ មានសេចក្តីអធិប្បាយដូចតទៅ ៖

### ២.១-បរិយត្ត

បានដល់ការសិក្សារៀនសូត្រនូវព្រះត្រៃបិដកដែលជាពុទ្ធវចនៈ ឲ្យបានយល់ដឹងច្បាស់ និងដោយមិនមានសល់សង្ស័យ ។ ការរៀនព្រះត្រៃបិដកបានដល់ការរៀន ៖
ក-រៀនវិន័យ ច្បាប់ ឧបង្គាប់ ខអនុញ្ញាត ខហាមប្រាម ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ញត្តិ និងអនុញ្ញាតដល់ភិក្ខុសង្ឃ ភិក្ខុនីសង្ឃ សាមណេរ សាមណេរី ឧបាសក និងឧបាសិកា ។ ក្នុងនោះ បានដល់វិន័យដែលមាន ២២៧ សិក្ខាបទ (មាត្រា) សំរាប់ឲ្យភិក្ខុសង្ឃគោរព, ៣១១ សិក្ខាបទ សំរាប់ឲ្យភិក្ខុនីគោរព, ១០ សិក្ខាបទ សំរាប់សាមណេរសាមណេរីគោរព, ៨ សិក្ខាបទ សំរាប់ឧបាសក-សិកាថ្នាក់ខ្ពស់, និង ៥ សិក្ខាបទ សំរាប់ឧបាសក-សិកា និងប្រជារាស្ត្រទូទៅអនុវត្ត ។

វិន័យនេះ គឺជាមេច្បាប់ក្នុងពុទ្ធសាសនា មានឧបមាដូចជាច្បាប់ប្រទេសនិមួយៗ ដែលមានឡើងសំរាប់ឲ្យប្រជារាស្ត្រគោរពអនុវត្តតាម ដើម្បីសេចក្តីសុខរបស់សង្គមសង្ឃ ។ ការដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តិវិន័យឲ្យរៀននេះ ព្រោះទ្រង់ឃើញ

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោជន៍ ១០ យ៉ាង ៖[17]

១-ដើម្បីរបៀបរៀបរយល្អរបស់សង្ឃ (សង្ឃសុដ្ឋុតាយ)

២-ដើម្បីសេចក្តីសុខស្រួលរបស់សង្ឃ (សង្ឃផាសុតាយ)

៣-ដើម្បីគាបសង្កត់បុគ្គលដែលប្រព្រឹត្តមិនគប្បី ថោកទាប ពិបាកប្រដៅ (ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ)

៤-ដើម្បីឲ្យជនអ្នកប្រព្រឹត្តល្អ មានសេចក្តីសុខ (បេសលានំ ភិក្ខូនំ ផាសុវិហារាយ)

៥-ដើម្បីរវាំង ប្រយ័ត្ន កុំឲ្យផ្លូវនៃសេចក្តីវិនាស សេចក្តីទុក្ខ ការក្តៅក្រហាយ ដែលប្រុង នឹងកើតមាននាបច្ចុប្បន្ន បានកើតឡើង (ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ)

៦-ដើម្បីការពារមិនឲ្យសេចក្តីវិនាស សេចក្តីទុក្ខ ការក្តៅក្រហាយ ដែលនឹងកើតមាន ឡើងនាអនាគត កើតឡើងបាន (សម្បរាយិកានំ អាសវានំ បដិឃាតាយ)

៧-ដើម្បីធ្វើឲ្យអ្នកដែលពុំទាន់ជ្រះថ្លា កើតជ្រះថ្លាឡើង (អប្បសន្នានំ បសាទាយ)

៨-ដើម្បីឲ្យអ្នកដែលជ្រះថ្លាហើយ កាន់តែជ្រះថ្លាឡើងថែមទៀត (បសន្នានំ ភិយ្យោ ភាវាយ)

៩-ដើម្បីឲ្យព្រះសទ្ធម្មស្ថិតនៅយូរអង្វែង (សទ្ធម្មដ្ឋិតិយា)

១០-ដើម្បីអនុគ្រោះដល់វិន័យ គឺការលើកទឹកចិត្តឲ្យមានបទបញ្ញត្តិ សំរាប់ឲ្យសង្គមមាន របៀបកាន់តែប្រសើរឡើង (វិនិយានុគ្គហាយ)

ខ-រៀនព្រះសូត្រ

ការសិក្សាព្រះសូត្រ គឺការសិក្សាឲ្យយល់ដឹងនូវអ្វីដែលជាការត្រាស់ដឹងរបស់ព្រះពុទ្ធ និងឲ្យយល់ច្បាស់ថាអ្វីដែលព្រះអង្គត្រាស់ដឹងនោះ មានអត្ថន័យយ៉ាងណាខ្លះ ។ គឺជាការសិក្សាពីជីវិតរបស់មនុស្សនេះឯង ដោយព្យាយាមឆ្លើយឲ្យរួចនឹងសំនួរថា ៖

---

17 សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត

www.budhist.gov.kh www.elibraryofcambodia.org

| សំនួរ | ចម្លើយ |
|---|---|
| ជីវិត គឺអ្វី ? | ខន្ធ ៥, អាយតនៈ ៦ |
| ជីវិតមានលក្ខណៈដូចម្តេច ? | ត្រៃលក្ខណ៍ |
| ជីវិតមានដំណើរដូចម្តេច ? | បដិច្ចសមុប្បាទ, កម្ម, ឥទប្បច្ចយតា |
| ជីវិតគួរឲ្យមានលក្ខណៈដូចម្តេច ? | វិជ្ជា, វិមុត្ត, វិសុទ្ធិ, សន្តិ, និព្វាន |
| តើគួររស់នៅក្នុងជីវិតដូចម្តេច ? | មជ្ឈិមាបដិបទា, អដ្ឋង្គិកមគ្គ |

ក្រៅពីនោះ បានដល់ការរៀនអំពីគោលធម៌ផ្សេងៗដែលជាវិធីជីវិតសំរាប់នាំឆ្ពោះទៅរកជីវិតដែលពោរពេញទៅដោយសេចក្តីសុខ និងឥស្សរភាព ។

ការសិក្សាព្រះសូត្រ ជាការសិក្សានូវមុខវិជ្ជាដែលមានខ្វែងដ៏ច្រើន ទាក់ទងទៅនឹងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ចិត្តសាស្ត្រ ចរិយាសាស្ត្រ សិក្សាសាស្ត្រ អក្សរសាស្ត្រ ការគ្រប់គ្រង សេដ្ឋសាស្ត្រ សាសនសាស្ត្រ ចក្រវាឡសាស្ត្រ ទស្សនវិជ្ជា សង្គមសាស្ត្រ យោធាសាស្ត្រ ពាណិជ្ជសាស្ត្រ និតិសាស្ត្រ សមាធិសាស្ត្រ ។ល។ គឺគេឃើញមាននូវចំណេះដ៏ទូលំទូលាយសំរាប់សិក្សាឲ្យបានចេះដឹង ជាជំនួយសំរាប់ជីវិត នៅក្នុងព្រះសូត្រនានា ។

## គ-រៀនព្រះអភិធម្ម

ជាការសិក្សាមុខវិជ្ជាដែលទាក់ទងទៅនឹងផ្លូវចិត្តសុទ្ធៗ មិនជំពាក់ដោយហេតុការណ៍ ឬបុគ្គលឡើយ ។ ការសិក្សាព្រះអភិធម្ម គឺជាការសិក្សាវែកញែកដោយល្អិតល្អន់ជាទីបំផុតអំពីវិធីកម្មនៃការធ្វើការងាររបស់ចិត្ត ។

ការសិក្សារៀនសូត្រនេះ ជាកូនសោរដំបូងបំផុតសំរាប់យល់អំពីអ្វីដែលហៅថាពុទ្ធសាសនា និងគុណប្រយោជន៍ដែលកើតចេញពីការយកពុទ្ធធម៌ធ្វើជាផ្លូវជីវិត របស់អ្នករៀន ។ ការរៀននេះ យ៉ាងហោចណាស់ក៏មានប្រយោជន៍ ៤ យ៉ាងដែរ គឺ :

១-ជាគ្រឿងជម្រុញទឹកចិត្តឲ្យស្ទុះទៅរកការបដិបត្តិតាមពុទ្ធធម៌

២-ជាពន្លឺសំរាប់ឲ្យអ្នករៀនអាចធ្វើការសំរេចចិត្តថា តើពុទ្ធធម៌ល្អ ឬមិនល្អ គួរយកមកបដិបត្តិ ឬគួរលះបង់ ព្រោះបើមិនរៀនសិនទេ យើងមិនអាច

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើសុភវិនិច្ឆ័យបានឡើយ ។

៣-ដើម្បីជ្រើសរើសរវាងការបដិបត្តិព្រាវៗ ឬស្មានៗ ព្រោះថាបើមិនបានរៀនទេ យើងមិនអាចដឹងថា យើងបដិបត្តិបានត្រឹមត្រូវឡើយ ដូចជាមនុស្សដែលវង្វេងគ្មានផែនទី និងត្រីវិស័យសំរាប់នាំផ្លូវដែរ ។

៤-ដើម្បីបន្តពុទ្ធសាសនា ដែលជាមត៌កពិភពលោកនេះ ឲ្យស្ថិតស្ថេរគង់វង្សតរៀងទៅ សំរាប់អ្នកដែលត្រូវការជំនាន់ក្រោយ ។

២.២-បដិបត្តិ

បានដល់ការបដិបត្តិ ការអនុវត្តតាមការប្រៀនប្រដៅ ការណែនាំ ការពន្យល់របស់ព្រះសម្មាសម្ពុទ្ធ ដែលមាននៅក្នុងព្រះត្រៃបិដក។ ការបដិបត្តិធម៌ ជាកិច្ចមួយដ៏សំខាន់បំផុតនៅក្នុងពុទ្ធសាសនា រហូតដល់ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា អ្នកណាដែលចង់គោរពបូជាព្រះអង្គ ចូរនាំគ្នាបដិបត្តិធម៌ចុះ ។

*បដិបត្តិធម៌ គឺការបំពេញនាទីជាមនុស្ស*

នៅក្នុងនិយមន័យរបស់ពាក្យថាធម៌ត្រង់ចំណុចទី ៣ ធម៌បានដល់ នាទីដែលត្រូវបដិបត្តិ ចំពោះច្បាប់ធម្មជាតិទាំងឡាយដែលនៅជុំវិញខ្លួនយើង ឬដែលយើងត្រូវមានទំនាក់ទំនងជាមួយ ។ ចាប់ផ្តើមតាំងពីនាទីដែលត្រូវបដិបត្តិចំពោះរូបរាងកាយ ចិត្តរបស់យើងផ្ទាល់ ចំពោះបុគ្គលដែលយើងមានទំនាក់ទំនងជាមួយ ចំពោះសង្គមដែលយើងរស់នៅ ចំពោះបរិដ្ឋានជាដើម។ល។ ព្រោះការបានបំពេញនាទីដ៏ត្រឹមត្រូវចំពោះវត្ថុទាំងនេះ នឹងធ្វើឲ្យយើងមានភាពស៊ីសង្វាក់គ្នា សុខដុមរមនាជាមួយវត្ថុទាំងនោះ ដែលយើងហៅថា បានទូវសេចក្តីសុខ ។ តែបើបដិបត្តិពុំបានត្រឹមត្រូវវិញទេនោះ ការប្រឆាំងការមិនត្រូវគ្នា មិនស៊ីសង្វាក់គ្នា អមិត្ត នឹងកើតឡើង ហើយលទ្ធផលដែលយើងបានទទួល ហៅថា សេចក្តីទុក្ខ ។

ពុទ្ធធម៌បង្ហាញនូវនាទី ដែលអាចនាំមកនូវសេចក្តីសុខ ដល់បុគ្គលអ្នកបានបដិបត្តិ បីដូចជាគ្រោះដែលរក្សាជនទាំងនោះឲ្យផុតពីមហន្តរាយ ដូច ពុទ្ធភាសិតសំដែងថា **ធម្មោ ហ វេ រក្ខតិ ធម្មចារី** ធម៌តែងរក្សាអ្នកប្រព្រឹត្តធម៌ ឲ្យបានសេចក្តីសុខ ។

www.budinst.gov.kh www.elibraryofcambodia.org

*បដិបត្តិ គឺការសិក្សា*

ពិតមែនហើយដែលពាក្យបដិបត្តិមានន័យថា ធ្វើ តែជា ការរៀនធ្វើ (សិក្ខា)។ ក្រៅពីរៀនយកចំណេះដឹង រៀនយកវិជ្ជាហើយ ពុទ្ធសាសនាបង្ហាញយើងឲ្យរៀនធ្វើ រៀនបដិបត្តិម្តងបន្តិចៗ រហូតដល់ចេះធ្វើ ចេះអនុវត្ត ចេះបដិបត្តិបានដោយប្រពៃ ។ ក្នុងនេះលោកបានណែនាំឲ្យពុទ្ធបរិស័ទរៀនធ្វើ រៀនបដិបត្តិ លើចំណុច ៣ ប្រការ គឺ ៖

១-រៀនរក្សាព្រឹត្តិកម្ម របស់ខ្លួនទាំងខាងផ្លូវកាយ និងផ្លូវវាចា ឲ្យមានប្រក្រតីភាព មានរបៀបរៀបរយ មិនប៉ះពាល់ ឬបៀតបៀនដល់អ្នកដទៃ ។ ព្រោះថា មនុស្សជាសត្វសង្គម ត្រូវរួមរស់ជាមួយគ្នាដោយខានពុំបាន ។ ការរស់នៅជាមួយគ្នានេះ ជាធម្មតាត្រូវមានការប៉ះទង្គិចគ្នាទៅវិញទៅមកពុំលែងឡើយ ដូច្នេះការប្រុងប្រយ័ត្ន រក្សា និងប្រយ័ត្នមិនឲ្យព្រឹត្តិកម្ម របស់ខ្លួនមានបញ្ហា ទើបជាការសំខាន់ណាស់ (សីលសិក្ខា)។

នៅក្នុងការរក្សាព្រឹត្តិកម្មនេះ ម្នាក់ៗត្រូវរៀនជៀសវាង វៀរចាកមិនធ្វើបាបធ្វើទារុណកម្ម បៀតបៀន សម្លាប់ដល់សត្វមានជីវិតទាំងឡាយ ជាពិសេសមនុស្សជាតិផងគ្នា; រៀនវៀរចាក ចៀសវាង មិនប៉ះពាល់ លួច ឆក់ ប្លន់ កេងប្រវ័ញ្ច ស៊ីសំណូក សូកប៉ាន់ទ្រព្យសម្បត្តិរបស់អ្នកដទៃ; រៀនវៀរចាក ជៀសវាង មិនរំលោភ ទៅលើសិទ្ធិរបស់ភេទផ្ទុយគ្នា ដែលជាការខុសនឹងប្រពៃណីសង្គម ដូចជាទៅផិតក្បត់ រំលោភ ឬលួចកូនប្រពន្ធ-ប្តីរបស់អ្នកដទៃ ឬទៅជ្រមុជជ្រមុលនឹងរឿងកាមគុណ រឿងភេទទាំងឡាយ; រៀនវៀរចាក ចៀសវាង មិននិយាយកុហក និយាយអាក្រក់ ញុះញង់ និយាយមិនបានប្រយោជន៍; និងរៀនវៀរចាក ជៀសវាងមិនសេពគប់ជាមួយគ្រឿង ញៀនដែលជាហេតុនាំឲ្យខូចសតិសម្បជញ្ញៈ បាត់បង់ស្មារតី មានផឹកស្រា ជក់កញ្ឆា ជក់អាភៀនជាដើម ។ ទាំង ៥ យ៉ាងនេះ យើងធ្លាប់ស្គាល់ថា រៀនរក្សាសីល ៥ ឬបញ្ចសីល ។

ក្រៅពីរៀនរក្សាព្រឹត្តិកម្មទាំង ៥ យ៉ាង ជាមូលដ្ឋានហើយ នៅមានការរៀនរក្សាច្បាប់ វិន័យ សរាចរណ៍ របៀប ក្រឹត្យក្រម ធម្មនុញ្ញ សិទ្ធិមនុស្ស សុជីវធម៌ទាំងឡាយដែលមាននៅក្នុងសង្គមយើងរស់នៅឲ្យបានល្អប្រសើរ ។ ក្នុងពុទ្ធសាសនា ការរក្សា ការគោរព ដែលបានពោលមកទាំងប៉ុន្មានខាងលើ រាប់បញ្ចូលទៅក្នុងពាក្យថា សីលសិក្ខា ដែលប្រែថា រៀនឲ្យមានសីល រៀនរក្សាសីល ឬរៀនរស់ឲ្យបានល្អនៅក្នុងសង្គមទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

២-រៀនតាំងចិត្តឲ្យនឹង ៖ តាមទស្សនៈព្រះពុទ្ធសាសនា មនុស្សយើងប្រកបឡើងដោយកាយ និងចិត្ត។ កាយ គឺជាប្រជុំនៃវត្ថុចំនួន ៣២ យ៉ាងរួមគ្នា មានសក់ រោម ក្រចក ស្បែក សាច់ ។ល។ កាយនេះមាននាទីទ្រទ្រង់ជីវិតឲ្យរស់នៅបាន ។ ចិត្ត គឺជាសភាវៈម្យ៉ាងដែលចាប់មិនបាន ប៉ះពាល់មិនត្រូវ មាននាទីទទួលអារម្មណ៍ទាំងឡាយថាសុខស្រួល ទុក្ខ លំបាក មិនសុខមិនទុក្ខ (វេទនា); មាននាទីចងចាំថា របស់នេះពណ៌អ្វី ជាអ្វី មកពីណា កើតពេលណា មានដំណើរដូចម្តេច (សញ្ញា); មាននាទីគិត កែច្នៃ ត្រិះរិះ (សង្ខារ) និងមាននាទីដឹងនូវអារម្មណ៍ទាំងឡាយឲ្យរឹតតែបានច្បាស់ (វិញ្ញាណ) ។

មនុស្សយើងមានចិត្តមិនទៀងទេ ម្តងគិតនេះ ម្តងគិតនោះ ជួនកាលគិតជិត ជួនកាលហោះហើរទៅឆ្ងាយរកទីដៅគ្មាន ជួនកាលឈឺចាប់ ជួនរីករាយក៏មាន ។ ពេលណាដែលចិត្តយើងមានការធ្វើច្រើន ធ្វើហួសសមត្ថភាព គិតច្រើនពេក ចិត្តនោះក៏កើតអាការៈមិនស្រួល បាត់បង់គុណភាព សុខភាពថយចុះ ឬបើមានអ្វីមកប៉ះពាល់ធ្វើឲ្យរំភើបខ្លាំងពេក ក៏អាចឲ្យទៅជាវង្វេងវង្វាន់ ឡប់សតិ ឬឆ្កួតក៏មាន ។

ការបាត់លំនឹងស្ថិរភាពចិត្ត សុខភាពចិត្ត ធ្វើឲ្យជីវិតនេះមានភាពមិនប្រក្រតីល្អក់កករ ដូចជាទឹកដែលប្រកបទៅដោយល្អងធូលីផ្សេងៗ មិនអាចយកមកប្រើប្រាស់ផឹកបានទេ ។ ចិត្តដែលមានកករ នឹងធ្វើឲ្យខូចគុណភាព សមត្ថភាព និងគុណធម៌របស់ចិត្ត មិនអាចយកមកប្រើប្រាស់ឲ្យកើតប្រសិទ្ធិភាព និងប្រសិទ្ធិផលឡើយ ។ ក្នុងភាសាបាលី ចិត្តដែលល្អក់កករ មានធូលី លោកហៅថា ចិត្តមានកិលេស ។ កិលេសប្រែថា ធូលី ឬកករ មានទាំងអស់ ១៦ យ៉ាងគឺ ៖[18]

១-ការដែលចង់តែពីបាន លោភលន់ហួសប្រមាណ (អភិជ្ឈា វិសមលោភៈ)

២-គំនិតព្យាបាទ បៀតបៀនគេឲ្យវិនាស (ព្យាបាទៈ)

៣-ការខឹងក្រេវក្រោធ ក្តៅក្រហាយ (កោធៈ)

៤-ការចងកំហឹង មានគំនុំគុំគួន ចងពៀរវេរាមិនបាត់ (ឧបនាហៈ)

៥-ការមានគំនិតបិទបាំង បំភ្លេច បំបាត់អំពើល្អ សេចក្តីល្អរបស់គេ (មក្ខៈ)

៦-គំនិតអង្គុយលើចង្អេរលើកខ្លួនឯង មិនឲ្យនរណាល្អជាងខ្លួន (បលាសៈ)

៧-ចិត្តច្រណែនឫស្យា ឈ្នានិះ (ឥស្សា)

[18] សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ

www.budinst.gov.kh www.elibraryofcambodia.org

៨-កំណាញ់ស្វិត គិតតែពីប្រយោជន៍ខ្លួន (មច្ឆរិយៈ)
៩-លាក់ពុតកំហូចដូចឆ្កែចចក (មាយា)
១០-បោកប្រាស់ដោយការអួតរវាង (សាថេយ្យៈ)
១១-ក្បាលរឹង ច្រងេងច្រងាង (ថម្ភៈ)
១២-ប្រកួតប្រជែង គិតតែពីចង់ឈ្នះ (សារម្ភៈ)
១៣-ប្រកាន់ខ្លួន វាយឫក មានះ (មានះ)
១៤-មើលងាយ ប្រមាថគេ ថាមានតែខ្លួនទេដែលគ្រាន់បើជាង (អតិមានះ)
១៥-ស្រវឹង វង្វេង ក្នុងយស ទ្រព្យ អាយុ បុណ្យសក្តិ (មទះ)
១៦-ប្រមាទ ធ្វេសប្រហែស ភ្លេចភ្លាំង (បមាទះ)

ធូលីរបស់ចិត្តទាំង ១៦ យ៉ាងនេះ តែងធ្វើឲ្យចិត្តមិនមានលំនឹង គ្មានសមាធិ និងបាត់បង់នូវគុណភាព សមត្ថភាព និងគុណធម៌អស់រលីង បើមានកាន់តែច្រើន កាន់តែក្រាស់ នោះមានន័យថា ចិត្តកាន់តែខ្សោយទៅៗហើយ ។ កាលណាបើខ្សោយ ហើយប្រសិទ្ធិភាព និងប្រសិទ្ធិផលរបស់ការងារ ក៏នឹងចុះខ្សោយដែរ ។

នៅមានធូលី ៥ ប្រភេទទៀត ដែលអាចធ្វើឲ្យចិត្តសៅហ្មង ថយសមត្ថភាព មិនមានកម្លាំងក្នុងការបំពេញការងារឲ្យបានល្អ ។ ធូលីប្រភេទនោះ លោកហៅថា នីវរណៈ ប្រែថា គ្រឿងរារាំងចិត្ត ឬឧបសគ្គរបស់ចិត្ត គឺ ៖[19]

១-ការត្រេកត្រអាល ជ្រមុជជ្រមុលតែនឹងកាមគុណពេក (កាមឆន្ទ)
២-ចំនិតចងគំនុំ ព្យាបាទ ចង់តែប្រទូស្តវាយគេ (ព្យាបាទ)
៣-ការងោកងុយ រសេះរសោះ ពុកស៊ិក (Toxic) ស៊ីៗ (ថីនមិទ្ធ)
៤-រវើរវាយ ស្រមើស្រមៃក្នុងរឿងមិនពិត គូរវិមានក្នុងលំហអាកាស (ឧទ្ធច្ចកុក្កុច្ច)
៥-មិនទុកចិត្ត សង្ស័យមិនអស់មិនហើយ គ្មានជំនឿលើអ្វីសោះ (វិចិកិច្ឆា)

កិលេស ១៦ប្រការ និងនីវរណៈទាំង ៥ ប្រការនេះ ជាឧបសគ្គរាំងមិនឲ្យចិត្ត

---
19 សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត

www.budinst.gov.kh www.elibraryofcambodia.org

បំពេញការងាររបស់ខ្លួនទាំង ៤ យ៉ាង គឺទទួលអារម្មណ៍ ចងចាំ គិត និងដឹងដោយគ្រប់គ្រាន់ឡើយ មានឧបមាដូចពិលដែលកញ្ចក់ប្រឡាក់ធូលី មិនអាចមើលបានច្បាស់ ឬទឹកមានកករ មិនអាចទទួលទានបានដូច្នោះដែរ ។

ការធ្វើសមាធិតាមបែបពុទ្ធសាសនា គឺជាការដុះសំអាត ឬចំរាញ់យកធូលី និងឧបសគ្គទាំងនោះចេញពីសន្តានរបស់ចិត្ត ដើម្បីឲ្យចិត្តនោះស្អាត ភ្លឺថ្លា និងកើនគុណភាពឡើងវិញ ។ វិធីដ៏ងាយមួយក្នុងការធ្វើទឹកដែលកករឲ្យថ្លាវិញ គឺការយកទឹកនោះទៅតម្កល់ឲ្យនឹងមួយកន្លែង កុំឲ្យមានអ្វីប៉ះពាល់ លុះយូរបន្តិចទៅ ទឹកនោះក៏រងម្តងបន្តិចៗជាលំដាប់ ។ ទឹកដែលថ្លាក៏នៅខាងលើ ធូលី ឬកករទាំងឡាយក៏រងទៅនៅបាតខាងក្រោម ។ ដូចគ្នា ដើម្បីឲ្យកិលេស និងឧបសគ្គទាំងប៉ុន្មានរបស់ចិត្តវិនាសអស់ទៅ យើងក៏ត្រូវតម្កល់ចិត្តនេះឲ្យនឹងមួយកន្លែង កុំឲ្យមានអ្វីមកប៉ះពាល់ដែរ ។ មិនយូរប៉ុន្មានចិត្តដែលនឹង ក៏នឹងជម្រុះ ធាក់បញ្ចេញនូវកិលេសទាំងអស់នោះជាពុំខាន ។ ការតម្កល់ចិត្តឲ្យនឹង ដើម្បីជំរះធូលីចេញនេះ ហៅថា ការធ្វើសមាធិ ។ (សមាធិសិក្ខា)

ការធ្វើសមាធិ គឺការធ្វើចិត្តឲ្យនឹង ឬបើនិយាយឲ្យងាយស្តាប់ គឺការទប់ចិត្តឲ្យនឹងមិនឲ្យរំជួយ កម្រើករំពើក ទៅដោយការអូសទាញ ការលង ការជន្ល របស់កិលេសទាំង ១៦ ប្រការនេះឯង ។ ធម្មជាតិរបស់ចិត្តភ្លឺថ្លាល្អ តែពីព្រោះកិលេសដែលចេញមកពីអតីតកាល បច្ចុប្បន្ន និងអនាគតទេ ដែលធ្វើឲ្យចិត្តនេះប្រឡាក់ ។ ដើម្បីឲ្យចិត្តនឹងមិនរំជួយដោយសារកិលេស គប្បីយកចិត្តមកចងឲ្យជាប់ ហើយសំឡឹងឃ្លាំមើល កុំឲ្យរួចចេញបាន ។ ការយកចិត្តមកចង និងឃ្លាំមើលនេះ លោកហៅថា មានសតិ ។

សតិ គឺការរស់នៅដោយការដឹងទាន់នូវគ្រប់សកម្មភាពរបស់ចិត្តគ្រប់ខណៈដែលនឹងអាចការពារមិនឲ្យកិលេសទាំង ១៦ យ៉ាង ចូលមកប្រឡាក់ ឬអាចនិយាយថាសតិ គឺជារបាំងដែលចល័តការពារមិនឲ្យកិលេសទាំងពួងចូលមកយាយីដល់ចិត្តរបស់យើងបាន ។ ពេលណាដែលចិត្តពុំមានកិលេសចូលមកបៀតបៀន ចិត្តនោះក៏មានសុខភាពល្អ ។ ចិត្តដែលមានសុខភាពល្អ រមែងធ្វើការងារដោយពេញសមត្ថភាព ចិត្តដែលធ្វើការងារដោយពេញសមត្ថភាព ជាចិត្តដែលនឹងងាយអាចបំពាក់សីលធម៌បានដែលនឹងមានប្រយោជន៍យ៉ាងច្រើនដល់ខ្លួន សង្គម និងប្រទេសជាតិ ។

www.budinst.gov.kh www.elibraryofcambodia.org

៣-វៀនបណ្ណុះបញ្ញា ពាក្យថាបញ្ញា មានសេចក្ដីពន្យល់ក្នុងភាសាបាលីថា: < បការេន ជានាតិ អនិច្ចា ទិវសេន អវពុជ្ឈតិតិ > បញ្ញា ប្រែជាភាសាខ្មែរថា បញ្ញា បានដល់ការដឹងដ៏ជ្រាលជ្រៅថា សព្វវត្ថុទាំងឡាយមានការប្រែប្រួលជាដើម ។ បញ្ញា មានកម្លាំងអំណាចក្នុងការដឹងនូវសភាវៈនៃសព្វវត្ថុទាំងពួង ទៅតាមសភាពពិត(យថាសភាវៈ) របស់វត្ថុនោះ ។ ក្នុងភាសាបាលី មានសព្ទដែលសំរាប់ហៅការដឹង ឬពុទ្ធិដែលស្រដៀងៗនឹងបញ្ញាដែរ តែមិនបានចាត់ចូលទៅក្នុងបញ្ញាទេ ចំនួនពីរសព្ទ គឺសញ្ញា និងវិញ្ញាណ៖

ក-សញ្ញា : មាននាទីត្រឹមតែជាការទទួលដឹងជាដើមដំបូង ដូចជាដឹងថាខៀវ តែមិនអាច កំណត់លក្ខណៈឲ្យបានច្បាស់ទេ

ខ-វិញ្ញាណ : អាចកំណត់លក្ខណៈបាន តែមិនអាចដឹងពីវិធីការ ឬរបៀបនៃដំណើរការ (Process) របស់វត្ថុនោះបានទេ

គ-បញ្ញា : រួមដោយនាទីរបស់សញ្ញា និងវិញ្ញាណចូលគ្នា

លោកប្រៀបធៀបសព្ទទាំង ៣ ម៉ាត់នេះ ទៅនឹងការដឹងអំពីរឿងប្រាក់កាក់ថា ៖ កូនក្មេងដឹងត្រឹមថា នុ៎ះគឺជាប្រាក់កាក់មូលៗតែប៉ុណ្ណោះ (សញ្ញា) ឯមនុស្សចាស់ដឹងជ្រៅទៅទៀតថា ប្រាក់កាក់នីមួយៗមានលក្ខណៈដូចម្ដេច (វិញ្ញាណ) តែចំពោះអ្នកផលិតប្រាក់កាក់វិញ ដឹងអំពីរបៀបផ្សំ និងរបៀបផលិតប្រាក់កាក់នោះទាំងអស់ ។ ទាល់តែដឹងរបៀបអ្នកផលិតនេះ ទើបហៅថា បញ្ញា ។

## រូបលក្ខណៈរបស់បញ្ញា

ក្នុងពុទ្ធសាសនា បញ្ញា គឺជាឧបករណ៍សំខាន់ជាទីបំផុតសំរាប់កំចាត់សេចក្ដីទុក្ខ ។ សេចក្ដីទុក្ខក្នុងទីនេះ គឺសេចក្ដីទុក្ខដែលកើតព្រោះការមិនដឹង (អវិជ្ជា) នូវវត្ថុទាំងឡាយទៅតាមសភាពពិតរបស់វា ។ លុះមិនដឹង មិនឃើញទៅតាមសភាពពិតរបស់វាហើយ ក៏នាំឲ្យកើតនូវការយល់ច្រឡំ វង្វេង (មោហៈ) ទៅជាលោភចង់បាន ទៅជាខឹងក្រោធជាដើម ។ មានសព្ទបាលីមួយម៉ាត់ទៀតដែលប្រើស្រដៀងគ្នានឹងបញ្ញាដែរគឺពាក្យ **យថាញាណទស្សនៈ** ប្រែថា ដឹងឃើញទៅតាមសភាពពិត ។ យថាញាណទស្សនៈ ជាមគ្គ (Means) ដែលនឹងនាំទៅរកផល (End) ។ ការរួមទាំង ២ ន័យនេះ លោកហៅ

www.budinst.gov.kh www.elibraryofcambodia.org

ថា បញ្ញា ។

ព្រះពុទ្ធអង្គទ្រង់សំដែងថា បញ្ញា គឺការឃើញដឹងនូវអរិយសច្ចៈ ៤ ប្រការ ៖

១- ដឹងឃើញថា ជីវិតនេះកំពុងជួបប្រទះនឹងបញ្ហា និងសេចក្ដីទុក្ខពិតៗ (ទុក្ខអរិយសច្ចៈ)

២- ដឹងឃើញថា សេចក្ដីទុក្ខនិងបញ្ហាទាំងឡាយនោះ កើតមកអំពីអ្វីមូលហេតុរបស់បញ្ហានោះ មានអ្វីខ្លះ (ទុក្ខសមុទយអរិយសច្ចៈ)

៣- ដឹងឃើញ និងមានជំនឿច្បាស់ថា សភាវៈដែលមិនមានទុក្ខ មិនមានបញ្ហានោះ មានហើយ នឹងកើតឡើងបាននៅពេលណាសេចក្ដីទុក្ខទាំងឡាយនោះរលត់អស់ទៅ (ទុក្ខ និរោធ អរិយសច្ចៈ)

៤- ដឹងឃើញនូវវិធីរំលត់នូវហេតុរបស់សេចក្ដីទុក្ខ (ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ)

ចំពោះបញ្ហាដែលត្រូវដឹងពីអរិយសច្ចៈទាំង ៤ ប្រការនេះ ត្រូវមានលក្ខណៈ ៣ ប្រការ ដែលហៅថា **បរិញ្ញា** គឺ ៖

១- កំណត់ដឹងនូវអ្វីដែលបានរៀនរួចហើយនោះយ៉ាងច្បាស់ ទាំងលក្ខណៈ និងសម្ព័ន្ធភាពរបស់វត្ថុនោះ ដូចជាដឹងថា នេះជាវេទនា ហើយវេទនានេះ គឺជារបស់ដែលមាន លក្ខណៈទទួលនូវអារម្មណ៍ដូច្នេះជាដើម (ញាតបរិញ្ញា) ។

២- កំណត់ដឹងដោយការពិចារណា ដោយការស៊ើបអង្កេត វិភាគ បានយ៉ាងច្បាស់លាស់ នូវលក្ខណៈ និងវិធីកម្ម (Process) របស់វត្ថុទាំងនោះ ដូចជារបស់ទាំងអស់ជាអនិច្ចំ ទុក្ខំ អនត្តា ដូច្នេះជាដើម (តីរណបរិញ្ញា) ។

៣- កំណត់ដឹងដើម្បីលះ ដើម្បីកំចាត់ចេញ ដោយការដឹងថារបស់នោះជាទុក្ខ ជាបញ្ហា ជាទោស ហើយក៏បានលះបង់ កំចាត់ចេញបានដោយត្រឹមត្រូវ ដូចជាបានដឹងថារបស់ ទាំងពួងជាទុក្ខ ប្រែប្រួល និងមិនមែនជារបស់ខ្លួន ហើយក៏លះនូវគំនិតប្រកាន់ខ្ជាប់ថា របស់ទាំងពួង មិនទុក្ខ ជាទៀង និងជារបស់ខ្លួននោះ ចោលចេញ (បហានបរិញ្ញា)។

ដើម្បីឲ្យងាយយល់ សូមលើកឧទាហរណ៍ពីរឿងព្យាបាលរោគដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

- វេជ្ជបណ្ឌិតទាំងឡាយតែងរៀនអំពីជំងឺទាំងឡាយមានគ្រុនផ្តាសាយ គ្រុនឈាម ឬគ្រុនចាញ់ដោយច្បាស់លាស់ ទាំងលក្ខណៈ ទាំងអាការៈរបស់ប្រភេទគ្រុននីមួយៗ ។ កាលណាមានអ្នកជំងឺណាមួយចូលមក គាត់អាចដឹងថាអ្នកជំងឺមានជំងឺគ្រុនប្រភេទណា មកអំពីអ្វី មានអាការៈយ៉ាងណាជាដើម ។ ការដឹងរបៀបវេជ្ជបណ្ឌិតនេះ ចាត់ទុកជាការដឹងបែបញាតបរិញ្ញា ។
- វេជ្ជបណ្ឌិតនោះតែងដឹងថា ប្រភេទគ្រុននីមួយៗ គួរព្យាបាលឲ្យជាតាមរបៀបណា ប្រើថ្នាំអ្វី ត្រឹមកំរិតណាទើបជា ។ ការដឹងបែបនេះ ចាត់ទុកជាការដឹងបែប តីរណបញ្ញា ។
- វេជ្ជបណ្ឌិតក៏ចាប់ផ្តើមព្យាបាលជំងឺគ្រុននោះចេញ រហូតដល់ជាដូចដើម ។ ការដែលដឹងថាបានព្យាបាលជំងឺនោះជាហើយដូច្នេះ ហៅថាការដឹងបែបបហានបរិញ្ញា ។

ការសិក្សាបញ្ញា ជាការសិក្សាខ្ពស់បំផុតក្នុងពុទ្ធសាសនា ។ ដូច្នេះជាការសំខាន់ណាស់ ដែលត្រូវធ្វើយ៉ាងណាដើម្បីឲ្យបញ្ញាកើតឡើង និងរីកដុះដាលបានល្អ។ ក្នុងនេះលោកបានថ្លែងថា ដើម្បីឲ្យកើតបញ្ញា បុគ្គលត្រូវធ្វើចិត្តរបស់ខ្លួនឲ្យស្ងប់សិន ដូចមានពុទ្ធដីកាថា: <ធម្មតា ឯសា យំ សមាហិតោ យថាភូតោ ជានាតិ បស្សតិ យថាភូតំ ជានតោ បស្សតោ ន ចេតនាយ .ករណីយំ និព្វិន្ទា វិរជុខាមីតិ> *បុគ្គលដែលមានចិត្តស្ងប់* រមែងបានឃើញរបស់ផ្សេងៗទៅតាមសភាពពិត បុគ្គលដែលឃើញទៅតាមសភាពពិត នឹងមិនធ្វើនាទីដែលគួរធ្វើ ដោយការនឿយណាយឡើយ ព្រោះនេះជារឿងធម្មតា ។

<ធម្មតា ឯសា យំ យថាភូតំ ជានំ បស្សំ និព្វិន្ទតិ វិរជុជតិ និព្វិន្ទស្ស វិរត្តស្ស ន ចេតនាយ ករណីយំ វិមុត្តិញាណទស្សនំ សច្ឆិករោមីតិ> បុគ្គលដែលដឹងឃើញតាមសភាពពិត រមែងនឿយណាយ រីអ្នកដែលអារម្មណ៍នឿយណាយ (មានចិត្តរួចស្រឡះពីកិលេស) នឹងមិនចាំបាច់ធ្វើកិច្ចដែលគួរធ្វើ ដើម្បីញាណ និងទស្សនៈទៀតទេ ព្រោះនេះក៏ជារឿងធម្មតា ។

<ធម្មតា ឯសា យំ និព្វិន្នោ វិរត្តោ វិមុត្តិញាណទស្សនំ សច្ឆិករោតិ> បុគ្គលអ្នកដឹងពេលនឿយណាយនូវការកំណត់ហើយ រមែងធ្វើញាណ និងទស្សនៈឲ្យប្រាកដឡើង នេះក៏ជារឿងធម្មតា ។

ដូច្នេះយើងឃើញថា ការសិក្សាលើរឿងសីល សមាធិ និងបញ្ញា មានសារៈ

www.budinst.gov.kh www.elibraryofcambodia.org

សំខាន់ជាកំពូល ក្នុងការរំដោះជីវិតនេះឲ្យផុតអំពីបញ្ហា និងសេចក្ដីទុក្ខទាំងពួងដែលយើងហៅថា និព្វាន ។ និព្វានអាចសំរេចបាន ក៏ព្រោះអាស្រ័យបញ្ញា បញ្ញាអាចកើតឡើងបាន ក៏ព្រោះចិត្តមានសមាធិរឹងមាំ ហើយសមាធិអាចកើតកើតឡើងបាន ក៏ព្រោះមានសីលជាមូលដ្ឋាន តែសីលដែលអាចនឹងបរិសុទ្ធបានល្អ ក៏ទាល់តែបុគ្គលនោះមានបញ្ញាសំរាប់គ្រប់គ្រងដែរ គឺត្រូវពឹងពាក់គ្នាទៅវិញទៅមក ។

បើនិយាយជាផ្លូវសង្គមវិញ ជនណាដែលមានការប្រព្រឹត្តល្អ មានការប្រព្រឹត្តជាសុចរិត (សីល) ជននោះរមែងមានសុខភាពចិត្តល្អ មានចិត្តនឹងមាំមួន ចិត្តស្ងប់ ពុំមានវិប្បដិសារីទេ (សមាធិ) ។ អ្នកដែលមានចិត្តស្ងប់ល្អដូច្នេះ រមែងរៀនអ្វីឆាប់ចេះចាំ មានសតិមិនងាយភ្លេច បញ្ញាឈ្លៀសវៃ អាចដោះស្រាយបញ្ហាទាំងឡាយបានដោយងាយ មានហេតុផល និងមិនមានសេចក្ដីទុក្ខចូលមកបៀតបៀនក្នុងដួងចិត្តឡើយ (បញ្ញា) ។ ជនដែលដោះស្រាយ បញ្ហាទាំងឡាយដោយបញ្ញា រមែងមិនបណ្ដោយឲ្យកំហឹង និងមោហៈ ចូលមកគ្របសង្កត់ រហូតដល់ទៅផ្ដេះផ្ដោយ ប្រព្រឹត្តនូវអំពើទុច្ចរិតឡើយ (សីល)។

## ការបដិបត្តិធម៌ គឺការអភិវឌ្ឍន៍ជីវិត

យើងបានឃើញរួចហើយ អំពីអ្វីដែលហៅថាការបដិបត្តិធម៌ក្នុងពុទ្ធសាសនា នៅក្នុងន័យការបំពេញនាទីរបស់ខ្លួនទៅតាមឋានៈ ការរៀនរក្សាព្រឹត្តិកម្មរបស់ខ្លួនឲ្យបានល្អ ការរៀនរក្សាចិត្តរបស់ខ្លួនឲ្យមានលំនឹង ការរៀនចំរើនបញ្ញារបស់ខ្លួនឲ្យពូកែ ។ ឥឡូវនេះ យើងងាកមើលទៅលើទិដ្ឋភាពមួយចំហៀងទៀត នៃការបដិបត្តិធម៌ក្នុងពុទ្ធសាសនា ដែលមានន័យថា **ការអភិវឌ្ឍន៍ជីវិត** ។

ពុទ្ធសាសនា ជាសាសនារបស់មនុស្ស ដើម្បីមនុស្ស និងដោយមនុស្ស ។ និយាយដោយរួម គឺយកមនុស្សជាបណ្ដូលនៃការអប់រំ (man centered) និងជឿថាមនុស្សជាសត្វដែលអាចទទួលការអប់រំ ហ្វឹកហាត់ កែប្រែ និងអភិវឌ្ឍន៍ឲ្យល្អបាន បើគេបានទទួលការណែនាំដ៏ត្រឹមត្រូវ (វេនេយ្យសត្វ) ។

## ហេតុអ្វីទើបចាំបាច់អភិវឌ្ឍន៍ជីវិត

www.budinst.gov.kh www.elibraryofcambodia.org

បើទោះជាយើងមិនអភិវឌ្ឍន៍ ក៏ជីវិតនេះមានវឌ្ឍនាការរីកចំរើនទៅមុខតាមធម្មជាតិរបស់វារួចទៅហើយ គ្រាន់តែថាវាអាចរីកចំរើនទៅលើផ្លូវខុស ឬទៅលើផ្លូវត្រូវ ។ មិនមានទរណាម្នាក់ចង់ឲ្យជីវិតខ្លួនរីកចំរើនទៅខាងផ្លូវវិនាសទេ លើកលែងតែមនុស្សនោះវង្វេង (មោហៈ) យល់ថាផ្លូវខុសនោះជាផ្លូវត្រូវរបស់ខ្លួន (មិច្ឆាទិដ្ឋិ) ឬក៏មិនដឹងថានោះជាផ្លូវខុស (អវិជ្ជា) ។

ព្រះពុទ្ធអង្គបានបែងចែកប្រភេទមនុស្សទៅជា ៥ ប្រភេទ ដើម្បីងាយស្រួលនឹងពិនិត្យមើលថា តើខ្លួនគេនៅត្រង់ណា និងគួរត្រូវអភិវឌ្ឍជីវិតត្រឹមកំរិតណា គឺ៖

**១-មនុស្សនិរយោ**៖មានខ្លួនជាមនុស្ស តែមានចិត្តនិងការរស់នៅដូចសត្វនរក បានដល់ប្រភេទមនុស្សដែលមានមូលដ្ឋានចិត្តជាអ្នកឃោរឃៅ យកខឹងជាត្រីមុខ ប៉ះដៃយកដៃ ប៉ះជើងយកជើង ហឹង្សា អំណាចផ្តាច់ការនិយម ចូលចិត្តរំលោភសិទ្ធិគេឯង កាច ។ល។ ពួកនេះគ្មានសីលបាណាតិបាតា វេរមណីទេ ។ ក្នុងន័យមួយទៀត បានដល់ជន ឬក្រុមជនដែលត្រូវគេជិះជាន់ ធ្វើបាបសង្កត់សង្កិន ធ្វើទារុណកម្ម រំលោភសិទ្ធិ មានតែសេចក្តីលំបាកវេទនា ខ្លោចផ្សារជានិច្ច ។

**២-មនុស្សបេតោ** ៖មានខ្លួនជាមនុស្ស តែមានចិត្តនិងការរស់នៅដូចជាសត្វប្រេត បានដល់ ប្រភេទមនុស្សដែលមានមូលដ្ឋានចិត្តលោភលន់ ឃ្លានស្រេកមិនចេះចប់ មិនចេះហើយ កេងប្រវញ្ច លួចប្លន់ ល្មោភ ញៀន ចេះតែចង់បាន មិនគិតថាបានដោយរបៀបណាទេ លោកឧបមាថាដូចសត្វប្រេត ដែលមានពោះធំ តែមានមាត់តូចប៉ុនគូថម្ជុល ។ ពួកនេះភាគច្រើន គ្មានសីលអទិន្នាទានា វេរមណី និងកាមេសុមិច្ឆាចារាវេរមណីទេ ។ ក្នុងន័យមួយទៀត បានដល់ជនឬក្រុមជនដែលក្រីក្រ ខ្វះមុខខ្វះក្រោយ ទុរគត គ្មានអ្វីហូប ស្រេកឃ្លានដោយការខ្វះខាត ។

**៣-មនុស្សតិរច្ឆានោ** ៖ មានខ្លួនជាមនុស្ស តែមានចិត្តនិងការរស់នៅដូចជាសត្វតិរច្ឆាន បានដល់ប្រភេទមនុស្សដែលមានមូលដ្ឋានចិត្តវង្វេង មិនដឹងខុសត្រូវ យល់សជាខ្មៅ មិនស្គាល់ម៉ែឪ បងប្អូនកូនចៅ មានតែសញ្ជាតិញាណ(instinct) ដូចជាសត្វធាតុ ល្ងង់មិនចេះឈឺចាប់ លោកឧបមាថាដូចជាសត្វគោ សត្វខ្លា ឬសត្វទូទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

៤-មនុស្សមនុស្សោ ៖ មានខ្លួនជាមនុស្ស ហើយមានចិត្តនិងការរស់នៅដូចជាមនុស្សជាតិ បានដល់ជនណាដែលគោរពខ្ជាប់នៅក្នុងសីល ៥ គឺមិនសម្លាប់ធ្វើបាបមនុស្សសត្វផងគ្នា; មិនលួចទ្រព្យសម្បត្តិគ្នា; មិនលួចស្វាមីភរិយាគ្នា; មិននិយាយកុហកគ្នា; និងមិនលុះទៅដោយអំណាចគ្រឿងញៀន ។ ទាំង ៥ យ៉ាងនេះ លោកហៅថា មនុស្សធម៌ ។ ជាមួយគ្នានេះ មនុស្ស មនុស្សោ ត្រូវស្គាល់ហេតុ (ធម្មញ្ញុតា), ស្គាល់ផល (អត្ថញ្ញុតា), ស្គាល់ខ្លួនឯង (អត្តញ្ញុតា), ស្គាល់ល្មម (មត្តញ្ញុតា), ស្គាល់កាលវេលា (កាលញ្ញុតា), ស្គាល់សង្គមដែលខ្លួនរស់នៅ (បរិសញ្ញុតា) និងស្គាល់បុគ្គលដែលខ្លួនមានទំនាក់ទំនង ជាមួយ(បុគ្គលញ្ញុតា) ។ ទាំង ៧ យ៉ាងនេះ លោកហៅថាសប្បុរសធម៌ ជនណាមាន ហើយ នឹងក្លាយខ្លួនទៅជាសប្បុរសជន គឺ មនុស្សល្អ ។

៥-មនុស្សទេវោ មានខ្លួនជាមនុស្ស តែមានចិត្តនិងការរស់នៅដូចជាទេវតា បានដល់មនុស្សណាដែលមានសីល ៥ ក្នុងខ្លួន និងមានចិត្តចេះខ្មាសបាប និងខ្លាចបាបគ្រប់បែបគ្រប់យ៉ាង និងមានមេត្តាករុណា ចង់តែជួយសង្គ្រោះដល់ជនទាំងឡាយណាដែលគ្មាក្រីក្រ លំបាកលំបិន ឲ្យបានរួចពីទុក្ខជានិច្ច ។ ក្នុងន័យមួយទៀត បានដល់ជន ឬក្រុមជនដែលបានធ្វើប្រយោជន៍ដល់ជនដទៃទៀតជាច្រើន រហូតដល់មានគេគោរពបូជា លើកឲ្យធ្វើជាប្រមុខ ក្នុងការនាំទៅរកសេចក្តីសុខរបស់ពួកគេ ។

មើលសង្កេតតាមន័យទាំង ៥ នេះ យើងអាចឃើញថា អ្នកណាក៏ចង់ទៅជាមនុស្សពេញលេញ និងជាទេវតាដែរ សង្គមណាក៏ចង់មានសមាជិកខ្លួនដែលជាមនុស្សពេញលក្ខណៈ និងមានមេត្តាករុណា គោរពច្បាប់ ចេះខ្មាសបាប និងមិនប្រព្រឹត្តអំពើអាក្រក់ដែរ ដែលជាចម្លើយសំរាប់សំនួរខាងលើ ដែលសួរថាហេតុអ្វីទើបត្រូវធ្វើអភិវឌ្ឍន៍នោះ ។

ក្នុងអតីតជាតិដែលកន្លងមក ព្រះពុទ្ធអង្គធ្លាប់កើតជាសត្វនរកក៏មាន ធ្លាប់កើតជាសត្វប្រេតក៏មាន ធ្លាប់កើតជាសត្វតិរច្ឆានក៏មានដែរ ដែលជាផលនៃការប្រព្រឹត្តិអំពើអាក្រក់ដ៏ផ្ដេះផ្ដាស កាលនៅជាតិជាមនុស្ស ។ តែព្រះអង្គក៏បានអភិវឌ្ឍន៍ជីវិតរបស់ព្រះអង្គម្ដងបន្តិចៗ រហូតមានសុក្រឹតភាពជាមនុស្សបរិសុទ្ធផូរផង់ គ្មានកិលេសតណ្ហា គ្មានការខឹង ការលោភ ការវង្វេង ក្នុងអំពើអាក្រក់ទៀតឡើយ ។ ត្រង់នេះសឲ្យយើង

www.budinst.gov.kh www.elibraryofcambodia.org

ឃើញថា មនុស្សយើងអាចអភិវឌ្ឍជីវិតខ្លួនឆ្ពោះទៅរកសេចក្តីសុខ និងសុក្រឹតភាពបានគ្រប់ៗគ្នាទាំងអស់ បើគេបានដើរតាមផ្លូវអភិវឌ្ឍន៍ដែលមានបទពិសោធន៍ត្រឹមត្រូវ និងធ្លាប់បានជោគជ័យរួចមកហើយ ។

### អភិវឌ្ឍន៍ជីវិតលើវិស័យអ្វីខ្លះ

ពុទ្ធសាសនាបានបង្ហាញនូវសេចក្តីត្រូវការរបស់ជីវិត ៤ យ៉ាង គឺអភិវឌ្ឍន៍ខាងរាងកាយ, អភិវឌ្ឍន៍លើការរស់នៅក្នុងសង្គម, អភិវឌ្ឍន៍ផ្លូវចិត្ត និងអភិវឌ្ឍន៍ផ្លូវបញ្ញា ។[20]







## កាយភាវនា ឬកាយាភិវឌ្ឍន៍

អភិវឌ្ឍន៍ខាងផ្នែករាងកាយ មានគោលបំណងដើម្បីឲ្យរាងកាយមនុស្សយើងនេះ *មានសុខភាព គុណភាព និងគុណតម្លៃ* បរិបូណ៌ ។

កាយមានសុខភាព គឺកាយដែលបានទទួលចំណីអាហារគ្រប់គ្រាន់ និងមានជីវជាតិល្អ, មានសំលៀកបំពាក់សមរម្យល្អ, មានផ្ទះសម្បែងជ្រកកោនត្រឹមត្រូវ និងមានថ្នាំព្យាបាលពេលមានជម្ងឺឈឺថ្កាត់ ។ ក្នុងន័យនេះ ការអភិវឌ្ឍន៍រាងកាយសំដៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចសំរាប់ជីវិត ដែលជាកត្តាសំខាន់ដំបូងដូចដែលព្រះអង្គមានបន្ទូលថា សព្វេ សត្តា អាហារដ្ឋិតិកា សត្វទាំងឡាយរស់បានដោយសារអាហារ ។ ក្រៅពីបច្ច័យទាំង ៤ ខាងលើ ក៏នៅមានបច្ច័យអមទាំងឡាយដ៏ច្រើនទៀត ដែលរួមទាំងគ្រឿងសំរាប់សំរួលដល់ការនឿយហត់របស់រាងកាយ ដូចជាយានជំនិះផ្សេងៗ ស្បែកជើង វ៉ែនតា

---

[20] យកតាមភាវនា ៤ ។ ក្នុងភាសាបាលី ពាក្យថាភាវនាប្រែថា ការចម្រើន ការធ្វើឲ្យច្រើន ត្រូវនឹងពាក្យភាសាអង់គ្លេសថា development

www.budinst.gov.kh www.elibraryofcambodia.org

គ្រឿងក្រអូប ។ល។ ជាមួយនេះផងដែរ គេក៏ត្រូវគិតអំពីបញ្ហាសន្តិសុខខាងផ្នែករាងកាយដែរ ដូចជាធ្វើយ៉ាងណាកុំឲ្យមានការប៉ះទង្គិចខ្លាំងដល់រាងកាយ ការមិនធ្វើទារុណកម្មដល់រាងកាយ វិធីការពារកុំឲ្យមានគ្រោះថ្នាក់ដោយសារមីន ឬគ្រឿងអាវុធយុទ្ធភ័ណ្ឌជាដើមនេះ ក៏សុទ្ធតែរាប់ចូលទៅក្នុងផ្នែក អភិវឌ្ឍន៍រាងកាយឲ្យមានសុខភាពទាំងអស់ ។

កាយមានគុណភាព គឺកាយដែលមានលក្ខណៈសមគួរដល់ការងារគ្រប់ប្រភេទ ដូចជារហ័សរហួន មាំទាំ ធ្វើការមិនងាយហត់ ធន់នឹងការលំបាក ។ល។ បើនិយាយឲ្យងាយស្តាប់ គឺយើងអាចលើកពីប្រសាទវិញ្ញាណយើងទាំង ៥ យកមកធ្វើជាឧទាហរណ៍ក្នុងការកំណត់គុណភាពរបស់កាយគឺ ៖

ចក្ខុប្រសាទៈ ភ្នែករហ័ស, ភ្លឺច្បាស់, ភ្នែកមុត, មិនចាញ់ភ្នែកគេពេលសម្លឹងមុខគ្នា មិនងាយមានជំងឺ ។ល។

សោតប្រសាទៈ ត្រចៀកឮច្បាស់, ស្តាប់មិនច្រឡំ, សម្លេងតិចក៏អាចស្តាប់បាន សម្លេងខ្លាំងអាចធន់បានងាយ ។ល។

ឃានប្រសាទៈ ច្រមុះពូកែហិតក្លិន, ច្រមុះរហ័សអាចវែកញែកក្លិនអ្វីជាអ្វីបាន, ស្រង់ក្លិនបានឆ្ងាយ, ពូកែធន់ក្លិនអាក្រក់ ឬក្រអូបបាន ។

ជីវ្ហាប្រសាទៈ អណ្តាតពូកែភ្លក្សរសជាតិ អាចញែករសជាតិបានដោយមិនងាយច្រឡំ ។ ជីវ្ហាប្រសាទនេះ រួមទាំងមានធ្មេញរឹងមាំ មិនងាយពុកបាក់ផងដែរ ។

កាយប្រសាទៈ មានអវៈយវៈមាំមួន រហ័សរហួន កាយមានការទទួលរំញោចបានងាយ មិនងាយស្ពឹកស្រពន់ មិនងាយហត់ ដើរបានឆ្ងាយ កាន់អ្វីបានយូរ អង្គុយ ឈរ ដេក ដើរ ទៅតាមចំណង់យូរ ឬឆាប់បានទាំងអស់ ទៅតាមការបញ្ជារបស់ចិត្ត ។ ក្នុងករណីកាយមានគុណភាពនេះ សមត្ថភាពរបស់កាយ គឺជាចំណុចសំខាន់បំផុត ។ ក្នុងករណីនេះ ក៏រួមដល់ជំនាញរបស់កាយក្នុងមុខវិជ្ជាទាំងឡាយ ដូចជាការសរសេរ ការជួសជុលគ្រឿងយន្តទាំងឡាយ ការគប់ត្រូវវែង បាញ់ត្រង់ ។ល។ ជាដើមនេះ

www.budinst.gov.kh www.elibraryofcambodia.org

រាប់បញ្ចូលទៅក្នុងកាយដែលមានគុណភាពទាំងអស់ ។

កាយមានគុណធម៌ៈ ការអភិវឌ្ឍន៍កាយឲ្យមានសុខភាព និងសមត្ថភាព ពុំអាចនិយាយថាគ្រប់គ្រាន់បានទេ នៅក្នុងបរិបទព្រះពុទ្ធសាសនា ។ បើយើងអាចនឹកបាន យើងគង់នឹងនឹកឃើញថា កាលពីក្មេង កាលណាយើងឈរជជែកគ្នាជាមួយនរណាម្នាក់ក្រោម ឬក្បែរដើមឈើណាមួយដើមនោះ អ្នកខ្លះដៃនៅមិនស្ងៀមទេ គឺបោចនេះ បេះនោះ ទាល់តែរេចស្លឹកអស់ ។ ជួនកាលជើងឈូសនេះ ទាត់នោះតែពាស ដែលជាអាកប្បកិរិយាមួយ មិនសមរម្យទាល់តែសោះ ។ ក្នុងព្រះពុទ្ធសាសនា លោកថាត្រូវសំរួមកាយឲ្យមានរបៀបរៀបរយ គឺសំរួមភ្នែក ត្រចៀក ច្រមុះ អណ្តាត និងអវៈយវៈទាំងឡាយនេះឯង ដែលក្នុងភាសាបាលីលោកហៅថា ឥន្ទ្រីយសំវរៈ ។ ភ្នែកយើងមានហើយ តែការដែលមើលរឿង ឬរបស់មិនសមរម្យ ដូចជារឿងអាសអាភាស រឿងបាញ់កាប់ចាក់សម្លាប់ ឃោរឃៅជាដើមនេះ មិនមែនជាការប្រពៃទេ មានតែហុចទោសឲ្យប៉ុណ្ណោះ ព្រោះវាអាចទៅពន្យះតណ្ហា លោភៈ ទោសៈ មោហៈ ឲ្យកើតឡើងបាន ។ ចំពោះត្រចៀក ច្រមុះ អណ្តាត និង អវយវៈ ក៏ដូចគ្នាដែរ។ កាលណាយើងមិនប្រុងប្រយ័ត្នលើការប្រើប្រាស់ឥន្ទ្រីយ៍ទាំង ៥ (ប្រសាទវិញ្ញាណ) ក្នុងការបញ្ចេញ ព្រឹត្តិកម្ម និងទទួលអារម្មណ៍ទេនោះ យើងប្រាកដជាទទួលទុក្ខទោសដោយសារទំនាក់ ទំនងនោះជាពុំខាន ។ ដូច្នេះការអភិវឌ្ឍន៍គុណធម៌ខាងរាងកាយ ឬការធ្វើឲ្យមានទម្លាប់ ក្នុងការបញ្ចេញនូវព្រឹត្តិកម្ម និងទទួលនូវអារម្មណ៍ទាំងឡាយដែលល្អៗនេះ ជាគោលដៅចុងក្រោយបំផុតរបស់កាយាភិវឌ្ឍន៍ និងជាមេបញ្ញាការរបស់សុខភាព និងសមត្ថភាពនៃកាយទៀតផង ។

ការអភិវឌ្ឍន៍រាងកាយយើងឲ្យមានសុខភាព សមត្ថភាព និងគុណធម៌នេះ មិនអាចញែកដាច់ចេញពីគ្នាបានឡើយ ព្រោះចំណុចមួយៗសុទ្ធតែមានប្រយោជន៍ទាក់ទងគ្នាទៅវិញទៅមក បើបាត់មួយណាហើយ កាយនោះនឹងកើតពិការភាពជាពុំខាន ។ បើបាត់សុខភាពឈ្មោះថា ខាតលាភយ៉ាងធំ (អរោគ្យា បរមាលាភា = ការមិនមានរោគជាលាភដ៏ឧត្តម) បើបាត់សមត្ថភាព អ្នកនឹងក្លាយខ្លួនដូចជាទីងមោងចាំចាប ហើយបើអ្នកបាត់គុណធម៌វិញ ជីវិតអ្នកនឹងអស់កិត្តិយសជាមិនខាន។

www.budinst.gov.kh www.elibraryofcambodia.org

# សីលាភិវឌ្ឍន៍ ឬ អភិវឌ្ឍន៍លើការរស់នៅក្នុងសង្គម

មនុស្សជាសត្វសង្គម (social animal) បានសេចក្ដីថា ត្រូវរស់នៅក្នុងសង្គម បញ្ចេញព្រឹត្តិកម្មជណ្ដប់ទៅលើសង្គម និងទទួលផលពីសង្គមមកវិញ ។ ពាក្យខ្មែរបានពោលថា ចានក្នុងរាវនៅតែរណ្ដំបែក ចុះទំរាំអ្វីមនុស្សដែលនៅជាមួយគ្នា នឹងមិនកើតជម្លោះនោះ? *សង្គម* គឺជាពាក្យបាលីដែលខ្មែរយកមកប្រើក្នុងន័យថា ការរស់នៅជាមួយគ្នា ការសេពគប់គ្នា សមាគមគ្នា ។ល។ ក្នុងភាសាបាលី ពាក្យថាសង្គម ក៏មានឫសមកពីពាក្យ សង្គាមៈ ដែលយើងប្រើជាសង្គ្រាម នៅក្នុងភាសាខ្មែរ-សំស្ក្រឹត ។ សង្គម ឬសង្គាម មានន័យតែមួយ ពោលគឺកាលណាមានមនុស្សចាប់ពីពីរនាក់ឡើងទៅមករួមរស់ជាមួយគ្នា(សង្គម) កាលនោះឯងដែលអ្នកទាំងពីរនោះចាប់ផ្ដើមមានសង្គ្រាម (សង្គាម) នឹងគ្នាឡើងដែរ តាំងពីការទាស់ពាក្យសំដីគ្នា ការរង្កៀសចិត្តគ្នា ការយកប្រៀបលើគ្នា ជណ្ដើមគ្នាស៊ីជាដើម ។ល។ ពាក្យខ្មែរលោកថា អណ្ដាតក្នុងមាត់ នៅមានឱកាសត្រូវធ្មេញខាំច្រឡំចេញឈាម ទំរាំអ្វីមនុស្សដែលនៅដាច់ពីគ្នានុ៎ះ! គំហើញរបស់ព្រះអង្គលើបញ្ហាសង្គម ជាគំហើញមួយដ៏តំទូលំទូលាយណាស់ ។ ថ្វីត្បិតតែការរស់នៅជាសង្គមមានបញ្ហាមែន តែព្រះអង្គបានយកចិត្តទុកដាក់នឹងបញ្ហាសង្គមទាំងនោះ ព្រមទាំងជំរុញឲ្យមនុស្សរស់ជាសង្គមទៀតផង ដូចជាករណីដែលព្រះអង្គបានកតាំងស្ថាប័នសង្ឃឡើងជាភស្ដុតាងស្រាប់ ព្រោះនេះគឺជាជំរើសសំរាប់និរន្តរភាពរបស់សង្គមមនុស្ស (សុខា សង្ឃស្ស សាមគ្គី សាមគ្គានំ) ប្រែថា ការរួមរស់ជាមួយគ្នា ជាសង្ឃ ជាក្រុម នាំមកនូវសេចក្ដីសុខ ។ ការរស់នៅជាមួយគ្នា (សង្គម,សង្ឃ) មានបញ្ហាមែន តែអត្ថប្រយោជន៍ដែលកើតពីការរួមរស់ជាមួយគ្នានោះ មានលើសលប់ពីបញ្ហាដែលមាន ។ ដូច្នោះហើយទើបព្រះពុទ្ធអង្គលោកបានបង្ហាញពីការចាំបាច់ដែលត្រូវដោះស្រាយលើរឿងការរស់នៅជាមួយគ្នា ដោយយកពាក្យថា សីល ជាមាត្រដ្ឋានក្នុងការអភិវឌ្ឍន៍ ។ ជំនាញលើការដោះស្រាយបញ្ហាការរស់នៅជាមួយគ្នានេះឯង ដែលធ្វើឲ្យព្រះអង្គបានទទួលកិត្តិនាមដ៏ខ្ពង់ខ្ពស់ថា «លោកវិទូ» = អ្នកប្រាជ្ញរឿងលោក រឿងមនុស្ស ឬដែលយើងតែងហៅថាសង្គមវិទូ ដែលប្រែថា អ្នកប្រាជ្ញខាងសង្គម។

www.budinst.gov.kh www.elibraryofcambodia.org

## អភិវឌ្ឍន៍ការរស់នៅជាមួយគ្នា ដូចម្ដេចខ្លះ?

### ១-អភិវឌ្ឍន៍សង្គមដោយមើលទៅលើព្រឹត្តិកម្ម (ឥន្ទ្រិយបារិសុទ្ធិសីល)

យើងបានឃើញរួចមកហើយនូវការអភិវឌ្ឍន៍ខាងរាងកាយ ដែលមានគោលបំណងដើម្បីឲ្យកាយមានសុខភាព គុណភាព និងគុណធម៌។ សារៈសំខាន់នៃការអភិវឌ្ឍន៍ ខាងផ្នែកគុណធម៌របស់កាយនៃបុគ្គលម្នាក់ៗ ត្រូវបានព្រះដ៏មានព្រះភាគលើកយកមកបញ្ជាក់ម្ដងទៀត នៅក្នុងការអភិវឌ្ឍន៍លើការរស់នៅក្នុងសង្គម ។ ចំពោះការអភិវឌ្ឍន៍ខាងផ្នែកព្រឹត្តិកម្មចំណុចទី ២ វិញ ទិសដៅគឺការធ្វើឲ្យមានការរីកចំរើនក្នុងកិច្ចទំនាក់ទំនងជាមួយអ្នកដែលនៅជុំវិញខ្លួន ដើម្បីធានាឲ្យបាននូវស្ថិរភាពនៃការរួមរស់ជាមួយគ្នាដ៏ស្ងប់សុខ។

វិញ្ញាណរបស់យើងទាំង ៥ នេះ ក្នុងបាលីលោកហៅថា ទ្វារ គឺកន្លែងចូលអារម្មណ៍ទាំងឡាយពីខាងក្រៅ និងជាកន្លែងចេញ នូវអារម្មណ៍ទាំងឡាយ ទៅខាងក្រៅវិញ ។ជួនកាល លោកឧបមានូវទ្វារទាំង ៥ នេះជា មាត់ សម្រាប់បរិភោគនូវអារម្មណ៍ទាំងឡាយ គឺភ្នែក បរិភោគរូប ត្រចៀកបរិភោគសំឡេង ច្រមុះបរិភោគក្លិន អណ្ដាតបរិភោគរសជាតិ និងកាយ បរិភោគវេទនាទាំងឡាយ ។ ដូច្នេះបើមាត់ទាំង ៥ នេះបរិភោគរបស់ដែលមិនមានអនាម័យល្អ មានមេរោគជិតជាប់ជាមួយ បរិភោគហួសប្រមាណ ក៏នឹងអាចធ្វើឲ្យបុគ្គលនោះមានសុខភាពមិនល្អ ឈឺពោះ មានជម្ងឺរ៉ាំរ៉ៃ ដែលនឹងធ្វើឲ្យបុគ្គលនោះ ជុះ ចេញ ឬបញ្ចេញមកវិញ នូវកាកសំណល់ដែលធ្វើឲ្យកើតពិសពុលដល់បរិដ្ឋានសង្គមជុំវិញជាពុំខាន ។ ជាឧទាហរណ៍ជាក់ស្ដែង គឺឥទ្ធិពលនៃ ទូរទស្សន៍ខ្លះដែលពុំបានប្រុងប្រយ័ត្នក្នុងការបញ្ចេញព្រឹត្តិកម្មរបស់ ខ្លួនតាមរយៈរូបភាពតំនូរជីវចលផ្សេងៗ មានរឿងកាប់ចាក់ តស៊ូឃោរឃៅ ជាដើមនេះអាច ធ្វើឲ្យកុមារទាំងឡាយយកតំរាប់តាម ហើយព្យាយាមបញ្ចេញនូវព្រឹត្តិកម្មដូចគ្នានេះដែរទៅលើបងប្អូនអ្នកជិតខាង សិស្សរួមថ្នាក់ផ្សេងៗ និងបរិដ្ឋានជុំវិញរបស់គេ ។ ដូច្នេះ ការអភិវឌ្ឍន៍លើការបញ្ចេញព្រឹត្តិកម្មនេះ ជាមូលដ្ឋានរបស់ការអភិវឌ្ឍន៍សង្គមមួយដ៏សំខាន់ ព្រោះវាមានផលប៉ះទង្គិច (Impact) ដោយត្រង់ទៅលើ មនុស្ស ដែលជាកោសិការបស់សង្គមនិមួយៗ ព្រោះថាបើកោសិកានិមួយៗមិនមានជម្ងឺទេ សង្គមនោះក៏នឹងមានសុខភាព, ល្អ

www.budinst.gov.kh www.elibraryofcambodia.org

ប្រសើរដែរ។

២-អភិវឌ្ឍន៍សង្គមដោយមើលទៅលើនិតិកម្មសង្គម (បាដិមោក្ខសំវរសីល)

ក្នុងការរស់នៅក្នុងសង្គម ថ្វីត្បិតតែការសង្រួមឥន្ទ្រីយ៍ទាំង ៥ គឺជាមូលដ្ឋាននៃសេចក្តីស្ងប់សុខមែន តែពុំទាន់គ្រប់គ្រាន់នៅឡើយដែរ ។ ការអភិវឌ្ឍន៍ផ្នែកព្រឹត្តិកម្មមានលក្ខណៈដូចជាការងារអាសាស្ម័គ្រ ដែលពឹងផ្អែកលើការផុះចេញពីទឹកចិត្ត ឬការភ្ញាក់រលឹកពីបុគ្គលម្នាក់ៗ ។ ចំពោះបុគ្គលដែលពុំមានទឹកចិត្ត ពុំមានការភ្ញាក់រលឹក ទើបជាការលំបាកណាស់ ដូច្នេះកតិកាសង្គមមួយ គប្បីកំណត់ឡើងដើម្បីប្រយោជន៍រួមគ្នាប្រយោជន៍កុំឲ្យបុគ្គលដែលពុំមានចិត្ត ឬស្មារតីទាំងនោះ មានការប្រព្រឹត្តិខុសដល់សង្គម ។ ក្នុងព្រះវិន័យ ការថែរក្សាសីលឲ្យបរិសុទ្ធ គឺពឹងផ្អែកទៅលើការសង្រួមឥន្ទ្រីយ៍នេះមួយ និងទីពីរ គឺគោរពទៅតាមភិក្ខុបាដិមោក្ខដែលជាគោលច្បាប់ដែលព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិទុកឲ្យពួកភិក្ខុគោរពតាម ។ ក្នុងសង្គមពុទ្ធ ព្រះពុទ្ធអង្គបានបែងចែកគោលច្បាប់នេះ ឲ្យបរិស័ទទាំង ៥ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា គោរពទៅតាមភេទ គុណធម៌ និងសមត្ថភាពនៃការដែលអាចបដិបត្តិបាន។ ចំពោះភិក្ខុ គោលច្បាប់នេះមាន ២២៧ មាត្រា (សិក្ខាបទ) ភិក្ខុនីមាន ៣១១ សិក្ខាបទ, សាមណេរមាន ១០ សិក្ខាបទ, ឧបាសក-ឧបាសិកាមាន ១០ សិក្ខាបទខ្លះ ៨ សិក្ខាបទខ្លះ និងសំរាប់មនុស្សទូទៅមាន ៥ សិក្ខាបទ។

ក្នុងសង្គមទូទៅ ការបង្កើតឡើងនូវច្បាប់ និងការគោរពច្បាប់ គឺជាគោលសំខាន់ជាងអ្វីទាំងអស់ ហើយដែលត្រូវតែខានមិនបាន ព្រោះខាងសង្គមគេពុំសូវបានចាប់អារម្មណ៍លើការសង្រួមឥន្ទ្រីយ៍បែបពុទ្ធសាសនាឡើយ ។ ច្បាប់រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលរបស់ប្រទេសនីមួយៗ ដែលតម្រូវឲ្យពលរដ្ឋគោរពតាមឲ្យបាន ហើយក្រៅពីនោះក៏មានច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ វិន័យ សវាចារ ទំនៀមទំលាប់ សុជីវធម៌ បទដ្ឋាននានា ដែលពលរដ្ឋម្នាក់ៗ គប្បីស្វែងរកការចេះដឹង និងគោរពតាមកុំឲ្យខុស។

ការមិនអនុវត្តតាម សីល ដែលព្រះសម្មាសម្ពុទ្ធបានចែងទុកមក និងមិនគោរពតាមច្បាប់រដ្ឋ ឬច្បាប់សង្គម គឺជាកំហុស ឬដែលព្រះវិន័យហៅថា អាបត្តិ ។ តែទោះជាយ៉ាងណាក្តី មាត្រាទាំងឡាយដ៏ច្រើននេះ អាចបង្រួមមកនៅត្រឹមតែ ៥ មាត្រា (សិក្ខា

www.budhist.gov.kh www.elibraryofcambodia.org

បទ) ដើម្បីឲ្យងាយស្រួលចាំ និងអនុវត្តបាន ដែលព្រះវិន័យលោកហៅថា និច្ចសីល គឺសីល ឬច្បាប់ដែលត្រូវមានប្រចាំគ្រប់នាទី គ្រប់ម៉ោងទាំងអស់ ។ សីល ៥ ឬ សិក្ខាបទដែលត្រូវរៀនធ្វើ ឬអភិវឌ្ឍន៍ឲ្យកើតមានដល់ខ្លួននោះ ខ្ញុំបានអធិប្បាយរួចម្តងហើយនៅក្នុងវគ្គ ការបដិបត្តិធម៌ គឺការសិក្សា ដែលនៅក្នុងនោះមាន ៖

១- គោរពសិទ្ធិក្នុងការមានជីវិតរស់នៅរបស់សត្វមានជីវិតទាំងឡាយ ដោយមិនបៀតបៀនដល់សេចក្តីសុខ មិនធ្វើបាបរាងកាយ និងមិនសម្លាប់ជាដាច់ខាត ចំពោះជីវិតមនុស្សទាំងឡាយ ដោយចេតនា (សិក្ខាបទទី ១ = បាណាតិបាតាវេរមណី)

២- គោរពសិទ្ធិលើការគ្រប់គ្រងកម្មសិទ្ធិរបស់អ្នកដទៃ ទាំងជាកម្មសិទ្ធិផ្ទាល់ខ្លួន និងកម្មសិទ្ធិសាធារណៈ ដោយមិនបៀតបៀន បំផ្លាញ លួចឆក់របស់ទ្រព្យ កម្មសិទ្ធិទាំងនោះ ដោយគេមិនបានអនុញ្ញាត ដោយចេតនាអាក្រក់ ។ (សិក្ខាបទទី ២ = អទិន្នាទានា វេរមណី)

៣- គោរពប្រពៃណីនៃការរួមរស់ជាមួយគ្នាក្នុងឋានៈជាស្វាមីភរិយា ក្រុមគ្រួសារ ដោយមិនប្រព្រឹត្តបំពានទៅលើស្វាមី ភរិយា កូនរបស់គេ(សិក្ខាបទទី ៣ = កាមេសុមិច្ឆាចារា វេរមណី)

៤- ប្រកាន់ទៀងត្រង់ មិននិយាយកុហកបោកបញ្ឆោតគេដោយការមិនពិត (សិក្ខាបទទី៤ = មុសាវាទា វេរមណី)

៥- វៀរចាកមិនប្រព្រឹត្តការសេពគ្រឿងស្រវឹង គ្រឿងញៀន ដែលនាំឲ្យសតិស្មារតី កើតវិប្បលាស កើតសេចក្តីប្រមាទ ហើយប្រព្រឹត្តនូវអំពើមិនគប្បីទាំងឡាយ (សិក្ខាបទទី ៥ = សុរាមេរយ មជ្ជបមាទដ្ឋានា វេរមណី)

ពុទ្ធសាសនិកត្រូវរៀនអភិវឌ្ឍន៍ខ្លួនឲ្យស្ថិតនៅយ៉ាងហោចណាស់ ក៏ក្នុងការប្រកាន់ខ្ជាប់តាមសិក្ខាបទ ឬមាត្រាទាំង ៥ នេះ ឲ្យបានជានិច្ច ព្រោះថា នេះជាមេច្បាប់មូលដ្ឋាននៃសេចក្តីស្ងប់សុខក្នុងសង្គម ។ ក្រៅពីនេះ ការគោរពច្បាប់ក្នុងសង្គម ប្រពៃណី ទំនៀម ទំលាប់ សាសនា សុជីវធម៌នានា តាមភូមិភាគ តាមតំបន់ជាដើមនេះ រាប់ចូលទៅក្នុងការអភិវឌ្ឍន៍ខ្លួន និងសង្គម បែបនិតិកម្មទាំងអស់ ។

## ៣-អភិវឌ្ឍន៍សង្គមដោយមើលទៅលើផ្នែកអាជីវកម្ម (អាជីវបារិសុទ្ធិសីល)

www.budinst.gov.kh www.elibraryofcambodia.org

ជាការមួយដែលមិនអាចប្រកែកបានឡើយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា (សព្វេ សត្តា អាហារដ្ឋិតា = សត្វទាំងឡាយរស់បានដោយអាហារ) ។ ដូច្នេះ ដើម្បីបានរស់ មនុស្សទាំងឡាយត្រូវតស៊ូទន្ទៀល ស្វះស្វែងរកអាហារនោះមកចិញ្ចឹមជីវិតខ្លួនជាចាំបាច់ ។ ក្នុងការស្វះស្វែងរកបច្ច័យទាំង ៤ ដើម្បីតបស្នងដល់សេចក្តីត្រូវការខាងរាងកាយនេះ មនុស្សប្រើគ្រប់មធ្យោបាយទាំងអស់ ទាំងល្អទាំងអាក្រក់ ដើម្បីសំរេចឲ្យបាន ជាពិសេសនាសម័យបច្ចុប្បន្ននេះ លុយ ដែលបានក្លាយទៅជាប្រភពនៃវត្ថុទាំងពួងនោះ មធ្យោបាយដើម្បីរកលុយបានកើតឡើងគ្រប់រូបភាពទាំងអស់ ។ គេអាចរកលុយដោយការងារសុចរិត គេអាចរកលុយដោយការលក់គ្រឿងសព្វាវុធ ដោយការប្រព្រឹត្តខុសច្បាប់គ្រប់បែបយ៉ាង ទាំងដោយចេតនា និងដោយការចាំបាច់ជាដើម ។ ដូច្នេះ បើសង្គមណាមានសមាជិកប្រកបរបរអាជីវកម្មមិនសុចរិត ឬនិយាយឲ្យងាយស្តាប់ថា រកលុយបានមកដោយមិនសុចរិត សង្គមនោះនឹងមិនអាចមានសន្តិសុខបានឡើយ ប្រាកដជាកើតមានវិបត្តិសង្គមជាក់ជាពុំខាន ។ ជាការសំខាន់ណាស់ ការអភិវឌ្ឍន៍លើការរស់នៅជាមួយគ្នាដោយសុខដុមរម្យនា មិនអាចមើលរំលងបច្ច័យអាជីវកម្មរបស់បុគ្គលម្នាក់ៗ ឬគ្រួសារនីមួយៗបានឡើយ ។ រឿងនេះ ក៏ជាករណីឆ្លុះបញ្ចាំង លើផ្នែកម្ខាងទៀតបានដែរថា កាលណាមនុស្សឥតមានអាជីវកម្ម ឬឥតការងារធ្វើ ក៏នឹងអាចឲ្យមនុស្សនោះប្រព្រឹត្តអំពើមិនគប្បី ដើម្បីរកឲ្យខាងតែបានទូវបច្ច័យសំរាប់ទ្រទ្រង់ជីវិតខ្លួនជាពុំខាន ។ ជ្រុងនេះចង់បង្ហាញថា ការបង្កើតការងារ និងការផ្តល់ឲ្យមនុស្សមានការងារធ្វើគ្រប់គ្រាន់ ក៏នឹងអាចលុបបំបាត់អាជីវកម្មទុច្ចរិតបានមួយផ្នែកធំដែរ ។

## ៤-អភិវឌ្ឍន៍សង្គមដោយមើលលើការបរិភោគប្រើប្រាស់(បច្ចយសន្និស្សិតសីល)

ព្រះសម្មាសម្ពុទ្ធ គឺជាលោកវិទូមួយរូប ដែលបានសំឡឹងមើលវិវឌ្ឍនាការរបស់សង្គម ដោយគ្រប់ជ្រុងជ្រោយទាំងអស់ គឺទាំងជ្រុងចិត្តវិទ្យា(ឥន្ទ្រិយសំវរៈសីល) ជ្រុងសង្គម(បាដិមោក្ខសំវរៈសីល) និងជ្រុងសេដ្ឋកិច្ច(អាជីវបារិសុទ្ធិសីល) ។ ក្នុងទ្រឹស្តីរបស់សាស្តានៃសាសនាទេវនិយមទាំងឡាយ និងក្នុងខ្សែរឿគអ្នកសេដ្ឋវិទូ សង្គមវិទូទាំងឡាយដ៏ច្រើន គេមានជំនឿថា ធម្មជាតិដែលមាននៅលើលោកនេះ ទាំងមានជីវិតក្តីឥតជីវិតក្តី ជារបស់ដែលបង្កើតមកសំរាប់មនុស្សប្រើប្រាស់តាមសេចក្តីប្រាថ្នា ។ ទ្រឹស្តី

www.budinst.gov.kh www.elibraryofcambodia.org

នេះបានពន្យុះនូវមហិច្ឆតារបស់មនុស្សឲ្យដណ្តើម ប្រជែង លួចប្លន់ យកនូវរបស់ទាំងនោះពីធម្មជាតិ យកមកប្រើប្រាស់យ៉ាងខ្ជះខ្ជាយបំផុត ទៅតាមចំណង់ដែលគ្មានព្រំដែន និងលើសពីសេចក្តីត្រូវការរបស់រាងកាយ ។ លទ្ធិបរិភោគនិយមនេះបានធ្វើឲ្យពិភពលោកកំពុងតែហិនហោចទៅៗ ធ្វើឲ្យមានចន្លោះរវាងវណ្ណៈ មូលធន និងអធនកាន់តែខ្លាំងឡើង ។ ការឃ្លាតឆ្ងាយគ្នារវាងវណ្ណៈទាំង ២ និងការដណ្តើមគ្នាបរិភោគទៅតាមចំណង់នៃវណ្ណៈនីមួយៗ បានធ្វើឲ្យពិភពលោកនេះ និងសង្គមរាល់សង្គម កើតការមិនស្ងប់ឡើយ ៖ សង្គ្រាមក្តៅដើម្បីអាណានិគមដែនដី សង្គ្រាមត្រជាក់ដើម្បីអាណានិគមលទ្ធិនយោបាយ សង្គ្រាមញញឹមដើម្បីអាណានិគមសេដ្ឋកិច្ច ។ យ៉ាងណាក៏ដោយបើមនុស្សពុំបានទប់ចំណង់របស់ខ្លួនលើការប្រើប្រាស់ និងបរិភោគវត្ថុទាំងឡាយទេនោះ សេចក្តីស្ងប់សុខពិតប្រាកដ ច្បាស់ជាមិនអាចកើតឡើងបានទេ ។ ព្រះសម្មាសម្ពុទ្ធ គឺជាលោកវិទូតែមួយរូបគត់ ដែលសំឡឹងមើលវិវឌ្ឍនាការរបស់សង្គម លើជ្រុងការបរិភោគ(បច្ច័យសន្និស្ស័ទសីល) ។ ព្រះអង្គបានទូន្មានអំពីការបរិភោគដោយមានប្រមាណ (ភោជនេមត្តញ្ញុតា) គឺ <u>មិនបរិភោគទៅតាមតណ្ហាចិត្តទេ តែបរិភោគទៅតាមសេចក្តីត្រូវការរបស់រាងកាយ</u>តែប៉ុណ្ណោះ។

ក្នុងវិន័យ មុននឹងបរិភោគប្រើប្រាស់ ភិក្ខុត្រូវសម្លឹងគិតថា ការប្រើប្រាស់ការបរិភោគរបស់ខ្លួន គឺដើម្បីឲ្យជីវិតអាចរស់នៅបាន និងដើម្បីបំពេញប្រយោជន៍ឲ្យដល់ខ្លួន និងសង្គម គឺមិនបរិភោគប្រើប្រាស់ខ្ជះខ្ជាយនោះទេ ។ យើងអាចនិយាយជាភាសាសាមញ្ញថា <u>ស៊ីដើម្បីរស់</u> <u>មិនមែនរស់ដើម្បីស៊ីទេ</u> ។ ដូច្នេះ បច្ច័យចុងក្រោយបង្អស់ ដើម្បីធានាសុវត្ថិភាព និងវឌ្ឍនភាពសង្គម ប្រាសចាកសង្គ្រាម ម្នាក់ៗអាចរស់នៅជាមួយគ្នាដោយសន្តិនោះ គឺការគិតឲ្យបានច្បាស់លើការប្រើប្រាស់ដ៏សន្សំសំចៃនូវផលិតផលទាំងឡាយដែលខ្លួនរកបាន និងដែលខ្លួនមាន ព្រោះថាផលិតផលទាំងនោះមានគ្រប់គ្រាន់សំរាប់មនុស្សដែលត្រូវការ តែមិនគ្រប់គ្រាន់ទេសំរាប់អ្នកដែលមានចំណង់ ។ ជាពិសេស ទ្រព្យសម្បត្តិធម្មជាតិទាំងឡាយដែលប្រើអស់ហើយ មិនអាចកើតឡើងទៀតបាន ដូចជារ៉ែផ្សេងៗ ជាដើមនេះ ត្រូវប្រើប្រាស់ដោយស្មារតីទទួលខុសត្រូវឲ្យបានខ្ពស់ ។ ដើម្បីឲ្យបានច្បាស់ថា ការអភិវឌ្ឍន៍រឿងការរស់នៅក្នុងសង្គម ឬការអភិវឌ្ឍន៍សីល មានសារៈសំខាន់ដូចម្តេចនោះ សូមលើកយកពុទ្ធភាសិតមួយចំនួន

www.budinst.gov.kh www.elibraryofcambodia.org

មកធ្វើជាភស្តុតាងដូចតទៅ ៖

សីលំ កិរេវ កល្យាណំ សីលនេះឯង ជារបស់ល្អ
សីលំ លោកេ អនុត្តរំ
មានតែសីលទេ ដែលប្រសើរជាងគេក្នុងសង្គម
សីលមេវិធ សិក្ខេថ អស្មឹ លោកេ សុសិក្ខិតំ
សីលំ ហិ សព្វសម្បត្តឹ ឧបនាមេតិ សេវិតំ
គប្បីសិក្សាអំពីសីលក្នុងលោកនេះ ព្រោះសីលដែលគេសិក្សាល្អហើយ
សេពសមហើយក្នុងលោកនេះ រមែងបង្អោនមកនូវសម្បត្តិទាំងពួង

សីលំ រក្ខេយ្យ មេធាវី បត្ថយានោ តយោ សុខេ
បសំសំ វិត្តិលាភញ្ច បេច្ច សគ្គេ បមោទនំ
អ្នកដែលប្រាថ្នាសុខ ៣ យ៉ាង គឺការសរសើរ ១, ការបាននូវទ្រព្យសម្បត្តិ ១,
សេចក្តីរីករាយក្នុងស្ថានសួគ៌ ១, គប្បីរក្សាសីល

## ចិត្តាភិវឌ្ឍន៍ ឬការអភិវឌ្ឍន៍ដើម្បីបានឋានៈជាមនុស្សជាតិ(ចិត្តភាវនា)

មនោបុព្វង្គមា ធម្មា
ទង្វើដែលមនុស្សបានធ្វើ សុទ្ធតែនាំមុខដោយចិត្តទាំងអស់
មនោសេដ្ឋា មនោមយា
មានចិត្តជាអ្នកបង្គាប់បញ្ជា និងអាចសំរេចបានក៏ព្រោះចិត្ត
មនសា ចេ បទុដ្ឋេន
បើអ្នកណាមានចិត្តមិនល្អ ចិត្តទន់ខ្សោយ ចិត្តបាបហើយ
ភាសតិវា ករោតិវា
ទោះជាអ្នកនោះ និយាយក្តី ធ្វើក្តី
តតោ នំ ទុក្ខមន្វេតិ
ក៏នឹងមានតែសេចក្តីទុក្ខ បញ្ហា លំបាក ជាលទ្ធផលតាមមកតែប៉ុណ្ណោះ

www.budihst.gov.kh www.elibraryofcambodia.org

**ចក្កំវ វហតោ បទំ**

ឧបមាដូចជាកង់រទេះ ដែលវិលតាមពីក្រោយជើងគោដូច្នោះដែរ ។

**មនោបុព្វង្គមា ធម្មា**

ទង្វើដែលមនុស្សបានធ្វើ សុទ្ធតែនាំមុខដោយចិត្តទាំងអស់

**មនោសេដ្ឋា មនោមយា**

មានចិត្តជាអ្នកបង្គាប់បញ្ជា និងអាចសំរេចបានក៏ព្រោះចិត្ត

**មនសា ចេ បសន្នេន**

បើអ្នកណាមានចិត្តសប្បុរស ចិត្តរឹងប៉ឹង ចិត្តបុណ្យហើយ

**ភាសតិ វា ករោតិ វា**

ទោះជាអ្នកនោះ និយាយក្តី ធ្វើក្តី

**តតោ នំ សុខមន្វេតិ**

ក៏នឹងមានតែសេចក្តីសុខ គ្មានបញ្ហា ជាលទ្ធផលទាំងអស់

**ឆាយាវ អនុបាយិនី**

ឧបមាដូចជាស្រមោល ដែលតែងអន្ទោលតាមប្រាណដូច្នោះដែរ ។[21]

ពុទ្ធវចនៈខាងលើនេះ ជាករណីបញ្ជាក់យ៉ាងច្បាស់ថា ហេតុអ្វីបានជាយើងត្រូវធ្វើការអភិវឌ្ឍន៍ចិត្តដោយខានមិនបាន នៅក្នុងប្រព័ន្ធនៃការអភិវឌ្ឍន៍ជីវិតតាមបែបព្រះពុទ្ធសាសនា ។ ព្រោះថា បើចិត្តមិនមានសុខភាព មិនមានសមត្ថភាព និងមិនមានគុណធម៌ល្អទេ ជីវិតយើងក៏នឹងជួបតែសេចក្តីទុក្ខ បញ្ហា មិនចេះចប់ជាមិនខាន ។ ជាឧទាហរណ៍ គឺសង្គ្រាម កាប់សម្លាប់គ្នា ការវិនាសហិនហោចទ្រព្យសម្បត្តិធម្មជាតិ ទុរ្គតភាពក្នុងពិភពលោកទាំងអស់នេះ សុទ្ធតែកើតមកពីចិត្តដែលមានសេចក្តីលោភលន់មិនចេះស្កប់ស្កល់ពីចិត្តដែលមាន កំហឹងក្តៅក្រហាយ ចិត្តព្យាបាទ និងពីចិត្តដែលយល់ខុសថាជាត្រូវ ត្រូវថាជាខុសនេះឯង ។ បើសិនជាពិភពលោកនេះមានមនុស្ស ដែលមានសេចក្តីលោភលន់តិចជាងសព្វថ្ងៃនេះតែបន្តិច មានកំហឹងគុំគួនថយចុះបន្តិច មានការ

21 ធម្មបទគាថា, ចិត្តវគ្គ

www.budinst.gov.kh www.elibraryofcambodia.org

យល់ថាអ្នកម្នាក់ទៀតក៏មានចិត្តចង់រស់ដូចខ្លួន ឲ្យបានច្រើនជាងនេះបន្តិច ពិភពលោកនេះប្រាកដជាពោរពេញដោយក្លិនក្រអូបនៃការញញឹមដាក់គ្នា ជួយសង្គ្រោះគ្នា និងស្រស់បំព្រងដោយរុក្ខជាតិ និងបុប្ផជាតិពណ៌ខៀវក្រហម ជាក់ជាពុំខាន។

សង្ឃឹមថា មនុស្សជាតិទាំងអស់ នឹងភ្ញាក់រលឹកដើម្បីអភិវឌ្ឍន៍ចិត្តរបស់គេ!

## គុណសម្បត្តិនៃចិត្តដែលបានទទួលការអភិវឌ្ឍន៍

ការអភិវឌ្ឍន៍ផ្លូវចិត្តក្នុងព្រះពុទ្ធសាសនា សំដៅការព្យាបាលចិត្តឲ្យជាចាករោគទាំងពួង (សុខភាព) ពង្រឹង និងបន្ថែមកម្លាំង ដើម្បីឲ្យចិត្តអាចបំពេញកិច្ចការបានយ៉ាងមានប្រសិទ្ធិភាព (សមត្ថភាព) និងបំពាក់អលង្ការឲ្យចិត្តកាន់តែមានលំអរប្រសើរឡើង (គុណធម៌)។

នៅក្នុងមង្គលសូត្រ ចិត្តដែលទទួលការអភិវឌ្ឍន៍ហើយ គឺ៖

១) ចិត្តដែលនឹងធឹង មិនកំរើករំពើក នៅពេលដែលលោកធម៌ទាំង ៨ ចូលមកប៉ះពាល់ (ផុដ្ឋស្ស លោកស្ស ធម្មេហិ ចិត្តំ យស្ស ន កម្បតិ)

២) ចិត្តដែលមិនមានសេចក្តីសោកសៅ (អសោកំ)

៣) ចិត្តដែលមិនមានធូលី គឺកិលេសទាំង ១៦ ស្ថិតនៅក្នុងសន្តាន (វិរជំ) និង

៤) ចិត្តដែលមានតែសុខក្សេមក្សាន្ត មិនមានទុក្ខ ចិត្តមាននិរភ័យ (ខេមំ)

នៅក្នុងព្រះបាលី លោកបានបង្ហាញពីគុណភាពចិត្តដែលបានទទួលការអភិវឌ្ឍន៍តាមការធ្វើសមាធិ ថា ៖

| | |
|---|---|
| ១. សមាហិតៈ | មានភាពមាំមួន |
| ២. បរិសុទ្ធៈ | មានភាពបរិសុទ្ធ |
| ៣. បរិយោទាតៈ | ល្អិតល្អន់ |
| ៤. អនង្គណៈ | ថ្លា |
| ៥. វិគតូបកិលេស | មិនមានគ្រឿងសៅហ្មង |
| ៦. មុទុភូតៈ | ទន់ភ្លន់ |
| ៧. កម្មនិយៈ | គួរដល់ការងារ |

www.budhist.gov.kh www.elibraryofcambodia.org

៨. បិត អនេញ្ជប្បត្តៈ នឹង មិនញាប់ញ័ររំជួយ

មកដល់ត្រង់នេះ លោកអ្នកអានប្រាកដជាអស់សង្ស័យហើយ ថាហេតុអ្វីបានជាព្រះពុទ្ធអង្គលោកសរសើរការធ្វើសមាធិ និងមានពុទ្ធដីកាពីសេចក្តីត្រូវការ ដើម្បីអភិវឌ្ឍន៍ផ្លូវចិត្តរបស់មនុស្ស ។ នាបច្ចុប្បន្ននេះ ការអភិវឌ្ឍន៍ផ្លូវចិត្តបានឈានឆ្ពោយទៅជាលក្ខណៈវិទ្យាសាស្ត្រ និងជាសកលដែលមនុស្សជាតិទាំងអស់ មិនថាតែពុទ្ធសាសនិកជនទេដែលធ្វើ សូម្បីតែសាសនិកនៃសាសនាដទៃក៏នាំគ្នាធ្វើដែរ ព្រោះគេយល់ថាមានប្រយោជន៍ខ្លាំង ក្នុងជីវិតដែលមានតែការប្រណាំងប្រជែងគ្នាដូចសព្វថ្ងៃនេះ ។

ក្រៅពីនេះ វេជ្ជបណ្ឌិតមួយចំនួនបានដើរទៅមុខកាន់តែឆ្ងាយ ដោយការយកសមាធិទៅព្យាបាលជំងឺធ្ងន់ៗទាំងឡាយ ដូចជាជំងឺមហារីកផ្សេងៗ ជំងឺឡប់សតិ ជំងឺវិបត្តិផ្លូវចិត្តជាដើម យ៉ាងមានប្រសិទ្ធិភាព និងស៊ុះសាយ ។

**ចិត្តេន នីយតិ លោកោ** ពិភពលោកនេះ មានចិត្តជាអ្នកដឹកនាំ
**វិហញ្ញតិ ចិត្តវសានុវត្តី** អ្នកដែលធ្វើអ្វីស្រេចតែចិត្ត រមែងលំបាក
**ចិត្តំ ទន្តំ សុខាវហំ** ចិត្តដែលបានអភិវឌ្ឍន៍ហើយ នាំសុខមកឲ្យ

**យោ ច សទ្ទបរិត្តាសី** **វនេ វាតមិគោ យថា**
**លហុចិត្តោតិ តំ អាហុ** **នាស្ស សម្បជ្ជតេ វតំ។**
អ្នកណាដែលគ្រាន់តែឮសំលេងហើយភ្ញាក់ផ្អើលដូចសត្វស្មាន់ក្នុងព្រៃ
លោកហៅអ្នកនោះថាមានចិត្តស្រាល កិច្ចការអ្នកនោះរមែងមិនសំរេចទេ។

**ទូរង្គមំ ឯកចរំ** **អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ** **មោក្ខន្តិ មារពន្ធនា។**
ចិត្តតែងត្រាច់ទៅឆ្ងាយ ដើរទៅតែឯង មិនមានរាងកាយ រស់នៅក្នុងគុហា បើជនណាបានសង្រួមចិត្តឲ្យនៅនឹងបានហើយ ជននោះនឹងអាចរួចអំពីចំណងរបស់មារបាន ។

www.budinst.gov.kh www.elibraryofcambodia.org

## បញ្ញាភិវឌ្ឍន៍ ឬការអភិវឌ្ឍន៍ដើម្បីរំលត់នូវសេចក្ដីទុក្ខ (បញ្ញាភាវនា)

មនុស្ស គឺជាសត្វមានបញ្ញា ។ បញ្ញានេះធ្វើឲ្យមនុស្សមានលក្ខណៈ និងការរស់នៅខុសប្លែកពីសត្វតិរច្ឆានទាំឡាយ ។

បញ្ញាមាន ២ យ៉ាង គឺបញ្ញាដែលមានប្រយោជន៍សំរាប់ការចិញ្ចឹមជីវិត ចិញ្ចឹមរាងកាយឲ្យលូតលាស់ និងដោះស្រាយបញ្ហាទាំងពួងដែលកើតមានក្នុងជីវិត (លោកិយបញ្ញា) និងបញ្ញាសំរាប់ដោះស្រាយសេចក្ដីទុក្ខដែលមានចំពោះចិត្តជារៀងរាលវិនាទី និងដើម្បីកំចាត់សេចក្ដីទុក្ខទាំងនោះឲ្យអស់ទៅ (លោកុត្តរបញ្ញា) ។

ចំពោះការពន្យល់ពីពាក្យថាបញ្ញា និងលក្ខណៈបញ្ញា មាននិយាយរួចពីខាងដើមខ្លះមកហើយ ក្នុងទីនេះ សូមនិយាយតែពីរបៀបធ្វើយ៉ាងដូចម្ដេច ដើម្បីឲ្យកើតបញ្ញាប៉ុណ្ណោះ ។

**១-បញ្ញាអាចកើតឡើងបានអាស្រ័យដោយការរៀន** តាមរយៈភ្នែក ត្រចៀក ច្រមុះ អណ្ដាត និងការប៉ះពាល់ (សម្ផស្ស) ។ ការបះទង្គិច រវាងប្រសាទទាំង ៥ ជាមួយនឹងវត្ថុមក ពីក្រៅនឹងធ្វើឲ្យកើនចំណេះ និងបញ្ញាដល់មនុស្សបាន ពីកម្រិតមួយទៅកម្រិតមួយ។ ពាក្យថា **ការរៀន** នេះ រួមទាំងការរៀនដោយខ្លួនឯង ដូចជាការសង្កេត ការមើល ការស្ដាប់ ការ ភ្លក់ជាដើម រួមទាំងការរៀនអំពីគ្រូ អំពីសៀវភៅ ឧបករណ៍ជំនួយ ។ល។ ទាំងអស់នេះ សុទ្ធតែជាប្រភពនាំឲ្យកើតបញ្ញាទាំងអស់ ។ ជាឧទាហរណ៍ក្នុងព្រះពុទ្ធសាសនា គឺកាលដែលព្រះសារីបុត្របានជួបព្រះអស្សជិ ជាពុទ្ធសាវ័កនៅតាមផ្លូវ ក៏សុំឲ្យលោកសំដែងធម៌ ។ ព្រះអស្សជិ លោកក៏ពោល ត្រឹមតែខ្លីៗថា ៖

**< យេ ធម្មា ហេតុប្បភវា — តេសំ ហេតុំ តថាគតោ**
**តេសញ្ច យោ និរោធោ ច — ឯវំ វាទី មហាសមណោ >**

<មហាសមណៈគឺព្រះសម្មាសម្ពុទ្ធ តែងមានពុទ្ធដីកាតែអំពីធម៌ណាដែលកើតពីហេតុ និងឧបាយសំរាប់រំលត់នូវហេតុរបស់ធម៌នោះ> តែប៉ុណ្ណោះ ព្រះសារីបុត្រក៏កើតបញ្ញាបានសំរេច ជាព្រះសោតាបន្នបុគ្គលភ្លាម ។ នេះជាលក្ខណៈរបស់បញ្ញដែលកើតមកអំពីរៀនដែលក្នុង បាលីលោកហៅថា សុតមយបញ្ញា ។

www.budinst.gov.kh www.elibraryofcambodia.org

២-បញ្ញាកើតឡើងអាស្រ័យដោយការត្រិះរិះ គិតសញ្ជឹង យកមកវិភាគពិចារណាតាមរបៀបហេតុផល ។ ក្នុងបាលីលោកហៅថា ចិន្តាមយបញ្ញា ។

នៅក្នុងសុតមយបញ្ញា យើងស្តាប់ អាន រៀនទូវទិន្នន័យ (data) ផ្សេងៗជាច្រើន ។ ចំណែកចិន្តាមយបញ្ញាវិញ គឺការនាំទិន្នន័យទាំងអស់នោះមកពិចារណាទៅតាមហេតុផល រហូតដល់ចម្រាញ់បានទូវសម្មតិកម្ម មួយដែលយើងសន្មតថាពិត ។ ពេលនោះហើយដែល យើងរៀនបានទូវចំណេះដឹងថ្មីមួយទៀត ។ ឧទាហរណ៍ ៖

ក- កា កិ កី កឹ ទៅលេងទឹកសមុទ្រជាមួយគ្នា។ លេងឆ្អែតហើយក៏នាំគ្នាឡើងមកវិញដើម្បីទទួលទានអាហារ ។

ខ- មួយសន្ទុះក្រោយមក កិ កី និងកឹ ក៏ឈឺពោះជាខ្លាំង ហើយរាករូសគ្រប់គ្នាលើកលែងតែ កា ដែលមិនមានកើតអ្វី ។

គ- កា ចង់ដឹងថារឿងនេះមានមូលហេតុពីអ្វី ទើបសាកសួរមិត្តទាំង ៣ នាក់ថាអ្នកណាញុាំអ្វីខ្លះ ដែលមានទិន្នន័យដូចខាងក្រោម៖

-កិ ញុាំមាន់អាំង បុកល្ហុងក្តាម សាច់ជ្រូកខ្ទៀន នំបញ្ចុក កាហ្វេ

-កី ញុាំសាច់គោអាំង បុកល្ហុងក្តាម នំប៉ាវ ទឹកក្រូចកំប៉ុង

-កឹ ញុាំសម្លម្ជូរសាច់គោ ណែម បុកល្ហុងក្តាម ស្រាបៀរ

-ឯ កា ខ្លួនឯង ញុាំសម្លម្ជូរ មាន់អាំង ណែម ទឹកក្រូច

ឃ- ពេលដែលបានទិន្នន័យហើយ កា ក៏ពិចារណាទៅលើម្ហូបទាំងនោះថា មានអ្នកណាខ្លះញុាំម្ហូបដូចគ្នា ក៏រកឃើញថា កិ កី កឹ ញុាំបុកល្ហុងដូចគ្នា ឯ កា មិនបានញុាំទេ

ង- កា ក៏សន្និដ្ឋានថា ការដែល កិ កី និងកឹ ញុាំបុកល្ហុងនេះឯង ដែលនាំឲ្យរាករូសឈឺពោះ

ការទទួលនូវចំណេះដឹង បញ្ញា តាមបែបផែននៃការគិតបែបនេះហៅថា បញ្ញាកើតឡើងដោយការគិត ឬ ចិន្តាមយបញ្ញា ។

៣-បញ្ញាដែលកើតឡើងដោយការពិសោធន៍ ឬភាវនាមយបញ្ញា ជាបញ្ញាឬពុទ្ធិ ដែលកើតឡើងព្រោះបានធ្វើការពិសោធន៍ ឬមានពិសោធន៍លើរបស់នោះជាច្រើនដងមកហើយ ។ ឧទាហរណ៍ មនុស្សម្នាក់គូររូបជាយូរឆ្នាំមកហើយ រមែងគូរកាន់តែបាន

www.budinst.gov.kh www.elibraryofcambodia.org

ល្អ ព្រោះមានការពិសោធន៍ថា ថ្នាំនេះលាយប៉ុននេះល្អ លាបប៉ុននោះ ដាក់ទំងន់ដៃត្រង់នេះ នឹងចេញសោភ័ណបែបណាៗ ។ បញ្ញាប្រភេទនេះ ត្រូវការយកចិត្តទុកដាក់ធ្វើហើយធ្វើទៀត គិតហើយគិតទៀតជារឿយៗ និងមានអារម្មណ៍បាញ់ផ្ដោតទៅលើតែរបស់នោះ (មានសមាធិចិត្ត) ជានិច្ច រហូតទាល់តែឃើញច្បាស់ដោយខ្លួនឯងថា ឱ! របស់នេះអញ្ចឹងទេតើហ្ន៎!

ខាងផ្នែកផ្លូវធម៌ ការតម្រង់ចិត្តបាញ់ផ្ដោះទៅលើកាយ វេទនា ចិត្ត និងធម៌ ជារឿយៗ ជាញឹកញាប់ និងជាបន្ត (ភាវនា) និងនាំឲ្យគេមើលឃើញជីវិតនេះយ៉ាងច្បាស់ (បញ្ញា) ថា ជីវិតនេះមិនទៀង (អនិច្ចំ) ធន់នៅសភាពដើមមិនបាន (ទុក្ខំ) និងមិនមែនរបស់ខ្លួន (អនត្តា) ។

**បញ្ញា លោកស្មិំ បជ្ជោតោ** បញ្ញា ជាពន្លឺបំភ្លឺលោក
**បញ្ញា ច ធនេន សេយ្យា** បញ្ញាហ្នឹងឯង ប្រសើរជាងទ្រព្យ
**ជីវតេវាបិ សប្បញ្ញោ** **អបិ វិត្តបរិក្ខយា**
**បញ្ញាយ ច អលាភេន** **វិត្តវាបិ ន ជីវតិ ។**

អ្នកមានបញ្ញា សូម្បីអស់ទ្រព្យក៏រស់នៅបាន តែបើមិនមានបញ្ញា សូម្បីមានទ្រព្យក៏រស់នៅមិនបាន ។

**បញ្ញវា ពុទ្ធិសម្បន្នោ** **វិធានវិធិកោវិទោ**
**កាលញ្ញូ សមយញ្ញូ ច** **ស រាជវសតី វសេ ។**

អ្នកណាមានបញ្ញា បរិបូណ៌ដោយពុទ្ធិ ឈ្លាសវៃក្នុងរបៀបចាត់ចែងការងារ (វិធានវិធី) ដឹងកាល និងសម័យ អ្នកនោះអាចធ្វើជាអ្នករាជការបាន ។

...He gave expression to truths of everlasting value and advanced the ethics of not India alone but of humanity. Buddha was one of the greatest ethical men of genius ever bestowed upon the world.

Albert Schweitzer(1875 - 1965)
Peace Nobel Price in 1952

ព្រះពុទ្ធអង្គបានសំដែងចេញនូវសច្ចធម៌ ដែលមានគុណតម្លៃជានិរន្តរ៍ និងបានធ្វើឲ្យចរិយធម៌រីកចំរើន មិនត្រឹមតែរបស់ឥណ្ឌាតែប៉ុណ្ណោះទេ គឺទាំងរបស់មនុស្សជាតិទៀតផង ។ ព្រះពុទ្ធគឺជាអច្ឆរិយមនុស្ស ខាងសីលធម៌មួយអង្គដែលពិភពលោកធ្លាប់បានជួបប្រទះមក ។

អាល់ប៊ែរ ស្វៃស៊ែរ, រង្វាន់ណូបែលសាខាសន្តិភាព ឆ្នាំ១៩៥២

www.budinst.gov.kh www.elibraryofcambodia.org

# យកព្រះធម៌ជាទីពឹង

ក- ពឹងព្រះធម៌ឲ្យជួយដោះស្រាយបញ្ហា

**យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ**

**សោ វោ មមច្ចយេន សត្ថា**

*"ម្នាលអានន្ទ ព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគតបានសំដែងហើយ បាន បញ្ញត្តិហើយដល់អ្នកទាំងឡាយ លុះអំណឹះតទៅពីតថាគតទៅ នឹងបានជាគ្រូប្រៀនប្រដៅអ្នកទាំងឡាយ ។"*

ដូច្នេះ ព្រះធម៌គឺជាទីពឹងរបស់យើងហើយនាបច្ចុប្បន្ននេះ ព្រោះថាព្រះពុទ្ធអង្គ លោកបរិនិព្វានហើយ ។ យើងអាចស្វែងរកព្រះធម៌មកធ្វើជាទីពឹងបាន តាមការអាន ការស្តាប់ ចងចាំ នឹង**យកមកបដិបត្តិតាម** ។ ឧទាហរណ៍ យើងចង់បានសុភមង្គលក្នុង ជីវិត យើងក៏រៀនមង្គលសូត្រដែលមាន ៣៨ ប្រការ ហើយបដិបត្តិតាមកុំឲ្យខ្វះ ។ យើងមិនចង់ទទួលបរាជ័យក្នុងជីវិត យើងក៏ស្តាប់ ឬសាកសួរអំពីបរាភវសូត្រដែលមាន ១២ ប្រការ ហើយយកមកអនុវត្តតាម ក៏នឹងមិនចេះបរាជ័យក្នុងជីវិតឡើយ ។ យើងចង់ បានសេចក្តីសុខ ជាមួយស្វាមី ភរិយា កូន យើងក៏មើលធម៌ដែលនិយាយអំពីទិស ៦ ហើយនាំគ្នាអនុវត្តតាមទៅ ទុំសុភមង្គលក្នុងគ្រួសារក៏នឹងមានសេចក្តីក្សេមក្សាន្តជាពុំ ខាន ដូចព្រះពុទ្ធអង្គទ្រង់សំដែងថា : **<យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។>** ជនណាប្រព្រឹត្តតាមធម៌ដែល តថាគតសំដែងល្អហើយ ជននោះនឹងឆ្លងសេចក្តីស្លាប់ដែលគេលំបាកឆ្លងក្រៃពេក ហើយ ដល់នូវត្រើយ គឺព្រះនិព្វាន ។

| | |
|---|---|
| **ធម្មប្បីតិ សុខំ សេតិ** | អ្នកក្រេបធម៌ តែងនៅជាសុខ |
| **ធម្មចារី សុខំសេតិ** | អ្នកប្រព្រឹត្តធម៌តែងនៅជាសុខ |
| **ធម្មោ ហវេ រក្ខតិ ធម្មចារី** | ធម៌ហ្នឹងឯង តែងរក្សាអ្នកប្រព្រឹត្តធម៌ |

ខ- ពឹងព្រះធម៌ឲ្យជួយសង្គ្រោះ

លើករណីនេះ ពុទ្ធបរិស័ទយើងតែងទុកព្រះធម៌ដូចជាមន្តអាគម ដែលសំរាប់

www.budinst.gov.kh www.elibraryofcambodia.org

ជួយស្រោចស្រង់ខ្លួនពេលមានអាសន្ន ឬសេចក្ដីត្រូវការផ្សេងៗ ដូចជាស្រង់ធម៌ខ្លះមកសរសេរជាយ័ន្ត្រការពារពេលមានអាសន្ន ជាស្នេហ៍មុខចូលទៅរកអ្នកធំជាដើម ដែលសូមលើកយក មកជាឧទាហរណ៍ខាងក្រោម ៖

**សក្កា ធនុំ អាកឌ្ឍិត្វំ ឥត្វា នាគាសិ** ជាបាលីសំកាំងស្រង់យកពីពុទ្ធដីកាព្រះអង្គ ពេលដែលទេវទត្តប្រើឲ្យខ្មាន់ធ្នូមកបាញ់ធ្វើគតព្រះអង្គ តែត្រូវគាំងបាញ់មិនចេញ ដោយសារពុទ្ធដីកាព្រះអង្គខាងលើនេះ ។

**សក្កត្វាំ ធម្មរតនំ ឱសថំ ឧត្តមំ វរំ បរិឡាហូបសមនំ ធម្មតេជេន សោត្ថិនា សន្ទេ្ត ឃបួទ្ទា សព្វេ ទុក្ខា សព្វេភយា សព្វេរោគា វូបសមេន្តុតេ** ជាបាលីសំរាប់ប្រើដាស់ថ្នាំឲ្យពូកែសក្ដិសិទ្ធិជាដើម ។

### ទីពឹងខាងផ្លូវចិត្ត

ពេលដែលមានភ័យចូលមកយាយី ពុទ្ធបរិស័ទតែងតែរលឹកនឹកដល់ព្រះនាមព្រះអង្គដើម្បីឲ្យបាត់ភ័យខ្លាច មានកំឡាំងចិត្តសំរាប់តស៊ូតទៅទៀត។ ក្នុងសម័យពុទ្ធកាល ព្រះសម្មាសម្ពុទ្ធក៏ត្រាស់ដែរ <ធជគ្គសូត្រ) ដូចជាពួកភិក្ខុដែលចេញដើរទៅក្នុងព្រៃស្ងាត់ ឬតាមរូងភ្នំដាច់ស្រយាលដើម្បីចំរើនធម៌ ហើយក៏មានការខ្លាចភ័យរន្ធត់ ព្រះអង្គក៏ត្រាស់ឲ្យរលឹកនឹកដល់គុណរបស់ព្រះធម៌ឲ្យជាប់។

នាបច្ចុប្បន្នពេលមានផ្លេកបន្ទោរ ផ្គរ មានភ័យ មានសង្គ្រាម ឬខ្លាចខ្មោចជាដើម ពុទ្ធបរិស័ទនាំគ្នាទន្ទេញពុទ្ធោៗ ជាប់មាត់ ដើម្បីបំបាត់ការភ័យខ្លាចទាំងនោះ ហើយមានជំនឿថា គុណរបស់ព្រះធម៌ នឹងជួយគេឲ្យរួចពីគ្រោះថ្នាក់ទាំងនោះ ជាពិតប្រាកដ ។

> ព្រះធម៌បរិសុទ្ធ យោងសត្វឲ្យផុត ពីក្ដីទុក្ខា នរប្រុសស្រី ដែលយកធម្មា ធ្វើជាមាគ៌ា តែងផុតទុក្ខសោក ។ ទុក្ខនាលោកនេះ ព្រោះគ្មានចំណេះ អវិជ្ជាបែនបោក ឲ្យសោកឲ្យយំ លង់លក់ងុយងោក ភ្លើងធម៌ចាំងមក ទុក្ខសោកវិនាស ។ ទុក្ខលោកខាងមុខ នរកជាប់គុក កើតប្រេតផ្ដេសផ្ដាស វិលវល់ក្នុងវដ្ដ កើតស្លាប់ច្រើនណាស់ លុះមានឱកាស ព្រះធម៌ទើបស្ងប់ ។ យកធម៌ជាពឹង ពេលសើចពេលខឹង ពេលរស់ពេលងាប់ ធម៌ច្រើនសុខច្រើន ធម៌ល្អបានគាប់ ជាតិមុខសូមជាប់ នឹងធម៌និព្វាន ។

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះសង្ឃ

ព្រះសង្ឃជាអ្វី ? ជាអ្នកបួសក្នុងព្រះពុទ្ធសាសនា

ព្រះសង្ឃជានរណា ? ជាក្រុមមនុស្សដែលស្ម័គ្រចិត្តចាកចេញពីការរស់នៅបែបមនុស្សធម្មតា ទៅរស់នៅជាក្រុម ដើម្បីសិក្សារៀនសូត្រ និង បដិបត្តិតាមធម៌របស់ព្រះសម្មាសម្ពុទ្ធ

ហេតុអ្វីត្រូវយកលោកជាទីពឹង? ព្រោះលោកបានសិក្សារៀនសូត្រធម៌ព្រះសម្មាសម្ពុទ្ធបានជ្រៅជ្រះ មានការពិសោធន៍ក្នុងការដិបត្តិធម៌ និងអាចប្រាប់យើងអំពីការសិក្សានិងបដិបត្តិនោះបាន

តើយកជាទីពឹងដូចម្តេច? សូមអញ្ជើញបើកទៅទំព័រខាងមុខចុះ លោកអ្នកនឹងបានជ្រាបជាពុំខាន

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

## សង្ឃ

ក្នុងន័យធម្មតា សង្ឃៈ មានន័យថា ក្រុម ឬសហគមន៍ ត្រូវនឹងភាសាអង់គ្លេសថា Community ។ ក្នុងព្រះពុទ្ធសាសនា បានដល់ក្រុមបព្វជិតបួសក្នុងព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនា ការសក់ ស្លៀកសំពត់ដែលហៅថា ស្បង់ និងរុំដណ្ដប់ដោយសំពត់ដែលហៅថា ចីវរ ។ យើងទាំងអស់គ្នាពិតជាមិនប្លែកទេ កាលណាឮពាក្យថា ព្រះសង្ឃ គឺពិតជាស្គាល់ភ្លាម ហើយដឹងថាត្រូវទៅរកនៅឯណា គឺនៅវត្ត ។

## ព្រះសង្ឃ - ព្រះភិក្ខុ

ខ្មែរយើងបើទោះជាបានឃើញព្រះសង្ឃ ១ អង្គ ឬច្រើនអង្គក្ដី តែងតែហៅលោកថា ព្រះសង្ឃ ឬលោកសង្ឃទាំងអស់។ តាមពិតនឹងអាចហៅថា ព្រះសង្ឃ បានលុះត្រាតែមានចំនួនចាប់ពី ៤ អង្គ ឡើងទៅ ។ បើមានតែ ១ អង្គ ទេ លោកហៅថា ព្រះភិក្ខុ ។ ទម្លាប់ហៅថាព្រះសង្ឃនេះ ក៏ក្លាយទៅជាប្រពៃណីនៃការហៅរបស់ខ្មែរយើងគ្រប់មាត់ទៅហើយ ។

## កំណើតព្រះសង្ឃ

នៅពេលដែលព្រះសិទ្ធត្ថៈបានត្រាស់ដឹងជាព្រះពុទ្ធហើយ ព្រះអង្គក៏បានយាងទៅកាន់ព្រៃមួយកន្លែងដែលមានឈ្មោះថា « ឥសិបតនមិគទាយវ័ន » ជាទីកន្លែងដែលអតីតសាវ័ករបស់ព្រះអង្គ កាលដែលទ្រង់ពុំទាន់បានត្រាស់ដឹងចំនួន ៥ នាក់ស្នាក់នៅ ។ នៅពេលដែលបានជួបហើយ ព្រះពុទ្ធអង្គក៏ទ្រង់បានសំដែងធម៌ឈ្មោះ **ធម្មចក្កប្បវត្តនសូត្រ** ដែលជាខ្លឹមសារនៃការត្រាស់ដឹងរបស់ព្រះអង្គចំពោះអ្នកទាំង ៥ នោះ រហូតដល់បានសំរេចជាព្រះអរហន្តទាំង ៥ អង្គ ។ លុះបានត្រាស់ហើយ អតីតសាវ័កទាំងនោះក៏បានសុំព្រះអង្គបួស ។ ព្រះពុទ្ធអង្គបានអនុញ្ញាតឲ្យអ្នកទាំង ៥ នោះ បួសហើយដាក់ឈ្មោះថា **ភិក្ខុសង្ឃ** ប្រែថា ក្រុមភិក្ខុ ឬក្រុមអ្នកឃើញភ័យក្នុងការ កើត ចាស់ ឈឺ ស្លាប់ ។ ហេតុការណ៍នេះកើតឡើង នៅក្នុងថ្ងៃ ៨ រោជ ខែអាសាឍ មុនពុទ្ធសករាជ ៤៥ ឆ្នាំ ។ ចាប់ពីពេលនោះមក ក៏មានអ្នកស្ម័គ្រចិត្តចូលមកបួស ជាមួយព្រះអង្គកាន់តែច្រើនឡើងៗជាលំដាប់ និងបានបន្តពូជពង្សរហូត មកដល់សព្វថ្ងៃនេះ ទូទាំងពិភពលោក ។ ក្នុងប្រទេសខ្មែរនាឆ្នាំ ១៩៩៥ នេះ មានព្រះសង្ឃចំនួន ប្រមាណ ៤ ម៉ឺនរូប ។

www.budinst.gov.kh www.elibraryofcambodia.org

## ប្រភេទព្រះសង្ឃ

ក្នុងពុទ្ធសាសនា ព្រះសង្ឃមានពីរប្រភេទគឺព្រះអរិយសង្ឃ និងព្រះសម្មតិសង្ឃ ។

**ព្រះអរិយសង្ឃ** គឺព្រះសង្ឃដែលបានសំរេចនូវគុណធម៌ជាន់ខ្ពស់ក្នុងព្រះពុទ្ធសាសនា ដែលមាន ៤ ថ្នាក់ គឺថ្នាក់សោតាបន្នបុគ្គល សកទាគាមីបុគ្គល អនាគាមីបុគ្គល និង អរហត្តបុគ្គល ។ គុណធម៌តាមលំដាប់និមួយៗមានសេចក្តីអធិប្បាយដូចនេះ ៖

សោតាបន្នបុគ្គល ប្រែថាអ្នកចូលដល់ក្រសែដែលនឹងនាំទៅកាន់ព្រះនិព្វាន ។ បុគ្គលដែលបានសម្រេចសោតាបត្តិផលមាន ៣ ប្រភេទ គឺ ១- ឯកពីជី កើតទៀតតែម្តងទេ នឹងបាននិព្វាន; ២- កោសំកោលៈ កើតតែ ២-៣ ជាតិទៀតទេ នឹងបាននិព្វាន; ៣- សត្តក្ខត្តុបរមៈ គឺកើតតែ ៧ ជាតិទៀតប៉ុណ្ណោះយ៉ាងច្រើន នឹងបាននិព្វានហើយ ។ បុគ្គលដែលបានសម្រេចសោតាបត្តិផល ជាអ្នកដែលមិនមានសក្កាយទិដ្ឋិ (ការយល់ឃើញថាមានខ្លួនជាខ្លួន) នៅក្នុងចិត្តទេ, មិនមានវិចិកច្ឆា (សេចក្តីសង្ស័យ ការមិនទុកចិត្ត) នៅក្នុងគុណព្រះរតនត្រ័យ នៅក្នុងទ្រឹស្តីកម្មផលទេ, និងមិនមានសីលព្វតបរាមាសៈទេ (ការជឿថាសេចក្តីទុក្ខអាចរលត់ទៅបាន ព្រោះអាស្រ័យដោយសីល និងវត្តប្រតិបត្តិផ្សេងៗ មានការធ្វើអត្តកិលមថានុយោគជាដើម) ។

សកទាគាមិបុគ្គល គឺព្រះអរិយបុគ្គលដែលបានលះសំយោជន៍ទាំង ៣ ខាងលើបានហើយ ព្រមទាំងបានធ្វើឲ្យរាគៈ- ទោសៈ និងមោហៈ ថយចុះ ស្តើងស្រាលនៅក្នុងជីវិតទាប ។

អនាគាមិបុគ្គល គឺព្រះអរិយបុគ្គលដែលបានទទួលញាណដែលជាហេតុលះនូវឱរម្ភាគិយសំយោជន៍បាន ២ លើសព្រះសោតាបន្នបុគ្គលថែមទៀត គឺបានលះកាមរាគៈ និង បដិឃៈអស់ពីខន្ធសន្តានរលីងហើយ ។

អរហត្តបុគ្គល គឺព្រះអរហន្ត ប្រែថាអ្នកដែលមិនមានកិលេសនៅក្នុងខន្ធសន្តាន ។ ចិត្តលោកបរិសុទ្ធផូរផង់ ពុំមានរាគៈ ទោសៈ និងមោហៈនៅក្នុងព្រះទ័យឡើយ ហើយក៏ជាទីបញ្ចប់នៃកិច្ចការដែលត្រូវបំពេញនៅក្នុងព្រះពុទ្ធសាសនាដែរ ។ ទាំងបីព្រះអង្គខាងលើ លោកហៅថាជា សេខៈបុគ្គល ប្រែថាបុគ្គលដែលនៅត្រូវរៀន ឯព្រះអរហន្តលោកហៅថា **អសេខៈ** បុគ្គល ប្រែថាអ្នកបញ្ចប់ការសិក្សារៀនសូត្រហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអរិយសង្ឃទាំងអស់អង្គនេះ លោកចាត់ទុកថាជាជនដ៏ប្រសើរ (អរិយៈ) ជាអ្នក ដែលធ្លាក់ទៅក្នុងក្រសែនៃការមិនកើត មិនស្លាប់ទៀត ។

ព្រះសម្មតិសង្ឃ គឺបានដល់ព្រះសង្ឃដែលកំពុងសិក្សារៀនសូត្រ និងព្យាយាមបដិបត្តិនូវសីល សមាធិ បញ្ញា ដើម្បីរំដោះខ្លួនឲ្យផុតពីសេចក្តីទុក្ខដូចព្រះអរិយសង្ឃដែរ តែលោកពុំទាន់បានសំរេចនូវគុណធម៌ណាមួយ ក្នុងចំណោមចំណាត់ថ្នាក់ទាំង ៤ នៅឡើយ ។

យើងអាចនឹងមានសំនួរសួរថា តើធ្វើដូចម្តេចយើងនឹងដឹងថា សង្ឃណាជាអរិយៈ និងសង្ឃណាជាសម្មតិ ? ចំណុចត្រង់នេះ យើងពិបាកនឹងមើលដឹងដោយភ្នែកធម្មតាណាស់ ព្រោះថាគុណធម៌នៃលំដាប់ថ្នាក់អរិយៈទាំង ៤ នេះ គឺជារឿងផ្លូវចិត្ត និងជារឿងសន្ទិដ្ឋិកោ គឺដឹងច្បាស់ ឃើញច្បាស់ចំពោះតែបុគ្គលណាដែលបានសំរេចធម៌នោះតែប៉ុណ្ណោះ អ្នកដទៃពុំអាចដឹងបានទេ អាចត្រឹមតែសង្កេតឃើញនូវព្រឹត្តិកម្មខ្លះៗតែប៉ុណ្ណោះ ទៅតាមគុណលក្ខណៈរបស់លំដាប់និមួយៗ ដូចជាថ្នាក់សោតា យើងអាចឃើញលោកដែលមានចិត្តពុំសូវខឹងក្រេវក្រោធ លោកមានសីលបរិសុទ្ធផូរផង់ មានជំនឿក្នុងព្រះពុទ្ធសាសនាច្បាស់ជាដើម តែក៏មិនអាចសន្និដ្ឋានចំពោះជនទាំងពួងដែរ ។ ព្រះពុទ្ធអង្គបានត្រាស់រឿងនេះថា : «ភិក្ខុទាំងឡាយ បុថុជ្ជនដែលមិនមានការសិក្សា រមែងសោយវេទនាដែលជាសុខខ្លះ ជាទុក្ខខ្លះ មិនមែនសុខមិនមែនទុក្ខខ្លះ អរិយសាវ័កដែលមានការសិក្សា ក៏រមែងសោយវេទនា (ដូច្នោះ) ដែរ អ្វីដែលជាការប្លែកគ្នា អ្វីដែលធ្វើឲ្យអរិយសាវ័កខុសពីបុថុជ្ជន ។

ភិក្ខុទាំងឡាយ បុថុជ្ជនដែលមិនមានការសិក្សា ពេលទុក្ខវេទនាកើតឡើងដល់ហើយគេរមែងសោកសៅ លំបាក ខ្សឹកខ្សួល រមែងសោយវេទនាទាំង ២ ផ្លូវ គឺទាំងខាងកាយ និងទាំងខាងចិត្ត ។

តែអរិយសាវ័ក ពេលទុក្ខវេទនាកើតឡើងដល់ហើយ រមែងមិនសៅសោក មិនលំបាកចិត្ត មិនខ្សឹកខ្សួល រមែងសោយវេទនាតែម្យ៉ាង គឺខាងកាយ តែមិនសោយវេទនាខាងចិត្ត »[22] ។

---

[22] សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ

www.budhist.gov.kh www.elibraryofcambodia.org

ដូច្នេះយើងឃើញថា ព្រះអរិយសង្ឃ និងសម្មតិសង្ឃ គឺមានរូបរាងដូចគ្នា ឈឺចាប់ផ្លូវកាយដូចគ្នា តែព្រះអរិយសង្ឃលោកមិនមានការឈឺចាប់ផ្លូវចិត្តទេ ព្រោះចិត្តរបស់លោករួចផុតពីរាគៈ ទោសៈ និងមោហៈ អស់ហើយ ។ ឯសង្ឃជាបុថុជ្ជនវិញ លោកនៅទទួលការឈឺចាប់ទាំងខាងកាយ និងខាងចិត្តដូចយើងដែរ ។

នៅមានព្រះសង្ឃប្រភេទមួយទៀត គឺ ភេទនារី ដែលស្ម័គ្រចិត្តចូលមកបួសក្នុងព្រះពុទ្ធសាសនា លោកហៅថាភិក្ខុនី ។ ភិក្ខុនី គឺលោកសង្ឃស្រីដែលកាន់ធម៌វិន័យដូចគ្នានឹងព្រះភិក្ខុដែរ តែសព្វថ្ងៃនេះមានសល់មិនច្រើនទេ ។ ភិក្ខុនីដែលមាននៅសព្វថ្ងៃស្ថិតនៅក្នុងនិកាយមហាយាន មាននៅក្នុងប្រទេសចិន ជប៉ុន កូរ៉េ តៃវ៉ាន់ និងទីបេ ។ ចំពោះអ្នកកាន់ហីនយាន ឬថេរវាទវិញ ភិក្ខុនីបានដាច់ពូជយូរណាស់មកហើយ ។ សព្វថ្ងៃនេះ កំពុងមានចលនាដើម្បីនឹងឲ្យកើតមានភិក្ខុនីត្រឡប់មកវិញ នៅតាមប្រទេសកាន់ថេរវាទជាច្រើន ជាពិសេសនៅប្រទេសស្រីលង្កា ភូមា និងប្រទេសថៃ ។

## ការក្លាយខ្លួនទៅជាសង្ឃ ឬ ការបួស ៖

ដើម្បីនឹងអាចទៅជាសង្ឃបាន គេត្រូវបួស ។ បួស គឺជាការសំរេចចិត្តលាលែងឈប់រស់នៅក្នុងសង្គមមនុស្សទូទៅធម្មតា ហើយទៅរស់នៅក្នុងសង្គមព្រះពុទ្ធ-សាសនា ក្នុងសង្គមសង្ឃ ដើម្បីសិក្សាបដិបត្តិរំដោះខ្លួនឲ្យផុតពីសេចក្តីទុក្ខ ។

ការបួសដែលគេឮហើយអាចស្រប់យល់ឃើញភ្លាមនោះ គឺ<u>ការកោរសក់ចេញ</u>, ឈប់ស្លៀកពាក់ខោអាវ តែ<u>ស្លៀកស្បង់ចីវរ</u> <u>មិនបរិភោគអាហារពេលល្ងាច</u> <u>និងកាន់វិន័យតឹងរ៉ឹង</u> តែការបួសជាពិតប្រាកដនោះមិនមែនត្រឹមតែប៉ុណ្ណឹងទេ ហើយដែលយើងទូទៅពុំសូវបានចាប់អារម្មណ៍ ឬដឹង ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃដំណើរការបួស ដើម្បីបានក្លាយទៅជាព្រះភិក្ខុក្នុងព្រះពុទ្ធសាសនាយើង ៖

១- អ្នកដែលប្រាថ្នាចង់បួស ត្រូវជាអ្នកមានសទ្ធាពិតប្រាកដក្នុងព្រះពុទ្ធសាសនា គឺបួសដើម្បីរំលត់នូវសេចក្តីទុក្ខ ឈោងចាប់ព្រះនិព្វាន ។

២- ត្រូវជាមនុស្សសុទ្ធសាធ និងមានលក្ខណៈដូចតទៅ ៖

១) មិនមែនជាមនុស្សខ្ទើយ (បណ្ឌកោ)

២) មិនមែនជាអ្នកមានភេទ ២ (ឧភតោព្យញ្ជនកោ)

www.budinst.gov.kh www.elibraryofcambodia.org

៣) មិនមែនជាអ្នកធ្លាប់បានលួចបួសជាភិក្ខុដោយខ្លួនឯង (ថេយ្យសំវាសកោ)

៤) មិនមែនជាអ្នកដែលធ្លាប់រត់ទៅចូលសាសនាគេម្តងហើយ (តិត្ថិយ - បក្កន្តកោ)

៥) មិនមែនជាសត្វតិរច្ឆាន (តិរច្ឆានោ)

៦) មិនមែនជាអ្នកធ្លាប់សម្លាប់មាតា (មាតុឃាតកោ)

៧) មិនមែនជាអ្នកធ្លាប់សម្លាប់បិតា (បិតុឃាតកោ)

៨) មិនមែនជាអ្នកធ្លាប់សម្លាប់ព្រះអរហន្ត (អរហន្តឃាតកោ)

៩) មិនមែនជាអ្នកដែលធ្លាប់ធ្វើឲ្យរបួសដល់ព្រះពុទ្ធអង្គ (លោហិតុប្បាទកោ)

១០) មិនមែនជាអ្នកធ្លាប់បំបាក់បំបែកសង្ឃ (សង្ឃភេទកោ)

១១) និងមិនមែនជាអ្នកដែលធ្លាប់បំពារបំពាន ឬរំលោភដល់ភិក្ខុនី ។

លក្ខណៈទាំង ១១ យ៉ាងនេះ ហាមបួសជាដាច់ខាត ទាំងបួសជាភិក្ខុ ទាំងបួសជាសាមណេរ ។ ហើយចំពោះមនុស្សនេះទៀតសោត ព្រះសម្មាសម្ពុទ្ធទ្រង់ហាមមិនឲ្យមនុស្សដែលមានបុគ្គលិកលក្ខណៈណាមួយក្នុងចំណោមលក្ខណៈ ៣២ ប្រការខាងក្រោមបួសទេ ៖

| | | |
|---|---|---|
| ១) | ហត្ថច្ឆិន្នោ | មនុស្សកំបុតដៃ |
| ២) | បាទច្ឆិន្នោ | មនុស្សកំបុតជើង |
| ៣) | ហត្ថបាទច្ឆិន្នោ | មនុស្សកំបុតទាំងដៃ ទាំងជើង |
| ៤) | កណ្ណច្ឆិន្នោ | មនុស្សកំបុតត្រចៀក |
| ៥) | នាសច្ឆិន្នោ | មនុស្សកំបុតច្រមុះ |
| ៦) | កណ្ណនាសច្ឆិន្នោ | មនុស្សកំបុតទាំងត្រចៀក ទាំងច្រមុះ |
| ៧) | អង្គុលិច្ឆិន្នោ | មនុស្សកំបុតម្រាមដៃ |
| ៨) | អឡច្ឆិន្នោ | មនុស្សកំបុតម្រាមជើង |
| ៩) | កណ្ឌរច្ឆិន្នោ | មនុស្សដាច់សរសៃធំ |
| ១០) | ផណហត្ថកោ | មនុស្សម្រាមដៃជាប់គ្នា |
| ១១) | ខុជ្ជោ | មនុស្សគម |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ១២) វាបន | មនុស្សតឿ |
| ១៣) គលឡណ្ឌិក | មនុស្សពកក |
| ១៤) លក្ខណាហក | មនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម |
| ១៥) កសាហត | មនុស្សដែលគេវាយដោយរំពាត់ |
| ១៦) លិខិតក | មនុស្សដែលរាជការព្យួរទោសទុក |
| ១៧) សីបទី | មនុស្សជើងស្អក់ |
| ១៨) បាបរោគី | មនុស្សមានរោគអាក្រក់ |
| ១៩) បរិសទូសក | មនុស្សប្រទូស្ត និងបរិស័ទ |
| ២០) កាណ | មនុស្សទើបនឹងខ្វាក់ |
| ២១) កុណី | មនុស្សក្ងែងដៃ-ជើង |
| ២២) ខញ្ជ | មនុស្សខ្វក |
| ២៣) បក្ខហត | មនុស្សស្លាប់កាយមួយចំហៀងខ្លួន |
| ២៤) ឆិន្នីរិយាបថ | មនុស្សខ្វិន |
| ២៥) ជរាទុព្វល | មនុស្សខ្សោយកម្លាំងព្រោះជរា |
| ២៦) អន្ធ | មនុស្សខ្វាក់ |
| ២៧) មូគ | មនុស្សគ |
| ២៨) អន្ធមូគ | មនុស្សទាំងខ្វាក់ - ទាំងគ |
| ២៩) ពធិរៈ | មនុស្សថ្លង់ |
| ៣០) អន្ធពធិរ | មនុស្សទាំងខ្វាក់ - ទាំងថ្លង់ |
| ៣១) មូគពធិរ | មនុស្សទាំងគ - ទាំងថ្លង់ |
| ៣២) អន្ធមូគពធិរៈ | មនុស្សទាំងខ្វាក់ - ទាំងគ - ទាំងថ្លង់ |

យើងអាចនឹងមានសំនួរថា ហេតុអ្វីទើបបានព្រះសម្មាសម្ពុទ្ធមិនឲ្យបួស ? គេថាពុទ្ធសាសនា ជាសាសនាមេត្តាករុណា ចុះបើឃើញមនុស្សមកសុំបួស ហេតុអ្វីមិនជួយផង ?

តាមសេចក្តីពិត ការដែលមិនឲ្យអ្នកទាំង ៣២ នេះបួសព្រោះមានហេតុផលដែលគួរឲ្យសិក្សាណាស់ គឺថា៖

www.budinst.gov.kh www.elibraryofcambodia.org

ក- ក្នុងពុទ្ធសាសនា អ្នកដែលបួសរួចហើយ ត្រូវចិញ្ចឹមជីវិតដោយខ្លួនឯង គឺត្រូវបិណ្ឌបាត្រ ត្រូវស្វែងរកស្បង់ចីពរ ត្រូវរកទីសេនាសនៈ និងរកថ្នាំសំរាប់ព្យាបាលខ្លួន។ ការដែលមានទុព្វលភាពខាងរាងកាយ ដូចជាកំបុតដៃជើង ខ្វាក់ភ្នែកជាដើមនេះ ពុំអាចឲ្យអ្នកដែលបួសហើយនោះ បំពេញករណីយកិច្ចជាសមណៈភាវៈបានឡើយ ទាំងការចិញ្ចឹមជីវិត និងការបដិបត្តិធម៌ ។

ខ- បួសរួចហើយ គឺត្រូវសិក្សា និងបដិបត្តិ ។ ពិការភាពខាងរាងកាយ ក៏ជាឧបសគ្គដល់ការរៀនសូត្រ និងបដិបត្តធម៌ឲ្យបានជោគជ័យដែរ ។

គ- មុខនាទីមួយទៀត គឺដើរប្រោសសត្វ អប់រំពុទ្ធបរិស័ទអំពីពុទ្ធសាសនា ។ ការដែលមានពិការភាព នឹងពុំអាចធ្វើជាអ្នកផ្សព្វផ្សាយធម៌បានល្អទេ ព្រោះទៅណាក៏ជាទីគយគន់ និងអាចឲ្យគេខ្លាចមិនហ៊ានទៅជិតទៀតផង ។ ក្នុងករណីខ្លះ មនុស្សពិការខ្លះ អាចមានប្រវត្តិត្រូវគេធ្វើទុក្ខទោស ព្រោះអំពើមិនគប្បីរបស់ខ្លួន លុះពេលបួសទៅ នឹងអាចឲ្យគេរិះគន់ថា រកស៊ីមិនរស់ទើបមកបួស ឬត្រូវកាត់ដៃ-ជើង រកលួចគេមិនបានទើបមកបួសជាដើម ដែលជាបញ្ហានាំឲ្យកករល្អក់ក្នុងរង្វង់ពុទ្ធសាសនា ។

ចំពោះមនុស្សចាប់ពីប្រភេទទី ១ ដល់ទី ៨ យើងឃើញថា លោកប្រើពាក្យកំបុត ដែលសឲ្យឃើញថា មនុស្សនេះត្រូវគេកាត់ឲ្យកំបុត ឬមានហេតុការណ៍អ្វីមួយនាំឲ្យកំបុត ដែលយើងអាចពិចារណាបាន ៖ អាចជាមនុស្សអាក្រក់ទើបគេកាត់ឲ្យកំបុត អាចមានគ្រោះថ្នាក់ដោយឧប្បទ្ទហេតុណាមួយ បើកាលណាឲ្យបួស អ្នកនោះមិនអាចចិញ្ចឹមខ្លួនឯងបានទេ មិនអាចបដិបត្តិធម៌បានស្រួលទេ និងមិនអាចបំពេញករណីយកិច្ចក្នុងការជួយបរិស័ទបានឡើយ ។ ម្យ៉ាងទៀត ស្ថាប័នសង្ឃអាចនឹងត្រូវគេចោទប្រកាន់ថា យកតែមនុស្សមានទោសមកបួស ដែលនឹងនាំឲ្យបរិស័ទអស់សទ្ធា ។

ចំពោះលេខ ១០ ដល់លេខ ១៣ គឺជាមនុស្សពិការពីកំណើត ចំណុចនេះកាលណាបួសទៅនឹងនាំឲ្យគេឆ្លើលចោមរោមមើល សើចចំអកឲ្យជាមិនខាន ដែលជាការនាំឲ្យរំខានដល់ការបដិបត្តិធម៌ ។ ចំពោះការផ្សព្វផ្សាយធម៌វិញ ក៏នឹងមិនមានប្រសិទ្ធភាពឡើយ ព្រោះបុគ្គលិកលក្ខណៈមិនសមរម្យ ។

ចំពោះលេខ ១៤ ដល់លេខ១៦ គឺសុទ្ធតែជាមនុស្សធ្លាប់ទទួលរងទារុណកម្ម ព្រោះដោយទោសណាមួយដែលខ្លួនប្រព្រឹត្ត ។ ការហាម គឺក្រែងលោបួសទៅអាច

www.budinst.gov.kh www.elibraryofcambodia.org

នឹងត្រូវមានរឿងជាមួយអ្នករាជការដែលតាមចាប់ជននោះទេវិញ ។

ចំពោះលេខ ១៧ គឺមនុស្សមានជើងស្អក់ តាមមើលទៅគឺជើងធំជាងធម្មតាពេក ព្រោះដោយជំងឺ ។ ត្រង់នេះ បើសិនជាព្យាបាលជាហើយ គិតថាប្រហែលអាចនឹងបួសបាន ។ ចំពោះមានមនុស្សមានរោគអាក្រក់វិញ គឺជៀសវាងការឆ្លងជំងឺដល់ភិក្ខុសង្ឃ ។ ជាពិសេស បច្ចុប្បន្ននេះ រោគអេសដ៍ (AIDS) អាចនឹងងាយឆ្លងណាស់ដល់ភិក្ខុសង្ឃ តាមរយៈការកោរព្រះកេសជារៀងរាល់កន្លះខែម្តង ។ វីរុសហ៊ីវ (HIV) នឹងឆ្លងតាមឈាមដែលជាប់នឹងកាំបិត ឡាមជាពិតប្រាកដ ។ ត្រង់នេះដែរ បើពេទ្យធានាថាជាហើយនោះ ក៏នឹងអាចបួសបានវិញ ។

ចំពោះលេខ ១៩ គឺអ្នកប្រទូស្តនឹងបរិស័ទ ដល់ពេលបួសបរិស័ទនឹងគ្មានការគោរព ហើយអ្នកនោះក៏នៅតែប្រទូស្តបរិស័ទដដែល ដែលជាការនាំឲ្យសៅហ្មងដល់សង្ឃ ឬជួនកាលអាចនឹងកើតរឿងឡើងរហូតដល់វាយតប់ កាប់ចាក់គ្នាក៏ថាបាន ។

ចាប់ពីលេខ ២០ ដល់លេខ ៣១ សំខាន់ គឺទាក់ទងដល់ការចិញ្ចឹមជីវិត និងបុគ្គលិកលក្ខណៈ ដើម្បីឲ្យគេគោរព មានសទ្ធាជ្រះថ្លា ។

៣- ជាធម្មតាបេក្ខជនអ្នកចង់បួស ត្រូវបានទទួលការអនុញ្ញាតពីមាតាបិតា និងអាណាព្យាបាលសិន ។ បើជាមន្ត្រីរាជការត្រូវបានច្បាប់ពីនាយចៅហ្វាយក្រសួងខ្លួនជាមុន បើមានប្រពន្ធ ក៏គប្បីបានទទួលការអនុញ្ញាតពីប្រពន្ធសិនទើបបាន ។

៤- ត្រូវមានអដ្ឋបរិក្ខាគឺគ្រឿងប្រើប្រាស់សំរាប់អ្នកបួស ៨ យ៉ាងឲ្យគ្រប់គ្រាន់គឺស្បង់ ចីវរ សង្ឃាដី បាត្រ កាំបិតកោរ ធម្មក្រក(ប្រដាប់ត្រងទឹក) ម្ជុល និងចេសសំរាប់ដេរ ។

៥- ត្រូវចូលទៅរកសំណាក់សង្ឃ ហើយសុំលោកបួស ។ ចំពោះការបួសជាសាមណេរ អាចបួសជាមួយនឹងភិក្ខុអង្គណាមួយក៏បាន តែបើបួសជាភិក្ខុ ត្រូវមានសង្ឃយ៉ាងតិចណាស់ចំនួន ៥ អង្គដែរ[23] ដើម្បីធ្វើជាសាក្សីដឹងឮក្នុងការបួសនេះ ។ បើអ្នកណាបួសដោយខ្លួនឯង លោកហៅថា ថេយ្យសង្វាស គឺមិនអាចក្លាយខ្លួនជាសង្ឃបានទេ ហើយមានបាបទោសធ្ងន់ ណាស់ក្នុងព្រះពុទ្ធសាសនា ។

[23] ក្នុងប្រទេសដែលក្រព្រះសង្ឃ ឬគ្មានព្រះសង្ឃ ចំនួន ៥អង្គនេះអាចបំបួសព្រះសង្ឃបាន តែបើក្នុងប្រទេសដែលមានព្រះសង្ឃច្រើន ត្រូវមានចំនួនរហូតដល់ទៅ ២១អង្គ ទើបអាចបួសបាន ។

www.budinst.gov.kh www.elibraryofcambodia.org

## របៀបបួស(បព្វជាវិធី)

អ្នកដែលចង់បួស ដំបូងត្រូវទៅទាក់ទងលោកគ្រូចៅអធិការវត្ត ដើម្បីសុំអនុញ្ញាតបួសជាមុនសិន លុះលោកអនុញ្ញាតហើយ[24] ក៏ត្រូវកោរសក់ ពុកមាត់ ពុកចង្ការ[25] កាន់នូវសំពត់កាសាវៈ គឺស្បង់ចីវរ ហើយចូលទៅថ្វាយបង្គំលោក ៣ ដង ។ រួចហើយ បេក្ខជននោះ ក៏បន្លឺវាចាចំពោះភិក្ខុដែលជាគ្រូឧបជ្ឈាយ៍ថា :[26]

### ក-ការសូមខមា

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំលោកម្ចាស់ សូមលោកម្ចាស់អត់នូវទោស គឺសេចក្ដីខុសទាំងពួងដល់ខ្ញុំព្រះករុណា និងសូមអនុមោទនាត្រេកអរទទួលនូវបុណ្យដែលខ្ញុំព្រះករុណាបានធ្វើ ហើយសូមលោកម្ចាស់ចែករំលែកនូវបុណ្យដែលលោកម្ចាស់បានធ្វើហើយដល់ខ្ញុំព្រះករុណាវិញផង ដើម្បីជាសេចក្ដីល្អនិងជាប្រយោជន៍ ឲ្យបានសម្រេចដល់ខ្ញុំព្រះករុណា ។

### ខ-សុំបួស

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោសករុណាឲ្យនូវបព្វជាដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវបព្វជា ជាលើកទី ២ ផង ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវបព្វជាជាលើកទី ៣ ផង ។

### គ-ប្រគេនស្បង់ចីវរ (សំពត់កាសាវៈ)

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោសអនុគ្រោះ បំបួសខ្ញុំព្រះករុណា ដើម្បីជាប្រយោជន៍អាចឲ្យខ្ញុំព្រះករុណាបានព្រះនិព្វាន ដែលជាធម៌អាចឲ្យ

---

24 ក្នុងកម្ពុជា ត្រូវមានសំបុត្របញ្ជាក់ពីអាជ្ញាធរមូលដ្ឋានសិន ។

25 ក្នុងទំនៀមទម្លាប់ព្រះពុទ្ធសាសនាខ្មែរ អ្នកបួសត្រូវកោរចិញ្ចើមដែរ តែក្នុងព្រះវិន័យពុំបានឲ្យកោរទេ ព្រោះចិញ្ចើមនេះ ទុកសំរាប់ការពារញើសដែលនឹងហូរចូលភ្នែក ។

26 ស្រង់ពីសៀវភៅបព្វជាខន្ធកសង្ខេបតែជាភាសាខ្មែរទេ ហើយថែមទាំងសម្រួលឲ្យទៅជាភាសាបច្ចុប្បន្នទៀតផង ដើម្បីឲ្យអ្នកអានងាយស្រួលយល់ ព្រោះភាសាប្រែពីបាលី មានការលំបាកយល់សំរាប់អ្នកទើបរៀន ។

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំព្រះករុណារលាស់ខ្លួនចេញពីសេចក្តីទុក្ខបាន ។ (ពោល ៣ ដង)។ រួចហើយក៏ប្រគេនស្បង់ចីវរនោះទៅព្រះឧបជ្ឈាយ៍ ។ ពេលព្រះឧបជ្ឈាយ៍ទទួលយកហើយ ក៏ពោលទៀតថា ៖

### ឃ-សុំស្បង់ចីវរមកវិញ

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោសឲ្យនូវសំពត់កាសាវៈនុះ ដល់ខ្ញុំព្រះករុណា ហើយអនុគ្រោះបំបួសខ្ញុំព្រះករុណា ដើម្បីជាប្រយោជន៍អាចឲ្យខ្ញុំព្រះករុណាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាធម៌អាចឲ្យខ្ញុំព្រះករុណារលាស់ខ្លួនចេញពីសេចក្តីទុក្ខបានផង ។ (ពោល ៣ដង)។

### ង-ឧបជ្ឈាយ៍ប្រាប់កម្មដ្ឋាន

ពេលបេក្ខជនពោលសុំបួសគ្រប់ ៣ ដងហើយ ព្រះឧបជ្ឈាយ៍ក៏ប្រគល់សំពត់កាសាវៈនោះមកវិញ ហើយក៏ប្រាប់ធម៌កម្មដ្ឋានសំរាប់ឲ្យបេក្ខជននោះចម្រើនជាដំបូងដែលមានឈ្មោះថា តចបញ្ចកកម្មដ្ឋាន គឺឲ្យបេក្ខជនរៀនពិចារណាលើរូបរាងកាយរបស់ខ្លួនថាជារបស់មិនស្អាត មិនគួរឲ្យជាប់ជំពាក់ ដោយផ្តើមពី សក់ រោម ក្រចក ធ្មេញ និងស្បែក បញ្ច្រាសចុះឡើងៗជាច្រើនសារ រហូតដល់បេក្ខជនអាចចាំ និងយល់បាន ។ ធម៌សំរាប់កម្មដ្ឋាននេះ ជាធម៌ដែលកុលបុត្រគ្រប់រូបបួសរួចហើយ ត្រូវចំរើនជាប្រចាំទៀតផង ។

### ច-ស្លៀកស្បង់ចីវរ

ពេលឃើញថាចាំហើយ ព្រះឧបជ្ឈាយ៍ក៏ឲ្យចេញមកក្រៅដើម្បីស្លៀក ស្បង់ចីវរជារបៀបសមណៈឲ្យបានត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ ហើយក៏ឲ្យចូលទៅវិញដើម្បីសុំសមាទានយកនូវព្រះរតនត្រ័យទាំង ៣ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ[27] និងសុំនូវសីលសម្រាប់សំគាល់ភេទខ្លួនជាបព្វជិត (សាមណេរ) ក្នុងព្រះពុទ្ធសាសនាតទៅ។

### ឆ-សុំសីល ឬសិក្ខាបទ យកមកអនុវត្ត

---

[27] សូមអានទំព័រ ១២

www.budinst.gov.kh www.elibraryofcambodia.org

ការសមាទានយកព្រះរតនត្រ័យជាទីពឹង ត្រូវពោលថាតាមព្រះឧបជ្ឈាយ៍ ៣ ដង ឲ្យបានត្រឹមត្រូវជាស់ទៀងភាសាបាលី ។ រួចហើយក៏ទទួលយកនូវមេរៀន (សិក្ខាបទ.ឬសីល) ពីព្រះឧបជ្ឈាយ៍មកអនុវត្ត ដោយត្រូវថាតាមលោកប្រាប់ម្តងមួយៗ។ សិក្ខាបទសម្រាប់អ្នកបួសដែលមានអាយុតិចជាង ២០ ឆ្នាំ មាន ១០ យ៉ាងគឺ ៖

១) វៀរចាកការសម្លាប់សត្វ
២) វៀរចាកការលួចទ្រព្យគេ
៣) វៀរចាកការសេពមេថុន (សេពកាម)
៤) វៀរចាកការនិយាយកុហក
៥) វៀរចាកការផឹកទឹកស្រវឹង
៦) វៀរចាកការបរិភោគអាហារក្រោយពេលថ្ងៃត្រង់
៧) វៀរចាកការច្រៀង រាំ ឬមើលគេប្រគំច្រៀង លេងមហោស្រពផ្សេងៗ
៨) វៀរចាកការលាបស្រឡាបដោយគ្រឿងក្រអូប ឬពាក់កម្រងផ្កាតុបតែងខ្លួន
៩) វៀរចាកការដេក អង្គុយនៅទីកន្លែងដែលប្រណីត
១០) វៀរចាកការកាន់នូវមាសប្រាក់

កាលបើបានសមាទាននូវត្រៃសរណគមន៍ និងសិក្ខាបទទាំង ១០ ហើយ បេក្ខជន នោះក៏បានក្លាយទៅជាអ្នកបួសកម្រិតទី ១ ដែលហៅថាសាមណេរ ដោយបរិបូរណ៍ ។ ចំពោះអ្នកដែលមានអាយុលើសពី ២០ ឆ្នាំ អាចសុំដល់ព្រះសង្ឃ[28] ដើម្បីឲ្យលោកទទួលខ្លួនឲ្យទៅជាអ្នកបួសកម្រិត ២ (ភិក្ខុ) ឬជាសមាជិករបស់សង្ឃពេញសិទ្ធិបាន ដោយត្រូវ ៖

ក-រកព្រះឧបជ្ឈាយ៍

បេក្ខសម្បទា (អ្នកដែលសុំទៅជាភិក្ខុ) ត្រូវរកឧបជ្ឈាយ៍ គឺគ្រូប្រៀនប្រដៅ ១

[28] ចំពោះអ្នកបួសត្រឹមតែជាសាមណេរ អាចបួសតែជាមួយនឹងភិក្ខុ ១អង្គ ក៏បាន តែចំពោះអ្នកបួសជាភិក្ខុវិញ ត្រូវតែបានទទួលការអនុញ្ញាតពីចំណោមសង្ឃច្រើនអង្គ ។

www.budget.gov.kh www.elibraryofcambodia.org

រូប សម្រាប់ឲ្យលោកជួយប្រៀនប្រដៅ និងមើលការខុសត្រូវក្នុងកំឡុងពេលបួស ។ ការសុំនេះលោកហៅថា **សុំនិស្ស័យ** ។ ពេលដែលលោកយល់ព្រមហើយ បេក្ខសម្បទានោះត្រូវធ្វើសេចក្ដីប្ដេជ្ញាថា « បពិត្រលោកម្ចាស់ដ៏ចម្រើន ចាប់តាំងពីថ្ងៃនេះតទៅ ព្រះថេរៈជាភារៈនៃខ្ញុំព្រះករុណា (គឺភារៈក្នុងកិច្ចដែលបេក្ខសម្បទាធ្វើវត្តប្រតិបត្តិកោតក្រែង ស្ដាប់តាមឱវាទជានិច្ច) ចំណែកខាងខ្ញុំព្រះករុណា ក៏ជាភារៈរបស់ព្រះថេរៈ (ភារៈកិច្ចដែលព្រះឧបជ្ឈាយ៍គប្បីរំលឹក ដាស់តឿន ប្រៀនប្រដៅជានិច្ច) ។

### ឈ-ដូរឈ្មោះថ្មី និងប្រាប់គ្រឿងបរិក្ខាសម្រាប់អ្នកបួស

បន្ទាប់មក ឧបសម្បទាចារ្យ(ព្រះសង្ឃជំនួយការ ២ អង្គរបស់ព្រះឧបជ្ឈាយ៍ មាននាទីសម្រាប់ត្រួតពិនិត្យប្រវត្តិបេក្ខជន ដាក់ញត្តិស្នើចំពោះសង្ឃ ជាគ្រូប្រៀនប្រដៅពេលទៅជាភិក្ខុហើយ) ក៏ប្រាប់ឲ្យបេក្ខសម្បទានូវឈ្មោះថ្មីគឺ នាគ និងប្រាប់នូវឈ្មោះព្រះឧបជ្ឈាយ៍ដល់នាគឲ្យបានដឹងដែរ គឺលោកព្រះនាមថា **តិស្សថេរៈ** [29] ព្រមទាំងប្រាប់នាគនោះឲ្យដឹងនូវគ្រឿងបរិក្ខាសំរាប់អ្នកបួស ៣ មុខ ដែលសំខាន់សម្រាប់ភេទជាបព្វជិត គឺឲ្យស្គាល់ថាអ្វីជា បាត្រ (បត្ត) សម្រាប់ស្វែងរកអាហារចិញ្ចឹមជីវិតមួយ ចីពរ (ឧត្តរាសង្គ) សម្រាប់ដណ្ដប់មួយ (ចីពរនេះអាចប្រៀបស្មើនឹងអាវ) ស្បង់ (អន្តរាវាសក) សម្រាប់ស្លៀកមួយ (ស្បង់នេះអាចប្រៀបស្មើនឹងខោ ឬសារុង) និងភួយ (សង្ឃាដី) សម្រាប់ក្រាល ឬដណ្ដប់ពេលរងារមួយ ។

### ញ-ត្រួតពិនិត្យប្រវត្តិបេក្ខសម្បទា

ប្រាប់បរិក្ខាររួចហើយ ព្រះឧបសម្បទាចារ្យក៏សុំសេចក្ដីអនុញ្ញាតិអំពីការកសង្ឃ (សមាជិកសង្ឃចំនួន ២១ រូប ក្នុងពិធីបួស ដែលមាននាទីសម្រាប់អនុម័ត ថាតើអាចឲ្យឧបសម្បទាបេក្ខជន ឬសាមណេរនោះក្លាយទៅជាភិក្ខុដែរ ឬទេ) ដើម្បីឆែកប្រវត្តិរូបរបស់បេក្ខជនដែលមកសុំបួសនោះជាលើកទីមួយ និងជាកំបាំងតែពីរនាក់តទល់ ថាតើបេក្ខជននោះសមស្របទៅតាមលក្ខខណ្ឌដែលព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិ និងអនុញ្ញាត

---

[29] ជូនកាលផ្លាស់ទៅជាឈ្មោះក្នុងព្រះពុទ្ធសាសនា ដែលលោកហៅថា **នាមបញ្ញត្តិ** ព្រោះថាកាលណាបួសហើយ មិនត្រូវនឹកនាដល់ឈ្មោះដើមទៀតទេ ដោយហេតុថា សង្គមសង្ឃ ខុសពីសង្គមគ្រហស្ថ ។

www.budinst.gov.kh www.elibraryofcambodia.org

ទុកឬទេ (សួរអន្តរាយិកធម៌) ដោយធ្វើជាសំណើថា ៖ « បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ត្បិតសាមណេរឈ្មោះនាគ ដែលជាសិស្ស (សទ្ធិវិហារិកៈ) នៃព្រះថេរៈឈ្មោះតិស្សដ៏មានអាយុជាអ្នកប្រាថ្នាយកនូវឧបសម្បទា, បើឧបសម្បទាកម្មនេះជាបត្តកល្ល គឺមានកាលដ៏សមគួរ (បើសង្ឃពុំយល់ទាស់ទេ) ដល់ការកសង្ឃហើយ ខ្ញុំគប្បីប្រៀនប្រដៅ (សាកសួរ) នូវសាមណេរឈ្មោះនាគ (ជាមុនសិន) » ។

ឧបសម្បទាចារ្យ ក៏ចេញពីជំនុំសង្ឃទៅពិនិត្យសាកសួរសាមណេរនោះថា មានជម្ងឺរោគឃ្លង់ រោគពកឬបូស រោគស្រែង[30] រោគហឺត រោគឆ្កួតជ្រូក ឬទេ ។ រួចហើយលោកត្រូវពិនិត្យថាបេក្ខជននោះជាមនុស្ស និងជាមនុស្សប្រុសឬទេ ដូចដែលបានអធិប្បាយពីខាងលើ ជាអ្នកមិនមានទោស ជាអ្នកមិនជំពាក់បំណុលគេ បើជារាជការលុះត្រាតែមានច្បាប់អនុញ្ញាត មាតាបិតាបានអនុញ្ញាតហើយ មានអាយុគ្រប់ ២០ ឆ្នាំបរិបូរណ៍ ។ ជាបញ្ចប់ លោកក៏បញ្ជាក់អំពីគ្រឿងបរិក្ខា ថាតើមានគ្រប់គ្រាន់ទេ អំពីឈ្មោះថ្មីរបស់ខ្លួនក្នុងពុទ្ធសាសនា ថាតើចាំឬទៅ និងចាំឈ្មោះព្រះឧបជ្ឈាយ៍ឬទេ ។

បើសិនជាពុំមានអ្វីទាស់ទៅនឹងលក្ខខណ្ឌនៃការបួសទេ ឧបសម្បទាចារ្យក៏ចូលត្រឡប់ទៅកាន់ជំនុំការកសង្ឃវិញ ហើយប្រកាសប្រាប់ថា បានសាកសួរពិនិត្យអស់ហើយពុំមានអ្វីទាស់ខុសទេ ព្រមទាំងសុំអនុញ្ញាតពីការកសង្ឃ ដើម្បីឲ្យសាមណេរនោះចូលមកសុំការទទួលស្គាល់ពីការកសង្ឃជាផ្លូវការ ។ បើការកសង្ឃអនុញ្ញាត សាមណេរអង្គនោះក៏អាចចូលមកបាន ។

## ង-សុំការទទួលស្គាល់

ពេលនោះ បេក្ខសម្បទាក៏ចូលទៅកណ្តាលជំនុំការកសង្ឃ ហើយក៏ពោលស្នើថា «បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវឧបសម្បទានឹងព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃអាស្រ័យនូវសេចក្តីអនុគ្រោះ លើកនូវខ្ញុំព្រះករុណាឡើងឲ្យផុតចាកភេទជាសាមណេរ ហើយតម្កល់នៅក្នុងភេទជាភិក្ខុភាវៈ» ចំនួន ៣ ដង ។ នៅពេលដែលប្រកាសសុំរួចហើយ ឧបសម្បទាចារ្យក៏សាកសួរពិនិត្យនូវប្រវត្តិរូប និង

---

[30] រោគស្រែងពាសពេញខ្លួន មិនមែនស្រែងកង្កែបដែលកើតពីការរាប់បន្តិចបន្តួចនោះទេ

www.budinst.gov.kh www.elibraryofcambodia.org

លក្ខខណ្ឌផ្សេងៗនៃការបួស (អន្តរាយិកធម៌) ជាលើកទី ២ និងជាចំហរ ចំពោះមុខការកសង្ឃ ដើម្បីឲ្យបានច្បាស់ទាំងអស់គ្នា ។ បើបេក្ខសម្បទាពុំបានឆ្លើយអ្វីឲ្យខុសពីការពិនិត្យ និងដែលបានសាកសួរពីលើកទី ១ ទេនោះ ឧបសម្បទាចារ្យក៏សុំស្នើចំពោះការកសង្ឃ ដើម្បីឲ្យលោកធ្វើការសម្រេចចិត្ត ដោយលើកជាញត្តិចំនួនមួយដង និងស្នើឲ្យសម្រេចចិត្តចំនួនបីដង ដូចតទៅ៖

« បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ត្បិតសាមណេរឈ្មោះនាគ ដែលជាសិស្ស (សទ្ធិវិហារិកៈ) នៃព្រះថេរៈឈ្មោះតិស្សដ៏មានអាយុ ជាអ្នកប្រាថ្នាយកនូវឧបសម្បទា បរិសុទ្ធផុតចាកអន្តរាយិកធម៌ទាំងឡាយហើយ បាត្រ និងចីវររបស់សាមណេរឈ្មោះនាគនេះ មានគ្រប់គ្រាន់ហើយ នាគនេះមានព្រះថេរៈឈ្មោះតិស្សថេរៈជាឧបជ្ឈាយ៍បានមកសូមឧបសម្បទានឹងព្រះសង្ឃ បើឧបសម្បទាកម្មនេះ ជាបត្តកល្លៈគឺមានកាលដ៏សមគួរ (បើសង្ឃពុំយល់ទាស់ទេ) ដល់ការកសង្ឃហើយ ព្រះសង្ឃគប្បីញ៉ាំងសាមណេរឈ្មោះនាគ ដែលមានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍ឲ្យបាននូវឧបសម្បទាផង ។ នេះជាញត្តិ គឺជាវាចាសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។»

រួចហើយ ឧបសម្បទាចារ្យក៏ស្នើសុំការកសង្ឃចំនួន ៣ ដង ដើម្បីឲ្យលោកធ្វើសេចក្តីសម្រេចចិត្ត ដែលមានសេចក្តីដូចតទៅ ៖

« បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ត្បិតសាមណេរឈ្មោះនាគ ដែលជាសិស្ស(សទ្ធិវិហារិកៈ) នៃព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាអ្នកប្រាថ្នាយកនូវឧបសម្បទាបរិសុទ្ធផុតចាកអន្តរាយិកធម៌ទាំងឡាយហើយ បាត្រ និងចីវររបស់សាមណេរឈ្មោះនាគនេះ មានគ្រប់គ្រាន់ហើយ នាគនេះមានព្រះថេរៈ ឈ្មោះតិស្សថេរៈជាឧបជ្ឈាយ៍បានមកសូមឧបសម្បទានឹងព្រះសង្ឃ ។ ចំពោះឧបសម្បទាកម្មនេះ បើលោកដ៏មានអាយុ (សមាជិកការកសង្ឃ) អង្គណាយល់ព្រម ក៏គប្បីនៅស្ងៀម បើលោកដ៏មានអាយុអង្គណាមិនយល់ព្រម ក៏គប្បីពោលឡើង » ។

បើឧបសម្បទាចារ្យស្នើសុំគ្រប់ ៣ ដងហើយ ពុំមានអង្គណាពោលជំទាស់ គឺនៅស្ងៀមទាំងអស់អង្គនោះ ឧបសម្បទាកម្ម គឺការបួសជាភិក្ខុ ក៏សន្មតថាសម្រេចជា

www.budinst.gov.kh www.elibraryofcambodia.org

ស្ពាន សាមណេរឈ្មោះនាគនោះ ក៏ក្លាយខ្លួនទៅជាភិក្ខុចាប់ពីពេលនោះដែរ ។ តែបើពេលកំពុងស្នើសុំទាំង ៣ ដងនោះ មានអង្គណាមួយជំទាស់ ឧបសម្បទាកម្មនោះមិនអាចសម្រេចបានទេ ត្រូវដោះស្រាយជាមួយការមិនយល់ព្រមនោះឲ្យរួចស្រេចសិន ទើបស្នើសុំការសម្រេចចិត្តជាថ្មីម្តងទៀត ។[31]

## ៥-បណ្តាំផ្ញើរបស់ព្រះឧបជ្ឈាយ៍

ជាចុងក្រោយបង្អស់ ព្រះឧបជ្ឈាយត្រូវប្រាប់ភិក្ខុជាសិស្សទើបនឹងបួសថ្មីនេះឲ្យស្គាល់ និងចាំ : ១- អំពី ថ្ងៃ ខែ រដូវ និងឆ្នាំដែលខ្លួនបួស; ២- និស្ស័យ ៤ យ៉ាង របស់សមណៈ និង ៣- អករណីយកិច្ច ៤ យ៉ាង របស់អ្នកបួសថ្មីៗ ។

### *និស្ស័យ ៤ យ៉ាង*

១) ត្រូវព្យាយាមដើរបិណ្ឌបាត្រ គឺរកនូវអាហារមកចិញ្ចឹមជីវិតដោយការសុំពីអ្នកមានសទ្ធាជារៀងរាល់ថ្ងៃ និងដោយកម្លាំងស្មងរបស់ខ្លួនផ្ទាល់ ប៉ុន្តែក៏អនុញ្ញាតឲ្យទទួលនូវអាហារដែលទាយកគេធ្វើបុណ្យ ដោយនិមន្តឲ្យទៅទទួលនៅឯផ្ទះ ឬយកមកប្រគេនដល់វត្តដែរ ។

២) ត្រូវព្យាយាមរកសំពត់បង្សុកូល គឺសំពត់ដែលបានមកពីការរើសតាមកន្លែងគេចោល ឬសំពត់ដែលគេរុំខ្មោចយកទៅចោលជាដើម មកស្លៀកដណ្តប់ ប៉ុន្តែក៏អនុញ្ញាតឲ្យទទួលបាននូវសំពត់ផ្សេងៗ ដែលទាយកមានសទ្ធាយកមកប្រគេនដែរ ។

៣) ត្រូវព្យាយាមអាស្រ័យនៅក្រោមម្លប់ឈើជាសេនាសនៈ គឺព្យាយាមនៅក្នុងព្រៃ តែក៏អនុញ្ញាតឲ្យនៅក្នុងរូងភ្នំ ឬកុដិ វត្តដែលទាយកមានសទ្ធាប្រគេន បាន ។

---

[31] ញត្តិ និងការសុំការទទួលស្គាល់ពីការកសង្ឃនេះ មិនជាខុសពីការស្នើញត្តិក្នុងរដ្ឋសភា ដើម្បីឲ្យសភាទទួលស្គាល់នូវសមាជិកគណៈរដ្ឋមន្ត្រីនោះទេ ខុសតែត្រង់ថា នៅរដ្ឋសភាគេយកសម្លេងភាគច្រើន ឯក្នុងឧបសម្បទាកម្មលោកឲ្យយកការព្រមព្រៀងគ្នាទាំង ១០០%

www.budinst.gov.kh www.elibraryofcambodia.org

៤) ត្រូវព្យាយាមអាស្រ័យនូវទឹកមូត្រគោធ្វើជាថ្នាំរម្ងាប់រោគ តែក៏អនុញ្ញាតនូវឱសថផ្សេងៗ មានទឹកដោះថ្លា ទឹកដោះខាប់ ទឹកឃ្មុំ ទឹកអំពៅ ប្រេង សំរាប់ប្រើប្រាស់ជាឱសថបាន ។

### *អករណីយកិច្ច ៤ យ៉ាង*

នៅពេលដែលការកសង្ឃ បានអនុម័តឲ្យសាមណេរអង្គណាបានក្លាយទៅជាភិក្ខុហើយ ភិក្ខុអង្គនោះ ត្រូវមានសីល ឬសិក្ខាបទដែលត្រូវសិក្សារហូតដល់ទៅ ២២៧ សិក្ខាបទ[32] មិនមែន ១០ សិក្ខាបទ ដូចមុនទេ ទើបជាការលំបាកសម្រាប់ភិក្ខុទើបនឹងបួសថ្មី ដែលនឹងអាចចេះ និងចងចាំទាំងអស់បាន ។ ដូច្នេះ ទើបលោកគ្រូឧបជ្ឈាយ៍ត្រូវប្រាប់តែសិក្ខាបទណាដែលសំខាន់ជាទីបំផុត ឲ្យសិស្សថ្មីបានដឹងជាដំបូងសិន ។ ព្រោះថា សីល ឬសិក្ខាបទទាំង ២២៧ នេះ បើភិក្ខុមិនបានធ្វើតាមទេ នឹងត្រូវមានទោសដែលហៅថា អាបត្តិ ទៅតាមកំហុសតូច ឬធំ ដែលសិក្ខាបទបានចែង ។ អករណីយកិច្ចទាំង ៤ យ៉ាង ជាទោសដែលធ្ងន់ធ្ងរបំផុត បើភិក្ខុណាប្រព្រឹត្តហើយ ភិក្ខុនោះនឹងត្រូវខូចឋានៈជាភិក្ខុ ហើយត្រូវសឹកចេញ មិនអាចបួសតទៅទៀតបានទេ ឧបមាដូចជាទោសឧក្រិដ្ឋខាងផ្លូវរដ្ឋ ដែលត្រូវប្រហារជីវិតដូច្នោះដែរ ។ ទោសធ្ងន់ទាំង ៤ យ៉ាងនេះ លោកហៅថា បារាជិក ប្រែថាអ្នកចាញ់ ។ ទោសក្រៅពី ៤ យ៉ាងនេះ អាចអនុគ្រោះបាន ដោយការដាក់ទណ្ឌកម្មខ្លះ ដោយការសារភាពមុខសង្ឃខ្លះ តែចំពោះទោសដែលហៅថា បារាជិកនេះ ពុំអាចអត់ទោសឲ្យបានឡើយ ។

១) ភិក្ខុដែលបានឧបសម្បទាហើយ មិនគប្បីសេពនូវមេថុនធម្ម(រួមសង្វាស) ជាដាច់ខាត សូម្បីតែជាមួយសត្វតិរច្ឆានក៏ពុំបានដែរ ។ ភិក្ខុដែលសេពមេថុនធម្ម ឧបមាដូចជាមនុស្សកំបុតក្បាល ពុំអាចតឲ្យរស់វិញបានឡើយ

២) ភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវកាន់យកនូវទ្រព្យ ដែលគេមិន

[32] ដោយហេតុថាសិក្ខាបទមានច្រើនពេក សុំចិត្តអ្នកអានរកមើលក្នុងសៀវភៅភិក្ខុបាដិមោក្ខ ឬក្នុងវិន័យភិក្ខុផងចុះ ។

www.budlist.gov.kh www.elibraryofcambodia.org

បានឲ្យដោយកាយ ឬដោយវាចា ដោយចំណែកនៃចិត្តលួចនោះឡើយ។

ភិក្ខុដែលលួចទ្រព្យគេ មានឧបមាដូចជាស្លឹកឈើទុំពណ៌លឿងដែលជ្រុះចាកទង ពុំអាចប្រែទៅជាខៀវ ឬតភ្ជាប់វិញបានឡើយ ។

៣) ភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវសម្លាប់មនុស្សជាដាច់ខាត ដោយហោចទៅ សូម្បីតែញុំាងគភ៌នៃមនុស្សឲ្យរលូត ក៏ពុំបានដែរ ។ ភិក្ខុដែលសម្លាប់មនុស្ស មានឧបមាដូចជាដុំថ្មតាន់ដ៏ក្រាស់ដែលបែកចេញជា ២ ភាគ ពុំអាចតឲ្យជាបវិញបានដូចដើមឡើយ ។

៤) ភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវពោលអួតអាងថា ឧត្តរិមនុស្សធម៌ជាដាច់ខាត ដោយហោចទៅ សូម្បីតែពោលថា ខ្ញុំត្រេកអរតែក្នុងទីសេនាសនៈដ៏ស្ងាត់ដូច្នេះ ក៏ពុំបានដែរ ។ ភិក្ខុដែលមានសេចក្តីលោភពោលអួតនូវឧត្តរិមនុស្សធម៌ គឺឈានក្តីវិមោក្ខក្តី សមាធិក្តី សមាបត្តិក្តី អត្ថក្តី ផលក្តី ដែលមិនមានក្នុងខ្លួន ។ ភិក្ខុដែលអួត មានឧបមាដូចដើមត្នោតដែលកំបុតចុង ដែលមិនអាចតឲ្យដុះលូតលាស់បានវិញទេ ។

**ករណីយកិច្ចពេលបួសរួចហើយ :**

ករណីយកិច្ចរបស់លោកសង្ឃពេលបួសរួចហើយមាន ៣ យ៉ាង គឺ :

១- **បរិយត្តិ** បានដល់ការសិក្សារៀនសូត្រនូវធម៌ និងវិន័យ ឬព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្មក្នុងព្រះត្រៃបិដក ដូចបានអធិប្បាយរួចហើយ នៅត្រង់ជំពូកព្រះធម៌ ។

២- **បដិបត្តិ** គឺការយកនូវធម៌ និងវិន័យនោះមកបដិបត្តិ ពោលគឺបដិបត្តិក្នុងរឿងសីល សមាធិ និងបញ្ញា ដូចដែលបានអធិប្បាយរួចមកហើយដែរក្នុងជំពូកព្រះធម៌។

៣- **ប្រោសសត្វ** បានដល់ការជួយណែនាំ បង្ហាញផ្លូវដល់ពុទ្ធបរិស័ទឲ្យបានរួចចាកផុតពីសេចក្តីទុក្ខ ដូចមានព្រះពុទ្ធដីកាព្រះអង្គថា៖

www.budinst.gov.kh www.elibraryofcambodia.org

<ម្នាលភិក្ខុទាំងឡាយ ចូរអ្នកត្រាច់ទៅកាន់ទីចារិក គឺភូមិ និគម និងធានី ហើយសម្ដែងធម៌ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវជាមួយគ្នាឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្ដែងធម៌អោយពិរោះបទដើម បទកណ្ដាល និងបទចុង ចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថៈ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ ។ សត្វទាំងឡាយដែលមានធូលិ គឺកិលេសតិចក៏មាន សត្វទាំងឡាយនោះនឹងសាបសូន្យចាកសន្តិភាព ព្រោះមិនបានស្ដាប់ធម៌ ឯសត្វទាំងឡាយដែលបរុងត្រាស់ដឹងធម៌ក៏មានដែរ................

នៅក្នុងសិង្គាលកសូត្រ នៃទីឃនិកាយ បាដិកវគ្គ ព្រះសម្មាសម្ពុទ្ធបានត្រាស់អំពីករណីយកិច្ចរបស់ព្រះសង្ឃ ៥ប្រការ គឺ៖

១) ហាមបរិស័ទមិនឲ្យធ្វើអំពើអាក្រក់ អំពើថោកទាប អំពើទុច្ចរិត

២) ណែនាំបរិស័ទឲ្យធ្វើអំពើល្អ អំពើសុចរិត

៣) អនុគ្រោះដោយទឹកចិត្តបរិសុទ្ធ

៤) ឲ្យបរិស័ទបានស្ដាប់នូវអ្វីដែលមិនធ្លាប់ស្ដាប់ និងអនុវត្តនូវអ្វីដែលធ្លាប់បានស្ដាប់ហើយនោះ ឲ្យបានប្រត្យ័ក្សច្បាស់

៥) ប្រាប់ផ្លូវស្ថានសួគ៌ គឺផ្លូវទៅរកសេចក្ដីសុខចម្រើន ប្រាប់វិធីអភិវឌ្ឍន៍ជីវិតដល់បរិស័ទ ណែនាំឲ្យបរិស័ទមានគុណភាពជីវិតប្រសើរឡើង

ដោយសារករណីយទាំងឡាយនេះហើយ ដែលបានធ្វើឲ្យព្រះសង្ឃក្លាយទៅជាអ្នកដែលបានទទួលការគោរពកោតក្រែងជាខ្លាំង ក្នុងសង្គមពុទ្ធសាសនាទូទាំងពិភពលោក ។

www.budinst.gov.kh www.elibraryofcambodia.org

# លក្ខណៈសំគាល់ព្រះសង្ឃ

ពិតហើយដែលថា យើងអាចសំគាល់លោកសង្ឃបាននៅលើការកោរព្រះកេស ស្លៀកស្បង់ គ្រងចីវរជ្រលក់ទឹកអម្មត់ ព្រះហស្ដកាន់បាត្រនិមន្តបិណ្ឌបាត្រក្ដី ក៏នេះត្រឹមតែ ជាការសំគាល់សំបកក្រៅសំរាប់បង្ហាញភេទជាអ្នកបួសតែប៉ុណ្ណោះ ។ ព្រះសម្មាសម្ពុទ្ធ បានកំណត់អ្នកដែលមានគុណសម្បត្តិថាជាសង្ឃ ដូចតទៅនេះ ÷

ក- នៅក្នុងមហាសន្និបាតសង្ឃដំបូងបំផុត នៅព្រៃឫស្សីនៃក្រុងរាជគ្រឹះ ព្រះសម្មាសម្ពុទ្ធបាន សំដែងពីលក្ខណៈរបស់សង្ឃដែលជាសាវ័កព្រះអង្គថា :

ខន្តី បរមំ តបោ តីតិក្ខា សេចក្ដីអត់ធន់ ជាតបធម៌ដ៏ឧត្ដម គឺបានន័យថា សាវ័ក ព្រះពុទ្ធត្រូវមានខន្តី គឺចេះអត់ធ្មត់ ។

និព្វានំ បរមំ វទន្តិ ពុទ្ធា ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតិដ៏ឧត្ដម គឺបានន័យថា សាវ័កព្រះអង្គត្រូវដើរឆ្ពោះទៅរកគោលដៅជីវិតរបស់ខ្លួនដ៏កំពូលឲ្យបាន គឺនិព្វាន ដែលជាការរំលត់ទុក្ខឲ្យអស់រលីងពីខ្លួន ។

ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ ឈ្មោះថា អ្នកបួស ឬសមណៈ គឺមិនមែនជាអ្នកបៀតបៀន ឬសម្លាប់សត្វទេ ។

ទាំង ៣ នេះ សំរាប់សំគាល់ថាជាសង្ឃសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ជាពិសេសត្រង់ចំណុចពាក្យថា <u>មិនបៀតបៀន</u> ឬ <u>មិនសម្លាប់សត្វ</u> ។ ដែលគួរឲ្យកត់សំគាល់ថែមទៀតនោះ គឺពាក្យថា <u>សមណៈ</u> នេះមានន័យថា <u>អ្នកស្ងប់</u> ដែលមានន័យស្មើនឹងមិនបៀតបៀនគេ ឬ អហិង្សានេះឯង ។

នៅក្នុងករណីមេត្តសូត្រ ព្រះអង្គបានសំដែងអំពីលក្ខណៈរបស់ព្រះសង្ឃថា :

| | |
|---|---|
| ១- សក្កោ | ជាអ្នកអង់អាច |
| ២- ឧជូ | មានកាយ និងវាចាត្រង់ |
| ៣- សុហុជូ | មានចិត្តត្រង់ |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ៤- សុវចោ | ជាមនុស្សងាយក្នុងការណែនាំប្រដៅ |
| ៥- មុទុ | ជាអ្នកទន់ភ្លន់ |
| ៦- អនតិមានី | មិនមានអតិមានះ |
| ៧- សន្តុស្សកោ | មានសន្តោស |
| ៨- សុភរោ | ងាយគេចិញ្ចឹម |
| ៩- អប្បកិច្ចោ | មានធុរៈកិច្ចតិច (មិនរវល់តែពីរឿងហូបចុក) |
| ១០- សល្លហុកវុត្តិ | ប្រព្រឹត្តស្រាលកាយ និងចិត្ត (ទៅណាមិនមានអ្វីច្រើន) |
| ១១- សន្តិន្ទ្រិយោ | មានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តជាសន្តិភាព |
| ១២- និបកោ | ឆ្លាត ឈ្លាសវៃ |
| ១៣- អប្បគព្ភោ | មិនឆ្គង |
| ១៤- កុលេសុ អននុគិទ្ធោ | មិនជាប់ជំពាក់ដោយត្រកូល, ពូជ, សាសន៍, បក្ស |

នៅក្នុងសង្ឃគុណដែលយើងតែងសូត្ររំលឹក ព្រះអង្គទ្រង់បានសរុបនូវគុណធម៌របស់សង្ឃសាវ័កព្រះអង្គចំនួន ៤ ប្រការ ដោយផ្អែកទៅលើការបដិបត្តិជាខ្នាតរង្វាស់គឺ :

១- សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគជាអ្នកបដិបត្តិល្អ មានគោលបំណង (Goal) ក្នុងជីវិតមិនងាករេ ក្នុងការសំរេចឲ្យបាននូវព្រះនិព្វាន គឺការរំលត់ទុក្ខ និងមានគោលដៅ (Objectives) ច្បាស់លាស់ ដោយត្រូវធ្វើឲ្យកើតនូវគុណធម៌ទាំង ៨ ក្នុងចិត្ត គឺសោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ និងអរហត្តផល ។

២- ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ

www.budinst.gov.kh www.elibraryofcambodia.org

ជាអ្នកបដិបត្តិត្រង់ គឺបដិបត្តិតាមមជ្ឈិមាបដិបទា ជាផ្លូវកណ្តាល មិនលំអៀងឆ្វេងជាបែបអត្តកិលមថានុយោគ (Self-Mortification: ការធ្វើខ្លួនឲ្យលំបាក ការធ្វើទារុណកម្មខ្លួនឯង) និងមិនលំអៀងស្តាំ ជាបែបកាមសុខល្លិកានុយោគ (Self-Indulgence ការគិតតែសប្បាយនឹងរឿងកាមសុខ) ។ ផ្លូវកណ្តាលនោះ ហៅថា អដ្ឋង្គិកមគ្គ គឺមគ្គដែល មានអង្គ ៨ :

- សម្មាទិដ្ឋិ យល់ត្រូវ (Right Understanding)
- សម្មាសង្កប្បៈ គិតត្រូវ (Right Thought)
- សម្មាវាចា និយាយត្រូវ (Right Speech)
- សម្មាកម្មន្តៈ ធ្វើការត្រូវ (Right Act)
- សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រូវ (Right Livelihood)
- សម្មាវាយាមៈ ព្យាយាមត្រូវ (Right Effort)
- សម្មាសតិ រំលឹកត្រូវ (Right Consciousness)
- សម្មាសមាធិ តំកល់ចិត្តត្រូវ (Right Concentration)




៣-ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ

www.budinst.gov.kh www.elibraryofcambodia.org

ជាអ្នកប្រតិបត្តដើម្បីត្រាស់ដឹងនូវព្រះនិព្វាន គឺការរំលត់នូវសេចក្តីទុក្ខ ។ ដើម្បីបានសំរេចនូវព្រះនិព្វាននោះ សង្ឃសាវ័ក គប្បីប្រកាន់ខ្ជាប់ក្នុងពោធិបក្ខិយធម៌ ៣៧ យ៉ាង មានសតិបដ្ឋាន ៤ សម្មប្បធាន ៤, ឥទ្ធិបាទ ៤, ឥន្ទ្រិយ៍ ៥, ពលៈ ៥, ពោជ្ឈង្គ ៧, និងមគ្គមានអង្គ ៨ ។

៤- សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ ជាអ្នកមានដំណើរជីវិតនៅក្នុងគន្លងសីល សមាធិ និងបញ្ញា (សូមមើលសីល សមាធិ បញ្ញា ក្នុងវគ្គព្រះធម៌)

ផលប្រយោជន៍នៃការបដិបត្តិល្អ

ជារឿងផ្ទាល់ខ្លួន ព្រះសង្ឃដែលបានបដិបត្តិល្អ បដិបត្តិត្រង់ បដិបត្តិដើម្បីការត្រាស់ដឹង និងបដិបត្តិដ៏សមគួរហើយ រមែងបានទទួលនូវផលមួយ ក្នុងចំណោមផលទាំង ៩ ប្រការ គឺសោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល និងព្រះនិព្វានជាពុំខាន ទៅតាមកំរិតនៃការបដិបត្តិ ។ នៅក្នុងផ្នែកសង្គមវិញ អង្គដែលបានបដិបត្តិតាមគោលការណ៍ទាំង ៤ ហើយនឹងបាននូវអានិសង្ស ៥ យ៉ាង និងដែលជាគុណសម្បត្តិរបស់លោកផងដែរ គឺៈ

- អាហុនេយ្យោ គួរជាគោរពបូជារបស់ពុទ្ធបរិស័ទ គួរឲ្យបរិស័ទពេញចិត្ត និងជាបុគ្គលដែលគេពេញចិត្តក្នុងការនាំយកនូវអាមិសទានមកបូជា ។ (លោកតែងធ្វើខ្លួនឲ្យគេគោរព)
- បាហុនេយ្យោ គួរឲ្យគេទទួលរាក់ទាក់ គឺទោះជាលោកនិមន្តទៅទីណា ក៏នឹងមានគេទទួលដោយរាក់ទាក់យកចិត្តទុកដាក់ និងឧបត្ថម្ភដោយអស់ពីចិត្ត ព្រោះមិនមានភ័យខ្លាច ថានឹងកើតទុក្ខទោសដោយសារលោក ។ (លោកធ្វើខ្លួនជាមិត្តនឹងមនុស្សគ្រប់រូប និង មានប្រយោជន៍ ដល់មនុស្សដែលលោកប្រាស្រ័យជាមួយជានិច្ច)
- ទក្ខិណេយ្យោ ជាអ្នកដែលគេគួរធ្វើបុណ្យជាមួយ ដើម្បីយកផលបុណ្យឧទ្ទិសទៅឲ្យដល់មាតាបិតា និងបុព្វការីរបស់គេដែលចែកឋានទៅ ។(លោកជាមនុស្សបរិសុទ្ធ)

www.budinst.gov.kh www.elibraryofcambodia.org

អញ្ជលិករណីយោ ជាអ្នកដែលគេគួរទឹងក្រាបថ្វាយបង្គំ គោរពសំពះ ដោយអស់ពីចិត្ត ពីថ្លើម ព្រោះលោកមានសីលល្អ មានចិត្តល្អ និងមានបញ្ញាល្អ ។ (លោកមានកិរិយាគួរជាទីជ្រះថ្លាដល់ជនដែលបានជួបលោក)

- អនុត្តរ បុញ្ញក្ខេត្តំ លោកស្ស ជាស្រែបុណ្យដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិភពលោក គឺអ្នកណាបានធ្វើបុណ្យនឹងលោក ប្រាកដជាបានទទួលនូវផលដ៏មហាសាលសំរាប់ជីវិតរបស់ខ្លួន

ចំពោះផ្នែកសង្គមវិញ ការបានបដិបត្តិល្អរបស់ព្រះសង្ឃក្នុងធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធ ជាការលើកទឹកចិត្តយ៉ាងខ្លាំងដល់សទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ ក្នុងការជឿនិងព្យាយាមគោរពតាមអ្វីដែលព្រះសង្ឃបានសម្តែងទេសនាប្រាប់ ព្រោះមានលោកជាគំរូឲ្យឃើញហើយ ។ ការបដិបត្តិល្អនេះ និងជះឥទ្ធិពលដល់ពុទ្ធបរិស័ទឲ្យនាំគ្នាបដិបត្តិល្អតាម ។

**តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ**
**បាដិមោក្ខេ ច សំវរោ មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។**

កិច្ចដំបូងដែលភិក្ខុអ្នកមានបញ្ញាត្រូវធ្វើក្នុងព្រះសាសនានេះគឺ សំរួមឥន្ទ្រីយ៍ មានសេចក្តីសន្តោស ប្រយ័ត្នប្រយែងក្នុងវិន័យបញ្ញត្តិ សេពគប់តែកល្យាណមិត្ត អ្នកដែលឧស្សាហ៍ព្យាយាម និងមានអាជីវកម្មស្អាតបរិសុទ្ធិ ។

**ហត្ថសញ្ញតោ បាទសញ្ញតោ វាចាសញ្ញតោ សញ្ញតុត្តមោ**
**អជ្ឈត្តរតោ សមាហិតោ ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។**

អ្នកសំរួមដៃ សំរួមជើង សំរួមវាចា សំរួមកាយ ព្រេកអរក្នុងការបំពេញវិបស្សនា
មានចិត្តជាសមាធិ និងសន្តោសនៅម្នាក់ឯង អ្នកនោះមានឈ្មោះថាជាភិក្ខុ ។

www.budinst.gov.kh www.elibraryofcambodia.org

# យកព្រះសង្ឃជាទីពឹង

សង្ឃំ សរណំ គច្ឆាមិ ! ខ្ញុំសូមយកព្រះសង្ឃជាទីពឹង ទីរលឹក

រយៈពេលជាងពីរពាន់ឆ្នាំហើយ ដែលពុទ្ធសាសនាមានកំណើតនៅលើលោកនេះ ។ ចាប់ផ្តើមនៅលើអនុទ្វីបឥណ្ឌា ពុទ្ធសាសនាបានចេញផុតពីព្រំដែននេះ ឆ្ពោះទៅកាន់ទ្វីប និងប្រទេសនានាគ្រប់ទិសទី ។ ការរីកសាយភាយដ៏ទូលំទូលាយនេះគឺដោយសារស្នាដៃ និងថ្វីព្រះឱស្ឋរបស់ព្រះភិក្ខុសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគរបស់យើងនេះឯង ។

គុណសម្បត្តិដែលសំខាន់ៗរបស់ព្រះសង្ឃ តាមដែលយើងអាចមើលឃើញគឺៈ

១. ជាអ្នករក្សា និងផ្សព្វផ្សាយព្រះធម៌

ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងអស់ដែលស្ថិតស្ថេរនៅបានរហូតដល់សព្វថ្ងៃនេះ ក៏ព្រោះមានព្រះសង្ឃជាអ្នកផ្សព្វផ្សាយដែរ ។ នៅពេលដែលព្រះពុទ្ធអង្គសំដែងធម៌រួចហើយ ព្រះសង្ឃទាំងអស់តែងតែចងចាំនូវពុទ្ធវចនៈនោះ ហើយក៏នាំយកទៅទេសនា និយាយ អប់រំ ពន្យល់ដល់អ្នកដទៃទៀតជានិច្ច ។ នៅពេលដែលព្រះពុទ្ធអង្គទ្រង់បរិនិព្វានហើយ លោកក៏រៀបចំសង្គាយនាឡើង ដើម្បីរៀបចំពុទ្ធវចនៈទាំងនោះឲ្យមានរបៀបរៀបរយ ជាក្រុមជាពួក និងចាត់កំលាំងគ្នាទន្ទេញនូវពុទ្ធវចនៈទាំងនោះឲ្យចាំរត់មាត់កុំឲ្យភ្លេច ។ ជាងពីររយឆ្នាំក្រោយមកទៀត ព្រះសង្ឃលោកក៏បាននាំពុទ្ធវចនៈចេញពីប្រទេសឥណ្ឌា ទៅកាន់ទីកន្លែងផ្សេងៗក្នុងពិភពលោក ដែលរួមទាំងប្រទេសនាជ្រោយសុវណ្ណភូមិផងដែរ ។ ប្រាំរយឆ្នាំមកទៀត ព្រះសង្ឃលោកក៏បានចារឹកពុទ្ធវចនៈ ដែលចាំមាត់នោះនៅលើស្លឹករឹត ហើយក៏វិវឌ្ឍន៍ម្តងបន្តិចៗរហូតកើតជាសៀវភៅដូចនាបច្ចុប្បន្ននេះ ។ បើគ្មានព្រះសង្ឃទេ ពុទ្ធសាសនាមិនអាចមាននៅដល់សព្វថ្ងៃនេះឡើយ ហើយយើងក៏មិនអាចមានសំណាងបាន ត្រេបត្រូវរសជាតិព្រះធម៌បានដែរ ។

២. ជាអ្នកផ្តល់ប្រយោជន៍

ទោះជានៅទីណាក៏ដោយ ព្រះសង្ឃយើងតែងតែទេសនាពន្យល់ដល់បរិស័ទ

www.budinst.gov.kh www.elibraryofcambodia.org

កុំឲ្យមានការខ្ជិលច្រអូស មានសេចក្តីព្យាយាមក្នុងការស្វែងរកទ្រព្យសម្បត្តិ ដែលជាប្រយោជន៍សំរាប់ជីវិតបច្ចុប្បន្នជានិច្ច ÷ ប្រឹងប្រែងរកទ្រព្យ (ឧដ្ឋានសម្បទា) ប្រឹងប្រែងរក្សាទ្រព្យឲ្យគង់ (អារក្ខសម្បទា) សេពគប់មិត្តល្អ (កល្យាណមិត្តតា) និងចិញ្ចឹមជីវិតដោយល្អ (សមជីវិតា) ។[33]

## ៣. ជាអ្នកផ្តល់សេចក្តីសុខដល់បរិស័ទ

ការណែនាំបរិស័ទឲ្យរស់នៅបានសុខស្រួល មានសុភមង្គល មានការរីកចំរើនក្នុងជីវិតខ្លួន និងសង្គម គឺជាភារកិច្ចរបស់ព្រះសង្ឃ ។ លោកណែនាំឲ្យយើងមានជំនឿលើអំណាចចិត្ត លើសម្តី និងអំពើដ៏ល្អរបស់ខ្លួន ក្នុងការរស់នៅដើម្បីជំនះលើឧបសគ្គទាំងពួង (សទ្ធាសម្បទា); លោកប្រាប់យើងឲ្យគោរពច្បាប់ ឲ្យកាន់វិន័យឲ្យស្រឡាញ់សីលធម៌ ក្នុងការរួមរស់នៅជាមួយគ្នាក្នុងសង្គម (សីលសម្បទា); លោកទូន្មានយើងឲ្យចេះចែករំលែក ចេះជួយគ្នា ចេះលះបង់ ដើម្បីប្រយោជន៍ដល់អ្នកដែលអន់ខ្សោយជាងយើង(ចាគសម្បទា) និងលើកទឹកចិត្តយើងឲ្យស្រឡាញ់វិជ្ជា ឲ្យប្រើបញ្ញាក្នុងការរស់នៅជានិច្ច (បញ្ញាសម្បទា)។[34] ពុទ្ធបរិស័ទដែលប្រតិបត្តិពិតៗតាមការណែនាំរបស់ព្រះសង្ឃ តែងតែមានសេចក្តីសុខនៅក្នុង សង្គមរបស់ខ្លួនជានិច្ច ។

## ៤. ជាអ្នកអនុគ្រោះដល់សត្វលោក

តាំងតែពីព្រះសង្ឃអង្គដំបូង បាននាំពុទ្ធសាសនាចូលមកតាំងនៅក្នុងប្រទេសខ្មែរមក ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញនូវតួនាទីមួយដ៏សំខាន់ ដែលព្រះសង្ឃលោកបានធ្វើដល់ប្រជាពលរដ្ឋខ្មែរ ទាំងខាងវិស័យសង្គមសេដ្ឋកិច្ច (socioeconomic) សង្គមចិត្តវិទ្យា (psychosocio) និងសង្គមវប្បធម៌ (socioculture) ។ តាមពិត នាទីរបស់ព្រះសង្ឃដោយផ្ទាល់ គឺការបដិបត្តិឲ្យបានត្រឹមត្រូវទៅតាមពុទ្ធឱវាទ ពោលគឺ សីល សមាធិ បញ្ញា ឯណោះទេ តែដោយសារក្តីមេត្តារបស់លោកដែលមានចំពោះសព្វសត្វ អនុគ្រោះ

---

33 ទិដ្ឋធម្មិកត្ថៈ ៤យ៉ាង

34 សម្បរាយិកត្ថៈ ៤យ៉ាង

www.budlist.gov.kh www.elibraryofcambodia.org

ចង់ឲ្យពុទ្ធបរិស័ទបាន សេចក្តីសុខទាំងខាងផ្លូវកាយនិងផ្លូវចិត្ត ទើបលោកប្រឡូកចូលទៅបំពេញនាទីទាំងនោះ គឺ៖

- ព្រះសង្ឃលោកជាធនធានមនុស្សដ៏ពិសេសបំផុតខាងផ្នែកអក្សរសាស្ត្រជាតិ ព្រោះលោកជាអ្នកមានជំនាញខាងភាសាបាលី ដែលជាប្រភពឫសគល់មួយដ៏សំខាន់នៃអក្សរសាស្ត្រខ្មែរ។ លើកជាឧទាហរណ៍ដ៏ជាក់ស្តែង គឺសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលលោកបានបូជាកម្លាំងព្រះកាយនិងចិត្ត ដើម្បីបង្កើតវចនានុក្រមខ្មែរឲ្យសម្រេចជារូបរាងបាន និងប្រើប្រាស់រហូតដល់បច្ចុប្បន្ន; ព្រះគ្រូអាចារ្យ ហែម ចៀវ និងព្រះសង្ឃ រាប់រយអង្គដទៃទៀត ដែលខំតស៊ូដោយយកព្រះជន្មាយុទៅប្តូរ ដើម្បីទាមទារបារាំង មិនឲ្យកែប្រែអក្សរខ្មែរទៅជាអក្សរឡាតាំងជាដើម ។ ក្រៅពីនេះ យើងក៏ឃើញថា វណ្ណកម្មអក្សរសិល្ប៍ជាច្រើន បានមានកំណើតពីក្នុងវត្ត ដូចជាច្បាប់ទូន្មានផ្សេងៗ កំណាព្យ រឿងជាតក រឿងទុំទាវ ជាដើម ។ ទាំងអស់នេះគឺសុទ្ធតែជាគុណសម្បត្តិរបស់ព្រះសង្ឃទាំងអស់ បើគ្មានលោកទេ យើងប្រាកដជាមានការលំបាកពីរឿងអក្សរសាស្ត្រ ជាតិជាពិតប្រាកដ។
- ព្រះសង្ឃជាគ្រូបង្រៀនអក្សរខ្មែរដល់កុលបុត្រខ្មែរសឹងតែទាំងអស់ កាលដែលសាលារៀនបែបទំនើបមិនទាន់កើតមាន ។ ទាំងរាស្ត្រ មន្ត្រី ទាំងព្រះរាជា សុទ្ធតែបានទទួលការបណ្តុះបណ្តាលផ្នែកអក្សរសាស្ត្រខ្មែរអំពីព្រះសង្ឃទាំងអស់ ។ សូម្បីតែបច្ចុប្បន្ននេះ កូនប្រុសខ្មែរជាច្រើនដែលពុំមានឱកាសចូលសាលារៀនរដ្ឋ ដោយមូលហេតុថវិកា ឬធំហួសអាយុនឹងចូលសាលាក្តី ក៏អាចនឹងចូលទៅនៅវត្ត ឬបួសជាសង្ឃ ដើម្បីបានទទួលការសិក្សាដែរ ដែលជាការចូលរួមចំណែកដ៏ធំមួយក្នុងការកាត់បន្ថយអនក្ខរភាពចេញពីសង្គមខ្មែរ ។
- ព្រះសង្ឃលោកបានដើរតួនាទីជាអ្នកថែរក្សាវប្បធម៌ និងសម្បត្តិវប្បធម៌ខ្មែរ ជាពិសេស ក្នុងពេលដែលមានសឹកសង្គ្រាមកើតឡើងក្នុងស្រុកៈ ទំនៀមទំលាប់នានា អក្សរសាស្ត្រជាតិ ក្បួនច្បាប់នៃសាស្ត្រ និងជំនាញផ្សេងៗ បេតិកភ័ណ្ឌជាតិ បុរាណវត្ថុជាដើម ។ល។

លោកជាតំណាងនៃភាពយុត្តិធម៌ ដែលប្រជាពុទ្ធបរិស័ទយកធ្វើជាទីពឹង ។ ក្នុងសម័យមុន កាលណាមានជំលោះផ្សេងៗ ឬក្តីក្តាំរវាងគ្នានឹងគ្នាក្នុងភូមិ អ្នកស្រុក

www.budinst.gov.kh www.elibraryofcambodia.org

តែងតែទៅរកព្រះសង្ឃដើម្បីឲ្យលោកជួយកាត់ក្ដីឲ្យ ព្រោះលោកជាអ្នកចេះដឹង មានសមត្ថភាព និងមានភាពយុត្តិធម៌ ។ ហេតុការណ៍នេះ បានធ្វើឲ្យលោកទទួលនូវកិត្តិនាមមួយដ៏ល្បី គឺគេតែងហៅលោកថា **អាចក្ដី** ព្រោះលោក អាច នៅក្នុង ក្ដី[35] ទាំងពួង ។

- ព្រះសង្ឃ លោកជាវេជ្ជបណ្ឌិតប្រចាំសហគមន៍ ខាងផ្នែកព្យាបាលរោគតាមថ្នាំឫសឈើ តាមមន្តអាគម និងតាមផ្លូវកម្លាំងសមាធិចិត្តរបស់លោកយ៉ាងមានប្រសិទ្ធិភាព ៖ ជំងឺផ្លូវកាយ ជំងឺផ្លូវចិត្ត ជំងឺសត្វពាហនៈជាដើម សុទ្ធតែនៅក្នុងបរិបទនៃការព្យាបាលរបស់លោកទាំងអស់ ។
- លោកជារុក្ខវិទូមួយដ៏ចំណានក្នុងសង្គមខ្មែរ ។ ដោយសារសេចក្ដីត្រូវការក្នុងការព្យាបាលជំងឺបរិស័ទ និងការពិសោធន៍លើការដើរធុតង្គក្នុងព្រៃ ធ្វើឲ្យលោកស្គាល់រុក្ខជាតិជាច្រើនប្រភេទ ព្រមទាំងផលប្រយោជន៍ផ្សេងៗរបស់រុក្ខជាតិទាំងនោះយ៉ាងច្បាស់ ។ មិនតែប៉ុណ្ណោះលោកបានទាំងដាំរុក្ខជាតិទាំងនោះនៅក្នុងវត្តទៀតផង ។
- ព្រះសង្ឃគឺជាអភិវឌ្ឍនករមួយដ៏សំខាន់នៅក្នុងសហគមន៍ខ្មែរ ។ បំពេញតួនាទីជាព្រះសង្ឃផង លោកឆ្លៀតឱកាសមើលដល់សុខទុក្ខ និងគុណភាពជីវិតបរិស័ទជានិច្ច ។ ការសាងសង់សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្រះទឹក ស្ពាន សុទ្ធតែបានដឹកនាំ និងរកថវិកាដោយព្រះសង្ឃទាំងអស់ ថ្វីត្បិតតែបច្ចុប្បន្ននេះកិច្ចការអភិវឌ្ឍន៍ជាតិបានធ្លាក់ទៅលើរាជរដ្ឋាភិបាលក្ដី ក៏ព្រះសង្ឃនៅតែបានដើរតួនាទីដ៏សំខាន់នៅឡើយ ។
- ។ល។

## ៥. ជាសន្តិភាវករ

សត្វទាំងឡាយនោះនឹងបាត់បង់សន្តិភាព ព្រោះមិនបានស្ដាប់ធម៌ !

គឺជាបន្ទូលដំបូង បំផុតរបស់ព្រះអង្គដែលត្រាស់ចំពោះភិក្ខុទាំងឡាយ មុននឹងព្រះអង្គបញ្ជូនឲ្យចេញទៅផ្សព្វផ្សាយធម៌ ។ លោកជាអ្នកប្រាប់ពុទ្ធបរិស័ទឲ្យស្គាល់នូវអ្វីដែលហៅថា សន្តិ និងវិធីដើម្បីជួបនូវសន្តិភាពនោះ ។ សង្គមនេះ ពោរពេញទៅដោយការ

[35] ក្ដី មានន័យថា ជំលោះ(ក្ដីក្ដាំ) ដំណើរជីវិត កិច្ចការទាំងពួង

www.budhist.gov.kh www.elibraryofcambodia.org

ច្របូកច្របល់ ការប្រកួតប្រជែង ដណ្ដើម បៀតបៀន និងសង្គ្រាម ដោយពុំចេះចប់ ។ សន្តិភាព គឺការស្ងប់ អាចនឹងរកឃើញបាន ក៏នឹងអាស្រ័យទៅលើបុគ្គលម្នាក់ៗថា ខ្លួននឹងព្យាយាមដើម្បីនឹងធ្វើ ខ្លួនឲ្យទៅជាអ្នកស្ងប់ (សមណៈ) ឬទេតែប៉ុណ្ណោះ ។ ព្រះសង្ឃលោកជា អ្នកស្ងប់ដោយភេទ (សមណៈ) តែលោកក៏បានព្យាយាម ដើម្បីនឹងឲ្យមនុស្សលោកបានក្លាយទៅជាសមណៈ (អ្នកស្ងប់ដោយផ្លូវចិត្ត) ដែរ ព្រោះមានតែវិធីនេះឯង ដែលពិភពលោកនេះអាចនឹងមានពាក្យ សន្តិភាព បាន ។

នាទីការផ្សព្វផ្សាយព្រះធម៌ក្ដី ការផ្ដល់នូវសេចក្ដីសុខក្ដី ការផ្ដល់នូវ ប្រយោជន៍ក្ដី ការអនុគ្រោះដល់សត្វលោកទាំងអស់ក្ដី សុទ្ធតែស្ថិតនៅក្នុងបរិបទនៃសន្តិភាវូបនីយកម្មរបស់ព្រះសង្ឃទាំងអស់ ព្រោះព្រះពុទ្ធអង្គទ្រង់សំដែងថា និព្វានំ បរមំ វទន្តិ និព្វានជាគោលបំណងរបស់ពុទ្ធសាសនា ។ និព្វាន គឺសន្តិភាព ! មានមនុស្ស ច្រើនរាប់មិនអស់ ដែលបានទទួលសន្តិភាព ដោយសារស្នាព្រះហស្តរបស់ព្រះសង្ឃ ហើយការដែលយើងយកនូវឱវាទរបស់លោកមកអនុវត្តតាម ដើម្បីឲ្យកើតប្រយោជន៍ ឲ្យមានសេចក្ដីសុខ និងព្យាយាមយកលោកជាគំរូក្នុងការរស់នៅរបស់យើងនេះ ឈ្មោះថាយើងបាន យកលោកជាទីពឹងទីរលឹកហើយ ។

● ព្រះសង្ឃសោភា លះបង់អាត្មា ដើម្បីពុទ្ធរតន៍ សំរួមផ្លូវចិត្ត ផ្លូវកាយហ្មត់ចត់ ឃើញហើយគួររត់ ជ្រះថ្លាមិនបាន ។ នឿយហត់វាចា ប្រាយប្រាប់ទេសនា ប្រោសសត្វគ្រប់ប្រាណ ឲ្យរួចផុតទុក្ខ បានសុខក្សេមក្សាន្ត ដើរតាមលំអាន បរមគ្រូជិនស្រី ។ ភ្លៀងក្ដៅរងារ មុតក្ដៅបាទា មិនមាត់មិនស្ដី ហេតុចង់ឲ្យសត្វ បានសុខសិរី រតនៈទីបី ព្រះសង្ឃអង្គម្ចាស់ ។ ខ្ញុំសូមពឹងលោក បំបាត់ទុក្ខសោក រោគភ័យវិប្បដិសារ កិលេសតណ្ហា ឈឺឲ្យក្ដៅណាស់ មេត្តាផ្ដាច់ផ្ដាស់ ពុទ្ធមន្តដល់ខាន ។ ព្រះធម៌ត្រជាក់ លើកដៃត្រងដាក់ ទូលលើត្បូងភាណ សូមគុណព្រះសង្ឃ លោកជួយឲ្យក្សាន្ត កើតសុខមានបាន ជួបនិព្វានហោង ៕

# ពុទ្ធសាសនា និង សង្គមខ្មែរ

មួយពាន់ប្រាំពីររយឆ្នាំជាងហើយ ដែលពុទ្ធសាសនាបានចូលមកប្រតិស្ឋានទៅប្រទេសខ្មែរយើង គឺតាំងពីនៅក្នុងជំនាន់ហ្វូណនមកម៉្លេះ ។ ការដែលអាចរស់រានមានជីវិតក្នុងរយៈកាលមួយដ៏យូរអន្លង់បែបនេះ ជាការបញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាប្រាកដជាមានអ្វីដែលល្អ និងជាប្រយោជន៍ដល់សង្គមខ្មែរជាពុំខាន ទើបប្រជារាស្ត្រយើងខិតខំថែរក្សារហូតមកដល់សព្វថ្ងៃនេះ ។ បើតាមប្រវត្តិសាស្ត្រ ពុទ្ធសាសនាបានទទួលនូវការបៀតបៀនពីសាសនាព្រាហ្មណ៍ និងលទ្ធិផ្សេងៗជាច្រើនដងមកហើយ ជាពិសេសនៅក្នុងរវាងឆ្នាំ ១៩៧៥ - ១៩៧៨ ដែលត្រូវរលាយស្ទើរបាត់រូបរាង ដោយសាររបបកុំមុយនិស្ត តែក៏រស់ត្រឡប់មកវិញគួរឲ្យស្ញប់ស្ញែង និងរីកដុះដាលគួរឲ្យរីករាយ ។ បើគ្មានប្រយោជន៍ ខ្មែរពិតជាមិនខំថែរក្សារហូតមកដល់សព្វថ្ងៃនេះទេ ។

ទំនាក់ទំនងរបស់ពុទ្ធសាសនានឹងសង្គមខ្មែរ អាចមើលឃើញនៅក្នុងលក្ខណៈពីរយ៉ាង គឺ លក្ខណៈជាគំនិត និងលក្ខណៈជាការអនុវត្ត គឺ ៖

## ១-ផលប្រយោជន៍ជាគំនិត

ផលប្រយោជន៍ដំបូងដែលខ្មែរសម្លឹងឃើញក្នុងការយកពុទ្ធសាសនាមកធ្វើជាសាសនាប្រចាំជាតិ គឺគោលធម៌ និង ទស្សនៈដែលពុទ្ធសាសនាមានចំពោះការដឹកនាំ និងគ្រប់គ្រងប្រទេស ។ ខ្ញុំគិតថា យ៉ាងហោចណាស់ ពុទ្ធសាសនាមានចំណុច ៥ យ៉ាង ដែលមានប្រយោជន៍ចំពោះការគ្រប់គ្រង គឺ ៖

១- <u>សន្តិភាព</u> : ក្នុងនាមនៃពុទ្ធសាសនា សន្តិភាព គឺជាគោលចំបងដែលសង្គមនិមួយៗប្រាថ្នាចង់បាន[៣៦] ។ ពុទ្ធសាសនា បានស្នើនូវវិធីដែលអាចអនុវត្តបាន ក្នុងការស្វែងរកសន្តិភាពនោះ ដោយចាប់ផ្តើមពីការស្រឡាញ់នូវសន្តិភាពដោយបុគ្គលម្នាក់ៗជាមុន និងការរស់នៅក្នុងវិធីជីវិតអហឹង្សា ព្រមទាំងការដោះស្រាយទំនាស់ដោយប្រើ

36 - នត្ថិ សន្តិ បរំ សុខំ

www.budinst.gov.kh www.elibraryofcambodia.org

ហេតុផល និងការយោគយល់គ្នាដើម្បីបញ្ចប់សង្គ្រាម[37] ។ សន្តិភាព គឺសភាវៈដែលគ្មានសង្គ្រាម គ្មានហឹង្សា និងគ្មានសេចក្តីខ្វះខាតទាំងផ្នែកសេដ្ឋកិច្ច(កាយ) និងដួងវិញ្ញាណ(ចិត្ត) ។ សន្តិភាពមិនអាចកើតបានទេ បើសង្គមនោះមានសេដ្ឋកិច្ចទន់ខ្សោយ (ខ្វះបច្ច័យ ៤) តែសន្តិភាពនោះក៏នឹងអាចបាត់បង់ភ្លាម បើសង្គមនោះមានពលរដ្ឋដែលបាត់បង់នូវចិត្តវិញ្ញាណ និងសីលធម៌ពីក្នុងសន្តានចិត្ត ឬពលរដ្ឋខ្លួនមានជម្ងឺផ្លូវចិត្ត[38] ។

២- ការអភិវឌ្ឍន៍ធនធានមនុស្ស : មនុស្សគឺជាកោសិកាសង្គម ឬសង្គមជាការប្រមូលផ្តុំនៃបុគ្គលិកច្រើនរូប ។ បុគ្គលខ្សោយ សង្គមខ្សោយ, បុគ្គលខ្លាំង សង្គមខ្លាំង, បុគ្គលល្អ សង្គមចំរើន ។ ពុទ្ធសាសនា សម្លឹងមើលការអភិវឌ្ឍន៍ទាំងឡាយដោយមានចំណុចចាប់ផ្តើមនៅត្រង់ការដែលបុគ្គលម្នាក់ៗ បានទទួលការអភិវឌ្ឍន៍ហើយទាំងខាងផ្នែករាងកាយ ការគោរពច្បាប់ អារម្មណ៍ និងសតិបញ្ញា[39] ។ ព្រះសម្មាសម្ពុទ្ធគឺជាអ្នកហ្វឹកហាត់មនុស្សដែលគ្មានគូប្រៀប(អនុត្តរោ បុរិសទម្មសារថិ) និងជាគ្រូបង្រៀនរបស់មនុស្សគ្រប់ស្រទាប់(សត្ថា ទេវមនុស្សានំ) ។ ពុទ្ធសាសនាអប់រំមនុស្សឲ្យទៅជាមនុស្សដែលពឹងខ្លួនឯង សំរេចវាសនាដោយខ្លួនឯង(អត្តហិ អត្តនោ នាថោ) ជាអ្នកមានការអភិវឌ្ឍន៍ដោយបរិបូណ៌ និងមានសេរីភាពលើជីវិតរបស់ខ្លួន ។

៣- ការចូលរួមៈ ក្នុងទស្សនៈពុទ្ធសាសនា មនុស្សត្រូវរស់នៅជាលក្ខណៈសង្គម(សង្ឃៈ) និងត្រូវមានការចូលរួមចំណែកក្នុងការធ្វើឲ្យសង្គមនោះមានការរីកចំរើន (សុខា សង្ឃស្ស សាមគ្គី សាមគ្គានំ) ។ ជនដែលគិតឃើញតែប្រយោជន៍ខ្លួន ឬគេចរស់តែឯង ជារឿងមួយដែលពុទ្ធសាសនាចាត់ទុកថាជាមនុស្សអសោចន៍ ឬអាចថាជាជម្ងឺ ឬដំបៅសង្គម(អត្តត្ថបញ្ញា អសុចិ មនុស្សា) ហើយលោកបានទូន្មានថា កុំឲ្យកើតមកជាមនុស្សចង្អៀតលោក(នសិ យា លោកវឌ្ឍនោ) ។ លក្ខណៈដ៏សំខាន់មួយរបស់ការចូលរួមគឺគំនិតប្រជាធិបតេយ្យ ឬការយកសង្ឃជាធំ ដែលជារឿងផ្ទុយស្រឡះ

37 - សមទិដ្ឋិ សមសីល សមចាគ សមបញ្ញា

38 - នីវរណៈ ៥

39 - សូមអានទំព័រ ៩៩

www.budlhist.gov.kh www.elibraryofcambodia.org

ទៅនឹងសាសនាទេវនិយម ដែលយកអ្នកដឹកនាំតែម្នាក់គត់(អាទិទេព) មកធ្វើជាមេគំនិត និងជាអ្នកសំរេចវាសនារបស់សង្គមទាំងមូល ។ ឧទាហរណ៍ដ៏ជាក់ស្តែងនៃគំនិតប្រជាធិបតេយ្យ គឺព្រះបន្ទូលរបស់ព្រះបាទជ័យវរ្ម័នទី ៧ ដែលជាពុទ្ធសាសនិកដ៏ល្បីល្បាញមួយអង្គ ដែលបានចារទុកថា ៖

**ទេហិនាំទេហរោគោ យ (ន្មនោ)**

**រោគោ វេទក្តរាធិ រាស្ត្រ ទុះខំ ហិ**

**ភត៌្តណាំ ទុះខំ ទុះខន្តុ នាត្មនះ**

*" ទ្រង់មានព្រះទ័យព្រួយបារម្ភចំពោះរោគរបស់ប្រជារាស្ត្រព្រះអង្គ ជាងព្រះអាពាធព្រះអង្គទៅទៀត ព្រោះថា សេចក្តីទុក្ខរបស់រាស្ត្រ គឺជាសេចក្តីទុក្ខរបស់អ្នកគ្រប់គ្រងទាំងឡាយ មិនមែនសេចក្តីទុក្ខផ្ទាល់ព្រះអង្គទេ ដែលនាំឲ្យព្រះអង្គព្រួយ "*

ការចូលរួម គឺជាការដាក់សង្គមជាតិឲ្យទៅជាកម្មសិទ្ធិរបស់ពលរដ្ឋ ហើយដែលនឹងធ្វើឲ្យគេខំរក្សាការពារ និងអភិវឌ្ឍន៍ប្រទេសនោះដោយខ្លួនគេផ្ទាល់ ។

៥- <u>និរន្តរភាព</u> : បុរាណាចារ្យខ្មែរ សម្លឹងឃើញនូវផលប្រយោជន៍នៃពុទ្ធសាសនាក្នុងការគ្រប់គ្រងប្រទេស ព្រោះអាស្រ័យលើគំនិតនិរន្តរភាពដែលព្រះពុទ្ធអង្គទ្រង់បានប្រទានទុក ។ ភាពមិនអាចបែកគ្នាបាននៃត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ បានបង្ហាញឲ្យអ្នកដឹកនាំនូវភាពប្រុងប្រយ័ត្ន ក្នុងការធ្វើឲ្យបច្ច័យទាំង ៣ គឺ បុគ្គលម្នាក់ៗ(Individual) សង្គម(Social) និងធម្មជាតិ(Nature) មានតុល្យភាព និងជាជំនួយគ្នាទៅវិញទៅមក ។ ការបាត់បង់នៃអង្គណាមួយរបស់ត្រៃសរណគមន៍ គឺជាការបង្ហាញនូវភាពចុះខ្សោយនៃពុទ្ធសាសនា ក៏ដូចជាការបាត់បង់នូវបច្ច័យណាមួយនៃសង្គម ក៏ជាការបង្ហាញនូវហិនភាពដែលសង្គមនោះកំពុងជួបប្រទះផងដែរ ។

គុណប្រយោជន៍ទាំង ៥ ប្រការនេះ គឺជាប្រយោជន៍ចំបង និងជារូបភាពរួមដែលខ្ញុំគិតថា ជាគ្រឿងទាក់ទាញអារម្មណ៍អ្នកដឹកនាំខ្មែរ ក្នុងការយកព្រះពុទ្ធសាសនាទៅប្រើក្នុងការគ្រប់គ្រងប្រទេស រហូតដល់ដាក់ពុទ្ធសាសនាថាជាសាសនារបស់រដ្ឋ និងជាអង្គមួយនៃបាវចនា គឺ " ជាតិ - សាសនា - ព្រះមហាក្សត្រ " ។

www.budinst.gov.kh www.elibraryofcambodia.org




ក្រៅពីនេះ ក្នុងការយកទៅអនុវត្ត ពុទ្ធសាសនា អាចយកទៅប្រើបានសឹងតែគ្រប់វិស័យទាំងអស់ ដូចជា ៖

- ក្នុងការដឹកនាំ ពុទ្ធសាសនាបានស្នើនូវគោលធម៌ទាំងឡាយដ៏ច្រើន សំរាប់ធ្វើឲ្យអ្នកដឹកនាំទៅជាប្រមុខដ៏ល្អ ព្រះរាជាដែលជាទីស្រឡាញ់ និងជាប្រធានដែលជាទីគោរព ។ល។ សេចក្ដីពិស្ដារនៃការដឹកនាំ សូមអញ្ជើញរកអានសៀវភៅឈ្មោះ ព្រះបាទធម្មិក ដែលសរសេរ និងបោះពុម្ពផ្សាយដោយអ្នកនិពន្ធ ។
- ក្នុងឋានៈជាសមាជិកសង្គម ពុទ្ធសាសនាបានបង្ហាញនូវសារៈសំខាន់នៃការអប់រំដល់គ្រួសារនិមួយៗ និងបុគ្គលម្នាក់ៗ ឲ្យស្រឡាញ់សន្តិភាព និងសុភមង្គល ឲ្យប្រឹងប្រែងអភិវឌ្ឍន៍ជីវិតខ្លួន និងអប់រំកូនចៅឲ្យចេះរស់នៅក្នុងសង្គមឲ្យបានល្អ ។ អ្នកអានដែលមានការចាប់អារម្មណ៍ត្រង់ចំណុចនេះ សូមអញ្ជើញរកអានសៀវភៅឈ្មោះ “ **ជីវិតអាពាហ៍ពិពាហ៍** ” ដែលរៀបរៀងដោយអ្នកនិពន្ធដដែល ។
- ក្នុងវិស័យការអភិវឌ្ឍន៍ ទាំងខាងផ្នែកសេដ្ឋកិច្ច សង្គម ការសិក្សា ការកំសាន្ត និងបរិស្ថាន ក៏ពុទ្ធសាសនាបានបង្ហាញនូវចំណុចសំខាន់ៗជាច្រើន ដែលគួរយកចិត្តទុកដាក់ និងអនុវត្ត ដូចជា : គំនិតសម្មាអាជីវៈ ដែលមាននៅក្នុងអដ្ឋង្គិកមគ្គ ដែលអាចយកទេវិភាគលើបញ្ហាសេដ្ឋកិច្ច, វិន័យ និងសីល ៥ អាចយកទៅធ្វើជាមូល

www.budinst.gov.kh www.elibraryofcambodia.org

ដ្ឋាននៃការសិក្សាច្បាប់ ការគោរពសិទ្ធិមនុស្ស និងការដោះស្រាយទំនាស់[40], របៀបបង្រៀន និងប្រព័ន្ធនៃការសិក្សាដ៏មានជោគជ័យរបស់ព្រះពុទ្ធអង្គក្នុងរយៈពេល ៤៥ ឆ្នាំ អាចយកមកប្រៀបធៀបនិងប្រព័ន្ធការសិក្សានាសម័យបច្ចុប្បន្នបានដោយឥតមានទាស់, គំនិតការរួមរស់ជាមួយធម្មជាតិរបស់ព្រះពុទ្ធ ព្រះសង្ឃ និងការយកធម្មជាតិជាគ្រូ អាចយកមកឆ្លុះបញ្ចាំងលើព្រឹត្តិកម្មរបស់យើងចំពោះបញ្ហាបរិស្ថាននាបច្ចុប្បន្ននេះ, ចរិយាស្ត្រ និងសីលធម៌ដ៏ល្អ និងទាន់សម័យ អាចយកមកបំពេញឡើងវិញ លើកង្វះខាតរបស់សង្គមដែលយើងកំពុងតែជួបប្រទះជាដើម ។

គុណប្រយោជន៍ទាំងឡាយ ដូចដែលបានពោលមកដោយសង្ខេបខាងលើនេះ កំពុងបានទទួលការយកចិត្តទុកដាក់ស្រាវជ្រាវជាខ្លាំង ពីសំណាក់អ្នកវិទ្យាករទាំងឡាយទូទាំងពិភពលោក ជាពិសេសនៅខាងផ្នែកអឺរ៉ុប និងអាមេរិក ។ យើងសង្ឃឹមថា ការស្រាវជ្រាវទាំងនោះ នឹងបានជាពន្លឺសំរាប់ខ្មែរយើងដែលមានពុទ្ធសាសនាជាសាសនាប្រចាំជាតិ ជាពិតប្រាកដ ។

## ២- ផលប្រយោជន៍ក្នុងលក្ខណៈជាការអនុវត្តន៍

ទីណាមានខ្មែរ ទីនោះមានវត្ត ។ វត្ត គឺជាមជ្ឈមណ្ឌលនៃព្រលឹង និងសេចក្តីសុខទុក្ខរបស់ខ្មែរ ។ ដូច្នេះហើយបានជាយើងឃើញថា កន្លែងណាដែលមានសហគមន៍ខ្មែររស់នៅ គេតែងតែឃើញមានវត្តនៅប្រចាំកន្លែងនោះជាពុំខាន ។ ខ្មែរសាងវត្ត ព្រោះសម្លឹងឃើញនូវអត្ថប្រយោជន៍ដ៏សន្ធឹកសន្ធាប់ដែលវត្តធ្លាប់បានធ្វើចំពោះខ្មែរ តាំងពីបុរាណកាលមក ដូចជា ៖

- វត្ត គឺជាផ្ចាលបណ្ណៈ និងជាសារៈមន្ទីរថែរក្សាវប្បធម៌ និងអត្តសញ្ញាណជាតិខ្មែរ។ អក្សរសាស្ត្រខ្មែរ និងសិល្បៈទាំងឡាយ ភាគច្រើនមានកំណើតពីវត្ត និងផ្សព្វផ្សាយដោយព្រះសង្ឃ ជាពិសេសក្នុងសម័យសង្គ្រាម វត្តបានដើរតួនាទីជាសារៈមន្ទីរថែរក្សាកេតនភ័ណ្ឌទាំងនោះទៀតផង ។ បើសិនជាគ្មានវត្ត និងព្រះសង្ឃខ្មែរដែលទាមទារតវ៉ាទេ អក្សរខ្មែរបច្ចុប្បន្ននេះ ប្រាកដជាត្រូវសរសេរជាអក្សរ

[40] - សូមអានសៀវភៅ សីល ៥ របស់អ្នកនិពន្ធ

www.budinst.gov.kh www.elibraryofcambodia.org

ឡាតាំង ដោយការគាបសង្កត់ពីរបបអាណានិគមបារាំង នាសតវត្សរ៍ទី ១៩ ជាពុំខាន ។

- វត្តជាមណ្ឌលនៃការរួមសាមគ្គីគ្នា និងជួយធុរៈគ្នាទៅវិញទៅមក ។ ពេលមានធុរៈចាំបាច់ ខ្មែរយើងតែងយកវត្តធ្វើជាកន្លែងប្រជុំ ពិភាក្សា និងរួបរួមកម្លាំងវត្តដើម្បីសំរេចកិច្ចការ ដូចជាការសាងសង់ផ្សេងៗ និងរហូតដល់ទៅកិច្ចការរំដោះទឹកដីទៀតផង ។
- វត្តជាជំរករបស់មនុស្សចាស់ និងជាកន្លែងដែលក្មេងកំព្រាអនាថាទាំងឡាយអាចស្នាក់អាស្រ័យ និងជាសំណាក់សំរាប់ឈានទៅរកអនាគត ។
- វត្តជាមណ្ឌលអប់រំសីលធម៌ និងចិត្តវិញ្ញាណរបស់ខ្មែរ ឲ្យមានភាពស្លូតបូត រឹងប៉ឹង និងពឹងលើខ្លួនឯងបាន ។
- វត្តជាមណ្ឌលអភិវឌ្ឍន៍ប្រចាំភូមិ ។ ការសាងសង់ផ្លូវ, សាលសាវៀន, មន្ទីរពេទ្យ ស្រះទឹក ។ល។ ដែលជាប្រយោជន៍សាធារណៈ សុទ្ធតែជាការដឹកនាំ និងជ្រោមជ្រែងយ៉ាងពេញទំហឹងពីវត្ត និងព្រះសង្ឃទាំងអស់ ។
- ។ល។ [៤១]

គុណប្រយោជន៍របស់វត្ត និងព្រះសង្ឃដែលបានពោលមកនេះ គ្រាន់តែជាការពណ៌នាដើម្បីឲ្យឃើញពីប្រយោជន៍ពុទ្ធសាសនា ដែលមានចំពោះសង្គមខ្មែរ តាមរូបភាពដែលអាចមើលឃើញបានដោយសង្ខេប ។ តាមពិតយើងអាចនិយាយថា : ព្រលឹង និងជីវិតខ្មែរ បានទទួលការជ្រួលកំពណ៌អំពីពុទ្ធសាសនា សឹងតែគ្រប់ផ្នែកទៅហើយ ។ ពណ៌នេះ អាចនឹងត្រូវស្ថិតស្ថេរនៅជាយូរអង្វែងតទៅទៀត បើសិនជាបានទទួលការថែរក្សា និងប្រើវិធីជ្រួលកំឲ្យបានត្រឹមត្រូវ ។ ខ្មែរយើងនឹងបាត់បង់នូវអ្វីមួយដ៏ធំដែលមិនអាចកាត់ថ្លៃបាន បើសិនជាពណ៌នេះ ត្រូវសាបរលាប ឬមានគេមករារាំង មិនឲ្យជ្រួលកំបានតទៅទៀត ។ ដូច្នេះ ការសិក្សាឲ្យបានជ្រៅជ្រះលើគុណប្រយោជន៍ និងទំនាក់ទំនងរវាងពុទ្ធសាសនា និងសង្គមខ្មែរ ជាកត្តាកំណត់មួយនៃនិរន្តរភាព និងសន្តិភាពសំរាប់សង្គមខ្មែរយើងទាំងមូល ទាំងនាបច្ចុប្បន្ន និងអនាគត ។

---

41 - សេចក្តីពិស្តារ សូមអានសៀវភៅពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ ដែលជារបាយការណ៍របស់សិក្ខាសាលាជាតិលើកទី ១ ទី ២ និងទី ៣ ដែលបោះពុម្ពផ្សាយដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ។

www.budinst.gov.kh www.elibraryofcambodia.org

# បច្ឆិមកថា

ការពន្យល់អំពីព្រះពុទ្ធសាសនានៅក្នុងសៀវភៅកម្រាស់ប៉ុននេះ មិនអាចធួនល្មមទៅនឹងអ្វីដែលហៅថាពុទ្ធសាសនាបានទេ ។ បើគិតទៅតាមតួលេខដែលបានរៀបរាប់ទុកមកថាព្រះវិន័យមាន ២១,០០០ ធម្មក្ខ័ន្ធ ព្រះសូត្រមាន ២១,០០០ ធម្មក្ខ័ន្ធ និងព្រះអភិធម្មមាន ៤២,០០០ធម្មក្ខ័ន្ធ ឬចំនួនទំព័រសៀវភៅចំនួន ៣៦,៦៣០ទំព័រ ដែលបោះពុម្ពជាព្រះត្រៃបិដកខ្មែរនោះ ឃើញថាមិនអាចប្រៀបធៀបគ្នាបានឡើយ ។ ពុទ្ធសាសនាគឺជាមហាសមុទ្រនៃវិជ្ជា និងចំណេះដឹង ដែលមិនមាននរណាអាចប្រាប់បាន ថាជ្រៅប៉ុណ្ណា និងមានបរិមាណប៉ុណ្ណាបានឡើយ។ អ្វីដែលព្យាយាមពន្យល់នៅក្នុងសៀវភៅដ៏តូចនេះ គឺគ្រាន់តែជាកូនពន្លឺ ទៀនដ៏តូចមួយដើមសំរាប់ទ្រោលបំភ្លឺក្នុងទីងងឹត ឬជាទឹកដបដ៏តូចមួយដបសម្រាប់កាន់ដើរ ជាស្បៀងទៅកាន់មហាសមុទ្រនោះតែ ប៉ុណ្ណោះឯង ។

អ្នកអានត្រូវរកប្រភពផ្សេងទៀតឲ្យបានច្រើនសំរាប់បំពេញនូវកង្វះខាតនេះ ។ ការសិក្សាក្នុងព្រះពុទ្ធសាសនាគ្មានទីបញ្ចប់ទេ កាន់តែរៀន កាន់តែឃើញនូវជំរៅដែលត្រូវការរៀនថែមទៀត ។ ការបដិបត្តិ ជាកិច្ចការពិសេសដែលមិនអាចលះបង់បានជាដាច់ខាតក្នុងពុទ្ធសាសនា ដើម្បីបញ្ចប់នូវការសិក្សារបស់ខ្លួន ។

អ្នកគោរពពុទ្ធសាសនា គឺ អ្នកដែលព្យាយាមរំដោះខ្លួនឲ្យផុតពីសេចក្ដីទុក្ខ ។ យល់នូវគោលបំណងនេះ ម្នាក់ៗគប្បីសិក្សាឲ្យយល់ច្បាស់នូវអ្វីដែលហៅថាទុក្ខ និងហេតុរបស់វាព្រមទាំងវិធី ដើម្បីរំដោះខ្លួនពីសេចក្ដីទុក្ខទាំងនោះ ។

ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹង ជាទីរលឹក និងជាមគ្គុទ្ទេសក៍ដែលគ្មាន សាសនាណាប្រដូចបាន ក្នុងការរំដោះខ្លួនឲ្យផុតពីទុក្ខទាំងនេះ ។ អង្គទាំង បីមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ និងដែលពុំអាចញែកចេញពីគ្នាបានទេ ក្នុងយន្តកម្មនៃការរំដោះខ្លួននោះ ។ ការបដិបត្តិដែលយកចិត្តទុកដាក់លើតុល្យភាពនៃសរណៈទាំង ៣ នឹងនាំមកនូវប្រយោជន៍ និងសេចក្ដីសុខយ៉ាងឆាប់រហ័ស ដល់សាធុជនជាពិតប្រាកដ ។

ដោយអានុភាពនៃព្រះរតនៈទាំងបី គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ

សូមឲ្យជនទាំងឡាយ បានរំដោះខ្លួនរួចពីសេចក្ដីទុក្ខ គ្រប់ៗអាត្មាទៅហោង ៕

www.budinst.gov.kh www.elibraryofcambodia.org

# ឯកសារពិគ្រោះ


១. ព្រះត្រៃបិដកភាសាខ្មែរ, បោះពុម្ពសារថ្មីឡើងវិញឆ្នាំ ១៩៩៥
២. ប្រជុំភាណវារបាលិ-ប្រែ ពិសេស, សែម សូរ ១៩៦៦
៣- គិហិបដិបត្តិពិស្តារពិសេស, ម.ឧ. កៅ ឈឹន, ១៩៩៥
៤. ព្រះបាទធម្មិក, ឥន្ទបញ្ញោហេង មណីចិន្តា, ១៩៩៥
៥. បព្វជាខន្ធកសង្ខេប, ការផ្សាយរបស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥១៣
៦. វចនានុក្រមពុទ្ធសាស្ត្រ, ព្រះទេពវាទី មហាចុឡាឡង្ករណរាជវិទ្យាល័យ (ច្បាប់ភាសាថៃ-អង់គ្លេស) ព.ស ២៥៣២
៧. មើលយើង មើលគេ(ភាសាថៃ), ព្រះរាជធម្មនិទេស(រះបែប ឋិតញាណោ), វត្តបវរនិវេសវិហារ, បាងកក, ព.ស. ២៥៣៥
៨. ពុទ្ធប្រាជ្ញា(ភាសាថៃ), សទិទ ស៊ីសាំដែង, ព.ស. ២៥៣៥
៩. The World Almanac and Book of Facts, 1988.
១០. The encyclopedia of World faiths, Bishop & Darton, 1987
១១. ឯកសារខ្មែរ និងបរទេសមួយចំនួនទៀត


www.budinst.gov.kh www.elibraryofcambodia.org

## តារាងឧត្តការនៃពុទ្ធសាសនា




www.budinst.gov.kh www.elibraryofcambodia.org

“ យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច
ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ”

ម្នាលអានន្ទ ព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគត បានសំដែងហើយ បានបញ្ញត្តិហើយ ដល់អ្នកទាំងឡាយ លុះអំណើះអត់ពីតថាគតទៅនឹងបានជាគ្រូ ប្រៀនប្រដៅអ្នកទាំងឡាយ ។

“ យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ”

ជនណាប្រព្រឹត្តិតាមធម៌ ដែលតថាគតសំដែងល្អហើយ ជននោះនឹង ឆ្លងសេចក្តីស្លាប់ ដែលគេលំបាកឆ្លងពេកក្រៃហើយដល់នូវត្រើយគឺព្រះនិព្វាន ។

www.budinst.gov.kh www.elibraryofcambodia.org